# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងមហាផ្ទៃ

# សៀវភៅ
# អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈ
# សម្រាប់មន្ត្រីនគរបាលជាតិ



ឆ្នាំ២០២៦

# ក្រសួងមហាផ្ទៃ

# MINISTRY OF INTERIOR



## ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

លេខ: ០២៧ ប

បានឃើញនិងអនុញ្ញាតឱ្យប្រើ

សៀវភៅ

**អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ**

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

# បុព្វកថា

រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវកម្មវិធីនយោបាយដោយបានកំណត់អំពីការកសាងសមត្ថភាពវិជ្ជាជីវៈនិងអភិវឌ្ឍធនធានមនុស្សលើគ្រប់វិស័យ ព្រមទាំងបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ដោយបានកំណត់យក «មនុស្ស» ជាអាទិភាពគន្លឹះទី១ក្នុងចំណោមលំដាប់អាទិភាពផ្សេងទៀតគឺ «ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា»។

ដើម្បីអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃនៅតែបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការកសាងធនធានមនុស្សដោយបានផ្តល់អាទិភាពលើការងារអប់រំបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិគ្រប់រូបក្នុងការបង្កើនសមត្ថភាពចំណេះដឹងនិងជំនាញដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ ការណ៍នេះក្រសួងមហាផ្ទៃពិនិត្យឃើញថា ការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីនគរបាលជាតិគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការជំរុញឱ្យក្រសួងមហាផ្ទៃកាន់តែមានកិត្យានុភាព ឧត្តមភាព និងសមត្ថភាពក្នុងការបំពេញតួនាទីនិងភារកិច្ចស្នូលរបស់ខ្លួន។

ក្នុងន័យនេះ សៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» គឺជាឯកសារដែលមានចរិតណែនាំតម្រង់ទិសដល់កម្លាំងនគរបាលជាតិជាមន្ត្រីអនុវត្តច្បាប់ឱ្យក្លាយជាកងកម្លាំងប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ គោរពច្បាប់ គោរពសិទ្ធិមនុស្ស សក្តិសមជាកងកម្លាំងបម្រើប្រជាពលរដ្ឋដោយស្មោះត្រង់មានសីលធម៌វិជ្ជាជីវៈ។ ជាការពិតណាស់ការប្រកាន់ខ្ជាប់ជាប្រចាំនូវលក្ខខណ្ឌត្រឹមត្រូវតាមគោលការណ៍អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីនគរបាលជាតិគឺជាដំណើរវិវឌ្ឍឆ្ពោះទៅរកការធ្វើកំណែទម្រង់ថ្មីប្រកបដោយឧត្តមានុវត្តន៍របស់ក្រសួងមហាផ្ទៃដើម្បីបង្កើនទំនុកចិត្តពីសាធារណជនកាន់តែទូលំទូលាយចំពោះស្ថាប័នរដ្ឋ។ ហេតុនេះមន្ត្រីនគរបាលជាតិមិនត្រឹមតែមានតួនាទីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈដែលជាសសរស្តម្ភនៃឥរិយាបថអាកប្បកិរិយានិងជាមូលដ្ឋានគ្រឹះនៃគោលនយោបាយដ៏សំខាន់មួយក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់មន្ត្រីនគរបាលជាតិឱ្យមានសុចរិតភាព សច្ចភាព និងភាពជាអ្នកដឹកនាំល្អនៅក្នុងសង្គម។

ជាសារវន្ត ដោយពិនិត្យឃើញនូវតម្រូវការនេះ ក្រសួងមហាផ្ទៃបានជំរុញឱ្យបណ្ឌិត្យសភានគរបាលកម្ពុជាបង្កើតក្រុមការងាររៀបចំនិងអភិវឌ្ឍសៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» នេះឡើងដើម្បីជាមូលដ្ឋានយកទៅប្រើប្រាស់ក្នុងការបម្រើសេវាលើវិស័យសន្តិសុខជាតិឱ្យកាន់តែមានប្រសិទ្ធភាពក្នុងយុគសម័យបច្ចុប្បន្ន។

ក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរចំពោះក្រុមការងាររៀបចំ និងអភិវឌ្ឍសៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» ដែលបានខិតខំប្រឹងប្រែងប្រមូលទិន្នន័យរៀបចំនិងចងក្រងឱ្យកើតចេញជារូបរាងឡើងដើម្បីផ្សព្វផ្សាយនិងប្រើប្រាស់ជាផ្លូវការបាន។

ក្រសួងមហាផ្ទៃមានសុទិដ្ឋិនិយមថា សៀវភៅដ៏មានសារៈសំខាន់នេះពិតជាបានរួមចំណែកធ្វើឱ្យកងកម្លាំងនគរបាលជាតិក្លាយជាកងកម្លាំងប្រកបដោយថាមពលក្នុងការកសាងនិងបង្កើនទំនុកចិត្តពីសាធារណជនកាន់តែប្រសើរឡើងបន្ថែមទៀតស្របតាមទស្សនវិស័យកំណែទម្រង់ដោយផ្តោតលើការកសាងមូលធនមនុស្សចូលរួមចំណែកជំរុញវឌ្ឍនភាពជាតិលើគ្រប់វិស័យក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថលនិងសកលភាវូបនីយកម្មក្រោមដំបូលនៃសន្តិភាព៕

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

# អារម្ភកថា

សៀវភៅ «អភិសមាចារនិងក្រមសីលធម៌សម្រាប់មន្ត្រីនគរបាលជាតិ» ដែលក្រុមការងារបានរៀបចំចងក្រង គឺជាឯកសារដ៏មានសារៈសំខាន់មួយនៃការងារកំណែទម្រង់ដែលត្រូវបានយកទៅផ្សព្វផ្សាយនិងអនុវត្តឆ្លើយតបនឹងការដឹកនាំបញ្ជារបស់ក្រសួងមហាផ្ទៃ និងស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាពនគរបាលយកទៅប្រើប្រាស់ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

ជាការពិតណាស់ ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់និងផ្តល់អាទិភាពខ្ពស់ដល់ការងារអប់រំបណ្តុះបណ្តាលដើម្បីកសាងធនធានមនុស្សឱ្យមានលក្ខណសម្បត្តិសមស្របក្នុងការបំពេញតួនាទីនិងភារកិច្ចតាមអង្គភាពជំនាញនីមួយៗឱ្យសម្រេចជោគជ័យតាមផែនការបានកំណត់។ ជាក់ស្តែងក្រសួងបានគាំទ្រនិងឧបត្ថម្ភគ្រប់បែបយ៉ាងក្នុងការជំរុញអភិវឌ្ឍនិងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់កម្រិត ព្រមទាំងអង្គភាពបណ្តុះបណ្តាលដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញ និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីនគរបាលឱ្យក្លាយទៅជាធនធានមនុស្សមានលក្ខណសម្បត្តិសមស្របក្នុងការបម្រើការងារជូនអង្គភាពនិងបង្កើនទំនុកចិត្តសាធារណៈស្របពេលដែលមានករណីខុសឆ្គងខ្លះដែលបានចែករំលែកក្នុងបណ្តាញសង្គមស្តីពីទង្វើអសីលធម៌របស់មន្ត្រីនគរបាលមួយចំនួនបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសកេរ្តិ៍ឈ្មោះរបស់ស្ថាប័ននគរបាលជាតិទាំងមូល។ ហេតុនេះទើបក្រសួងមហាផ្ទៃជំរុញឱ្យមានការរៀបចំចងក្រង «សៀវភៅអភិសមាចារនិងក្រមសីលធម៌សម្រាប់មន្ត្រីនគរបាលជាតិ» នេះឡើងសម្រាប់ជាគុណប្រយោជន៍ដល់មន្ត្រីនគរបាលយកទៅផ្សព្វផ្សាយនិងអនុវត្តនៅតាមអង្គភាពប្រតិបត្តិការឱ្យបានត្រឹមត្រូវ ឯកភាពគ្នាក្នុងនាមជាមន្ត្រីបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ក្នុងន័យនេះ ក្រុមការងាររៀបចំចងក្រងនិងអ្នកពាក់ព័ន្ធទាំងអស់បានខិតខំរួមសហការគ្នាយ៉ាងសកម្មដើម្បីរៀបចំសៀវភៅនេះធ្វើជាមូលដ្ឋានគ្រឹះស្តីពីស្តង់ដា ឥរិយាបថ អាកប្បកិរិយា ការប្រព្រឹត្ត និងទំនួលខុសត្រូវរបស់មន្ត្រីនគរបាលក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ អត្ថន័យ ខ្លឹមសារដែលចែងនៅក្នុងសៀវភៅនេះមានគោលបំណងបណ្តុះស្មារតីដល់មន្ត្រីនគរបាលគ្រប់រូប គ្រប់កម្រិតឱ្យមានការយល់ដឹងច្បាស់លាស់អំពីតួនាទីអភិសមាចារនិងក្រមសីលធម៌ក្នុងការអនុវត្តច្បាប់ ការគោរពសិទ្ធិមនុស្ស និងការប្រាស្រ័យទាក់ទងល្អជាមួយនឹងប្រជាពលរដ្ឋ។

សៀវភៅនេះ ត្រូវបានរៀបចំឡើងផ្អែកលើទ្រឹស្តី បទប្បញ្ញត្តិពាក់ព័ន្ធនានា និងបទពិសោធន៍ជាក់ស្តែងរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ដោយបានរៀបចំនូវមាតិកាចែកចេញជា៦ផ្នែកសំខាន់ៗរួមមាន៖ ផ្នែកទី១: ស្តីពីទស្សនាទាននៃមន្ត្រីនគរបាលជាតិ, ផ្នែកទី២: ស្តីពីសញ្ញាណទូទៅនៃអភិសមាចារនិងក្រមសីលធម៌, ផ្នែកទី៣: ស្តីពីមូលដ្ឋានគ្រឹះនៃអភិសមាចារនិងក្រមសីលធម៌មន្ត្រីនគរបាល, ផ្នែកទី៤: ស្តីពីតួនាទីអភិសមាចារក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលជាតិក្នុងកិច្ចប្រតិបត្តិការ, ផ្នែកទី៥: ស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលក្នុងការប្រើបច្ចេកវិទ្យាព័ត៌មាន, និងផ្នែកទី៦: ស្តីពីគោលការណ៍សកលនៃកិច្ចប្រតិបត្តិការនិងក្រមសីលធម៌នគរបាល។ ម៉្យាងទៀត ក្រៅពីយកទៅប្រើប្រាស់ជាផ្លូវការសៀវភៅនេះមានសារប្រយោជន៍សម្រាប់បម្រើឱ្យការងារបណ្តុះបណ្តាលអប់រំមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ព្រមទាំងបម្រើឱ្យសេចក្តីត្រូវការផ្សេងៗទៀតតាមដែលអាចប្រើបាន។

សង្ឃឹមថា សៀវភៅនេះគឺជាឯកសារដ៏មានតម្លៃសម្រាប់មន្ត្រីនគរបាលនិងអ្នកសិក្សាទាំងអស់ ក្នុងការលើកកម្ពស់គុណវុឌ្ឍិវិជ្ជាជីវៈនិងការអភិវឌ្ឍខ្លួនឱ្យកាន់តែល្អប្រសើរឡើងស្របតាមតម្រូវការសង្គមនាយុគសម័យថ្មី។ ទោះជាយ៉ាងណាក្តី ខ្លឹមសារនិងអត្ថន័យពាក្យពេចន៍ដែលមាននៅក្នុងសៀវភៅនេះពិតជានៅមានចំណុចខ្វះខាតមួយចំនួនដោយអចេតនា ហើយទើបតែធ្វើការបោះពុម្ពជាលើកទី១ ដែលពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងពុំទាន់អាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងបានទាំងស្រុងនៅឡើយទេ។ ហេតុនេះចាំបាច់ត្រូវទទួលយកគំនិតស្ថាបនាកែលម្អបន្ថែមពីឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាជាថ្នាក់ដឹកនាំនិងមន្ត្រីនគរបាលគ្រប់កម្រិតដើម្បីកែលម្អសៀវភៅនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយធ្វើជាមូលដ្ឋាននៃការធ្វើនវានុវត្តន៍សម្រាប់បោះពុម្ពលើកក្រោយៗទៀតឱ្យកាន់តែមានសុក្រឹតភាពបន្ថែមទៀត។

**សូមអរគុណ!**

## សេចក្តីផ្តើម

ក្នុងបរិបទសង្គមកម្ពុជាកំពុងមានការប្រែប្រួលវិវត្តយ៉ាងឆាប់រហ័ស ទាំងសេដ្ឋកិច្ច នយោបាយនិងបច្ចេកវិទ្យា ក្រសួងមហាផ្ទៃក្រោមការដឹកនាំដ៏ឈ្លាសវៃនិងទស្សនៈកំណែទម្រង់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានយកចិត្តទុកដាក់និងផ្តល់អាទិភាពខ្ពស់លើការពង្រឹងសមត្ថភាពជំនាញនិងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ដើម្បីជំរុញឱ្យក្រសួងមហាផ្ទៃកាន់តែមានកិត្យានុភាព ឧត្តមភាពនិងសមត្ថភាពក្នុងការបំពេញការងារស្នូលរបស់ខ្លួនដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋស្របតាមការវិវត្តប្រែប្រួលនៃបរិបទសង្គមឱ្យសម្រេចជោគជ័យប្រកបដោយចីរភាព។

ទន្ទឹមនេះ ក្រសួងបានកត់សម្គាល់ឃើញមានព្រឹត្តិការណ៍ជាក់ស្តែងកើតឡើងមួយចំនួនដែលបានចែករំលែកតាមបណ្តាញសង្គម ស្តែងចេញពីសកម្មភាពនៃការប្រព្រឹត្តខុសឆ្គងអសីលធម៌របស់មន្ត្រីនគរបាលមួយចំនួនតូចធ្វើឱ្យមជ្ឈដ្ឋានសាធារណជនក្នុងនិងក្រៅប្រទេសមួយចំនួនមានការមិនពេញចិត្តនិងធ្វើការរិះគន់ដល់កងកម្លាំងនគរបាលជាតិដោយបានវាយតម្លៃថាជាមន្ត្រីគ្មានវិជ្ជាជីវៈ។ បញ្ហានេះគឺជាការព្រួយបារម្ភនិងសោកស្តាយជាទីបំផុតសម្រាប់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

ទោះក្នុងស្ថានភាពបែបណាក៏ដោយ ក្រសួងមហាផ្ទៃតម្រូវឱ្យថ្នាក់ដឹកនាំគ្រប់កម្រិត គ្រប់ស្ថាប័ននិងអង្គភាពចំណុះទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់ដោយមិនត្រូវមើលរំលងនិងមិនអាចឱបដៃសម្លឹងមើលទិដ្ឋភាពអវិជ្ជមានដែលនាំឱ្យកេរ្តិ៍ឈ្មោះ កិត្តិយស និងតម្លៃរបស់កងកម្លាំងនគរបាលជាតិត្រូវអាប់ឱន បង្កឡើងដោយសារការប្រព្រឹត្តរបស់មន្ត្រីអសីលធម៌ទាំងនោះបានទេ ដូចដែលពាក្យស្លោកខ្មែរមួយបានតំណាលថា «ត្រីមួយកន្ត្រកតែស្អុយមួយគឺស្អុយទាំងអស់»។

ការសំដែងនូវអាកប្បកិរិយា ឥរិយាបថនៃការប្រព្រឹត្តមិនត្រឹមត្រូវរបស់កងកម្លាំងនគរបាលជាតិគឺជាសញ្ញាបង្ហាញឱ្យឃើញពីភាពគ្មាន «អភិសមាចារនិងក្រមសីលធម៌របស់មន្ត្រីនគរបាលជាតិ» ធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ទំនុកចិត្ត បាត់បង់ភាពកក់ក្តៅ បែកបាក់សាមគ្គីភាព ភាពអនាធិបតេយ្យក្នុងសង្គម អសន្តិសុខ គ្មានសណ្តាប់ធ្នាប់របៀបរៀបរយ។ ក្នុងន័យនេះ កងកម្លាំងនគរបាលជាតិទាំងអស់ត្រូវប្តេជ្ញាចិត្តជម្នះឱ្យបានកុំបណ្តោយឱ្យអំពើអាក្រក់អសីលធម៌ទាំងនោះមកលងបន្លាចក្នុងពេលវេលាណាមួយ ឬថ្ងៃណាមួយឱ្យសោះ សូម្បីតែមួយវិនាទីណាក៏ដោយ។ បើមិនដូច្នោះទេវានឹងនាំឱ្យយើងម្នាក់ៗធ្លាក់ទៅក្នុងអន្លង់ដ៏សែនជ្រៅនៃភាពងងឹតងងុល អសីលធម៌ មិនអាចអភិវឌ្ឍសង្គមជាតិបានឡើយ។

## គោលបំណង

គោលបំណងនៃការរៀបចំតាក់តែងសៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» នេះគឺដើម្បីបំពេញជូនតាមមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានផ្ដល់នូវអនុសាសន៍កែលម្អ លើកកម្ពស់គុណភាពនៃការប្រតិបត្តិ ឥរិយាបថ អាកប្បកិរិយារបស់មន្ត្រីនគរបាលជាតិឱ្យមានចរិតអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈពិតប្រាកដដើម្បីពង្រឹងភាពរឹងមាំថ្មីៗបន្ថែមទៀត។

ជាមួយគ្នានេះអត្ថន័យឬខ្លឹមសារដែលមានចែងនៅក្នុងសៀវភៅបានបង្ហាញពីគោលបំណងសំខាន់ៗមួយចំនួនទៀតដែលមានចរិតណែនាំអប់រំមន្ត្រីនគរបាលជាតិដូចខាងក្រោម៖

១- បង្កើនការអប់រំឱ្យមានការយល់ដឹងពី ចរិតអភិសមាចារនិងចរិតសីលធម៌របស់មន្ត្រីនគរបាលឱ្យមានឥរិយាបថថ្លៃថ្នូរ សមរម្យនិងត្រឹមត្រូវក្នុងពេលបំពេញភារកិច្ចសក្ដិសមជាមន្ត្រីនគរបាលគំរូបង្កើតទំនុកចិត្តរបស់ប្រជាពលរដ្ឋប្រកបដោយភាពពេញចិត្តនិងការគោរព។

២- ដើម្បីបង្ការនិងកាត់បន្ថយការប្រព្រឹត្តខុសរបស់មន្ត្រីនគរបាលតាមរយៈការផ្ដល់នូវមូលដ្ឋានទ្រឹស្ដីណែនាំច្បាស់លាស់ក្នុងការសម្រេចចិត្តថា អ្វីដែលត្រូវធ្វើនិងអ្វីដែលមិនត្រូវធ្វើ ព្រមទាំងបង្ការនិងកែលម្អបានត្រឹមត្រូវ កាត់បន្ថយសកម្មភាពឬឥរិយាបថមិនសមរម្យដែលតែងតែបង្កើតបញ្ហាប៉ះពាល់ដល់សេចក្ដីសុខ សុវត្ថិភាព និងអារម្មណ៍ប្រជាពលរដ្ឋ។

៣- ដើម្បីសម្របសម្រួលនីតិវិធីនិងស្តង់ដាការងារសម្រាប់មន្ត្រីទាំងអស់តាមរយៈការបណ្ដុះបណ្ដាលដោយធានាថា រាល់ការបំពេញភារកិច្ចលើគ្រប់ស្ថានភាពនិងកាលៈទេសៈណាក៏ដោយត្រូវតែបំពេញដោយការគោរពច្បាប់ គោរពសិទ្ធិមនុស្ស និងគោរពសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

៤- ដើម្បីដឹកនាំជំរុញមន្ត្រីនគរបាលឱ្យបង្កើតវប្បធម៌ការងារប្រកបដោយការទទួលខុសត្រូវយល់ដឹងច្បាស់ពីតម្លៃបុគ្គល អង្គភាព និងតម្រូវការកិត្តិយសសំខាន់ៗផ្សេងៗទៀតដូចជាវិន័យ ការប្ដេជ្ញាចិត្ត ភាពស្មោះត្រង់ ការទទួលខុសត្រូវ ការផ្ដល់តម្លៃ ការគោរពគ្នាទៅវិញទៅមក និងផ្ដោតលើសេវាមូលដ្ឋានដោយចាត់ទុកប្រជាពលរដ្ឋជាអាទិភាព។

៥- បណ្ដុះបណ្ដាលស្មារតីវិជ្ជាជីវៈដល់អ្នកសិក្សាជាមន្ត្រីនគរបាលយកចំណេះដឹងរបស់ខ្លួនទៅប្រើប្រាស់ក្នុងពេលបំពេញការងារនៅតាមអង្គភាពប្រកបដោយគុណភាព ប្រសិទ្ធភាព ទទួលបានជោគជ័យលើការងារ ថែរក្សាការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

## សារៈសំខាន់

ជាទូទៅនៅពេលដែលជាតិមួយត្រូវបានគ្របដណ្ដប់ញាំញីដោយអំពើអសីលធម៌នៅក្នុងសង្គមប្រាកដណាស់ថាជាតិមួយនោះពិតជាមិនមានភាពរីកចម្រើននោះទេ។ នេះគឺជាទស្សនៈសកលបែបវិទ្យាសាស្ត្រដែលថ្នាក់ដឹកនាំនៅក្នុងតំបន់និងនៅលើពិភពលោកតែងតែពិចារណាដោយការយកចិត្តទុកដាក់ខ្ពស់បំផុត។ ដោយឡែកកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យភាពធ្លាប់មានប្រវត្តិវប្បធម៌ អារ្យធម៌រុងរឿងថ្លៃថ្លាតាំងពីបុរាណកាលមកហើយទទួលបានការកោតសរសើរពីមជ្ឈដ្ឋានអន្តរជាតិថាជាប្រទេសដែលមានថ្នាក់ដឹកនាំនិងប្រជាជនរួសរាយរាក់ទាក់ប្រកបដោយកិត្តិយសនិងសេចក្ដីថ្លៃថ្នូរគួរឱ្យគោរព។

កងកម្លាំងនគរបាលជាតិដែលកើតពីប្រជាជនដើម្បីប្រជាជនគឺជាកងកម្លាំងអនុវត្តច្បាប់មានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ មានតួនាទីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋ។ អ្វីដែលជាគុណតម្លៃខ្ពស់របស់នគរបាលគឺការអនុវត្តច្បាប់ដោយស្មោះត្រង់ យុត្តិធម៌ សច្ចធម៌ និងឧត្តមភាពនៃការលើកស្ទួយអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈ។

សៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» បានផ្តល់សារៈសំខាន់ដូចខាងក្រោម៖

១- កសាងកម្លាំងនគរបាលមានវិជ្ជាជីវៈនិងវិន័យខ្ពស់ ប្រែក្លាយជាកម្លាំងស្នូល គំរូក្នុងការគោរពនិងអនុវត្តច្បាប់សង្គម លើកកម្ពស់តម្លៃសង្គម មានកិត្យានុភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានរួមទាំងសាធារណជនជាតិនិងអន្តរជាតិ ធ្វើឱ្យមន្ត្រីនគរបាលយល់ថា ការបំពេញតួនាទីមិនមែនត្រឹមតែអនុវត្តច្បាប់ទេ ប៉ុន្តែត្រូវមានវិន័យ សុចរិតភាព និងការទទួលខុសត្រូវ។

២- បង្កើនសមត្ថភាពនៃការគ្រប់គ្រងអំណាចសាធារណៈរបស់នគរបាលបានត្រឹមត្រូវ មិនប្រើអំណាចលើសកម្រិត មិនបំពានសិទ្ធិពលរដ្ឋ និងអនុវត្តការងារតាមគោលការណ៍យុត្តិធម៌ ព្រមទាំងធានាបានថា អំណាចត្រូវបានប្រើ «សម្រាប់ប្រជាពលរដ្ឋ» មិនមែន «លើប្រជាពលរដ្ឋទេ»។

៣- លុបបំបាត់អំពើពុករលួយនិងអំពើមិនសុចរិត លើកកម្ពស់កិត្តិយសក្រសួងស្ថាប័ន បង្កើតនូវរដ្ឋបាលស្អាតស្អំនិងមានភាពជឿជាក់ជួយដោះស្រាយជម្លោះដោយសន្តិវិធី បង្កើតបរិយាកាសសង្គមមានសុវត្ថិភាពនិងលើកកម្ពស់កិត្តិយស ភាពស្របច្បាប់ ភាពរឹងមាំរបស់ស្ថាប័នសម្រាប់អភិវឌ្ឍជាតិ។

៤- ពង្រឹងការកែលម្អសេវាបម្រើដោយការគោរពសិទ្ធិមនុស្សនិងគ្រប់គ្រងតាមគោលការណ៍គុណាធិបតេយ្យដើម្បីចូលរួមគាំទ្រគោលនយោបាយកំណែទម្រង់និងសម្រេចគោលដៅអភិវឌ្ឍលើវិស័យសន្តិសុខជាតិរបស់ក្រសួង។

៥- បង្កើនទំនាក់ទំនងល្អរវាងនគរបាលនិងប្រជាពលរដ្ឋដោយការគោរពនិងបម្រើប្រជាពលរដ្ឋដោយភាពគួរសម ធ្វើការជាមួយនឹងសហគមន៍មានកិច្ចសហការល្អនិងជំរុញឱ្យមានវប្បធម៌នៃការគោរពច្បាប់សង្គមទាំងអស់គ្នា បង្កើតបានបរិយាកាសសង្គមមានសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពល្អ។

៦- មានការចូលរួមសហការល្អលើការអនុវត្តជំនាញក្នុងការប្រាស្រ័យទាក់ទងជាពិសេសក្នុងការជួយផ្តល់ព័ត៌មាន ការកំណត់មុខសញ្ញាល្បិចកលទុច្ចរិតរបស់ជនសង្ស័យ បង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តវិធានការជំនាញទាន់ពេលក្នុងការបង្ការនិងការទប់ស្កាត់រាល់លក្ខខណ្ឌនាំឱ្យកើតបទល្មើសនៅមូលដ្ឋានឬសហគមន៍។

៧- ប្រជាពលរដ្ឋមានជំនឿនិងបានចាត់ទុកថា កងកម្លាំងនគរបាលជាកងកម្លាំងតំណាងឱ្យភាពស្មោះត្រង់ យុត្តិធម៌ សច្ចធម៌នៅក្នុងសង្គម ជាអ្នកបម្រើសេវាពិតប្រាកដ ព្រមទាំងជានិមិត្តរូបនៃអំពើល្អនិងសន្តិភាពនៅក្នុងបេះដូង «មានវត្តមាននគរបាលធ្វើឱ្យប្រជាពលរដ្ឋមានភាពកក់ក្តៅ»។

៨- បង្កើតបានវប្បធម៌ការងាររបស់មន្ត្រីនគរបាលតំណាងឱ្យសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់មនុស្សជាតិ គោរពច្បាប់ គោរពសិទ្ធិមនុស្ស មិនរើសអើងជាតិសាសន៍ លើកកម្ពស់ការងារជំនាញដើម្បីបម្រើសេវាសន្តិសុខនិងសេវាសាធារណៈជូនប្រជាពលរដ្ឋនិងជួយដោះស្រាយបញ្ហាសង្គមដោយសន្តិវិធីដោយបានជួយកាត់បន្ថយអំពើហិង្សា ភាពភ័យខ្លាចនានាក្នុងសង្គម។

# មាតិកា


**បុព្វកថា** ........ i

**អារម្ភកថា** ........ iii

**សេចក្ដីផ្ដើម** ........ v

**គោលបំណង** ........ vi

**សារៈសំខាន់** ........ vi

**មាតិកា** ........ viii

**ផ្នែកទី១**

**ឧត្ដមភាពនៃមន្ត្រីនគរបាលជាតិ**

**១- មន្ត្រីនគរបាលជាតិ** ........ - ១ -

**១.១- អត្ថន័យតាមការស្រាវជ្រាវបុរេប្រវត្តិ** ........ - ១ -

**១.២- អត្ថន័យតាមវចនានុក្រមខ្មែរនិងភាសាបរទេស** ........ - ២ -

**១.៣- កិច្ចសន្យាសង្គមនិងភាពស្របច្បាប់របស់នគរបាល** ........ - ៥ -

**១.៤- មោទនភាពជាមន្ត្រីនគរបាលជាតិ** ........ - ៦ -

**២- ភាពខុសគ្នារវាងនគរបាលនិងពលរដ្ឋទូទៅ** ........ - ៦ -

**ផ្នែកទី២**

**សញ្ញាណទូទៅនៃអភិសមាចារនិងក្រមសីលធម៌**

**១- អភិសមាចារ** ........ - ៨ -

**១.១- និយមន័យ** ........ - ៨ -

**១.២- គោលបំណងនិងសារៈសំខាន់** ........ - ៩ -

**១.៣- តួនាទីអភិសមាចារក្នុងវិជ្ជាជីវៈ** ........ - ១០ -

១.៣.១- អភិសមាចារក្នុងការអនុវត្តការងារ ........ - ១១ -

១.៣.២- អភិសមាចារនៅកន្លែងធ្វើការ ........ - ១១ -

១.៣.៣- អភិសមាចារក្នុងការទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋ ........ - ១១ -

១.៣.៤- អភិសមាចារក្នុងជីវិតផ្ទាល់ខ្លួន ........ - ១១ -

១.៣.៥- អភិសមាចារក្នុងការទំនាក់ទំនងជាមួយនឹងមិត្តរួមការងារ ........ - ១១ -

**១.៤- មូលដ្ឋាននៃអភិសមាចារក្នុងការគ្រប់គ្រងអំណាច** ........ - ១២ -

**២- សីលធម៌** ........ - ១៣ -

**២.១- និយមន័យ** ... - ១៣ -
**២.២- សារៈសំខាន់នៃសីលធម៌** ... - ១៤ -
**២.៣- ប្រភេទផ្សេងៗនៃសីលធម៌** ... - ១៥ -
២.៣.១- សីលធម៌ចំពោះខ្លួនឯង ... - ១៥ -
២.៣.២- សីលធម៌ចំពោះគ្រួសារនិងអ្នកដទៃ ... - ១៥ -
២.៣.៣- សីលធម៌ចំពោះសង្គមជាតិ ... - ១៦ -
២.៣.៤- សីលធម៌សម្រាប់ពិភពលោក ... - ១៧ -
**២.៤- ការលើកកម្ពស់សីលធម៌** ... - ១៨ -
**៣- ក្រមសីលធម៌** ... - ២០ -
**៣.១- និយមន័យនិងសារៈសំខាន់** ... - ២០ -
៣.១.១- និយមន័យ ... - ២០ -
៣.១.២- សារៈសំខាន់ ... - ២១ -
**៣.២- មុខងារក្រមសីលធម៌និងភាពខុសគ្នាជាមួយនឹងច្បាប់** ... - ២២ -
៣.២.១- មុខងាររបស់ក្រមសីលធម៌ ... - ២២ -
៣.២.២- មុខងាររបស់ច្បាប់ ... - ២២ -
៣.២.៣- ទំនាក់ទំនងរវាងក្រមសីលធម៌និងច្បាប់ ... - ២៣ -
៣.២.៤- តារាងប្រៀបធៀបរវាងក្រមសីលធម៌និងច្បាប់ ... - ២៣ -
**៣.៣- ការកសាងមុខងារក្រមសីលធម៌** ... - ២៤ -
**៣.៤- ការអនុវត្តមុខងារក្រមសីលធម៌** ... - ២៥ -
**៣.៥- អន្តរកម្មនិងភាពផ្សេងគ្នារវាងអភិសមាចារនិងក្រមសីលធម៌** ... - ២៥ -
៣.៥.១- អន្តរកម្មនិងអត្ថប្រយោជន៍ ... - ២៥ -
៣.៥.២- ភាពផ្សេងគ្នារវាងអភិសមាចារនិងក្រមសីលធម៌ ... - ២៦ -
**៤- ក្រមសីលធម៌វិជ្ជាជីវៈ** ... - ២៦ -
**៤.១- និយមន័យ** ... - ២៦ -
**៤.២- គុណសម្បត្តិនៃក្រមសីលធម៌វិជ្ជាជីវៈ** ... - ២៧ -
៤.២.១- គុណសម្បត្តិចំពោះសង្គម ... - ២៧ -
៤.២.២- គុណសម្បត្តិចំពោះអង្គភាពឬស្ថាប័ន ... - ២៧ -
**៤.៣- គោលការណ៍នៃក្រមសីលធម៌វិជ្ជាជីវៈ** ... - ២៨ -
**៤.៤- តារាងប្រៀបធៀបរវាងអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈ** ... - ២៩ -

# ផ្នែកទី៣
# មូលដ្ឋានគ្រឹះនៃអភិសមាចារនិងក្រមសីលធម៌មន្ត្រីនគរបាល


**១- មូលដ្ឋានគ្រឹះនៃអភិសមាចារមន្ត្រីនគរបាល** ........ - ៣០ -

**១.១- មនសិការវិជ្ជាជីវៈ** ........ - ៣០ -

១.១.១- ឆន្ទៈបំពេញការងារ ........ - ៣០ -

១.១.២- ការលះបង់ ........ - ៣២ -

១.១.៣- សុចរិតភាព ........ - ៣២ -

១.១.៤- ភាពស្មោះត្រង់ ........ - ៣៣ -

១.១.៥- ការទទួលខុសត្រូវចំពោះសង្គម ........ - ៣៣ -

១.១.៦- ការបង្កើតទំនុកចិត្តសាធារណៈ ........ - ៣៤ -

១.១.៧- ការអភិវឌ្ឍសមត្ថភាព (ជំនាញនិងច្បាប់) ........ - ៣៤ -

**១.២- វប្បធម៌នៃការបម្រើសេវា** ........ - ៣៥ -

១.២.១- ការសម្របសម្រួលផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយា ........ - ៣៥ -

១.២.២- ការបម្រើសេវា ........ - ៣៦ -

១.២.៣- ការផ្សព្វផ្សាយ ........ - ៣៦ -

១.២.៤- ការសម្របសម្រួល ........ - ៣៦ -

**១.៣- ស្មារតីសាមគ្គីភាព** ........ - ៣៧ -

១.៣.១- ការបង្កើតឱ្យមានក្រមសីលធម៌គិតពីគោលបំណងរបស់ស្ថាប័ន ........ - ៣៧ -

១.៣.២- ការបង្កើតឱ្យមានក្រមសីលធម៌គិតពីឧត្តមប្រយោជន៍របស់ស្ថាប័ន ........ - ៣៨ -

១.៣.៣- ការបង្កើតឱ្យមានក្រមសីលធម៌និងគុណធម៌ ........ - ៣៨ -

១.៣.៤- ការគោរពច្បាប់និងសិទ្ធិសេរីភាពអ្នកដទៃ ........ - ៣៨ -

១.៣.៥- ការបង្រួបបង្រួមទស្សនៈ ........ - ៣៩ -

១.៣.៦- បង្កើតភាពជាអ្នកដឹកនាំប្រកបដោយសីលធម៌និងការធ្វើជាគំរូ ........ - ៣៩ -

**២- មូលដ្ឋានគ្រឹះនៃក្រមសីលធម៌មន្ត្រីនគរបាល** ........ - ៤០ -

**២.១- ក្រមសីលធម៌មន្ត្រីនគរបាល** ........ - ៤០ -

២.១.១- សីលធម៌ ........ - ៤០ -

២.១.២- សុចរិតភាព ........ - ៤១ -

២.១.៣- តម្លៃ ........ - ៤១ -

**២.២- ក្រមសីលធម៌ក្នុងការបំពេញការងារ** ........ - ៤១ -
២.២.១- មូលដ្ឋានក្រមសីលធម៌នៃវិន័យ ........ - ៤១ -
២.២.២- មូលដ្ឋានគណនេយ្យភាពនិងទំនួលខុសត្រូវ ........ - ៤២ -
២.២.៣- មូលដ្ឋានយុត្តិធម៌និងសមធម៌ ........ - ៤២ -
២.២.៤- មូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស ........ - ៤៣ -
២.២.៥- មូលដ្ឋាននៃការប្រើសិទ្ធិអំណាច ........ - ៤៣ -
**២.៣- ការប្រព្រឹត្តខុស ការរំលោភអំណាច និងអំពើពុករលួយ** ........ - ៤៥ -
២.៣.១- លក្ខណៈនៃការប្រព្រឹត្តខុស ........ - ៤៥ -
២.៣.២- ការរំលោភអំណាច ........ - ៤៥ -
២.៣.៣- ទម្រង់នៃអំពើពុករលួយ ........ - ៤៦ -
២.៣.៤- ការបង្ការអំពើពុករលួយ ........ - ៤៦ -

## ផ្នែកទី៤
## តួនាទីអភិសមាចារនិងក្រមសីលធម៌
## វិជ្ជាជីវៈមន្ត្រីនគរបាលជាតិក្នុងកិច្ចប្រតិបត្តិការ

**១- ការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលជាតិ** ........ - ៤៨ -
**១.១- តួនាទីទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ** ........ - ៤៨ -
១.១.១- ការគោរពវិន័យនិងបញ្ញាស្របច្បាប់ ........ - ៤៨ -
១.១.២- ការរក្សាការសម្ងាត់នៃព័ត៌មានសន្តិសុខ ........ - ៤៩ -
១.១.៣- ការគោរពសិទ្ធិនិងឯករាជ្យភាពរបស់បុគ្គល ........ - ៥០ -
១.១.៤- ការបម្រើសេវានិងផលប្រយោជន៍សាធារណៈ ........ - ៥១ -
១.១.៥- ការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ........ - ៥២ -
១.១.៦- ការទាក់ទងជាមួយជនងាយរងគ្រោះ (កុមារ ស្ត្រី វ័យចំណាស់ និងជនពិការ) ........ - ៥២ -
**១.២- តួនាទីប្រតិបត្តិក្នុងវិស័យសន្តិសុខជាតិ** ........ - ៥៣ -
១.២.១- វិធានជាមូលដ្ឋានដែលត្រូវប្រតិបត្តិ ........ - ៥៤ -
១.២.២- ការរក្សាសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម ........ - ៥៤ -
១.២.៣- ការស្វែងរកវត្ថុតាងដោយក្រមសីលធម៌វិជ្ជាជីវៈ ........ - ៥៦ -
១.២.៤- តុល្យភាពនៃការប្រើកម្លាំងនិងអាវុធ ........ - ៥៦ -

**២- ការបំពេញតួនាទីក្នុងភាពជាអ្នកដឹកនាំបញ្ជា** ........ - ៥៨ -
**២.១- ការដឹកនាំ** ........ - ៥៨ -
**២.២- ការបញ្ជា** ........ - ៥៨ -
**២.៣- ដំណើរការនៃការបញ្ជា** ........ - ៥៩ -
**២.៤- ខ្លឹមសារការដឹកនាំបញ្ជា** ........ - ៥៩ -
**២.៥- លក្ខណៈពិសេសនៃការដឹកនាំបញ្ជា** ........ - ៦០ -
**៣- ការកសាងសាមគ្គីភាព សុខដុមនីយកម្ម** ........ - ៦១ -

## ផ្នែកទី៥

## ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

**១- តួនាទីក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** ........ - ៦២ -
**១.១- សីលធម៌វិជ្ជាជីវៈក្នុងការប្រើប្រាស់បណ្តាញសង្គម** ........ - ៦៣ -
១.១.១- ការគោរពសេចក្តីថ្លៃថ្នូរវិជ្ជាជីវៈ ........ - ៦៣ -
១.១.២-ការគោរពច្បាប់និងបទបញ្ជាស្ថាប័ន ........ - ៦៣ -
១.១.៣- ភាពទទួលខុសត្រូវចំពោះមាតិកា ........ - ៦៣ -
១.១.៤- មិនលាយបញ្ចូលរវាងជីវិតផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ........ - ៦៣ -
១.១.៥- ការគោរពសិទ្ធិ និងឯកជនភាពអ្នកដទៃ ........ - ៦៣ -
១.១.៦- ចៀសវាងការបង្ហោះមាតិកាបង្កការបែកបាក់សង្គម ........ - ៦៤ -
១.១.៧- ជាគំរូល្អដល់សង្គម ........ - ៦៤ -
**១.២- ការរក្សាព័ត៌មានសម្ងាត់** ........ - ៦៤ -
១.២.១- ប្រភេទព័ត៌មានត្រូវរក្សាការសម្ងាត់ ........ - ៦៤ -
១.២.២- គោលការណ៍សំខាន់ក្នុងការរក្សាព័ត៌មានសម្ងាត់ ........ - ៦៤ -
១.២.៣- វិធានការរក្សាការសម្ងាត់ ........ - ៦៤ -
១.២.៤- ការប្រុងប្រយ័ត្នពេលប្រើបណ្តាញសង្គម ........ - ៦៥ -
១.២.៥- ការទទួលខុសត្រូវនិងវិន័យ ........ - ៦៥ -
១.២.៦- គំរូនៃការអនុវត្តល្អ ........ - ៦៥ -
**១.៣- ចៀសវាងការប្រើព័ត៌មានខុសច្បាប់** ........ - ៦៦ -
១.៣.១- អ្វីទៅជា «ព័ត៌មានខុសច្បាប់» ........ - ៦៦ -
១.៣.២- ការប្រុងប្រយ័ត្នពេលប្រើបណ្តាញសង្គម ........ - ៦៦ -

១.៣.៣- ការប្រើព័ត៌មានឱ្យបានត្រឹមត្រូវ ....... - ៦៦ -
១.៣.៤- ទណ្ឌកម្មនិងផលប៉ះពាល់ ....... - ៦៧ -
**២- សីលធម៌នៃការរក្សាឯកសារនិងវត្ថុតាង** ....... - ៦៧ -
**២.១- នីតិវិធីប្រតិបត្តិការតាមស្តង់ដា** ....... - ៦៧ -
២.១.១- គោលការណ៍សីលធម៌មូលដ្ឋាន ....... - ៦៧ -
២.១.២- ការរក្សាវត្ថុតាងឱ្យបានត្រឹមត្រូវពីរចំណុច ....... - ៦៧ -
២.១.៣- វិធានការរក្សាសុវត្ថិភាព ....... - ៦៨ -
២.១.៤- ការគោរពសិទ្ធិនិងឯកជនភាព ....... - ៦៨ -
២.១.៥- ការប្រើប្រាស់និងការបង្ហាញវត្ថុតាង ....... - ៦៨ -
២.១.៦- វិន័យនិងទណ្ឌកម្ម ....... - ៦៨ -
២.១.៧- គំរូនៃការអនុវត្តល្អ ....... - ៦៨ -
**២.២- ការលេចធ្លាយព័ត៌មានរបស់នគរបាល** ....... - ៦៩ -
២.២.១- សេចក្តីពិពណ៌នាករណី (Case Description) ....... - ៦៩ -
២.២.២- ប្រភេទព័ត៌មានដែលបានបែកធ្លាយ ....... - ៦៩ -
២.២.៣- វិភាគតាមសីលធម៌វិជ្ជាជីវៈ ....... - ៦៩ -
២.២.៤- វិភាគតាមច្បាប់និងបទបញ្ជា ....... - ៦៩ -
២.២.៥- ផលប៉ះពាល់ពាក់ព័ន្ធ ....... - ៧០ -
២.២.៦- មូលហេតុជាចម្បងនាំឱ្យមានផលវិបាក ....... - ៧០ -
២.២.៧- វិធានការកែតម្រូវនិងការពារ ....... - ៧០ -
២.២.៨- មេរៀនសំខាន់សម្រាប់ពិចារណា ....... - ៧០ -

## ផ្នែកទី៦

## គោលការណ៍សកលនៃកិច្ចប្រតិបត្តិការនិងក្រមសីលធម៌នគរបាល

**១- ក្រមប្រតិបត្តិអន្តរការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់** ....... - ៧២ -
**២- វិជ្ជាជីវៈនិងអាកប្បកិរិយាប្រកបដោយសីលធម៌របស់មន្ត្រីអនុវត្តច្បាប់** ....... - ៧៣ -
**២.១- អាកប្បកិរិយាដោយសីលធម៌** ....... - ៧៣ -
**២.២- បញ្ហាប្រឈមនៃក្រមសីលធម៌នគរបាល** (Ethical Challenges) ....... - ៧៤ -
**២.៣- យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សីលធម៌** (Strategies for Strengthening Ethics) ....... - ៧៥ -

**៣- គោលការណ៍សីលធម៌នៃមន្ត្រីនគរបាល** ........ - ៧៥ -

**៤- បទដ្ឋានគតិយុត្តអន្តរជាតិអំពីភាតព្វកិច្ចមន្ត្រីនគរបាល** ........ - ៧៦ -

**៥- បញ្ហានៃសីលធម៌ក្នុងវិជ្ជាជីវៈនគរបាល** ........ - ៧៨ -

**៥.១- សីលធម៌និងការប្រើកម្លាំងនិងអាវុធជាតិផ្ទុះ** ........ - ៧៨ -

**៥.២- អំពើហិង្សារបស់នគរបាលនិងការរើសអើង** ........ - ៧៩ -

**៥.៣- សីលធម៌និងវិធានការប្រឆាំងអំពើពុករលួយ** ........ - ៧៩ -

**៥.៤- សីលធម៌និងធារុណកម្ម** ........ - ៨១ -

**សេចក្តីសន្និដ្ឋាន** ........ - ៨២ -

**សារចងចាំនិងរូបភាព** ........ - ៨៣ -

**គំរូវីរភាពរបស់វីរកងកម្លាំងស្នេហាជាតិជួរមុខ** ........ - ៨៣ -

**សារសំណេរដ៏មានអត្ថន័យរបស់វីរកងកម្លាំងស្នេហាជាតិក្នុងសមរភូមិប្រយុទ្ធ** ........ - ៨៤ -

**គំរូវីរភាពនៃការលះបង់របស់ប្អូនៗយុវជនកងកម្លាំងស្នេហាជាតិ** ........ - ៨៥ -

**គំរូវីរភាពដ៏អង់អាចក្លាហានរបស់វីរកងកម្លាំងស្នេហាជាតិ** ........ - ៨៦ -

**គំរូវីរភាពប្រកបដោយទឹកចិត្តមនសិការដើម្បីបុព្វហេតុជាតិមាតុភូមិ** ........ - ៨៧ -

**សារសំណេរចេញពីបេះដូងរបស់ប្រជាពលរដ្ឋ** ........ - ៨៨ -

**ទឹកចិត្តរបស់ក្មួយៗសិស្សានុសិស្សដឹងគុណនិងជូនពរដល់វីរកងកម្លាំងស្នេហាជាតិ** ........ - ៩០ -

**ស្លាដែឯកជាប្រវត្តិសាស្ត្រនៃការរួបរួមគ្នារបស់សិល្បករ ៥០រូបគូរគំនូរខ្នាតយក្ស៣០ម៉ែត្រ** ........ - ៩៤ -

**រាជរដ្ឋាភិបាលនិងវីរកងកម្លាំងស្នេហាជាតិព្រមទាំងប្រជាជនកម្ពុជារួមគ្នាជាធ្លុងមួយ** ........ - ៩៥ -

**បទចម្រៀងរំឭកដល់គំរូវីរភាពអង់អាចក្លាហានរបស់កងកម្លាំងស្នេហាជាតិ** ........ - ៩៦ -

**បទចម្រៀងនៃការនឹករឭកលំនៅឋានរបស់កុមារី ចាន់ត្រា** ........ - ៩៧ -

**ឯកសារពិគ្រោះ** ........ - ៩៨ -

**ឧបសម្ព័ន្ធ** ........ - ១០១ -

# ផ្នែកទី១
# ទស្សនាទាននៃមន្ត្រីនគរបាលជាតិ

## ១- មន្ត្រីនគរបាលជាតិ

### ១.១- អត្ថន័យតាមការស្រាវជ្រាវចុះប្រវត្តិ

តាមការសិក្សាស្រាវជ្រាវរបស់លោកបណ្ឌិត **វង់ សុជាវ៉** អ្នកជំនាញខាងសិលាចារឹក លោកបានមានប្រសាសន៍ថា អត្តសញ្ញាណនគរបាលឃើញមានតាំងពីសម័យអង្គរមកម្ល៉េះ ហើយដែលបានកត់ត្រានៅលើថ្មអំពីការគ្រប់គ្រងដឹកនាំរាជកិច្ចរបស់ព្រះរាជា។ ចាប់តាំងពីសតវត្សទី១០មកគេឃើញមានសិលាចារឹកជាច្រើនរៀបរាប់អំពីរដ្ឋមន្ត្រីនិងមន្ត្រីជាន់ខ្ពស់ខាងសន្តិសុខនិងមហាផ្ទៃដែលមានបច្ចេកសព្ទជាពាក្យថា «គុណទោសទស៌» (Gunadosadarśi) ដែលទាក់ទងជាមួយនឹងរដ្ឋមន្ត្រីនិងមន្ត្រីជាន់ខ្ពស់ខាងយុត្តិធម៌និងតុលាការ។

ជានិច្ចកាលពួកគេតែងបំពេញការងារជាមួយគ្នានៅក្នុងសមាសភាពគណៈកម្មការដោះស្រាយបញ្ហាដីធ្លីដែលព្រះរាជាបង្កើតឡើងដើម្បីដោះស្រាយទំនាស់និងបោះបង្គោលព្រំដែនដីធំៗជាពិសេសដីធ្លីដែលជាអំណោយដល់អាទិទេពនៃប្រាសាទធំៗដែលនៅពេលនោះរដ្ឋមន្ត្រីនិងមន្ត្រីជាន់ខ្ពស់ជាច្រើនមានឋានន្តរនាមជា «បណ្ឌិត»។ ជាក់ស្តែងសិលាចារឹក(K.1198) បានបង្ហាញពីមន្ត្រីជាន់ខ្ពស់ខាងនគរ-បាលពីរនាក់ ម្នាក់ជាអ្នកទទួលរាជបញ្ជាឱ្យចេញរាជបញ្ជាមានឋានន្តរនាមជា **កំស្តែងមហាត្មៈ** និងម្នាក់ទៀតជាអ្នកទទួលបញ្ជានោះបន្តទៅអនុវត្តដែលមានឋានន្តរនាមជា **មតាញខ្លោញស្រីជលាវង្កស្វរៈ** គឺជាមហាបណ្ឌិតមានមូលដ្ឋាននៅទឹកឆាស្រុកព្រៃឈរ ខេត្តកំពង់ចាម។ មន្ត្រីនគរបាលជាន់ខ្ពស់នេះត្រូវបានព្រះបាទសូរ្យវរ្ម័នទី១បញ្ជាឱ្យចូលរួមក្នុងគណៈកម្មការតាក់តែងសិលាចារឹកវត្តសំរោងនៃទីរួមខេត្តឧត្តរមានជ័យដោយឱ្យមេទ័ពកម្រិតទី២ម្នាក់មានឋានន្តរនាម **វ្រះកំស្តែងអញស្រីលក្សីវតីវម្ម័** ដែលជាអភិបាលខេត្តល្វោ។ ហេតុនេះ អ្នកគ្រប់គ្រងនគរបាលមិនមែនមានចំណេះដឹងតែរឿងកាប់ចាក់ដោយកាំបិត ដាវ លំពែងនោះទេ តែត្រូវមានចំណេះដឹងខាងផ្នែកផ្សេងៗទៀតជ្រៅជ្រះផងដែរ។

មកដល់សម័យក្រោយអង្គរ តួនាទីរដ្ឋមន្ត្រីសន្តិសុខនិងមហាផ្ទៃនៅតែភ្ជាប់គ្នាជាមួយនឹងរដ្ឋមន្ត្រីយុត្តិធម៌ដដែល។ នៅឆ្នាំ១៦៩៦ក្នុងរាជព្រះបាទជ័យជេដ្ឋាទី៣ អង្គសូរ រដ្ឋមន្ត្រីមួយរូបរបស់ព្រះអង្គគឺលោកជ័យនន្ទបានឱ្យដឹងថា គាត់ជាឧកញ៉ាយមរាជមានតួនាទីជាអគ្គមហាសេនាផង ព្រះមហានគរបាលដ៏អង់អាចមិនចេះភ័យខ្លាចផង និងជារដ្ឋមន្ត្រីថ្នាក់ទី១ផង។ ដូច្នេះតួនាទីនេះគឺជារដ្ឋមន្ត្រីនៃសសរស្តម្ភមួយក្នុងចំណោមរដ្ឋមន្ត្រីសសរស្តម្ភបួនរបស់រាជការដែលគេហៅថា មន្ត្រីចតុស្តម្ភឬមន្ត្រីមុខចតុស្តម្ភ (នៅក្នុងសិលាចារឹកនគរវត្តលេខ៣និងលេខ៤)។

ទន្ទឹមនេះ យោងតាមគណៈកម្មការស្រាវជ្រាវនិងចងក្រងប្រវត្តិសកម្មភាពនិងសមិទ្ធផលនានានៃកងកម្លាំងនគរបាលជាតិកម្ពុជាដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ន សំណាង** បានបញ្ជាក់ថាក្នុងប្រវត្តិសាស្ត្រនគរបាលកម្ពុជាតែងមានទំនាក់ទំនងជិតស្និទ្ធទៅនឹងប្រវត្តិនយោបាយ សង្គម និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណាព្យាបាលបារាំងចាប់ពីឆ្នាំ១៨៦៣មក «យោងតាមសន្ធិសញ្ញាបារាំង-ខ្មែរថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣»។ តាមការស្រាវជ្រាវគេមិនអាច

រកឃើញឯកសារជាលាយលក្ខណ៍អក្សរណាមួយដែលបាននិយាយទាក់ទងនឹងវិស័យនគរបាលនៅប្រទេសកម្ពុជាអស់រយៈពេល២ទសវត្សពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៨៨៣។ គេបានឃើញឯកសារជាលាយលក្ខណ៍អក្សរដែលចំណាស់ជាងគេស្ដីពីវិស័យនគរបាលនេះមាននៅចាប់ពីឆ្នាំ១៨៨៤ដែលបានតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានជាតិក្រុងភ្នំពេញសព្វថ្ងៃ។

ចំណេរតមកនគរបាលជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៥ដោយព្រះរាជក្រមលេខ ៣៥-ន.ស.ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៥ដែលស្ថិតនៅចំណុះក្រសួងមហាផ្ទៃនិងកិច្ចការនយោបាយក្នុងអាណត្តិនៃរាជរដ្ឋាភិបាលកម្ពុជាឯករាជ្យជាលើកដំបូង។ ផ្អែកលើឯកសារដ៏សំខាន់នេះធ្វើឱ្យក្រុមការងារស្រាវជ្រាវអាចធ្វើការចងក្រងអំពីប្រវត្តិសកម្មភាពនិងសមិទ្ធផលនៃកងកម្លាំងនគរបាលជាតិនៅកម្ពុជាចាប់ពីឆ្នាំ១៨៨៤មកដោយមានមូលដ្ឋានច្បាស់លាស់។ ម្យ៉ាងទៀតនៅក្នុងអនុសញ្ញាបារាំង-ខ្មែរ ឆ្នាំ១៨៨៤ (មាត្រា៣) មានការបញ្ជាក់យ៉ាងច្បាស់ថា មន្ត្រីរាជការខ្មែរនៅតែបន្តការគ្រប់គ្រងទឹកដីរបស់ខ្លួននៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំងដដែល ហើយជនរួមជាតិខ្មែរយើងជាច្រើននាក់ក៏បានចូលរួមចំណែកធ្វើពលិកម្មគ្រប់បែបយ៉ាងក្នុងការពង្រឹងការងារសន្តិសុខនិងសណ្ដាប់ធ្នាប់សង្គមជាមួយនឹងបារាំងក្នុងវិស័យនគរបាលអស់រយៈពេល៦១ឆ្នាំ (១៨៨៤-១៩៤៥) មកមុនពេលបង្កើតនគរបាលជាតិ (Police Nationale) នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៥ក្នុងពេលដែលប្រទេសកម្ពុជាបានឯករាជ្យរយៈពេលតែជិត៧ខែ (មីនា-តុលា ១៩៤៥) ក្រោយពីស្ថិតនៅក្រោមអាណាព្យាបាលបារាំងអស់រយៈពេល៨២ឆ្នាំកន្លងមក (១៨៦៣-១៩៤៥) និងបន្តមកក្រោយសង្គ្រាមលោកលើកទី២ ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងអស់រយៈពេល៨ឆ្នាំបន្ថែមទៀត (១៩៤៥-១៩៥៣) មុននឹងទទួលបានឯករាជ្យពិតប្រាកដ។ ក្នុងន័យខាងលើនេះយើងអាចដឹងថា នគរបាលមានការកកើតឡើងតាំងពីយូរណាស់មកហើយ ប៉ុន្តែជាសញ្ញាណដែលបង្ហាញច្បាស់លាស់និងមានកត់ត្រាជាឯកសារត្រឹមត្រូវនៅឆ្នាំ១៨៨៤រហូតមកដល់សព្វថ្ងៃនេះ ទើបថ្ងៃកំណើតនគរបាលត្រូវបានកំណត់យកថ្ងៃទី១៦ ខែឧសភាឆ្នាំ១៩៤៥ផ្អែកតាមព្រះរាជក្រឹត្យលេខនស/រកត០៨០៦/៣៤២ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៦។ យោងតាមការចុះផ្សាយរបស់ទស្សនាវដ្ដីស្ដីពី «ប្រវត្តិសកម្មភាពនគរបាល» បានបង្ហាញថា ប្រវត្តិនគរបាលជាតិកម្ពុជាដែលមានរយៈពេល១២៣ឆ្នាំ (១៨៨៤-២០០៧) ត្រូវបានគណៈកម្មការស្រាវជ្រាវនិងចងក្រងបានបែងចែកជាបីផ្នែករួមមាន ផ្នែកទី១គិតចាប់ពីឆ្នាំ១៨៨៤ដល់ឆ្នាំ១៩៤៥ (ឯកសារភាគច្រើនជាភាសាបារាំង) ផ្នែកទី២គិតពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៧៥ (ឯកសារមានមិនគ្រប់ក្នុងសម័យឆ្នាំ១៩៧៣-១៩៧៥) និងផ្នែកទី៣គិតពីឆ្នាំ១៩៧៩ដល់ឆ្នាំ២០០៧។ សូមបញ្ជាក់ជូនថា ពីឆ្នាំ១៩២៥ដល់ឆ្នាំ១៩៥៩ ពាក្យខ្មែរផ្សេងៗដែលប្រើស្របនឹងពាក្យបារាំង «Police» រួមមានដូចជាកងក្រវែល ក្រុមប៉ូលិស ក្រុមព្រះនគរបាល និងកងរាជតម្រួតជាដើម។

**១.២- អត្ថន័យតាមវចនានុក្រមខ្មែរនិងភាសាបរទេស**

ការសិក្សាស្រាវជ្រាវបានបង្ហាញថា ពាក្យ «នគរបាល» តាមវចនានុក្រមខ្មែរភាគទី១និងភាគទី២ របស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានបញ្ជាក់ថា «នគរបាល» គឺជាអ្នករក្សានគរឬជាឈ្មោះមួយដែលសំដៅទៅលើក្រសួងឬក្រុមរាជការត្រួតត្រារក្សាប្រជាជន។ ការប្រតិបត្តិតាមបញ្ញត្តិសម្រាប់ក្រុមនោះមានន័យថាជាក្រុមនគរបាលឬតម្រួតនគរបាលដែលនៅរក្សាការពារសណ្ដាប់ធ្នាប់តាមក្រុង ខេត្ត

ស្រុកឬតាមសង្កាត់ឱ្យមានរបៀបរៀបរយនិងសណ្តាប់ធ្នាប់សង្គម។ ក្នុងន័យម្យ៉ាងទៀតពាក្យ «នគរបាល» បានមកតាមន័យអក្សរសាស្ត្រដែលមានពាក្យពីរបូកបញ្ចូលគ្នាគឺ «នគរ + បាល» យោងតាមវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ គ.ស.១៩៦៧ដោយពុទ្ធសាសនបណ្ឌិត្យបានពន្យល់ថា «នគរ» ជាពាក្យបាលីសំស្ក្រឹតមានន័យថា បុរីឬក្រុង រីឯពាក្យ «បាល» ពុំមានការពន្យល់ក្នុងវចនានុក្រមខ្មែរទេ ប៉ុន្តែយើងពិនិត្យឃើញមានពាក្យផ្សំដែលកើតឡើងដោយបន្សំពាក្យ «បាល» ជាមួយនឹងធាតុផ្សេងទៀតដូចជា «អភិបាល» មានន័យថា អ្នកគ្រប់គ្រងឬការគ្រប់គ្រងជាន់ខ្ពស់។ បន្ថែមលើនេះក៏មានពាក្យមួយចំនួនទៀតផងដែរដូចជា «គេហបាល» មានន័យថាអ្នករក្សាផ្ទះ អ្នកចាំផ្ទះ (ឆ្មាំផ្ទះ) «ទ្វារបាល» មានន័យថាអ្នករក្សាទ្វារ អ្នកចាំទ្វារ (ឆ្មាំទ្វារ)។ ផ្អែកតាមពាក្យ អភិបាល គេហបាល និងទ្វារបាលទាំងបីខាងលើនេះយើងអាចពន្យល់ន័យនៃពាក្យ «បាល» ដែលមានន័យសំដៅទៅលើមនុស្សឬសកម្មភាពនៃអ្នកគ្រប់គ្រង អ្នកថែរក្សាឬការគ្រប់គ្រងនិងការថែរក្សាជាដើម។ ជាមួយគ្នានេះវចនានុក្រមខ្មែរ (១៩៦៧) បានពន្យល់ពាក្យ «**នគរបាល** ដែលមានន័យថា អ្នករក្សានគរ ហៅក្លាយជាអង្គរបាល» ដែលជាក្រសួងឬក្រុមរាជការត្រួតត្រារក្សាប្រជាជនក្នុងក្រុងឱ្យប្រតិបត្តិតាមបញ្ញត្តិរបស់ក្រុងនិងជាន័យផ្សេងទៀតថាជាក្រុមនគរបាលឬតម្រួតនគរបាលឬក៏រាជតម្រួតក្រុង (ចំពោះតែរាជធានីភ្នំពេញ)។ សម្រាប់ខេត្តស្រុកហៅថា រាជតម្រួតខេត្ត រាជតម្រួតស្រុក ហើយសម្រាប់មណ្ឌលនីតិកម្មក្នុងតំបន់ឬក្នុងសង្កាត់ក៏គេហៅថា រាជតម្រួតស្រុកដែរ។ តាមហេតុផលខាងលើនេះពាក្យ «នគរបាល» គេបានឱ្យន័យពីរយ៉ាងគឺន័យទីមួយគេសំដៅទៅលើមនុស្សដែលជាមន្ត្រីនគរបាលនិងន័យមួយទៀតសំដៅទៅលើស្ថាប័នដែលជាអង្គភាពនគរបាលបំពេញការងារ។ បច្ចុប្បន្ននេះពាក្យ «តម្រួតនគរបាលនិងពាក្យរាជតម្រួតនគរបាល» មិនត្រូវបានយកមកប្រើក្នុងក្របខណ្ឌការងារនគរបាលនោះទេ ប៉ុន្តែយើងមានប្រើពាក្យ «តម្រួតបទបញ្ជា» ដែលជាឈ្មោះអង្គភាពមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

យោងតាមសេចក្តីពន្យល់ខាងលើ ពាក្យ «នគរបាល» មានអត្ថន័យស្របគ្នានឹងភាសាអង់គ្លេសថា «Police» ដែលត្រូវបានកំណត់សេចក្តីពន្យល់ដូចជាពាក្យថា «Police» ពាក្យនេះបានក្លាយមកពីពាក្យក្រិក «Politeia» ឬស្មើនឹងពាក្យឡាតាំង «Politia»។ ពាក្យថា «Politia» សំដៅទៅលើ «រដ្ឋ» ឬ «រដ្ឋបាល» ឬ State or Administration ពាក្យនេះសំដៅទៅលើស្ថាប័នផងនិងមុខងារផង ពាក្យនេះក៏ធ្លាប់បានប្រើនៅក្នុងទ្រឹស្តីទស្សនវិទ្យានយោបាយរបស់លោកប្លាតុងនិងអារីស្តូតផងដែរ។

ខាងក្រោមនេះគឺជាការបកស្រាយអត្ថន័យពាក្យក្នុងតួអក្សរនីមួយៗនៃភាសាបារាំងនិងអង់គ្លេសមកជាខេមរភាសាដើម្បីបានឈ្វេងយល់តាមតួអក្សរនីមួយៗ៖

| ភាសាបារាំង | ភាសាអង់គ្លេស | អត្ថន័យជាខេមរភាសា |
|---|---|---|
| P = Polie | = Polite | - សុភាពរាបសា |
| O = Obeir | = Obey | - គោរពវិន័យ |
| L = Loyal | = Loyal | - សេចក្តីស្មោះត្រង់ |
| I = Intelligent | = Intelligent | - ភាពឈ្លាសវៃ ឆ្លាតមានបញ្ញា |
| C = Courageux | = Courageous | - សេចក្តីក្លាហាន អង់អាច |
| E = Efficacite | = Effectiveness | - ប្រសិទ្ធភាព |

តាមអត្ថន័យខាងលើមានន័យថា នគរបាលជាកងកម្លាំងមួយដែលមានអត្តចរិតសុភាពរាបសា គោរពវិន័យ ស្មោះត្រង់ ឈ្លាសវៃ ប៉ិនប្រសប់ និងមានសេចក្តីក្លាហានអង់អាចក្នុងការបម្រើជាតិជាពិសេស នៅពេលបំពេញភារកិច្ចស្នូលរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវការគោរពប្រតិបត្តិច្បាប់បានត្រឹមត្រូវប្រកប ដោយក្រមសីលធម៌ខ្ពស់នៅក្នុងវិជ្ជាជីវៈ។

បច្ចុប្បន្ននេះទាំងថ្នាក់ដឹកនាំ ទាំងប្រជាជនមហាជនខ្មែរទូទៅតែងតែប្រើពាក្យលាយឡំគ្នានូវ ពាក្យ «នគរបាលនិងPolice» គឺអាស្រ័យដោយប្រទេសកម្ពុជាធ្លាប់ជាប្រទេសដែលស្ថិតនៅក្រោម អាណានិគមនិយមបារាំងធ្វើឱ្យផ្ទត់គំនិតរបស់ប្រជាជនច្រើនប្រើពាក្យជាភាសាបារាំងគឺ «Police» ហើយពាក្យនេះគេសំដៅទៅលើអង្គភាពនៃមន្ត្រីសាធារណៈដែលមានភារកិច្ចក្នុងការរក្សាសណ្តាប់ធ្នាប់ សាធារណៈ ការងារបង្ការ ការទប់ស្កាត់ និងការតាមដានស៊ើបអង្កេតបទល្មើស ព្រមទាំងការអនុវត្តច្បាប់ ផងដែរ។ គេបានឱ្យអត្ថន័យនៃពាក្យ «Police» មានន័យពីរយ៉ាងគឺ

- **ន័យទី១ :** Police សំដៅទៅលើកងកម្លាំងផ្លូវការរបស់រដ្ឋដែលត្រូវបានបង្កើតឡើងដើម្បី ប្រតិបត្តិច្បាប់ធានាឱ្យមានសណ្តាប់ធ្នាប់សាធារណៈ បង្ការ ទប់ស្កាត់ បង្ក្រាប និងស្រាវជ្រាវបទល្មើស ព្រហ្មទណ្ឌនិងបទល្មើសផ្សេងៗទៀត។

- **ន័យទី២ :** Police សំដៅទៅលើស្ថាប័ននគរបាលឬអង្គភាពកងកម្លាំងមិនមែនយោធាដែលមាន ភារកិច្ចទទួលខុសត្រូវលើការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តច្បាប់។ ឧទាហរណ៍ ខ្ញុំនឹងហៅទូរសព្ទទៅនគរបាល... I will call Police...។ ប្រយោគនេះអាចមានន័យថា ខ្ញុំនឹងហៅទូរសព្ទ ទៅមន្ត្រីនគរបាលដែលជាអ្នកមានសមត្ថកិច្ចឬហៅទូរសព្ទទៅអង្គភាពនគរបាលណាមួយដែលមាន សមត្ថកិច្ចដូចជាប៉ុស្តិ៍នគរបាលរដ្ឋបាល អធិការដ្ឋាននគរបាល ឬស្នងការដ្ឋាននគរបាលជាដើម។

ផ្អែកលើហេតុផលនេះយើងពិនិត្យឃើញថា ទាំងភាសាខ្មែរ (នគរបាល) ទាំងភាសាអង់គ្លេស (Police) មានអត្ថន័យស្របគ្នាដែលសំដៅលើមនុស្សជាមន្ត្រីនគរបាលផងនិងជាស្ថាប័នឬអង្គភាព ដែលមន្ត្រីនគរបាលបម្រើការងារផង។ ប៉ុន្តែពាក្យ «នគរបាលឬ Police» មិនមានអត្ថន័យគ្របដណ្តប់ លើមុខងារឬកិច្ចការនគរបាលឬបទប្បញ្ញត្តិទាក់ទងនឹងភារកិច្ចនគរបាលនោះទេ។ ក្នុងភាសាអង់គ្លេស ក្រៅពីពាក្យ «Police» មានពាក្យ «Policing» សំដៅទៅលើការងារឬសកម្មភាពរបស់មន្ត្រីនគរបាល ក្នុងការការពារនិងសង្គ្រោះជីវិតមនុស្ស រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ រក្សាការពារទ្រព្យសម្បត្តិ និងបម្រើការងារក្នុងសហគមន៍។ ជាមួយគ្នានេះដែរយើងឃើញមានពាក្យ «Police Act» ដែលសំដៅ លើច្បាប់នគរបាលឬសំណុំនៃវិធានគតិយុត្តសម្រាប់ប្រើដើម្បីគ្រប់គ្រងលើស្ថាប័នឬអង្គភាពនគរបាល មន្ត្រីនគរបាល និងមុខងារឬកិច្ចការនគរបាលដែលជាកងកម្លាំងមិនមែនជាយោធា។

យោងតាមគណៈកម្មការស្រាវជ្រាវចងក្រងប្រវត្តិសកម្មភាពនិងសមិទ្ធផលនានានៃកងកម្លាំង នគរបាលជាតិកម្ពុជាដែលបានចុះផ្សាយក្នុងទស្សនាវដ្តីនៃក្រសួងមហាផ្ទៃអបអរសាទរខួបអនុស្សាវរីយ៍ លើកទី៦២នៃកំណើតនគរបាលបានសរសេរថា ពាក្យ «នគរបាល» ត្រូវនឹងពាក្យបារាំងថា «Police» មានន័យពីរយ៉ាងគឺបណ្តាវិធានការដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ (Ensemle des measures ayant pour but de garantir l'ordre public) និងកងកម្លាំងសាធារណៈដែលរក្សាសន្តិសុខសាធារណៈ (Force publique qui veille au maintien de la sécurité publique)។

មកដល់ចំណុចនេះយើងអាចទាញសេចក្តីសន្និដ្ឋានបានថា ពាក្យ «នគរបាល» ជាភាសាខ្មែរ និងពាក្យ «Police» ជាភាសាអង់គ្លេសនិងភាសាបារាំងមានអត្ថន័យ៣យ៉ាងគឺ

**- ន័យមនុស្ស** : សំដៅទៅលើកងកម្លាំងនគរបាលឬជាមន្ត្រីអនុវត្តច្បាប់ បំពេញភារកិច្ចស្នូលក្នុងការថែរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈដូចជាការស្រាវជ្រាវ ការបង្ការនិងការទប់ស្កាត់ ការចុះប្រតិបត្តិការបង្ក្រាបបទល្មើស ការស៊ើបអង្កេតព្រហ្មទណ្ឌ ការកសាងសំណុំរឿងទៅតុលាការ ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋជាដើម។

**- ន័យស្ថាប័ន** : សំដៅទៅលើស្ថាប័នឬអង្គភាពដែលគ្រប់គ្រងកងកម្លាំងនគរបាល ឬស្ថាប័ន ឬអង្គភាពដែលនគរបាលបម្រើការងារដូចជាអគ្គស្នងការដ្ឋាននគរបាលជាតិ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលខណ្ឌ ស្រុក ក្រុង ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ជាដើម។

**- ន័យច្បាប់** : សំដៅទៅលើសំណុំវិធានគតិយុត្តទាំងឡាយដែលបង្កើតឡើងដើម្បីជានាឱ្យការបំពេញបេសកកម្មរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋប្រកបដោយភាពត្រឹមត្រូវស្របតាមនីតិវិធីនៃច្បាប់បានកំណត់។ សរុបសេចក្តីមក ពាក្យ «នគរបាល» និងពាក្យ «Police» ត្រូវបានគេប្រើជាទូទៅដោយមានបណ្តាប្រទេសនានាជាច្រើនបានកំណត់រហូតមកដល់បច្ចុប្បន្ននេះដែលមានន័យថា «ស្ថាប័នឬអង្គភាពអនុវត្តច្បាប់» ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនសង្គមជាតិនិងប្រជាជន។

### ១.៣- កិច្ចសន្យាសង្គមនិងភាពស្របច្បាប់របស់នគរបាល

ទំនាក់ទំនងរវាងនគរបាលនិងសង្គមកើតចេញពីអត្ថន័យនៃកិច្ចសន្យាសង្គម ដែលត្រូវបានលើកឡើងជាលើកដំបូងដោយទស្សនវិទូមួយចំនួនដូចជាលោក Thomas Hobbes (ឆ្នាំ១៦៥១) លោក John Locke (ឆ្នាំ១៦៨៩) និងលោក Jean-Jacques Rousseau (ឆ្នាំ១៧៦២)។ យោងទ្រឹស្តីនៃទស្សនវិទូទាំងនោះបានបង្ហាញថា បុគ្គលម្នាក់ៗបានយល់ព្រមរួមគ្នាប្រគល់សិទ្ធិសេរីភាពមួយចំនួនទៅឱ្យរដ្ឋជាថ្នូរនឹងការទទួលបានសន្តិសុខ សណ្តាប់ធ្នាប់សង្គម។ ក្នុងលក្ខខណ្ឌនេះនគរបាលតំណាងឱ្យអាជ្ញាធរស្របច្បាប់របស់រដ្ឋដែលត្រូវបានប្រគល់ភារកិច្ចឱ្យការពារពលរដ្ឋនិងរក្សាយុត្តិធម៌ក្នុងសង្គម ហើយអាជ្ញាធរនេះមិនមែនជារឿងដែលត្រូវតែអនុវត្តដោយខ្លួនឯងនោះដែរ។ អំណាចរបស់នគរបាលត្រូវតែធ្វើឱ្យស្របច្បាប់តាមរយៈការយល់ព្រមពីសាធារណជននូវផ្នត់គំនិត ដែលពួកគេបានយល់ឃើញថាជាភាពស្របច្បាប់របស់នគរបាល។ ប៉ុន្តែត្រូវយល់ថា ភាពស្របច្បាប់មិនមែនចេះតែនិយាយតាមការនឹកឃើញនោះទេ វាត្រូវបានសម្រេចនៅពេលដែលសាធារណជនយល់ឃើញថា នគរបាលមានភាពយុត្តិធម៌ គោរពច្បាប់ និងអាចទទួលខុសត្រូវសង្គមក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ ការយល់ឃើញនេះត្រូវបានគាំទ្រពង្រឹងនៅពេលដែលមន្ត្រីនគរបាលអនុវត្តអំណាចដោយមានភាពយុត្តិធម៌ និងត្រឹមត្រូវតាមនីតិវិធី ព្រមទាំងការប្រព្រឹត្តរបស់គេម្នាក់ៗប្រកបដោយសេចក្តីថ្លៃថ្នូរ ភាពស្មោះត្រង់ ភាពអព្យាក្រឹត និងការគោរពសិទ្ធិមនុស្ស។

ក្នុងសង្គមប្រជាធិបតេយ្យ នគរបាលមិនមែនជាអ្នកគ្រប់គ្រងទេ ប៉ុន្តែជាអ្នកអនុវត្តច្បាប់ ភាពស្របច្បាប់របស់ពួកគេអាស្រ័យលើឥរិយាបថនិងអាកប្បកិរិយាប្រកបដោយអភិសមាចារក្រមសីលធម៌ជាប់លាប់ មានតម្លាភាព និងការប្រកាន់ខ្ជាប់នូវការគោរពសិទ្ធិមនុស្សផងដែរ។ នៅពេលដែលមានការ

ប្រព្រឹត្តខុសឆ្គងណាមួយ ដូចជាការប្រព្រឹត្តអំពើពុករលួយឬការប្រើប្រាស់កម្លាំងហួសហេតុពេកនោះធ្វើឱ្យកិច្ចសន្យាសង្គមនឹងចុះខ្សោយ ហើយប្រជាពលរដ្ឋបាត់បង់ទំនុកចិត្តលើស្ថាប័នឬអាជ្ញាធរនេះ។ ដូច្នេះកិច្ចប្រតិបត្តិប្រចាំថ្ងៃរបស់មន្ត្រីនគរបាលម្នាក់ៗបានរួមចំណែកទាំងការពង្រឹងភាពថ្លៃថ្នូរសម្រាប់សង្គមនិង/ឬអាចជាការបំផ្លាញភាពស្របច្បាប់សាធារណៈសង្គមផងដែរ ប្រសិនជាពួកគេប្រព្រឹត្តផ្ទុយពីកិច្ចសន្យាសង្គមនោះ។ ក្នុងន័យនេះហើយដែលធ្វើឱ្យអភិសមាចារនិងក្រមសីលធម៌ក្លាយជាមូលដ្ឋានគ្រឹះដ៏ចាំបាច់នៃការងារនគរបាលប្រកបដោយវិជ្ជាជីវៈដើម្បីពង្រឹងភាពថ្លៃថ្នូរនិងកិត្តិយសសង្គម។

### ១.៤- មោទនភាពជាមន្ត្រីនគរបាលជាតិ

ជាការពិតណាស់ រយៈកាលកន្លងមកកេរ្តិ៍ឈ្មោះនិងកិត្តិយសរបស់កងកម្លាំងនគរបាលជាតិធ្លាប់តែមានភាពល្បីល្បាញរាប់សិបឆ្នាំមកហើយ «លើកលែងតែក្នុងសម័យប្រល័យពូជសាសន៍ប៉ុលពតតែប៉ុណ្ណោះ»។ ប្រជាពលរដ្ឋគ្រប់ជំនាន់បានចាត់ទុកកងកម្លាំងនគរបាលជាកងកម្លាំងប្រកបដោយថាមពល កាយសម្បទារឹងមាំ ជាមនុស្សពូកែ ឧស្សាហ៍ ព្យាយាម ជាអ្នកអនុវត្តច្បាប់ គោរពច្បាប់ គោរពសិទ្ធិមនុស្ស ជាអ្នកលះបង់អាយុជីវិត ជាគំរូវីរភាពដ៏ថ្លៃថ្លាឧត្តុង្គឧត្តម ជួយការពារសន្តិសុខ បង្ក្រាបបទល្មើស និងជាអ្នកដោះស្រាយបញ្ហាសម្រាលការលំបាករបស់ប្រជាពលរដ្ឋទៀតផង។ ជាងនេះទៀតនៅក្នុងអារម្មណ៍បេះដូងរបស់ពួកគាត់បានបញ្ជាក់យ៉ាងច្បាស់ថា «មានវត្តមានកងកម្លាំងនគរបាល ពួកគាត់មានភាពកក់ក្តៅនិងមានសេចក្តីសុខ» ហើយបានឱ្យតម្លៃកងកម្លាំងនគរបាលថាជាតំណាងនៃអំពើល្អ តំណាងនៃភាពស្មោះត្រង់ ត្រឹមត្រូវយុត្តិធម៌ មិនបំពានច្បាប់ ហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីជាតិនិងប្រជាពលរដ្ឋ។

ក្នុងន័យខាងលើនេះ ដើម្បីរក្សាបាននូវតម្លៃដ៏មានកិត្យានុភាពឧត្តុង្គឧត្តមនេះយូរអង្វែង កងកម្លាំងនគរបាលជាតិទាំងអស់ត្រូវយល់ថា កេរ្តិ៍ឈ្មោះ កិត្តិយស ព្រមទាំងសេចក្តីថ្លៃថ្នូររបស់ខ្លួនពិតជាមានតម្លៃលើសពីប្រាក់បៀវត្សដែលយើងទទួលបានទៅទៀត ហើយឧត្តមភាពវិជ្ជាជីវៈរបស់នគរបាលម្នាក់ៗបានធ្វើឱ្យសាច់ញាតិក្រុមគ្រួសាររបស់គេមានមោទនភាពជាទីបំផុតដែលមានបង ប្អូន កូន ក្មួយ ប្តី ប្រពន្ធ ឪពុកម្តាយ ឬសាច់ញាតិជាកងកម្លាំងដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ។ ទោះគ្រប់កាលៈទេសៈណាក៏ដោយ ក៏នគរបាលម្នាក់ៗត្រូវដឹងខ្លួនឯងថា ខ្លួនមិនមែនជាពលរដ្ឋធម្មតាទេគឺជាតំណាងដ៏ខ្ពង់ខ្ពស់របស់ជាតិនិងប្រជាពលរដ្ឋ។ ដូចនេះរាល់ទង្វើឬសកម្មភាពទាំងឡាយណាដែលនាំឱ្យអាប់ឱនកិត្តិយសកេរ្តិ៍ឈ្មោះដល់ជាតិ ក្រុមគ្រួសារ និងខ្លួនឯង កុំសូម្បីតែគិត សូម្បីចង់ សូម្បីតែស្រមៃក៏មិនត្រូវឱ្យពាក់ព័ន្ធនូវរឿងដែលមិនត្រឹមត្រូវទាំងនោះឡើយ។ មន្ត្រីនគរបាលគ្រប់រូប គ្រប់កម្រិតពិតជាបានយល់បានដឹងច្បាស់ពីតួនាទី ភារកិច្ចរបស់ខ្លួនដែលត្រូវបំពេញក្នុងនាមជាអ្នកបម្រើសេវាសន្តិសុខនិងសេវាសាធារណៈជូនជាតិនិងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា ដោយត្រូវធ្វើយ៉ាងណារក្សាឱ្យបាននូវគុណតម្លៃដ៏ឧត្តុង្គឧត្តមរបស់នគរបាលជាតិឱ្យបានខ្ពស់បំផុតទោះក្នុងស្ថានភាពឬក្នុងតម្លៃណាក៏ដោយ។

## ២- ភាពខុសគ្នារវាងនគរបាលនិងពលរដ្ឋទូទៅ

គុណសម្បត្តិនៃអភិសមាចារនិងសីលធម៌របស់មន្ត្រីនគរបាលនិងពលរដ្ឋទូទៅ ផ្អែកលើសិទ្ធិជាមូលដ្ឋានគឺមានសិទ្ធិ សេចក្តីថ្លៃថ្នូរ និងកិត្តិយសស្មើៗគ្នា។ ពួកគេខុសគ្នាជាមូលដ្ឋាននៅក្នុងមុខងារនិងទំនួលខុសត្រូវ។ ពលរដ្ឋទូទៅរស់នៅក្រោមការការពារនៃច្បាប់ ចំណែកមន្ត្រីនគរបាលត្រូវបានប្រគល់

ភារកិច្ចយល់ដឹងអំពីច្បាប់ និងអនុវត្តច្បាប់។ ភាពខុសគ្នានេះបានផ្តល់ឱ្យមន្ត្រីនគរបាលនូវអាជ្ញាពិសេសក្នុងការប្រើកម្លាំងរឹតត្បិតសេរីភាពបុគ្គល ឃាត់ខ្លួនបុគ្គលក្នុងកាលៈទេសៈចាំបាច់និងធ្ងន់ធ្ងរណាមួយ។

ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានេះក៏មិនបាននាំឱ្យនគរបាលឃ្លាតឆ្ងាយបំបែកខ្លួនចេញពីសហគមន៍ឡើយ។ ការងារនគរបាលប្រកបដោយប្រសិទ្ធភាពអាស្រ័យលើការរក្សាភាពស្និទ្ធស្នាល និងការយល់ចិត្តជាមួយនឹងសាធារណជននិងការចូលរួមសហការពីប្រជាជនមហាជន។ មន្ត្រីនគរបាលដែលល្អបំផុតគឺជាអាជ្ញាធរពិតប្រាកដដែលកើតចេញពីការបម្រើមិនមែនមកពីឋានៈនោះទេ។ ដូចទ្រឹស្តីរបស់លោក «Sir RobertPeel» ដែលជាស្ថាបនិកនៃការងារនគរបាលសម័យទំនើបបានលើកឡើងយ៉ាងល្បីល្បាញនៅឆ្នាំ១៨២៩ថា «នគរបាលគឺជាសាធារណជន ហើយសាធារណជនគឺជានគរបាល»។ ទស្សនវិជ្ជារបស់លោកបានគូសបញ្ជាក់ថា ភាពស្របច្បាប់និងការគោរពត្រូវបានទទួលមិនមែនដោយការបញ្ជាទិញនោះទេ ប៉ុន្តែគឺជាការបម្រើក្នុងភាពជាអ្នកដឹកនាំខាងសីលធម៌ គុណធម៌និងការបម្រើប្រកបដោយមនុស្សធម៌ខ្ពស់បំផុតទៀតផង។ ក្រៅពីភាពខុសគ្នាខាងលើក៏មានទស្សនៈសច្ចភាពសង្គមមួយបានលើកឡើងថា តម្រូវការជាចម្បងរបស់នគរបាលនិងប្រជាជនគឺចង់បាន «សុវត្ថិភាពនិងកិត្តិយស» ដូចគ្នា។









# ផ្នែកទី២
# សញ្ញាណទូទៅនៃអភិសមាចារនិងក្រមសីលធម៌

## ១- អភិសមាចារ

### ១.១- និយមន័យ

ជាទូទៅគេសង្កេតឃើញអ្នកប្រាជ្ញទាំងឡាយតែងតែបង្ហាញពីទស្សនៈរបស់ខ្លួនផ្សេងៗពីគ្នាលើបេកគំហើញមួយចំនួនទាក់ទងនឹងប្រធានបទអ្វីមួយ។ នៅពេលខ្លះប្រធានបទទាំងនោះវាស្តែងចេញឱ្យឃើញនូវទស្សនៈស្របគ្នាឬស្រដៀងគ្នាតាមរបៀបនៃការព្យាយាមអប់រំប្រៀនប្រដៅកូនជាប្រចាំតាំងពីតូចរហូតដល់ធំឱ្យស្គាល់អំពីការប្រតិបត្តិតាមទំនៀមទម្លាប់ ប្រពៃណី សិល្បៈ វប្បធម៌របស់ខ្មែរយើងឱ្យចេះស្រលាញ់និងការពារអ្វីដែលជាអត្តសញ្ញាណជាតិ និងលើសពីនេះ ពួកគាត់ទាំងនោះតែងតែបានបំពាក់បំប៉ននូវគុណសម្បត្តិផ្សេងៗជាច្រើនទៀត ជាពិសេសគឺគុណសម្បត្តិខាងសីលធម៌អប់រំអត្តចរិតដែលបានរៀបចំនិងចងក្រងនូវទស្សនៈសីលធម៌របស់អ្នកប្រាជ្ញល្បីៗទាំងឡាយក្នុងលោកយើងនេះ។

- លោក **កាល់ ម៉ាក្ស** ដែលជាទស្សនវិទូ សេដ្ឋវិទូ សង្គមវិទូ ប្រវត្តិវិទូ និងជាអ្នកបដិវត្តសង្គមនិយមអាល្លឺម៉ង់បានផ្តល់អត្ថន័យដោយសង្ខេបទាក់ទងនឹងអភិសមាចារ (បដិច្ចសមុប្បាទសម្ភារនិយម) នៃការរីកចម្រើនដែលបានបង្ហាញថា សម្ភារៈជាដំណើរការមួយគ្មានទីបញ្ចប់នៃការស្លាប់ទៅនូវអ្វីដែលចាស់ហើយការកើតមានឡើងនូវអ្វីដែលថ្មី។ សង្គមមនុស្សត្រូវតែមានការវិវឌ្ឍពីសង្គមបុព្វកាលមកជាសក្តិភូមិនិងពីសក្តិភូមិមកជាសង្គមមូលធន។

- លោក **ការវ៉ាកាស** បានលើកឡើងនូវទស្សនៈ (តម្រេកនិយម) ដែលបង្ហាញថាគេមិនអាចឈប់ទទួលទានត្រីព្រោះតែវាមានឆ្អឹងនៅក្នុងនោះទេ ហើយគេក៏មិនអាចបដិសេធនូវការសប្បាយព្រោះតែសេចក្តីសង្ឃឹមខុសចំពោះជីវិតអនាគតនោះឡើយ។

- លោក **ទៀត ឆេ** ទស្សនវិទូដែលបានរកឃើញអភិសមាចារ (អំណាចនិយម) បង្ហាញអំពីឆន្ទៈខ្លាំងខ្ពស់បំផុតក្នុងជីវិតដែលមិនបានសំដៅលើការតស៊ូដ៏លំបាកវេទនាដើម្បីតែអត្ថិភាពនោះទេ។ ប៉ុន្តែវាជាឆន្ទៈដ៏ស្រួចស្រាល់ក្នុងការធ្វើសង្គ្រាម ឆន្ទៈដើម្បីអំណាច និងជាឆន្ទៈដើម្បីឈ្នះទៅលើគេ។

- លោក **ខុង ជឺ** បង្ហាញពីអភិសមាចារដែលជាទស្សនៈកែទម្រង់រដ្ឋបាលនិងសីលធម៌គ្រប់គ្រង «កិរិយាមិនបណ្តុះគុណធម៌ កិរិយាមិនសិក្សាឡើងវិញនូវអ្វីដែលខ្លួនចេះ កិរិយាមិនបដិបត្តិខ្លួនឯងនូវអ្វីដែលត្រឹមត្រូវ និងកិរិយាមិនកែកំហុសខ្លួនឯងឱ្យទាន់ពេល» កត្តាទាំងអស់នេះជាកង្វល់របស់គាត់។

- អភិសមាចារតាមទស្សនវិជ្ជានៃ **ព្រះពុទ្ធសាសនា** សំដៅទៅលើកត្តាសន្តិភាពនិយមដូចជា (មេត្តា ករុណា មុទិតា ឧបេក្ខា) កត្តាទាំងនេះជាព្រហ្មវិហារធម៌ទាំង៤នៃព្រះពុទ្ធសាសនា។ ប្រសិនបើជនទាំងឡាយណាអាចកាន់រក្សាឱ្យបានជិតដល់ សមលោកទាំងមូលបានសុខស្ងប់ ត្រលប់ជាឥតជ្រួលច្របល់ព្រោះធម៌ទាំង៤នេះបញ្ចេញផលផ្តល់ឱ្យនូវសុខសន្តិភាពជាប់ជានិច្ច។

ដូចនេះផ្អែកតាមទស្សនៈសាមញ្ញធម្មតាទូទៅ អភិសមាចារមានន័យថា គោលការណ៍សីលធម៌ តែបើតាមទស្សនវិជ្ជាពាក្យថា អភិសមាចារ (Ethics) ក្លាយចេញពីពាក្យឡាតាំង Ethos មានន័យថា «អាកប្បកិរិយា» (Character)។ តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត «អភិសមាចារ»

ក្លាយមកពីពាក្យ «អភិ+សមាចារ»។ «**អភិ**» មានន័យថា ក្រៃលែង ពេកក្រៃ រីឯ «**សមាចារ**» មានន័យថាមារយាទល្អ មារយាទត្រឹមត្រូវ រៀបរយដែលធម្មតាមានបីយ៉ាងគឺមារយាទរៀបរយខាងកាយ ខាងវាចា ខាងចិត្ត ហៅថា កាយសមាចារ វចីសមាចារ មនោសមាចារ។ ដូច្នេះអភិសមាចារមានន័យថា មារយាទល្អក្រៃពេកឬការប្រព្រឹត្តរបៀបរៀបរយ គួរឱ្យពេញចិត្ត និងគួរឱ្យជ្រះថ្លាបំផុត។

ការសិក្សាបានបង្ហាញនូវអត្ថន័យមួយទៀតលើកឡើងថា «អភិសមាចារ» អាចហៅបានថាជាទស្សនវិជ្ជាសីលធម៌ ( Moral Philosophy ) គឺជាវិទ្យាសាស្ត្រខាងអាកប្បកិរិយាឬចរិយាមារយាទរបស់មនុស្សបានមកពីវប្បធម៌ទម្លាប់ដែលជាលក្ខណៈអចិន្ត្រៃយ៍នៃឥរិយាបថនិងជាកញ្ចក់ឆ្លុះពីអាកប្បកិរិយា។ គេបានកំណត់ថា «អភិសមាចារ» គឺជាវិទ្យាសាស្ត្រនៃអាកប្បកិរិយាឬ «ទម្លាប់»។ វាវាស់ស្ទង់តម្លៃនៃទម្លាប់ តម្លៃនៃអាកប្បកិរិយា ការប្តេជ្ញាចិត្តរបស់មនុស្ស និងការពិចារណាពិភាក្សាពីបែបបទរបស់វា។

អភិសមាចារជារបៀបសមរម្យមួយដែលបង្ហាញពីការគោរពខ្លួនឯង អ្នកដទៃ និងជាឥរិយាបថសំខាន់មួយធ្វើឱ្យមនុស្សទទួលបានការជឿទុកចិត្តនិងសន្តិភាពនៅរួមរស់ជាមួយគ្នា។ ជាងនេះទៀត អភិសមាចារមិនត្រឹមតែជាការអនុវត្តតាមទម្លាប់ឬវប្បធម៌ទេ ប៉ុន្តែជាវិធីបង្ហាញពីចរិតល្អនិងការគោរពគ្នាទៅវិញទៅមកក្នុងសង្គម។ ឧទាហរណ៍ដូចជាការប្រតិបត្តិរបស់មនុស្សចំពោះការសំពះមនុស្សចាស់ ការនិយាយដោយសុភាពរាបសា ការបង្ហាញអាកប្បកិរិយាសមរម្យនៅទីកន្លែងសាធារណៈ និងការមិនប្រើពាក្យអាក្រក់អសុរសជាដើម។ល។ ដូចនេះ «អភិសមាចារ» បានជួយឱ្យសង្គមមានសណ្តាប់ធ្នាប់និងជួយឱ្យមនុស្សរស់នៅក្នុងស្មារតីសាមគ្គីភាពល្អ។

សរុបមកអភិសមាចារជាវិទ្យាសាស្ត្រនៃអំពើល្អខ្ពស់បំផុតដែលពិចារណាអំពីករណីយកិច្ចរបស់មនុស្សនិងសិក្សាអំពីអ្វីដែលត្រូវនិងអ្វីដែលខុស អ្វីដែលល្អ និងអ្វីដែលអាក្រក់ក្នុងផ្នត់គំនិតនិងអាកប្បកិរិយារបស់មនុស្សផ្អែកតាមវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាតិសាសន៍នីមួយៗ។

**១.២- គោលបំណងនិងសារៈសំខាន់**

គោលបំណងជាមូលដ្ឋាននៃអភិសមាចារ សំដៅដល់ការវិនិច្ឆ័យសីលធម៌ដែលតម្រូវឱ្យមានការសិក្សាផ្នែកចិត្តសាស្ត្រ។ ដូចនេះវាជាបញ្ហារបស់អភិសមាចារផងដែរក្នុងការយល់ដឹងចរិតនៃការវិនិច្ឆ័យទាំងនេះ។ ការវិនិច្ឆ័យសីលធម៌ទម្រង់នៃអភិសមាចារគឺជាការសម្រេចទៅលើអំពើល្អឬអំពើអាក្រក់អ្វីមួយ «អំពើល្អគឺជាអំពើត្រឹមត្រូវនិងជាកាតព្វកិច្ច រីឯអំពើអាក្រក់វិញគឺជាអំពើខុសនិងមិនត្រូវធ្វើ» អំពើល្អជាមធ្យោបាយឆ្ពោះទៅរកអំពើល្អខ្ពស់បំផុតនៃខ្សែចង្វាក់មធ្យោបាយ គោលដៅ និងទីបញ្ចប់។ រីឯអំពើអាក្រក់ជាទង្វើដែលមិនមែនជាកាតព្វកិច្ចត្រូវបំពេញនោះទេ។ គោលបំណងរបស់អភិសមាចារមួយទៀតគឺការឈ្វេងយល់អំពីចរិតពិតនៃទស្សនៈ ទម្លាប់ជាមូលដ្ឋានរបស់មនុស្ស និងការឈ្វេងយល់អំពីឫសគល់ ប្រភព និងមូលដ្ឋាននៃកាតព្វកិច្ចនិងសីលធម៌។

នៅពេលដែលទម្លាប់ត្រូវបានស្វែងរកស្របតាមលក្ខណៈវិនិច្ឆ័យលើអត្ថន័យអភិសមាចារគឺបានសំដៅឆ្ពោះតែទៅលើសកម្មភាពស្មគ្រចិត្តរបស់មនុស្ស ស្របតាមចរិតនៃសេរីភាពដែលត្រូវផ្សារភ្ជាប់ទៅនឹងការទទួលខុសត្រូវ។ ភាពចាំបាច់នៃការទទួលខុសត្រូវនេះហើយដែលរង្វាន់លើកទឹកចិត្តត្រូវបានផ្តល់ឱ្យចំពោះអំពើល្អនិងការដាក់ទណ្ឌកម្មទៅលើអំពើអាក្រក់។ គុណសម្បត្តិនៃអភិសមាចារបានពិពណ៌នាស្វែងរកឱ្យឃើញអំពីការទទួលខុសត្រូវនៃការប្រព្រឹត្តអំពើល្អនិងបង្ហាញពីមូលដ្ឋាននៃការដាក់ទណ្ឌកម្មនៃការប្រព្រឹត្តអំពើអាក្រក់របស់មនុស្សនាំមកជាមួយនូវការបែងចែករវាងអំពើ «បាប» និង «បុណ្យ»។

### ១.៣- តួនាទីអភិសមាចារក្នុងវិជ្ជាជីវៈ

តួនាទីអភិសមាចារក្នុងវិជ្ជាជីវៈនៅទីនេះសំដៅទៅលើសកម្មភាពក្នុងវិជ្ជាជីវៈនៃវិស័យការងារទូទៅដោយមិនបានចង្អុលទៅកាន់វិជ្ជាជីវៈជំនាញជាក់លាក់ណាមួយឡើយ ហើយគ្រាន់តែចង់បង្ហាញអំពីលក្ខណៈដូចម្តេចខ្លះដើម្បីណែនាំឱ្យអ្នកដែលប្រកបវិជ្ជាជីវៈត្រូវមានឥរិយាបថនិងអាកប្បកិរិយាគោរពតាមគោលការណ៍អនុវត្តការងារអ្វីខ្លះ សំដៅធានាថាសេវាកម្មឬសមិទ្ធិផលវិជ្ជាជីវៈមានគុណភាពមានភាពស្របច្បាប់អាចទុកចិត្តបាននិងអាចយកទៅបម្រើសង្គមដោយកិត្តិយសនិងភាពជឿជាក់។

ខាងក្រោមនេះជាចំណុចសំខាន់ៗដែលបង្ហាញពីគោលការណ៍នៃអភិសមាចារក្នុងវិជ្ជាជីវៈ៖

- ធានាគុណភាពនិងនិយាមវិជ្ជាជីវៈជាគោលការណ៍ណែនាំឱ្យអ្នកប្រកបវិជ្ជាជីវៈអនុវត្តការងារដោយគោរពតាមនិយាមបច្ចេកទេសនិងវិធានការដែលបានកំណត់

- ការកសាងទំនុកចិត្តនិងភាពជឿជាក់ពីសាធារណជនក្នុងការអនុវត្តវិជ្ជាជីវៈណាមួយដែលទទួលបានការគោរពនិងការជឿជាក់ពីសង្គម។ បើអ្នកប្រកបវិជ្ជាជីវៈនោះអនុវត្តការងារដោយមានអភិសមាចារដែលជាខ្សែភ្ជាប់រវាងអ្នកជំនាញនិងសាធារណជនអាចធ្វើឱ្យមានទំនុកចិត្តយូរអង្វែង

- ការពារសេចក្តីថ្លៃថ្នូរនិងកិត្តិយសវិជ្ជាជីវៈទាំងមូលដោយរារាំងអំពើមិនសមរម្យ ការបំពានសីលធម៌ ឬអាកប្បកិរិយាដែលអាចប៉ះពាល់ដល់រូបភាពវិជ្ជាជីវៈនៅក្នុងក្រសែភ្នែកសង្គមឬមហាជន

- ជាមូលដ្ឋាននៃការសម្រេចចិត្តប្រកបដោយមនសិការនៅពេលជួបបញ្ហាស្មុគស្មាញឬជម្លោះអភិសមាចារជួយណែនាំអ្នកវិជ្ជាជីវៈឱ្យធ្វើសេចក្តីសម្រេចដែលមានតុល្យភាពរវាងផលប្រយោជន៍ផ្ទាល់ខ្លួនផលប្រយោជន៍អង្គភាព និងផលប្រយោជន៍សង្គម

- ការពារអ្នកទទួលសេវានិងភាគីពាក់ព័ន្ធនូវសិទ្ធិ សុវត្ថិភាព និងផលប្រយោជន៍សមស្របរបស់អ្នកទទួលសេវាអតិថិជនឬសាធារណជនដោយមិនអនុញ្ញាតឱ្យមានការប្រើប្រាស់ចំណេះដឹងវិជ្ជាជីវៈទៅក្នុងទិសដៅមិនសមស្រប «ខុសគោលការណ៍ឬខុសគោលបំណង»

- ការទប់ស្កាត់ជម្លោះផលប្រយោជន៍ដោយជួយកំណត់ព្រំដែនច្បាស់លាស់រវាងតួនាទីវិជ្ជាជីវៈនិងផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីចៀសវាងភាពលំបាកក្នុងការសម្រេចចិត្តនិងការប្រើប្រាស់តួនាទីវិជ្ជាជីវៈមិនត្រឹមត្រូវតាមគោលការណ៍នៃច្បាប់កំណត់

- ជាមូលដ្ឋានសម្រាប់ការពង្រឹងវិន័យនិងការទទួលខុសត្រូវក្នុងការបង្កើតវិន័យផ្ទៃក្នុង និងការទទួលខុសត្រូវចំពោះសកម្មភាពផ្ទាល់ខ្លួនដែលធ្វើឱ្យអ្នកប្រកបវិជ្ជាជីវៈយល់ថាការបំពេញការងារមិនមែនគ្រាន់តែ «ធ្វើតាមបញ្ជានោះទេ» ប៉ុន្តែត្រូវធ្វើដោយមានមនសិការនិងស្មារតីទទួលខុសត្រូវខ្ពស់ផងដែរ

- ការលើកកម្ពស់វប្បធម៌ការងារល្អជួយបង្កើតបរិយាកាសការងារដែលផ្អែកលើការគោរពគ្នាសហការគ្នា សុចរិតភាពនិងភាពស្មោះត្រង់ដែលការនេះវានឹងបង្កើនប្រសិទ្ធភាពការងារ និងភាពរីកចម្រើនរបស់អង្គការឬស្ថាប័ននិងវិជ្ជាជីវៈ

- ជាគោលដៅអភិវឌ្ឍន៍វិជ្ជាជីវៈយ៉ាងចីរភាពដោយមិនមែនជាឧបករណ៍ដាក់កំហិតនោះទេ ប៉ុន្តែការប្រើចំណេះដឹងដោយមានការទទួលខុសត្រូវចំពោះសង្គម

- ជាមូលដ្ឋានសម្រាប់អភិវឌ្ឍវិជ្ជាជីវៈយូរអង្វែងដោយជំរុញការរៀនសូត្របន្តដើម្បីកែលម្អខ្លួន

- ជាគ្រឿងការពារខ្លួនអ្នកប្រកបវិជ្ជាជីវៈចៀសបញ្ហាខាងផ្លូវច្បាប់និងការរិះគន់ពីសង្គម ព្រមទាំងការបាត់បង់កិត្តិយសដែលអាចកើតឡើងពីការអនុវត្តការងារមិនសមស្រប។

**១.៣.១- អភិសមាចារក្នុងការអនុវត្តការងារ**

ក្នុងនាមជាមន្រ្តីសាធារណៈត្រូវបំពេញភារកិច្ចដោយមានភាពស្មោះត្រង់ ទំនួលខុសត្រូវ និងភាពប្រុងប្រយ័ត្ន។ ការអនុវត្តការងារដោយមានអភិសមាចារមានន័យថា ត្រូវគោរពច្បាប់និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពឬស្ថាប័នត្រូវបង្ហាញចរិតសុភាពរាបសានិងសមរម្យពេលទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋ មិនប្រើអំណាចខុសច្បាប់ មិនទទួលផលប្រយោជន៍ខុសច្បាប់ និងមិនប្រើអំពើអយុត្តិធម៌ក្នុងការងារ។ អភិសមាចារល្អក្នុងការងារបង្កើតភាពជឿទុកចិត្តពីអ្នកទទួលសេវាហើយយល់ថា បុគ្គលនោះជាអ្នកបម្រើសាធារណៈពិតប្រាកដនិងជួយឱ្យសង្គមមានភាពរួបរួមសាមគ្គី និងសមត្ថភាពក្នុងការបំពេញភារកិច្ច។

**១.៣.២- អភិសមាចារនៅកន្លែងធ្វើការ**

នៅកន្លែងធ្វើការមន្រ្តីត្រូវមានវិន័យនិងរបៀបរៀបរយក្នុងការបំពេញការងារ ហើយត្រូវចូលធ្វើការងារតាមពេលវេលាមិនយឺតយ៉ាវឬរំលងកាតព្វកិច្ច។ ត្រូវរក្សាភាពស្អាតនិងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យឬកន្លែងបម្រើការងារពាក់ឯកសណ្ឋានឱ្យស្អាត ត្រឹមត្រូវ និងសមរម្យតាមបទបញ្ជាត្រូវប្រើពាក្យសមរម្យពេលនិយាយជាមួយនឹងអ្នកដទៃ មិនត្រូវប្រើពាក្យបណ្តេញជាពាក្យមិនសមរម្យនោះទេ។ ការរក្សាបានអភិសមាចារនៅកន្លែងធ្វើការ ជារូបភាពយ៉ាងប្រពៃរបស់អង្គភាពឬស្ថាប័នសាធារណៈទាំងមូល ហើយវាជាផ្នែកសំខាន់ក្នុងការរក្សាកិត្តិយសរបស់អាជ្ញាធរមានសមត្ថកិច្ច។

**១.៣.៣- អភិសមាចារក្នុងការទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋ**

មន្រ្តីសាធារណៈរបស់រដ្ឋជាមនុស្សដែលស្ថិតជិតស្និទ្ធជាមួយនឹងប្រជាពលរដ្ឋ ដូច្នេះត្រូវបង្ហាញនូវចរិតអភិសមាចារក្នុងការទំនាក់ទំនងជាមួយនឹងពួកគេ។ ត្រូវគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋមិនប្រើអំពើបង្ខំឬសកម្មភាពមិនសមរម្យ។ ត្រូវស្តាប់បញ្ហារបស់ប្រជាពលរដ្ឋដោយមានអធ្យាស្រ័យនិងជួយដោះស្រាយដោយយុត្តិធម៌។ ការបង្ហាញអភិសមាចារជាមួយនឹងប្រជាពលរដ្ឋនឹងធ្វើឱ្យប្រជាពលរដ្ឋមានទំនុកចិត្តលើមន្រ្តីបំពេញការងារនិងចូលរួមសហការក្នុងការងារសង្គម។ លក្ខណសម្បត្តិអភិសមាចារជាគន្លងសម្រាប់បង្កើតទំនាក់ទំនងល្អរវាងប្រជាពលរដ្ឋជាមួយអង្គភាពឬស្ថាប័នសាធារណៈ។

**១.៣.៤- អភិសមាចារក្នុងជីវិតផ្ទាល់ខ្លួន**

មន្រ្តីនគរបាលត្រូវរក្សាបាននូវចរិតអភិសមាចារមិនត្រឹមតែពេលធ្វើការប៉ុណ្ណោះ ប៉ុន្តែក្នុងជីវិតផ្ទាល់ខ្លួនផងដែរ។ ត្រូវរស់នៅដោយមានសុចរិតភាព មិនប្រព្រឹត្តអំពើអាក្រក់ ឬប្រើសារធាតុញៀន ស្រា ឬអំពើអាសអាភាស។ ត្រូវរក្សាកិត្តិយសនិងកេរ្តិ៍ឈ្មោះដ៏ល្អរបស់អង្គភាពឬស្ថាប័ននិងធ្វើជាមនុស្សគំរូសម្រាប់សង្គម។ មន្រ្តីដែលមានអភិសមាចារល្អក្នុងជីវិតផ្ទាល់ខ្លួននឹងក្លាយជាមនុស្សដែលប្រជាពលរដ្ឋគោរពនិងទុកចិត្ត ហើយអាចជាបទដ្ឋានគំរូសម្រាប់មន្រ្តីដទៃទៀតអនុវត្តតាមផងដែរ។

**១.៣.៥- អភិសមាចារក្នុងការទំនាក់ទំនងជាមួយនឹងមិត្តរួមការងារ**

មន្រ្តីបំពេញការងារត្រូវគោរពថ្នាក់លើ ថ្នាក់ក្រោម និងថ្នាក់ស្មើគ្នាដោយសេចក្តីគោរពគ្នាទៅវិញទៅមកមិនប្រើអំណាចបង្ខំឬប្រើអំពើមិនសមរម្យ។ ត្រូវមានសាមគ្គីភាព សហការល្អក្នុងក្រុមការងារនិងជួយគ្នាដោះស្រាយបញ្ហាប្រកបដោយសុចរិតភាព។ មានចរិតអភិសមាចារក្នុងក្រុមការងារបានជួយ

បង្កើតបរិយាកាសធ្វើការឱ្យមានសុខដុមនីយកម្មនិងមានផលិតភាពខ្ពស់ដែលជាចំណុចដ៏សំខាន់ក្នុងការរក្សាផ្នត់គំនិតនិងការរួមសាមគ្គីភាពនៅក្នុងអង្គភាពឬស្ថាប័នកាន់តែប្រសើរ។

### ១.៤- មូលដ្ឋាននៃអភិសមាចារក្នុងការគ្រប់គ្រងអំណាច

មូលដ្ឋានអភិសមាចារក្នុងការគ្រប់គ្រងអំណាច សំដៅទៅលើគុណធម៌សីលធម៌និងអាកប្បកិរិយាដែលអ្នកកាន់អំណាចឬអ្នកដឹកនាំត្រូវគោរពនិងអនុវត្តក្នុងដំណើរការប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីធានាថា អំណាចនោះត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ មានការទទួលខុសត្រូវ មានតម្លាភាព និងបម្រើផលប្រយោជន៍សាធារណៈជាចម្បងមិនមែនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឬក្រុមណាមួយឡើយ។

មូលដ្ឋាននៃអភិសមាចារក្នុងការគ្រប់គ្រងអំណាចគឺជាគន្លឹះធានាឱ្យអំណាចក្លាយជាឧបករណ៍បម្រើប្រយោជន៍សាធារណៈមិនមែនជាមធ្យោបាយបង្កអំណាចផ្ទាល់ខ្លួនឡើយ។ វាជាស្នូលនៃការដឹកនាំល្អនិងការគ្រប់គ្រងដែលមានសុវត្ថិភាព ស្ថិរភាព និងទំនុកចិត្តពីសាធារណជននៅក្នុងសង្គម។

ខាងក្រោមនេះជាគោលការណ៍មូលដ្ឋាននៃអភិសមាចារដែលណែនាំដល់ការសម្រេចចិត្តរបស់អ្នកដឹកនាំឬមន្ត្រីសាធារណៈក្នុងការគ្រប់គ្រងអំណាច៖

**១- មូលដ្ឋាននៃយុត្តិធម៌** អ្នកកាន់អំណាចត្រូវប្រើអំណាចដោយស្មើភាពមិនលម្អៀងមិនរើសអើងនិងមិនប្រកាន់ភាគីចំណុះណាមួយឡើយ។ ការសម្រេចចិត្តគ្រប់យ៉ាងត្រូវផ្អែកលើច្បាប់និងហេតុផលមិនមែនលើអារម្មណ៍ឬដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

**២- មូលដ្ឋាននៃសុចរិតភាពនិងសេចក្តីស្មោះត្រង់** ការគ្រប់គ្រងអំណាចត្រូវផ្អែកលើសុចរិតភាពមិនប្រើអំណាចដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឬក្រុមពិសេសណាមួយ។ ជាមួយគ្នានេះ ក៏ត្រូវតែគួបផ្សំជាមួយនឹងសេចក្តីស្មោះត្រង់ដែលជាគ្រឹះនៃសេចក្តីទុកចិត្តពីសាធារណជនឬអ្នកក្រោមបង្គាប់។

**៣- មូលដ្ឋាននៃភាពទទួលខុសត្រូវ** អ្នកកាន់អំណាចត្រូវទទួលខុសត្រូវចំពោះសកម្មភាពនិងសេចក្តីសម្រេចរបស់ខ្លួន ហើយត្រូវទទួលនូវការត្រួតពិនិត្យ ការសួរដេញដោល និងការវាយតម្លៃពីសង្គមឬស្ថាប័នពាក់ព័ន្ធ។ ប្រព័ន្ធទទួលខុសត្រូវសំខាន់ៗបំផុតរបស់អ្នកដឹកនាំទៅលើការគ្រប់គ្រងអំណាចដូចជា **ទីមួយ**- អំណាចតួនាទីដែលរូបវន្តបុគ្គលទទួលបានតំណែងជាថ្នាក់ដឹកនាំគ្រប់កម្រិត **ទីពីរ**- អំណាចលើកសរសើរនិងដាក់ទណ្ឌកម្មដោយផ្អែកលើការវាយតម្លៃរបស់ក្រុមការងារមានសមត្ថ-កិច្ចឬគណៈកម្មការមានសមត្ថកិច្ច និង**ទីបី**- អំណាចនៃការសម្រេចចិត្តជាអ្នកធ្វើឱ្យមានការគោរពច្បាប់ឬថ្នាក់បទបញ្ជាដឹកនាំជាន់ខ្ពស់ក្នុងបុព្វហេតុផលប្រយោជន៍សាធារណៈ។

**៤- មូលដ្ឋានតម្លាភាព** ការប្រើអំណាចត្រូវមានភាពបើកចំហ ច្បាស់លាស់អាចពិនិត្យបានមានន័យថារាល់ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្តនិងការអនុវត្តសេចក្តីសម្រេចចិត្តត្រូវផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបានជាពិសេសចំពោះហានិភ័យទាំងឡាយដែលកើតចេញពីការសម្រេចចិត្តនិងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ។ ព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់និងងាយយល់។ ជាមួយគ្នានេះតម្លាភាពជួយកាត់បន្ថយនូវអំពើពុករលួយ បង្កើននូវការជឿទុកចិត្តជាសាធារណៈ និងធានាថាអំណាចមិនត្រូវបានប្រើប្រាស់ដោយសម្ងាត់និងបំពានលើគោលការណ៍ច្បាប់និងបទបញ្ជាឡើយ។

**៥- មូលដ្ឋាននៃការគោរពច្បាប់** អំណាចទាំងអស់ត្រូវស្ថិតក្រោមច្បាប់គ្មានបុគ្គលណាម្នាក់នៅលើច្បាប់បានឡើយ។ អភិសមាចារណែនាំអ្នកកាន់អំណាចត្រូវគោរពច្បាប់និងអនុវត្តច្បាប់ដោយស្មើភាពដើម្បីបម្រើនិងការពារផលប្រយោជន៍របស់អង្គភាពនិងសិទ្ធិជាមូលដ្ឋាននានារបស់មនុស្ស។ ការអនុវត្តច្បាប់ទាំងនោះត្រូវអនុវត្តដោយមិនលម្អៀង ត្រូវមានភាពយុត្តិធម៌ ឯករាជ្យ អព្យាក្រឹត មានប្រព័ន្ធទទួលខុសត្រូវច្បាស់លាស់និងមិនប្រព្រឹត្តអំពើពុករលួយ។

**៦- មូលដ្ឋាននៃការគោរពសិទ្ធិមនុស្សនិងសេចក្ដីថ្លៃថ្នូររបស់មនុស្ស** ការគ្រប់គ្រងអំណាចត្រូវគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្ស គោរពសិទ្ធិ សេរីភាពមូលដ្ឋានរបស់មនុស្សដោយមិនប្រើអំណាចជាឧបករណ៍បង្ខំឬរំលោភសិទ្ធិអ្នកដទៃ ទោះបីជាមានឋានៈឬមតិយោបល់ខុសគ្នាក៏ដោយ។

ការអនុវត្តគោលការណ៍នេះមិនមែនត្រឹមតែជាទ្រឹស្ដីប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្ហាញជាការប្រតិបត្តិជាក់ស្ដែងក្នុងការសម្រេចចិត្តនិងការប្រើអំណាចរាល់ថ្ងៃ។ អ្នកដឹកនាំត្រូវទទួលស្គាល់ថាតម្លៃនិងសេចក្ដីថ្លៃថ្នូររបស់មនុស្សគ្រប់រូបមានដូចគ្នាមិនថាមានឋានៈ ភេទ ជំនឿ អាយុ ឬនិន្នាការនយោបាយខុសគ្នានោះទេ។ ការសម្រេចចិត្តណាមួយមិនត្រូវបង្កើតឱ្យមានការរើសអើងឬបន្ទាបតម្លៃមនុស្សឡើយ ហើយត្រូវធានាថា សិទ្ធិមូលដ្ឋានដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព សិទ្ធិបញ្ចេញមតិ សិទ្ធិទទួលយុត្តិធម៌ និងសិទ្ធិការពារខ្លួនត្រូវបានគោរពនិងមិនត្រូវរំលោភដោយអំណាចរដ្ឋឬអំណាចផ្ទាល់ខ្លួនឡើយ។ ការគោរពសិទ្ធិមនុស្សត្រូវបានបង្ហាញតាមរយៈការស្ដាប់ដោយយកចិត្តទុកដាក់ ទោះបីជាមតិនោះផ្ទុយពីគំនិតរបស់ខ្លួនក៏ដោយ មិនត្រូវបិទសិទ្ធិបញ្ចេញមតិឬប្រើអំណាចបង្ក្រាបការរិះគន់ដោយអយុត្តិធម៌ឡើយ។ ត្រូវមានការបើកចំហនូវការប្រាស្រ័យទាក់ទងដោយមិនអនុញ្ញាតឱ្យមានការគំរាមកំហែង ការប្រមាថ ឬការប្រើអំណាចហួសហេតុលើសកម្រិតឡើយ។

**៧- មូលដ្ឋាននៃការប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរនិងការអត់ធ្មត់** ក្នុងការគ្រប់គ្រងអំណាច អភិសមាចារបង្ហាញតាមរយៈការនិយាយ សកម្មភាព និងការសម្រេចចិត្តដែលមានភាពថ្លៃថ្នូរ អត់ធ្មត់ និងគិតពីផលប៉ះពាល់រយៈពេលវែង។ អំណាចដែលមានអភិសមាចារ ជាអំណាចដែលបម្រើប្រជាជន បម្រើច្បាប់ និងបម្រើការអភិវឌ្ឍសង្គមដោយស្មោះត្រង់ មិនមែនគ្រាន់តែជាការសំដែងហើយមិនប្រតិបត្តិជាក់ស្ដែងនោះទេ អភិសមាចារគឺជាគ្រឹះដ៏សំខាន់ដែលភ្ជាប់អំណាចជាមួយសេចក្ដីស្រលាញ់យុត្តិធម៌និងការគោរព។

សរុបសេចក្ដីមក មូលដ្ឋាននៃអភិសមាចារក្នុងការគ្រប់គ្រងអំណាចគឺជាគន្លឹះធានាឱ្យអំណាចក្លាយជាឧបករណ៍បម្រើប្រយោជន៍សាធារណៈមិនមែនជាមធ្យោបាយបង្កអំណាចផ្ទាល់ខ្លួននោះទេនិងជាស្នូលនៃការដឹកនាំល្អនិងការគ្រប់គ្រងមានសុវត្ថិភាព ស្ថិរភាព និងទំនុកចិត្តពីសង្គម។

## ២- សីលធម៌

សង្គមមនុស្សមិនអាចដំណើរការទៅមុខបានដោយរលូនទេ ប្រសិនបើខ្វះសីលធម៌ជាគ្រឹះពីព្រោះសីលធម៌ជាសរសៃឈាមនៃសង្គម ដែលភ្ជាប់មនុស្សឱ្យរស់នៅជាមួយគ្នាដោយសេចក្ដីថ្លៃថ្នូរនិងការគោរព។

### ២.១- និយមន័យ

សីលធម៌ ជាសំណុំគោលការណ៍នៃគំនិតឬបទប្បញ្ញត្តិផ្លូវចិត្ត ធ្វើឱ្យមនុស្សមានការពិចារណាក្នុងការសម្ដែងឱ្យឃើញនូវអាកប្បកិរិយា ការនិយាយស្ដី និងការគិត ស្របទៅតាមអ្វីដែលសង្គមទទួល

ស្គាល់ថា «ល្អ សមរម្យ និងត្រឹមត្រូវ»។ វាជាតម្លៃផ្លូវចិត្តដែលណែនាំឱ្យមនុស្សដឹងអំពីអ្វីដែលគួរធ្វើនិងមិនគួរធ្វើ ដើម្បីរស់នៅជាមួយគ្នានៅក្នុងសង្គមដោយសេចក្ដីសុចរិត យុត្តិធម៌ និងមនុស្សធម៌។

ក្នុងបរិបទសង្គមនិងវប្បធម៌ខ្មែរ សីលធម៌មានមូលដ្ឋានយ៉ាងជ្រាលជ្រៅទៅលើគុណធម៌ព្រះពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់ វប្បធម៌គោរពឪពុកម្ដាយ គ្រូបង្រៀន និងអ្នកចាស់ទុំ។ សីលធម៌មិនមែនជាច្បាប់ដែលមានការបង្ខំផ្លូវរដ្ឋបាលទេ ប៉ុន្តែជាច្បាប់ផ្លូវចិត្តនិងសង្គមដែលគ្រប់គ្រងអាកប្ប-កិរិយាមនុស្សតាមរយៈមនសិការ ស្មារតីទទួលខុសត្រូវ និងការយល់ដឹងអំពីល្អនិងអាក្រក់។ បន្ថែមលើនេះសីលធម៌ជាបណ្ដុំនៃសង្គមដែលផ្អែកលើសហគមន៍ ការគោរព និងសាមគ្គីភាពដែលបានបង្ហាញតាមរយៈការគោរពឋានានុក្រមនៃសង្គមមនុស្ស អាយុ និងការប្រកាន់ខ្ជាប់លក្ខណៈសុចរិតភាព ការជួយគ្នា និងការចែករំលែក ការអត់ធ្មត់ និងការអភ័យទោស។ សីលធម៌បានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតនូវអត្តសញ្ញាណជាតិនិងរក្សាភាពរឹងមាំនៃសង្គមខ្មែរតាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន។

នៅក្នុងទស្សនៈ «**ព្រះពុទ្ធសាសនា**» សីលធម៌ត្រូវបានចាត់ទុកជាមូលដ្ឋាននៃការអភិវឌ្ឍមនុស្សដែលភ្ជាប់ជាមួយ «សីល» (ការគ្រប់គ្រងអាកប្បកិរិយា) «សមាធិ» (ការគ្រប់គ្រងចិត្ត) «បញ្ញា» (ការយល់ដឹងត្រឹមត្រូវ)។ កត្តាទាំងនេះបង្ហាញថា សីលធម៌មិនត្រឹមតែជាការមិនធ្វើអំពើអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែជាការបណ្ដុះអំពើល្អនិងចិត្តល្អផងដែរ។ ប៉ុន្តែបើប្រៀបធៀបនិងច្បាប់វិញមានលក្ខណៈខុសគ្នានៅត្រង់ថា «ច្បាប់មានការបង្ខំនិងទណ្ឌកម្ម» រីឯសីលធម៌អាស្រ័យលើ «មនសិការនិងស្មារតី»។

សរុបសេចក្ដីមកសម្រាប់សង្គមខ្មែរដែលមានឫសគល់វប្បធម៌និងសាសនាឧត្តុង្គឧត្តម សីលធម៌មិនត្រឹមជាការបង្រៀនខាងផ្លូវទ្រឹស្ដីទេ ប៉ុន្តែជាវិធីណែនាំឱ្យមនុស្សរស់នៅតាមផ្លូវចិត្តដែលបន្តពីមួយជំនាន់ទៅមួយជំនាន់។ មនុស្សអាចមិនរំលោភច្បាប់ ប៉ុន្តែបើខ្វះសីលធម៌សង្គមនៅតែជួបបញ្ហា។ ដូច្នេះហើយសីលធម៌ជាមូលដ្ឋានតម្រង់ទិសទៅរកការគោរពច្បាប់និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព។

### ២.២- សារៈសំខាន់នៃសីលធម៌

សីលធម៌ជាគ្រឹះដ៏សំខាន់នៃជីវិតមនុស្សនិងសង្គមខ្មែរ។ ការបណ្ដុះសីលធម៌គឺជាការបណ្ដុះមនុស្សឱ្យមានគុណតម្លៃ មានស្មារតីជាតិនិយម មានទំនួលខុសត្រូវ និងមានសមត្ថភាពរស់នៅក្នុងសង្គមយ៉ាងសុខដុមរមនា។ សីលធម៌មិនត្រឹមតែបង្កើតមនុស្សល្អប៉ុណ្ណោះទេ តែជាមូលដ្ឋានសម្រាប់ការរស់នៅប្រកបដោយសុខសន្តិភាព សាមគ្គីភាព និងការអភិវឌ្ឍជាតិជាបន្តបន្ទាប់។ ក្នុងន័យនេះសីលធម៌បានផ្ដល់នូវសារៈសំខាន់ដូចខាងក្រោម៖

- សីលធម៌ជាគ្រឹះនៃការរស់នៅរួម ដែលបានជួយឱ្យមនុស្សរស់នៅជាមួយគ្នាដោយសុខដុមរមនា ការអប់រំសីលធម៌ជួយបង្កើតមនុស្សដែលមានចរិតល្អ មានស្មារតីទទួលខុសត្រូវ មានការគោរពច្បាប់ និងគោរពសិទ្ធិអ្នកដទៃ

- សង្គមដែលមានសីលធម៌រឹងមាំនិងមានភាពសុខសាន្ត មានការគោរពគ្នា និងមានការគ្រប់គ្រងសង្គមបានល្អប្រសើរ។ សីលធម៌ជាគ្រឹះនៃវិជ្ជាជីវៈនិងភាពជាអ្នកដឹកនាំក្នុងវិស័យរដ្ឋបាល សន្តិសុខ អប់រំនិងវិជ្ជាជីវៈផ្សេងៗ។ ប៉ុន្តែប្រសិនបើការអប់រំដែលផ្ដោតតែលើចំណេះដឹង ហើយមិនបានបណ្ដុះនូវសីលធម៌នឹងមិនអាចបង្កើតពលរដ្ឋល្អបានទេ ពលរដ្ឋដែលមានសីលធម៌ខ្ពស់នឹងក្លាយជាកម្លាំងវិជ្ជមានប្រកបដោយសក្ដានុពលសម្រាប់សង្គមជាតិ

- សីលធម៌ជាចំណុចស្នូលសម្រាប់បង្កើតទំនុកចិត្ត សេចក្តីថ្លៃថ្នូរ ភាពសុចរិតរបស់មន្ត្រី និងអ្នកដឹកនាំព្រមទាំងការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ យើងមិនអាចពឹងផ្អែកតែលើវិស័យសេដ្ឋកិច្ចឬបច្ចេកវិទ្យាតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្អែកលើសីលធម៌និងគុណធម៌របស់ប្រជាពលរដ្ឋផងដែរ

- សីលធម៌ជាគ្រឹះនៃសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ មានសីលធម៌ល្អនឹងកាត់បន្ថយអំពើហិង្សា កាត់បន្ថយអំពើពុករលួយ និងបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋ។ ក្នុងវិស័យសន្តិសុខនិងរដ្ឋបាលដែនដី សីលធម៌មានតួនាទីសំខាន់ក្នុងការអនុវត្តអំណាចដោយយុត្តិធម៌និងការបម្រើសេវាប្រជាពលរដ្ឋដោយស្មោះត្រង់ ព្រមទាំងការរក្សាបាននូវកិត្តិយសរបស់អង្គភាពឬស្ថាប័ន

- សីលធម៌ជាគ្រឹះនៃការអភិវឌ្ឍជាតិយ៉ាងចីរភាព ការអភិវឌ្ឍដែលខ្វះសីលធម៌អាចនាំឱ្យសង្គមមានវិបត្តិ សង្គមគ្មានសមធម៌ និងបាត់បង់តម្លៃនៃវប្បធម៌សង្គម។ ផ្ទុយមកវិញសីលធម៌បានជួយឱ្យការអភិវឌ្ឍឱ្យមានតុល្យភាពរវាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ផងដែរ។

### ២.៣- ប្រភេទផ្សេងៗនៃសីលធម៌

ជាទូទៅតាមទ្រឹស្តីព្រះពុទ្ធសាសនា សីលធម៌សំដៅដល់ការអប់រំទូន្មានប្រៀនប្រដៅ ដឹកនាំឱ្យមនុស្សរស់ទៅរកផ្លូវល្អនិងចៀសវាងផ្លូវអាក្រក់។ សីលធម៌ជាឧបករណ៍ជំរុញឱ្យរូបវន្តបុគ្គលក្លាយជាបុគ្គលដែលមានប្រយោជន៍នៅក្នុងសង្គម។

សីលធម៌ត្រូវបានបែងចែកទៅតាមប្រភេទនីមួយៗដូចខាងក្រោម៖

#### ២.៣.១- សីលធម៌ចំពោះខ្លួនឯង

ដើម្បីធ្វើឱ្យជីវិតមានខ្លឹមសារ បុគ្គលម្នាក់ៗត្រូវមានសីលធម៌ចំពោះខ្លួនឯង។ សីលធម៌ចំពោះខ្លួនឯងមានដូចជា៖

- ការដឹងខុសត្រូវ ស្គាល់ខ្លួនឯង ធ្វើជាម្ចាស់លើខ្លួនឯង គ្រប់គ្រងចិត្តរបស់ខ្លួនឯង
- ការស្គាល់ល្អនិងអាក្រក់នាំឱ្យមនុស្សត្រូវមានមនសិការ សតិសម្បជញ្ញៈ និងស្មារតីទទួលខុសត្រូវនូវរាល់ផលវិបាកនិងសកម្មភាពរបស់ខ្លួន
- ការតាំងចិត្តធ្វើជាម្ចាស់លើខ្លួនឯងដោយត្រូវចេះអភិវឌ្ឍខ្លួន ខិតខំរៀនសូត្រ និងបង្កើនសមត្ថភាពចំណេះដឹង សមត្ថភាពសីលធម៌អត្តចរិត និងសមត្ថភាពខាងកាយសម្បទា
- ការទទួលខុសត្រូវនឹងអំពើរបស់ខ្លួនដោយមិនត្រូវបណ្តោយខ្លួនឱ្យធ្លាក់ក្នុងភាពខ្ជិលច្រអូស ឬអបាយមុខផ្សេងៗនាំឱ្យកើតមានមហន្តរាយដល់ខ្លួន
- មានភាពក្លាហានក្នុងផ្លូវដែលត្រឹមត្រូវ សុចរិត ទៀងត្រង់ និងយុត្តិធម៌
- ហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តចំពោះសង្គមនិងចំពោះខ្លួនឯង។

#### ២.៣.២- សីលធម៌ចំពោះគ្រួសារនិងអ្នកដទៃ

លក្ខណៈពិសេសនៃសីលធម៌ក្នុងសង្គមខ្មែរ គឺកុលបុត្រកុលធីតានៃគ្រួសារខ្មែរទាំងអស់ត្រូវតែប្រកាន់ខ្ជាប់នូវការគោរពដល់អ្នកមានគុណ ឪពុកម្តាយ គ្រូបង្រៀន ចាស់ព្រឹទ្ធាចារ្យប្រកបដោយសុចរិតភាព មិនបោកប្រាស់ មិនរំលោភសិទ្ធិអ្នកដទៃ រស់នៅដោយភាពត្រឹមត្រូវសាមគ្គីភាព និងការជួយគ្នាក្នុងគ្រាលំបាក ការចែករំលែកក្នុងសហគមន៍ ការអត់ធ្មត់ និងការអភ័យទោសមិនប្រើអំពើហិង្សា ដោះ

ស្រាយបញ្ហាដោយសន្តិវិធី។ ក្នុងសង្គមគ្រួសារមួយដែលមានការរស់នៅប្រកបដោយសុភមង្គល លុះត្រាតែសមាជិកក្នុងគ្រួសារនោះមានសីលធម៌ប្រចាំគ្រួសារគឺឪពុកម្តាយត្រូវប្រតិបត្តិតាមតួនាទីរបស់ខ្លួនជាមាតាបិតាល្អ ហើយកូនចៅប្រុសស្រីទាំងអស់ត្រូវប្រតិបត្តិនូវតួនាទីរបស់ខ្លួនក្នុងនាមជាកុលបុត្រកុលធីតាខ្មែរដែលធ្លាប់មានវប្បធម៌ល្អផូរផង់រុងរឿងពីបុរាណកាលមក។

**ក- សីលធម៌របស់ឪពុកម្តាយចំពោះកូន**

- ត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យមានភាពកក់ក្តៅដោយពុំគិតដល់ពីការតបស្នងសងគុណរបស់កូនមកវិញឡើយ
- ផ្គត់ផ្គង់ជាថវិកា សម្ភារៈផ្សេងៗសម្រាប់កូនសិក្សាឬប្រកបការងារអ្វីមួយ
- ត្រូវចេះអប់រំកូនឱ្យដើរផ្លូវល្អ សុចរិតទៀងត្រង់
- ស្រលាញ់កូនស្មើៗគ្នាមានព្រហ្មវិហារធម៌ចំពោះកូន
- អប់រំកូនជាប្រចាំឱ្យកូនចៅប្រុសស្រីក្លាយជាក្មេងល្អ ពលរដ្ឋល្អក្នុងសង្គម
- ត្រូវចេះធ្វើគំរូល្អដល់កូនៗ ព្រមទាំងផ្តល់ក្តីសង្ឃឹមដល់ពួកគេ
- រៀបការនិងចែកទ្រព្យសម្បត្តិដល់កូនៗនូវមេត្តាធម៌សម្រាប់សេចក្តីសុខនិងសុភមង្គល។

**ខ- សីលធម៌របស់កូនចំពោះឪពុក ម្តាយ ឬអាណាព្យាបាល**

- គោរពតបស្នងសងគុណនិងចិញ្ចឹមបីបាច់លោកដោយបច្ច័យបួនឱ្យបានល្អ
- ចេះថែរក្សាវង្សត្រកូលនិងលើកតម្កើងកិត្តិយសឱ្យបានល្អ ព្រមទាំងខិតខំរៀនសូត្រដើម្បីអនាគតខ្លួននិងគ្រួសារ
- ស្តាប់ដំបូន្មានលោកទាំងពីរ ជួយធ្វើការងារគ្រប់យ៉ាងជូនលោក និងចេះថែរក្សាទ្រព្យសម្បត្តិដែលលោកផ្តល់ឱ្យយើង
- ប្រកាន់ឥរិយាបថឱ្យត្រឹមត្រូវចំពោះអ្នកមានគុណដោយមិនត្រូវធ្វើអាកប្បកិរិយាមិនគប្បីណាមួយដោយកាយក្តីនិងវាចាក្តី
- ធ្វើបុណ្យទានឧទ្ទិសកុសលតាមផ្លូវព្រះពុទ្ធសាសនាដល់ឪពុកម្តាយដែលបានចែកឋាន។

**គ- សីលធម៌ចំពោះអ្នកដទៃ**

- គោរពសិទ្ធិអ្នកដទៃដោយមិនប្រកាន់ពណ៌សម្បុរ ក្មេងចាស់ ប្រុសស្រីឡើយ
- មិនធ្វើឱ្យអ្នកដទៃឈឺចាប់ រកស៊ីតាមសមត្ថភាពរបស់ខ្លួន (មិនបោកប្រាស់ កេងប្រវញ្ចប្រកបតែរបរសុចរិត)
- មិនបង្កមហន្តរាយឬអសុវត្ថិភាពដល់អ្នកដទៃ (មិនលួចឬកេងប្រវញ្ចទ្រព្យអ្នកដទៃ)
- ជួយសង្គ្រោះអ្នកដទៃពេលមានទុក្ខលំបាក (មិនរំលោភបំពានលើអ្នកតូចជាងខ្លួន)។

**២.៣.៣- សីលធម៌ចំពោះសង្គមជាតិ**

ក្នុងការរស់នៅក្នុងសង្គមជាតិ យើងត្រូវមានសីលធម៌ដូចខាងក្រោម៖

- ស្រលាញ់រាប់អានមនុស្សទូទៅ មិនឈ្លានពានជីវិតអ្នកដទៃ គោរពសិទ្ធិគ្នាទៅវិញទៅមក
- មានសាមគ្គីភាពល្អរវាងគ្នានឹងគ្នា មិនធ្វើឱ្យអ្នកដទៃរងទុក្ខដោយសារខ្លួន

- ស្រលាញ់យុត្តិធម៌ សន្តិភាពសង្គម និងត្រូវរស់នៅក្នុងភាពបម្រុងប្រយ័ត្នគ្រប់វិនាទី។ ដូចជាពាក្យស្លោកមួយបានពោលថា «នៅម្នាក់ឯងត្រូវប្រយ័ត្នគំនិត នៅក្នុងគ្រួសារត្រូវប្រយ័ត្នទឹកមុខ នៅក្នុងសង្គមត្រូវប្រយ័ត្នពាក្យសំដី»
- ត្រូវបញ្ចូលមុខវិជ្ជាសីលធម៌ទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនឱ្យបានច្រើននិងលោកគ្រូអ្នកគ្រូត្រូវដើរតួជាគំរូល្អដល់យុវជន សិស្ស ឬនិស្សិត
- រាល់ច្បាប់ដែលបង្កើតឡើងត្រូវតែមានភាពយុត្តិធម៌និងស្មើភាពចំពោះបុគ្គលគ្រប់រូបប្រកបដោយក្រមសីលធម៌
- រឹតបន្តឹងច្បាប់និងត្រូវលុបបំបាត់អំពើពុករលួយនិងការកេងប្រវ័ញ្ចនៅក្នុងសង្គម
- តាមដានឱ្យបានល្អិតល្អន់នូវរាល់ការផ្សព្វផ្សាយផ្សេងៗដូចជាទស្សនាវដ្ដី កាសែត វីដេអូ វិទ្យុ និងទូរទស្សន៍ដើម្បីដឹងថា ការផ្សព្វផ្សាយទាំងនោះមានក្រមសីលធម៌វិជ្ជាជីវៈដែរឬទេ?
- ត្រូវបង្កើតឱ្យមានកម្មវិធីអប់រំសីលធម៌ឱ្យបានច្រើនតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- លើកទឹកចិត្តដល់អ្នកដែលបានសាងអំពើល្អចំពោះជាតិនិងសមូហភាព
- តាមដានត្រួតពិនិត្យ ទប់ស្កាត់ និងចេះច្នៃប្រឌិតអ្វីដែលជាវប្បធម៌បរទេសឱ្យសមស្របទៅតាមវប្បធម៌របស់ជាតិសាសន៍យើង។

### ២.៣.៤- សីលធម៌សម្រាប់ពិភពលោក

សីលធម៌សម្រាប់ពិភពលោកសំដៅដល់តម្លៃសីលធម៌រួមនិងគំរូសីលធម៌ដែលផ្សំឡើងពីវប្បធម៌និងជំនឿផ្សេងៗនៅលើភពផែនដីនេះ។ តម្លៃសីលធម៌រួមនិងគំរូសីលធម៌ទាំងនេះបង្កើតបានជាសីលធម៌របស់មនុស្សជាតិ។ ការយល់ស្របជាមូលដ្ឋាននៃតម្លៃគំរូនិងឥរិយាបថដែលមានលក្ខណៈសាមញ្ញ ប៉ុន្តែមានសារៈសំខាន់បំផុតដែលត្រូវបានលើកឡើងថា «ចូរអ្នកប្រព្រឹត្តចំពោះអ្នកដទៃដូចដែលអ្នកចង់ឱ្យអ្នកដទៃប្រព្រឹត្តមកលើអ្នកវិញ»។ ទ្រឹស្តីនេះគេហៅថាជាទ្រឹស្តីសកលដែលជាច្បាប់មាសនៃជីវិតបានផ្តោតសំខាន់លើខ្លឹមសារនៃការយោគយល់ ហើយត្រូវបានគេរកឃើញនៅក្នុងប្រព័ន្ធជំនឿសាសនានិងប្រព័ន្ធជំនឿមិនមែនសាសនានៅលើពិភពលោក ហើយក៏មាននៅក្នុងទស្សនវិជ្ជាសំខាន់ៗដែលមិនជឿលើសាសនាផងដែរ។ វាជាច្បាប់មូលដ្ឋាននៃការរស់នៅរួមគ្នា (សហអត្ថិភាព) របស់មនុស្សប្រកបដោយសន្តិភាពដែលគេអាចចាត់ទុកថាជាមាតានៃសីលធម៌របស់មនុស្សជាតិ។ ទស្សនវិទូអាល្លឺម៉ង់ (**អ៊ីម៉ា-ទុយអែលកាន្ត**) ហៅច្បាប់មាសនៃជីវិតថាជាបញ្ញាដាច់ខាតនៃសហអត្ថិភាពរបស់មនុស្សនៅលើភពផែនដី។ ច្បាប់នេះហាក់ដូចជាដើរតួជាច្បាប់រដ្ឋធម្មនុញ្ញរបស់មនុស្សជាតិ ក្រៅពីនេះក៏នៅមានគំរូនិងតម្លៃសីលធម៌ជាច្រើនទៀតដែលផ្សំពីជំនឿសាសនានិងជំនឿផ្សេងៗទៀតមានដូចជាការគោរពសិទ្ធិមនុស្ស ការស្រលាញ់ ការអាណិត ការអាសូរ ការយកចិត្តទុកដាក់ ការចែករំលែក ការការពារបរិស្ថាន សេចក្តីសុចរិត ភាពយុត្តិធម៌ ភាពស្មោះត្រង់ និងគណនេយ្យភាពវាបង្កើតបានជាសីលធម៌សកល។

គុណសម្បត្តិនៃ «សីលធម៌សកល» មានតម្លៃសម្រាប់មនុស្សគ្រប់គ្នាត្រូវតែមានជាចាំបាច់មិនអាចខ្វះបានឡើយ។ វាប្រៀបបានទៅនឹងសត្វបក្សីដែលពឹងផ្អែកទៅលើស្លាបរបស់វាក្នុងការស្វែងរកចំណីចិញ្ចឹមជីវិតខ្លួនឯងនិងកូនៗរបស់វា។ មនុស្សមានវិជ្ជាហើយត្រូវតែប្រកាន់យកនូវសីលធម៌បន្ថែមទៀតដើម្បីបញ្ជាក់ពីគុណភាពនៃវិជ្ជាក្នុងការលើកកម្ពស់តម្លៃជីវិតឱ្យកាន់តែមានរស្មីត្រចះត្រចង់និង

សន្តិភាពនៅលើពិភពលោកទាំងមូល។ ដើម្បីទទួលភាពត្រចះត្រចង់និងសន្តិភាពតម្រូវឱ្យប្រទេសទាំងឡាយនៅលើពិភពលោកមានប្រជាជនមានសីលធម៌ទៅតាមវប្បធម៌ប្រពៃណីរៀងៗខ្លួន តាមរយៈការរាប់អានគ្នាដោយមិនរើសអើងឬប្រកាន់ពូជសាសន៍ សាសនា សញ្ជាតិ ពណ៌សម្បុរ។ល។ ជាការពិតណាស់ការរួមសហការគ្នាក្នុងទិសដៅពង្រឹងវប្បធម៌សន្តិភាព ការដោះស្រាយបញ្ហាដោយសន្តិវិធី កត្តាសាមគ្គីភាពនិងការពង្រឹងសាមគ្គីភាពបានល្អនៅក្នុងប្រទេស តំបន់ និងពិភពលោកគឺជាធាតុផ្សំដ៏សំខាន់និងចាំបាច់បំផុតនៃការកសាងសីលធម៌សម្រាប់ពិភពលោក។

## ២.៤- ការលើកកម្ពស់សីលធម៌

ក្នុងសង្គមមនុស្សគ្រប់សម័យកាល សីលធម៌តែងតែត្រូវបានចាត់ទុកជាគ្រឹះសំខាន់បំផុតសម្រាប់ការរស់នៅរួមនិងការអភិវឌ្ឍសង្គមយ៉ាងមានស្ថិរភាព។ ការលើកកម្ពស់សីលធម៌មិនមែនជាកិច្ចការដែលកើតឡើងដោយចៃដន្យទេ ប៉ុន្តែជាដំណើរការដែលត្រូវការការយកចិត្តទុកដាក់បណ្តុះបណ្តាលនិងមានការចូលរួមពីគ្រប់ភាគីក្នុងសង្គម។ នៅពេលដែលសង្គមប្រឈមនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សទាំងផ្នែកនយោបាយ សេដ្ឋកិច្ច បច្ចេកវិទ្យា និងវប្បធម៌ តួនាទីសីលធម៌បានក្លាយជាបញ្ហាស្នូលដែលមិនអាចមើលរំលងបានឡើយ។ សីលធម៌ជាច្បាប់ផ្លូវចិត្តដែលគ្រប់គ្រងអាកប្បកិរិយាមនុស្សឱ្យធ្វើអំពើល្អដោយស្មគ្រចិត្តដោយមិនមែនជាការបង្ខិតបង្ខំនោះទេ។

ក្នុងបរិបទសង្គមខ្មែរការលើកកម្ពស់សីលធម៌មានមូលដ្ឋានជ្រាលជ្រៅលើវប្បធម៌ ប្រពៃណី និងគុណធម៌ព្រះពុទ្ធសាសនាដែលបានបណ្តុះបណ្តាលឱ្យប្រជាជនខ្មែរចេះគោរពអ្នកមានគុណ ស្រលាញ់សន្តិភាព ប្រកាន់ខ្ជាប់សុចរិតភាព និងរស់នៅដោយសាមគ្គីភាព។ ទោះជាយ៉ាងណាក្នុងបរិបទសង្គមបែបទំនើបកត្តាផ្សេងៗដូចជាវប្បធម៌បរទេស បច្ចេកវិទ្យាឌីជីថល និងការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចបានធ្វើឱ្យតម្លៃសីលធម៌ប្រឈមនឹងការប្រែប្រួលឬការថយចុះប្រសិនបើគ្មានការយកចិត្តទុកដាក់លើកកម្ពស់ការពង្រឹងឱ្យបានសមស្របទៅតាមសម័យកាលនីមួយៗ។ ដូចនេះការលើកកម្ពស់សីលធម៌ត្រូវបានចាត់ទុកជាបេសកកម្មរួមរបស់គ្រួសារ សាលារៀន ស្ថាប័នរដ្ឋ សង្គម និងសាសនាដើម្បីបណ្តុះបណ្តាលមនុស្សឱ្យក្លាយជាពលរដ្ឋល្អ មានវិន័យ មានទំនួលខុសត្រូវ និងស្មារតីសង្គម។ ការលើកកម្ពស់សីលធម៌មិនត្រឹមតែផ្តោតលើការបង្រៀនទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានអនុវត្តជាក់ស្តែងតាមរយៈគំរូល្អ ការអប់រំតាំងពីវ័យក្មេងនិងការបង្កើតបរិយាកាសសង្គមដែលលើកទឹកចិត្តឱ្យអំពើល្អត្រូវបានគេគោរពនិងលើកតម្កើង។ ខាងក្រោមនេះជាសូចនាករមួយចំនួនដែលតម្រូវឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលត្រូវតែប្រកាន់ខ្ជាប់ដើម្បីលើកកម្ពស់សីលធម៌សម្រាប់សង្គមខ្មែរបច្ចុប្បន្នៈ

**១- ការស្គាល់ពីខ្លួនឯង** ការព្យាយាមគ្រប់គ្រងខ្លួនឯងជាបញ្ហាចម្បងដែលធ្វើឱ្យយើងស្គាល់និងយល់ពីសន្តានចិត្តរបស់អ្នកដទៃ។ អ្នកទស្សនវិទូ **សូក្រាត** បានពោលថាដើម្បីឱ្យមានសីលធម៌មនុស្សម្នាក់ៗត្រូវស្គាល់ខ្លួនឯងជាមុនសិន។ ការស្គាល់ខ្លួនឯងមិនត្រឹមស្គាល់ឈ្មោះ ដើមកំណើត អាយុ ភេទប៉ុណ្ណោះទេគឺត្រូវស្គាល់ចំណុចខ្លាំង ចំណុចខ្សោយរបស់ខ្លួន ហើយខ្លួនកំពុងនៅទីណា ស្គាល់ពីចិត្តខ្លួនឯងត្រូវការអ្វី ស្រលាញ់អ្វី និងស្អប់អ្វីផងដែរ។ បុគ្គលគ្រប់រូបត្រូវស្គាល់ពីតួនាទីរបស់ខ្លួនឱ្យល្អប្រពៃតាមតួនាទីដូចជាធ្វើអំពើល្អក្នុងគ្រួសារ សិស្សល្អក្នុងសាលារៀន ពលរដ្ឋល្អក្នុងសង្គម បុគ្គលិកល្អក្នុងអង្គភាពឬស្ថាប័ន និងជាសហការីល្អជាមួយនឹងមេដឹកនាំជាដើម។

**២- ការស្គាល់ពីគុណតម្លៃខ្លួនឯងនិងអ្នកដទៃ** មនុស្សត្រូវការការផ្ដល់តម្លៃ ការគោរពរាប់អាន ដូច្នេះបើខ្លួនអ្នកត្រូវការឱ្យអ្នកដទៃឱ្យតម្លៃវិជ្ជមានមកលើអ្នក គោរពស្រលាញ់អ្នក លុះត្រាអ្នកឱ្យតម្លៃវិជ្ជមាន គោរពស្រលាញ់អ្នកដទៃវិញដែរ។ លោក **ខុង ជឺ** បាននិយាយថា បើអ្នកចង់ឱ្យអ្នកដទៃធ្វើអំពើល្អមកលើខ្លួននោះ លុះត្រាតែអ្នកធ្វើអំពើល្អទៅគេផងដែរ។ បុគ្គលគ្រប់រូបត្រូវចេះជួយទុក្ខធុរៈគ្នា ស្មោះត្រង់ចំពោះគ្នានឹងគ្នា ចែករំលែកផលប្រយោជន៍គ្នាតាមសមគួរ មានចិត្តរីករាយជាប្រចាំ មានព្រហ្មវិហារធម៌គឺមេត្តា ករុណា មុទិតា និងឧបេក្ខាចំពោះគ្នាទៅវិញទៅមកដោយយល់ថា «បើចង់ឱ្យអ្នកដទៃគោរពខ្លួនយ៉ាងណា អ្នកត្រូវគោរពអ្នកដទៃយ៉ាងនោះដែរ»។

**៣- ការលើកទឹកចិត្តក្នុងសកម្មភាពសីលធម៌** គ្មានបុគ្គលណាម្នាក់មិនត្រូវការការកោតសរសើរនោះទេ នេះជាតម្រូវការមួយក្នុងចំណោមតម្រូវការទាំងប្រាំដែលលោកម៉ាស្លូបានលើកឡើងដែលយើងហៅថា «តម្រូវការម៉ាស្លូ» ដែលមានតាមឋានានុក្រមពីកម្រិតទាបទៅខ្ពស់ដូចជាតម្រូវការផ្នែកសារពាង្គកាយ តម្រូវការផ្នែកសុវត្ថិភាព តម្រូវការសង្គមគឺការស្រលាញ់ តម្រូវការ ការឱ្យតម្លៃនិងការគោរព និងតម្រូវការកិត្តិយសផ្ទាល់ខ្លួន។ ដូចនេះបើយើងឱ្យតម្លៃខ្ពស់និងលើកសរសើរដល់អ្នកដែលធ្វើសកម្មភាពសីលធម៌នោះ ពួកគេនឹងព្យាយាមធ្វើសកម្មភាពទាំងនោះកាន់តែខ្លាំងឡើង។ ដូចជាសកម្មភាពជួយទុក្ខធុរៈគ្នា ចែករំលែកនូវសម្ភារៈប្រើប្រាស់ ទ្រព្យសម្បត្តិ និងចំណេះដឹងផ្សេងៗដែលយើងក៏គួរផ្តល់ឱ្យពួកគេនូវរង្វាន់ទៅតាមអ្វីដែលពួកគេរីករាយនឹងទទួលយក។

ព្រះសម្មាសម្ពុទ្ធបានសំដែងថា យើងត្រូវតបស្នងសងគុណដល់អ្នកដែលបានធ្វើគុណមកលើយើង។ នេះក៏ជាកត្តាដែលធ្វើឱ្យមនុស្សចេះអធ្យាស្រ័យគ្នានិងធ្វើឱ្យសកម្មភាពសីលធម៌មានភាពរស់រវើកឡើង។ ចំពោះទស្សនវិទូ **សូក្រាត** យល់ថាការគ្រប់គ្រងដោយសីលធម៌ប្រសើរជាងការគ្រប់គ្រងដោយច្បាប់។

**៤- ការបង្កើនការអប់រំផ្នែកសីលធម៌** បច្ចេកវិទ្យាកាន់តែទំនើបធ្វើឱ្យមនុស្សកាត់បន្ថយជំនឿទៅលើសាសនាដែលបង្កប់ទៅលើខ្លឹមសារទស្សនវិជ្ជា ធ្វើឱ្យមនុស្សមានសីលធម៌ តែពួកគេគួរដឹងដែរថាបើកាលណាវិទ្យាសាស្ត្រមិនមានសីលធម៌នោះវានឹងបំផ្លាញសង្គមមនុស្ស។ ដូចនេះសង្គមគួរយកចិត្តទុកដាក់អប់រំបង្រៀនឱ្យមនុស្សដែលមិនបានដឹងមិនបានស្គាល់ ដើម្បីជាស់ស្មារតីឱ្យពួកគេបានស្គាល់បានយល់ពីតម្លៃរបស់សីលធម៌។ រីឯការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយទំនើបដទៃទៀតក៏ជាកត្តារួមចំណែកដល់ការអប់រំផ្នែកសីលធម៌ដែរ។ ដូចនេះយើងគួរផ្សព្វផ្សាយផ្នែកសីលធម៌និងប្រើប្រាស់ភាសាប្រកបទៅដោយសីលធម៌ឱ្យបានច្រើនជាជាងការប្រើពាក្យជេរប្រទេចគ្នាឬយកសីលធម៌ធ្វើជារឿងកំប្លែងសម្រាប់សើចកម្សាន្ត។ ការអប់រំក៏ជាកត្តាទប់ស្កាត់មនុស្សដែលអណ្តែតត្រសែតទៅតាមមនោសញ្ចេតនាក្នុងភាពអស់សង្ឃឹមឬបាក់ទឹកចិត្តបានដែរ។ និយាយរួមគឺជាការគ្រប់គ្រងអារម្មណ៍អ្នកដទៃផងនិងខ្លួនឯងផង។

**៥- ការបណ្តុះគំនិតជាតិនិយមនិងសន្តិភាពក្នុងចិត្ត** ជាតិនិយមជាទ្រឹស្តីមួយអប់រំឱ្យស្រលាញ់ជាតិរបស់ខ្លួន ស្រលាញ់វប្បធម៌ ស្រលាញ់ប្រវត្តិសាស្ត្រ និងមានគំនិតកសាងប្រទេសជាតិរបស់ខ្លួនឱ្យក្លាយទៅជានីតិរដ្ឋត្រឹមត្រូវនិងសម្បូរសប្បាយ។ ថ្វីដ្បិតតែមនុស្សគ្រប់រូបតែងគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនក៏ពិតមែន តែបើបុគ្គលមានជាតិនិយមក្នុងខ្លួន គេនឹងស្រលាញ់សង្គមជាតិរបស់គេនិងចង់ឱ្យពិកភព

លោកទាំងមូលរស់ក្នុងសុខសន្តិភាព។ នៅពេលដែលសន្តិភាពមាននៅក្នុងចិត្តហើយនោះ គ្រប់យ៉ាងនឹងបង្ហាញនូវសេចក្តីស្ងប់ ស្រលាញ់ មេត្តា ករុណា អធ្យាស្រ័យ យុត្តិធម៌ សេចក្តីថ្លៃថ្នូរ និងសន្តិភាព។

ដើម្បីឱ្យមនុស្សឬសង្គមមានសន្តិភាពស្ថិតស្ថិរគង់វង្សបាន លុះត្រាតែមានការគោរពសិទ្ធិ ការអត់ឱន ការអធ្យាស្រ័យ ការមានទំនាក់ទំនងល្អជាមួយនឹងអ្នកដទៃ មានយុត្តិធម៌ សច្ចធម៌ និងប្រជាធិបតេយ្យ។

**៦- ការរឹតបន្តឹងច្បាប់** សង្គមជាតិមួយមានច្បាប់ដែលបង្កើតឡើងដោយប្រជាពលរដ្ឋដើម្បីប្រជាពលរដ្ឋ ច្បាប់នោះត្រូវតែបានអនុវត្តទៅលើគ្រប់បុគ្គលទាំងអស់ដោយស្មើភាព។ លោក **អារីស្តូត** បានពោលថា ប្រទេសមួយដែលរឹងមាំ មានស្ថិរភាព មានការរីកចម្រើនអាស្រ័យលើច្បាប់ ហើយច្បាប់នោះត្រូវតែមានអានុភាពចំពោះថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋទាំងអស់។ ដូចនេះបើកាលណាច្បាប់ត្រូវបានរឹតបន្តឹងនឹងដាក់ទោសទណ្ឌស្មើភាពគ្នាចំពោះអ្នកដែលប្រព្រឹត្តល្មើស វានឹងធ្វើឱ្យមនុស្សខ្លាចរអាមិនហ៊ានប្រព្រឹត្តអំពើឆ្គាំឆ្គងណាមួយដែលខុសសីលធម៌ឬច្បាប់សង្គមនោះឡើយ។

សរុបសេចក្តីមក យើងឃើញថា ការអប់រំសីលធម៌មានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលមនុស្សឱ្យយល់ដឹងអំពីច្បាប់ វិន័យ គុណតម្លៃ សីលធម៌ គុណធម៌ សច្ចធម៌ យុត្តិធម៌ សុជីវធម៌ និងអាកប្បកិរិយាដែលតម្រូវឱ្យមនុស្សប្រតិបត្តិដោយស្មើភាពក្លាយជាពលរដ្ឋល្អក្នុងសង្គម។ ប៉ុន្តែលទ្ធផលយ៉ាងណានោះ គឺអាស្រ័យទៅលើចរិតលក្ខណៈរបស់រូបវន្តបុគ្គល នីតិបុគ្គល ឬអ្នកអប់រំនិងអ្នកទទួលយកចំណេះដឹងយកទៅអនុវត្តឱ្យស្របនឹងសីលធម៌សង្គមនិងសីលធម៌ដែលខ្លួនមាន។

ដូចដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយថា កម្ពុជាជាប្រទេសដែលមានវ័យចំណាស់យូរលង់ណាស់មកហើយ ធ្លាប់មានវប្បធម៌ អរិយធម៌ខ្ពង់ខ្ពស់ មានជនជាតិខ្មែរដែលជាជាតិសាសន៍ពូកែរឹងមាំ ឧស្សាហ៍ព្យាយាម មានចរិតលក្ខណៈល្អ សុភាពរាបសា រួសរាយរាក់ទាក់ និងមានសីលធម៌កេរ្តិ៍ឈ្មោះល្អល្បីរន្ទឺលើឆាកអន្តរជាតិដែលប្រវត្តិសាស្ត្រខ្មែរពីបុរាណបានចារទុកមក។ មរតកជាប្រវត្តិសាស្ត្រទាំងនេះជាស្នាដៃដូនតាចាស់ទុំរបស់ខ្មែរបានបន្សល់ទុកឱ្យជាកេរដំណែលនៃព្រលឹងជាតិជូនប្រជាជនខ្មែរគ្រប់រូបកុំឱ្យបាត់បង់ហើយត្រូវថែរក្សាវប្បធម៌ប្រពៃណីជាតិឱ្យបានគង់វង្សដូចពាក្យស្លោកមួយបានលើកឡើងថា «**វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន**»។

# ៣- ក្រមសីលធម៌

## ៣.១- និយមន័យនិងសារៈសំខាន់

### ៣.១.១- និយមន័យ

ដើម្បីងាយយល់ដល់អត្ថន័យក្រមសីលធម៌ យើងគួរគប្បីឈ្វេងយល់ពីពាក្យនីមួយៗដែលមានអត្ថន័យវិភាគតាមបែបសម្រាយពាក្យដូចខាងក្រោម៖

យើងអាចបំបែកញែកក្រមសីលធម៌ចេញជា «ក្រមនិងសីលធម៌» ក្រមជានាមសព្ទមានន័យថា លំដាប់ ក្បួន បែប ពួក ប៉ែក បណ្តុំ ចង្កោម ឬងារក្នុងតំណែងរាជការឃុំក្នុងសម័យពីដើម ក្លាយមកពីពាក្យ «ក្រមការ» (ជួន ណាត ១៩៦៧) «សីលធម៌» (សីលធម្ម) មានន័យថា សីលដែលជាធម៌ (របស់សត្វលោក) ឬសីលនិងធម៌ កិរិយាមារយាទ សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អដូចជាប្រកបដោយសីលធម៌ ប្រាសចាកសីលធម៌ជាដើម។ ម្យ៉ាងទៀតយើង

អាចបំបែកចែកចេញបន្តទៀតជា «សីលនិងធម៌» ហើយសីលជានាមសព្ទមានន័យថាវិរតិចេតនាដែលវៀរចាកអំពើអាក្រក់ ការកាន់ឬប្រព្រឹត្តល្អដោយកាយ វាចា ការមិនប្រព្រឹត្តកន្លងនូវសិក្ខាបទឬវិន័យបញ្ញត្តិ ការកាន់ចរិយាល្អ ការសង្រួមអង្គនៃចរិយា ចរិត ចរិយាមារយាទល្អ សេចក្ដីល្អ គតិ លក្ខណៈ និស្ស័យ អជ្ឈាស្រ័យ សុភាព ប្រក្រតី ទម្លាប់ សណ្ដាប់ធ្នាប់ ធម្មជាតិ ធម្មតា។ល។ (ជួន ណាត ១៩៦៧)។ «ធម៌» ជានាមសព្ទមានន័យថាសភាវៈដែលទ្រទ្រង់សត្វលោក គឺបុណ្យបាបសុចរិត ទុច្ចរិត ពាក្យនេះខ្មែរយើងធ្លាប់ប្រើជាធម្មតាមក គឺសំដៅយកពាក្យឱវាទរបស់ព្រះពុទ្ធនិងអត្ថបទទូទៅដែលទាក់ទងដោយពុទ្ធសាសនា ដូចជារៀនធម៌ សូត្រធម៌ ចេះធម៌ ចាំធម៌ ស្ដាប់ធម៌ អត្ថបទរបស់ធម៌ (ជួន ណាត ១៩៦៧)។ ក្នុងន័យនេះតាមការបែងចែកខាងលើយើងអាចយល់ថា «ក្រមសីលធម៌» មកពី «ក្រមនិងសីលធម៌» មានន័យថាបណ្ដុំឬចង្កោមនៃសណ្ដាប់ធ្នាប់កិរិយាមារយាទ ឬបណ្ដុំឬចង្កោមនៃដំបូន្មានដែលនាំឱ្យមនុស្សចៀសវាងអំពើអាក្រក់ហើយប្រព្រឹត្តតែអំពើល្អ។

សរុបសេចក្ដីមក «ក្រមសីលធម៌» ជាមូលដ្ឋានចិត្តសាស្ត្រក្នុងការរៀបចំបទដ្ឋានអាកប្បកិរិយាដែលកំណត់ទិសដៅឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលប្រតិបត្តិខ្លួនបានត្រឹមត្រូវមានភាពសុចរិត តម្លាភាព ទំនួលខុសត្រូវ និងគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សក្នុងការបំពេញភារកិច្ចនៃវិជ្ជាជីវៈរបស់ខ្លួន ហើយក្រមសីលធម៌មិនមែនជាច្បាប់ដែលតម្រូវឱ្យមានទណ្ឌកម្មសម្រាប់អ្នកដែលមិនបានប្រតិបត្តិតាមនោះទេ គ្រាន់តែជាច្បាប់ផ្លូវចិត្តនិងសតិសម្បជញ្ញៈដែលគ្រប់គ្រងអាកប្បកិរិយាមនុស្សពីខាងក្នុងឱ្យធ្វើអំពើល្អក្លាយជាទម្លាប់និងវប្បធម៌វិជ្ជាជីវៈឬអាចនិយាយបានថាជាស្ដង់ដានៃគុណតម្លៃមនុស្សដែលបណ្ដុះឱ្យបុគ្គលមានស្មារតីខុសត្រូវចេះគោរពខ្លួនឯង គោរពអ្នកដទៃ និងគោរពសង្គមជាតិទាំងមូល។

**៣.១.២- សារៈសំខាន់**

ក្រមសីលធម៌មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការបណ្ដុះបណ្ដាលនិងការអភិវឌ្ឍធនធានមនុស្សដូចខាងក្រោម៖

- ក្រមសីលធម៌ជាមូលដ្ឋាននៃការបង្កើតមនុស្សល្អមុននឹងក្លាយជាអ្នកជំនាញ។ ការបណ្ដុះបណ្ដាលដែលផ្ដោតតែចំណេះដឹងនិងជំនាញប៉ុន្តែខ្វះក្រមសីលធម៌អាចបង្កើត «អ្នកជំនាញគ្មានគុណធម៌»។ ដូច្នេះក្រមសីលធម៌ជាមូលដ្ឋានបណ្ដុះបណ្ដាលមនុស្សឱ្យមានទាំងសមត្ថភាពនិងគុណធម៌រួមគ្នា

- ក្រមសីលធម៌ជាឧបករណ៍ទប់ស្កាត់ការប្រើអំណាចខុសទិសដៅ។ ក្នុងវិជ្ជាជីវៈដែលមានអំណាច ឬមានឥទ្ធិពលលើសិទ្ធិរបស់អ្នកដទៃ ក្រមសីលធម៌មានតួនាទីទប់ស្កាត់ការប្រើអំណាចដោយអំពើបំពាន អំពើពុករលួយឬអំពើអយុត្តិធម៌។ វាជាខ្សែបន្ទាត់សុវត្ថិភាពផ្លូវគុណធម៌ដែលរំឭកឱ្យអ្នកបំពេញការងារដឹងថា អំណាចត្រូវប្រើដើម្បីបម្រើប្រយោជន៍សាធារណៈមិនមែនប្រយោជន៍ផ្ទាល់ខ្លួននោះទេ

- ក្រមសីលធម៌បង្កើតទំនុកចិត្តនិងសេចក្ដីគោរព ទំនុកចិត្តពីសង្គមមិនបានកើតឡើងដោយពាក្យសំដីនោះទេ ប៉ុន្តែកើតពីអាកប្បកិរិយាដែលមានស្ថិរភាពនិងសុចរិតភាព។ ការអនុវត្តក្រមសីលធម៌ជាប្រចាំធ្វើឱ្យសាធារណជនជឿជាក់ថា អង្គភាពស្ថាប័នឬបុគ្គលកំពុងបំពេញការងារពិតជាមានគោលការណ៍ត្រឹមត្រូវ មានភាពច្បាស់លាស់អាចជឿជាក់និងពឹងផ្អែកបាន

- ក្រមសីលធម៌ជាគ្រឹះនៃវិន័យខាងក្នុងដែលមិនមែនជាវិន័យកើតចេញពីការភ័យខ្លាចទណ្ឌកម្មដូចមានចែងជាវិន័យខាងក្រៅនោះទេ។ តែក្រមសីលធម៌បង្កើតវិន័យខាងក្នុងធ្វើឱ្យបុគ្គលគោរពច្បាប់និងបទបញ្ជាដោយសារតែការយល់ដឹងនិងជំនឿលើតម្លៃល្អមិនមែនដោយសារតែការបង្ខិតបង្ខំឡើយ

- ក្រមសីលធម៌ជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តត្រឹមត្រូវនៅពេលជួបស្ថានភាពស្មុគស្មាញ ដែលច្បាប់មិនអាចកំណត់បានលម្អិតក្រមសីលធម៌នឹងក្លាយជាគន្លងដឹកនាំលើការសម្រេចចិត្ត។ វាជួយឱ្យអ្នកបំពេញការងារសួរខ្លួនឯងថា៖ «ការសម្រេចចិត្តនេះត្រឹមត្រូវតាមសីលធម៌ដែរឬទេ ?»។

- ក្រមសីលធម៌ជាគ្រឹះនៃវប្បធម៌អង្គភាព មានក្រមសីលធម៌រឹងមាំនឹងបង្កើតវប្បធម៌ការងារដែលមានការគោរពគ្នា សាមគ្គីភាព និងភាពទទួលខុសត្រូវ។ វប្បធម៌នេះនឹងបន្តបណ្តុះមនុស្សជំនាន់ក្រោយឱ្យរក្សាគុណតម្លៃជានិច្ចនិរន្តរ៍ដោយមិនចាំបាច់បង្ខំ។

## ៣.២- មុខងារក្រមសីលធម៌និងភាពខុសគ្នាជាមួយនឹងច្បាប់

ដូចអ្វីដែលយើងបានដឹងរួចមកហើយថា «ក្រមសីលធម៌មិនមែនជាច្បាប់ទេ» អាស្រ័យដូចនេះ ដើម្បីមានការប្រៀបធៀបបានគប្បីត្រូវឈ្វេងយល់ពីមុខងាររបស់ក្រមសីលធម៌និងច្បាប់ជាមុនសិន តើវាងជាតុទាំងពីរនេះមានអត្ថន័យនិងខ្លឹមសារដូចម្តេចខ្លះ ?

### ៣.២.១- មុខងាររបស់ក្រមសីលធម៌

ក្រមសីលធម៌មានមុខងារតម្រង់ទិសអាកប្បកិរិយាផ្លូវគុណធម៌និងកំណត់ថា អ្វីគួរធ្វើនិងអ្វីមិនគួរធ្វើតាមគុណតម្លៃមនុស្សនិងវិជ្ជាជីវៈ ព្រមទាំងបានបង្កើតវិន័យខាងក្នុងធ្វើឱ្យបុគ្គលគ្រប់គ្រងខ្លួនឯងដោយស្មារតីនិងមនសិការមិនចាំបាច់រង់ចាំការបង្ខំពីអ្នកដទៃ។ មិនតែប៉ុណ្ណោះក្រមសីលធម៌ជាគ្រឹះនៃការសម្រេចចិត្តត្រឹមត្រូវ ហើយអាចបត់បែនបាននៅពេលជួបស្ថានភាពស្មុគស្មាញដែលច្បាប់មិនបានកំណត់លម្អិត។ បន្ថែមលើនេះក្រមសីលធម៌មានមុខងារជាមាគ៌ាក្នុងការដឹកនាំមនុស្សឱ្យប្រព្រឹត្តតែអំពើល្អ សុចរិត ទៀងត្រង់ ចៀសវាងការប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាងទាំងកាយ វាចា ចិត្ត និងលើកកម្ពស់សុចរិតភាព។ ម្យ៉ាងទៀតក្រមសីលធម៌តម្រូវឱ្យបុគ្គលមានភាពស្មោះត្រង់និងមានស្មារតីទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន បង្កើតបាននូវឥទ្ធិពល និងតម្លៃមានកិត្យានុភាពប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរជូនសង្គមជាតិ។

### ៣.២.២- មុខងាររបស់ច្បាប់

ដោយឡែកបើពិនិត្យមកលើច្បាប់វិញមានន័យថា ច្បាប់មានមុខងារផ្សេងពីក្រមសីលធម៌ ដោយមានលក្ខណៈផ្លូវការជាងនៅក្នុងការងារគ្រប់គ្រងសង្គមដោយអំណាចរបស់រដ្ឋ។ មានការលើកឡើងថាច្បាប់ជាបទប្បញ្ញត្តិដែលកំណត់ដោយស្ថាប័ននីតិប្បញ្ញត្តិមានអានុភាពជាទូទៅនិងជាអចិន្រ្តៃយ៍ ដែលតម្រូវឱ្យអង្គភាពឬស្ថាប័នមានសមត្ថកិច្ចនិងប្រជាពលរដ្ឋគ្រប់រូបប្រតិបត្តិតាមដោយការទទួលខុសត្រូវដើម្បីធ្វើការគ្រប់គ្រងសណ្តាប់ធ្នាប់រស់នៅក្នុងសង្គមឱ្យមានរបៀបរៀបរយ។ អាចនិយាយមួយបែបទៀតថា ច្បាប់ជានិយាមឬជាកាតព្វកិច្ចចាំបាច់បំផុតរបស់មនុស្សក្នុងការការពារសិទ្ធិនិងសេរីភាពដែលធម្មជាតិបានសម្រិតសម្រាំងឡើងដើម្បីកែលម្អជីវភាពរស់នៅរបស់មនុស្សនិងសម្រួលកិច្ចការនានាក្នុងសង្គមប្រឆាំងនឹងអំពើឧក្រិដ្ឋនានា។

**ច្បាប់មានមុខងារសំខាន់ដូចខាងក្រោម៖**

- ធ្វើឱ្យមានសណ្តាប់ធ្នាប់សង្គម ចៀសវាងជម្លោះនិងដោះស្រាយបញ្ហាដោយសន្តិវិធី
- ធ្វើឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងមនុស្សនិងមនុស្ស
- កំណត់ព្រំដែនអំណាចនិងការប្រព្រឹត្តរបស់អ្នកដឹកនាំដើម្បីសម្រួលឱ្យមានតម្លៃសីលធម៌

- តម្រង់ទិសអ្នកដឹកនាំ ការពារសេរីភាពបុគ្គល អ្នកទន់ខ្សោយ និងលើកស្ទួយយុត្តិធម៌សង្គម
- អនុវត្តស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប មិនរើសអើង និងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ
- កំណត់សិទ្ធិ ភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ពលរដ្ឋក្នុងសង្គម
- ជាមូលដ្ឋានគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការវិនិយោគ និងសុខុមាលភាព
- ការពារសិទ្ធិសេរីភាពរបស់មនុស្សក្នុងសង្គមនិងផលប្រយោជន៍សង្គម។

### ៣.២.៣- ទំនាក់ទំនងរវាងក្រមសីលធម៌និងច្បាប់

ក្រមសីលធម៌ផ្អែកលើមនសិការ សីលធម៌សង្គម ប្រពៃណី និងវប្បធម៌ ជាមាគ៌ាតម្រង់ទិសទៅរកផ្លូវគុណធម៌ សច្ចធម៌ នៃឥរិយាបថនិងអាកប្បកិរិយាល្អរបស់មនុស្សក្នុងសង្គមដែលជាប្រព័ន្ធគុណតម្លៃ គោលការណ៍និងបទប្បញ្ញត្តិផ្លូវចិត្ត ជួយណែនាំឱ្យមនុស្សប្រព្រឹត្តអំពើល្អចៀសវាងអំពើអាក្រក់និងរស់នៅក្នុងសង្គមដោយគោរពសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ។ ដោយឡែកចំពោះច្បាប់វិញគឺជាបទប្បញ្ញត្តិដែលរដ្ឋកំណត់និងអនុវត្តដោយអំណាចផ្លូវការដើម្បីគ្រប់គ្រងសង្គម ការពារសិទ្ធិ និងសុវត្ថិភាពសាធារណៈ ហើយមានទណ្ឌកម្មច្បាស់លាស់ចំពោះការរំលោភបំពាន។ ជាដែនកំណត់អប្បបរមានៃសកម្មភាពរបស់មនុស្សដែលសង្គមមិនអនុញ្ញាតឱ្យប្រព្រឹត្តនូវអ្វីដែលបំពានលើច្បាប់បានកំណត់។

ក្រមសីលធម៌និងច្បាប់មានទំនាក់ទំនងជិតស្និទ្ធមិនអាចបំបែកចេញពីគ្នាបានទេ។ មានន័យថា ក្រមសីលធម៌ផ្តល់គុណតម្លៃនិងទិសដៅ ខណៈដែលច្បាប់ផ្តល់អំណាចនិងការអនុវត្តជាក់ស្តែង។ ទំនាក់ទំនងនេះជាគ្រឹះសំខាន់សម្រាប់ការគ្រប់គ្រងសង្គមដោយយុត្តិធម៌ សន្តិភាព និងមនុស្សធម៌។ ច្បាប់កើតចេញពីគុណតម្លៃសីលធម៌របស់សង្គមដូចជាគោលការណ៍យុត្តិធម៌ ការគោរពសិទ្ធិមនុស្ស ការហាមឃាត់អំពើហិង្សានិងអំពើអយុត្តិធម៌ដោយបានប្រែក្លាយក្រមសីលធម៌ឱ្យមានអំណាចផ្លូវការដើម្បីអនុវត្តជាក់ស្តែង។

### ៣.២.៤- តារាងប្រៀបធៀបរវាងក្រមសីលធម៌និងច្បាប់

| ល.រ. | ចំណុចប្រៀបធៀប | ក្រមសីលធម៌ | ច្បាប់ |
|---|---|---|---|
| ១ | **ប្រភព** | - គុណតម្លៃ សីលធម៌ វប្បធម៌<br>- លក្ខណៈស្មគ្រចិត្ត ផ្លូវចិត្ត | - រដ្ឋ រដ្ឋសភា ឬអាជ្ញាធរ<br>- បង្ខិតបង្ខំ ផ្លូវច្បាប់ |
| ២ | **វិសាលភាព** | - ទូលំទូលាយ គ្រប់គ្រងជីវិត<br>- កំហឹង កិត្តិយស និងសីលធម៌ | - កំណត់ជាក់លាក់ទណ្ឌកម្ម<br>- ពិន័យ ឃុំឃាំង ទោស |
| ៣ | **វិន័យ** | - អាកប្បកិរិយាខាងក្នុង | - សកម្មភាពជាក់ស្តែងខាងក្រៅ |
| ៤ | **គោលដៅ** | - មានមនុស្សល្អ | - សង្គមមានសណ្តាប់ធ្នាប់ |
| ៥ | **ការអនុវត្ត** | - អាស្រ័យលើឆន្ទៈមនសិការ | - អានុភាពចាប់បង្ខំដោយរដ្ឋ |

ផ្អែកលើតារាងប្រៀបធៀបរវាងក្រមសីលធម៌និងច្បាប់ខាងលើ បានបង្ហាញអំពីការបំពេញបន្ថែមគ្នាទៅវិញទៅមកមិនអាចខ្វះបាន។ មានន័យថាក្រមសីលធម៌គ្មានទណ្ឌកម្មផ្លូវច្បាប់ ប៉ុន្តែច្បាប់ជួយធានាឱ្យគុណតម្លៃសីលធម៌ត្រូវបានគោរពដោយប្រើគ្រប់វិធានការដើម្បីទប់ស្កាត់អំពើអសីលធម៌ធ្ងន់ធ្ងរ

ក្នុងសង្គម «ក្រមសីលធម៌បង្កើតមនសិការ» ឱ្យមនុស្សគោរពច្បាប់ដោយស្មគ្រចិត្ត» រីឯ «ច្បាប់វិញបង្កើតវិន័យសង្គម» ដើម្បីគ្រប់គ្រងអាកប្បកិរិយាឬសកម្មភាពរបស់មនុស្សដែលក្រមសីលធម៌មិនអាចគ្រប់គ្រងបាន។ ទំនាក់ទំនងនេះធ្វើឱ្យច្បាប់មានលក្ខណៈមនុស្សធម៌ យុត្តិធម៌ និងឆ្លុះបញ្ចាំងអំពីតម្លៃសង្គមពិតប្រាកដ។

នៅពេលច្បាប់ស្របតាមក្រមសីលធម៌ មនុស្សមានទំនោរគោរពច្បាប់ដោយស្មគ្រចិត្តមិនមែនដោយសារតែខ្លាចទណ្ឌកម្មនោះទេ។ ការរួមបញ្ចូលគ្នារវាងក្រមសីលធម៌និងច្បាប់ ជួយកាត់បន្ថយជម្លោះបង្កើតការរស់នៅរួមដោយសន្តិភាពនិងទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ក្នុងសង្គម។

### ៣.៣- ការកសាងមុខងារក្រមសីលធម៌

មុខងារក្រមសីលធម៌មិនអាចកើតឡើងដោយស្វ័យប្រវត្តិទេ ប៉ុន្តែកើតពីការកសាងជាប្រព័ន្ធដោយការបញ្ចូលគ្នារវាងគោលការណ៍នៃចំណេះដឹង ការអប់រំល្អ គំរូល្អ ការអនុវត្តពិតប្រាកដ ការត្រួតពិនិត្យជាក់ស្តែង និងវប្បធម៌អង្គភាព។ ការកសាងមុខងារក្រមសីលធម៌តាមរយៈការកំណត់នូវគោលការណ៍ច្បាស់លាស់គឺជាការរៀបចំក្រមសីលធម៌ជាឯកសារផ្លូវការមានភាសាច្បាស់លាស់ ងាយយល់ កំណត់តម្លៃស្នូលពិតដូចជាសុចរិតភាព យុត្តិធម៌ ទំនួលខុសត្រូវ មនុស្សធម៌ដែលបានបញ្ជាក់ពីអាកប្បកិរិយា «គួរធ្វើ» និង «មិនគួរធ្វើ» ក្នុងវិជ្ជាជីវៈ។ បើគ្មានគោលការណ៍ច្បាស់លាស់ទេ ក្រមសីលធម៌នឹងនៅត្រឹមតែជាពាក្យសំដីដោយមិនអាចក្លាយជាមុខងារបានទេ។

ខាងក្រោមនេះជាការអធិប្បាយជាលំដាប់ជំហានៗតាមទ្រឹស្តីអនុវត្តអំពីរបៀបកសាងនិងពង្រឹងមុខងារក្រមសីលធម៌ដែលអាចយកទៅប្រើជាមូលដ្ឋានក្នុងការបំពេញការងារប្រចាំថ្ងៃ៖

**១- កសាងតាមរយៈការអប់រំនិងបណ្តុះបណ្តាលជាប្រព័ន្ធ** បញ្ចូលមេរៀនក្រមសីលធម៌ក្នុងកម្មវិធីបណ្តុះបណ្តាលគ្រប់កម្រិត។ រីឯការបង្រៀនមិនត្រឹមតែអត្ថន័យទេ ប៉ុន្តែបង្រៀនការគិតតាមគុណធម៌ត្រូវប្រើករណីសិក្សា ការពិភាក្សាជាក្រុមបង្កើតសំណួរសីលធម៌អប់រំល្អធ្វើឱ្យក្រមសីលធម៌ចូលទៅក្នុង «ការគិត» មុនចូលទៅក្នុង «សកម្មភាព» ក្នុងវិជ្ជាជីវៈណាមួយ។

**២- កសាងតាមរយៈគំរូល្អពីអ្នកដឹកនាំ** សកម្មភាពនិងអាកប្បកិរិយារបស់អ្នកដឹកនាំជាគំរូនៃក្រមសីលធម៌ដែលជះឥទ្ធិពលដល់អ្នកដទៃ។ ដូចនេះមុននឹងបញ្ជាប្រតិបត្តិការអ្វីមួយត្រូវមានភាពស្មោះត្រង់ យុត្តិធម៌និងស្របតាមក្រមសីលធម៌ «និយាយដូចម្តេចធ្វើដូច្នោះ» បើមិនដូច្នោះទេអ្នកដឹកនាំនឹងមិនអាចគ្រប់គ្រងអំណាចរបស់ខ្លួនបានស្ថិតស្ថិរយូរអង្វែងនោះទេ។

**៣- កសាងតាមរយៈការអនុវត្តជាក់ស្តែងនិងការត្រួតពិនិត្យ** ការបង្កើតឱ្យមានយន្តការត្រួតពិនិត្យវាយតម្លៃអាកប្បកិរិយាការងារប្រចាំថ្ងៃ តាមរយៈក្រមសីលធម៌ជាមូលដ្ឋានក្នុងការវាយតម្លៃសមត្ថភាពនិងវិន័យដើម្បីកេឱ្យឃើញថាក្រមសីលធម៌ត្រូវតែ «ប្រើ» មិនមែនត្រឹមតែ «ព្យួរ» លើជញ្ជាំងនោះទេ។

**៤- កសាងតាមរយៈរង្វាន់និងការទទួលខុសត្រូវ** ការលើកទឹកចិត្តនិងផ្តល់រង្វាន់ដល់អ្នកអនុវត្តការងារល្អនិងការដាក់វិធានការទៅលើអ្នករំលោភបំពានបទវិន័យរបស់ស្ថាប័នឬអង្គភាព «មិនមែនជាទោសទណ្ឌដែលត្រូវតែចាប់កំហុសជានិច្ចនិរន្តរ៍នោះឡើយ» ការពិចារណាថ្លឹងថ្លែងដោយមានលក្ខណៈវិនិច្ឆ័យត្រឹមត្រូវ ជានាភាពយុត្តិធម៌ មិនរើសអើង និងមានការទទួលខុសត្រូវក្នុងការបង្កើតបាននូវមុខងារក្រមសីលធម៌។

**៥- កសាងតាមរយៈវប្បធម៌អង្គភាព** បង្កើតបរិយាកាសការងារដែលធ្វើឱ្យមានការគោរពនិងការអធ្យាស្រ័យគ្នាទៅវិញទៅមក ជាគុណធម៌ធ្វើឱ្យក្រមសីលធម៌ក្លាយជា «របៀបនៃទំនាក់ទំនងការងារល្អ» ដែលបានផ្តល់នូវតម្លៃអង្គភាពឬស្ថាប័នរបស់អ្នកដឹកនាំពីមួយជំនាន់ទៅមួយជំនាន់។ ពេលនោះហើយដែលក្រមសីលធម៌ក្លាយជាវប្បធម៌ដំណើរការដោយស្វ័យប្រវត្តិ។

សរុបសេចក្តីមក មុខងារក្រមសីលធម៌ មិនអាចកើតពីការបង្ខំដូចមុខងារច្បាប់បានទេ ប៉ុន្តែកើតចេញពីការបណ្តុះបណ្តាលនិងការអនុវត្តជាបន្តបន្ទាប់រហូតក្លាយជាមនសិការនិងវប្បធម៌អង្គភាព។

### ៣.៤- ការអនុវត្តមុខងារក្រមសីលធម៌

ការអនុវត្តមុខងារក្រមសីលធម៌ សំដៅដល់ដំណើរការរយៈពេលវែងដែលតម្រូវឱ្យមានការចូលរួមអនុវត្តពីគ្រប់សមាសភាពនិងគ្រប់កម្រិតដែលមិនមែនត្រឹមតែការប្រកាសជូនដំណឹងនោះទេ។ នៅពេលដែលមនុស្សគ្រប់ៗគ្នាអនុវត្តបានល្អ ក្រមសីលធម៌នឹងក្លាយជាវិន័យខាងក្នុងនៃវប្បធម៌អង្គភាពនិងជាមូលដ្ឋានទំនុកចិត្តរបស់សង្គមនិងអ្នកដឹកនាំអង្គភាពឬស្ថាប័ន។

ជាទូទៅតាមការចាំបាច់គេតែងតែប្រើប្រាស់បញ្ចូលមុខងារក្រមសីលធម៌ក្នុងប្រព័ន្ធការងារជាក់ស្តែងក្នុងការរៀបចំកសាងបទបញ្ញានិងនីតិវិធីដោយភ្ជាប់ក្រមសីលធម៌ជាមួយបទបញ្ញាតាមនីតិវិធីប្រតិបត្តិ (SOP) ដោយកំណត់ក្នុងស្ថានភាពណាមួយដែលត្រូវយោងទៅលើក្រមសីលធម៌ឱ្យក្លាយទៅជា «លក្ខខណ្ឌក្នុងការត្រួតពិនិត្យមុននឹងធ្វើការសម្រេចចិត្តអ្វីមួយ»។

ដោយឡែកក្នុងក្របខណ្ឌវិជ្ជាជីវៈនៃវិស័យការងារមុខងារសាធារណៈរបស់រដ្ឋនៃបណ្តាអង្គភាពឬស្ថាប័នគេតែងតែប្រែក្លាយមុខងារក្រមសីលធម៌ទៅជាឯកសារគតិយុត្តក្នុងការណែនាំតម្រង់ទិសឱ្យរូបវន្តបុគ្គលនីតិបុគ្គលជាមន្ត្រីរាជការចំណុះស្ថាប័ន អនុវត្តតាមដោយការទទួលខុសត្រូវ មានប្រសិទ្ធភាពតាមអត្ថន័យខ្លឹមសារដែលបានចែងតាមវិជ្ជាជីវៈនីមួយៗ។ ឧទាហរណ៍ដូចជាក្រមសីលធម៌វិជ្ជាជីវៈដែលមានចែងក្នុងបទវិន័យមន្ត្រីនគរបាលជាតិរបស់ក្រសួងមហាផ្ទៃ ក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់របស់ស្ថាប័នអន្តរជាតិ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ក្រមសីលធម៌គ្រូពេទ្យ ក្រមសីលធម៌គណមេធាវីនិងបទវិន័យមន្ត្រីអនុរក្សពន្ធនាគារជាដើម។

### ៣.៥- អន្តរកម្មនិងភាពផ្សេងគ្នារវាងអភិសមាចារនិងក្រមសីលធម៌

#### ៣.៥.១- អន្តរកម្មនិងអត្ថប្រយោជន៍

អភិសមាចារនិងក្រមសីលធម៌គឺជាគោលគំនិតសំខាន់ដែលមានតួនាទីជាមូលដ្ឋានគ្រឹះក្នុងការបណ្តុះបណ្តាលអាកប្បកិរិយានិងការរស់នៅរួមក្នុងសង្គមមនុស្ស។ ទោះបីមានវិសាលភាពនិងវិធីអនុវត្តខុសគ្នា ក៏ធាតុទាំងពីរនេះមិនអាចបំបែកចេញពីគ្នាបានឡើយព្រោះវាបំពេញបន្ថែមនិងគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្កើតមនុស្សឱ្យមានគុណភាពនិងសង្គមមានសុចរិតភាព។

ក្នុងន័យនេះអត្ថប្រយោជន៍ដែលបានពីទំនាក់ទំនងគ្នារវាងអភិសមាចារនិងក្រមសីលធម៌ជាគ្រឹះសម្រាប់ការរស់នៅរួមដោយសន្តិភាព យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ។ អន្តរកម្មនេះបានធ្វើឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលមានវិជ្ជាជីវៈនិងសង្គមទាំងមូលទទួលបានជាប្រយោជន៍សំខាន់ៗដូចខាងក្រោម៖

- បង្កើតបុគ្គលមានគុណភាពនិងសុចរិតភាពជួយបណ្តុះមនុស្សឱ្យមានទាំងអាកប្បកិរិយាល្អខាងក្រៅនិងមនសិការល្អខាងក្នុង បង្កើតជាបុគ្គលដែលមានភាពគួរឱ្យទុកចិត្តនិងសេចក្តីគោរព

- លើកកម្ពស់សន្តិភាពនិងការរស់នៅរួមដោយសមធម៌នៅពេលសង្គមមានអភិសមាចារល្អនិងគោរពក្រមសីលធម៌ ជម្លោះនឹងត្រូវបានកាត់បន្ថយនិងការប្រាស្រ័យទាក់ទងមានភាពទន់ភ្លន់ថ្លៃថ្នូរ ព្រមទាំងបង្កើតបរិយាកាសសន្តិភាពក្នុងសង្គម

- ការពង្រឹងវិន័យនិងការគោរពច្បាប់ មនុស្សដែលមានសីលធម៌និងអភិសមាចារល្អនឹងគោរពច្បាប់ដោយស្មគ្រចិត្តមិនចាំបាច់ត្រូវបង្ខំដោយទណ្ឌកម្មនោះទេ នេះជាគ្រឹះសំខាន់សម្រាប់សង្គមនីតិរដ្ឋ

- លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈក្នុងអង្គភាពឬស្ថាប័ននៃវិស័យការងារដូចជាការងារនគរបាល ការងារអប់រំ ការងារគ្រប់គ្រងរដ្ឋបាល ការងារសុខាភិបាល។ល។ បង្កើតបាននូវភាពជឿជាក់របស់សាធារណជន បង្កើតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អង្គភាពឬស្ថាប័ន

- ជាគ្រឹះសម្រាប់ការអភិវឌ្ឍសង្គមប្រកបដោយចីរភាពដែលផ្អែកលើអភិសមាចារនិងក្រមសីលធម៌មិនត្រឹមតែរីកចម្រើនផ្នែកសេដ្ឋកិច្ចតែប៉ុណ្ណោះទេ ប៉ុន្តែបានបង្កើននូវភាពរីកចម្រើនផ្នែកមនុស្សធម៌ វប្បធម៌ និងស្មារតីជាតិនិយមផងដែរ។

### ៣.៤.២- ភាពផ្សេងគ្នារវាងអភិសមាចារនិងក្រមសីលធម៌

ដូចអ្វីដែលបានជ្រាបពីខាងដើមរួចមកហើយថា «អភិសមាចារ» ជាវិទ្យាសាស្ត្រនៃអំពើល្អខ្ពស់បំផុតដែលពិចារណាអំពីករណីយកិច្ចរបស់មនុស្សនិងបានសិក្សាអំពី «អ្វីដែលត្រូវនិងអ្វីដែលខុស» និង «អ្វីដែលល្អនិងអ្វីដែលអាក្រក់» នៅក្នុងអាកប្បកិរិយារបស់មនុស្សផ្អែកតាមវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីជាតិ។ ផ្ទុយទៅវិញ **ក្រមសីលធម៌** ជាមូលដ្ឋានចិត្តសាស្ត្រក្នុងការរៀបចំបទដ្ឋានអាកប្បកិរិយាដែលកំណត់ទិសដៅឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលប្រតិបត្តិខ្លួនបានត្រឹមត្រូវ មានភាពសុចរិត តម្លាភាព ទំនួលខុសត្រូវ គោរពសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងការបំពេញភារកិច្ចដោយវិជ្ជាជីវៈរបស់ពួកគេ។ ក្រមសីលធម៌មានលក្ខណៈទូលំទូលាយជាគ្រឹះនៃការវិនិច្ឆ័យសកម្មភាពមនុស្សនិងជាមូលដ្ឋានសម្រាប់កំណត់ច្បាប់និងបទប្បញ្ញត្តិផ្សេងៗក្នុងសង្គម។

ក្នុងន័យនេះទោះបីអភិសមាចារនិងក្រមសីលធម៌មានគោលបំណងរួមគ្នាក្នុងការនាំឱ្យមនុស្សរស់នៅរួមដោយសន្តិភាពនិងគោរពគ្នាទៅវិញទៅមកក៏ដោយ ប៉ុន្តែទាំងពីរនេះមានភាពខុសគ្នាទាំងផ្នែកអត្ថន័យវិសាលភាពនិងតួនាទី។ ការយល់ដឹងច្បាស់អំពីភាពផ្សេងគ្នានេះជួយឱ្យបុគ្គលអាចអនុវត្តអាកប្បកិរិយាដោយសមរម្យ មានសុចរិតភាព និងសមស្របនឹងតម្លៃសង្គមនាសម័យទំនើប។

## ៤- ក្រមសីលធម៌វិជ្ជាជីវៈ

### ៤.១- និយមន័យ

ក្រមសីលធម៌វិជ្ជាជីវៈសំដៅដល់សេចក្តីណែនាំសំខាន់សម្រាប់មនុស្សគ្រប់រូបដែលបំពេញភារកិច្ចក្នុងវិស័យការងារណាមួយ ដើម្បីធានាថាការងារនោះមានសុចរិតភាព កិត្តិយស និងអាចទទួលបានការគោរពពីសង្គម។ វាជាមាគ៌ាណែនាំឱ្យអ្នកមានវិជ្ជាជីវៈដើរតាមមធ្យោបាយត្រឹមត្រូវមានសីលធម៌និងការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចទាំងក្នុងជីវិតការងារនិងជីវិតប្រចាំថ្ងៃ។ ការអនុវត្តតាមក្រមសីលធម៌ជួយឱ្យការអនុវត្តវិជ្ជាជីវៈមានសុចរិតភាពនិងបង្កើតភាពជឿជាក់របស់សាធារណជនក្នុងសង្គម។

## ៤.២- គុណសម្បត្តិនៃក្រមសីលធម៌វិជ្ជាជីវៈ

ក្រមសីលធម៌វិជ្ជាជីវៈមិនត្រឹមតែមានប្រយោជន៍ដល់បុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវគុណសម្បត្តិធំធេងដល់សង្គមនិងអង្គភាពរដ្ឋជាច្រើនផងដែរ។ ខាងក្រោមនេះជាការបង្ហាញលម្អិតតាមមាត្រដ្ឋានសំខាន់ៗនៃការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈយ៉ាងខ្ជាប់ខ្ជួនរបស់មន្ត្រីបំពេញការងារសម្រាប់ទំនុកចិត្តសង្គម ប្រសិទ្ធភាពរដ្ឋបាល កិត្តិយសស្ថាប័ន និងការអភិវឌ្ឍជាតិយូរអង្វែង។

### ៤.២.១- គុណសម្បត្តិចំពោះសង្គម

ក្រមសីលធម៌វិជ្ជាជីវៈបានផ្តល់នូវគុណសម្បត្តិជាច្រើនចំពោះសង្គមដូចជា៖

- ធ្វើឱ្យប្រជាពលរដ្ឋមានជំនឿ ផ្តល់ទំនុកចិត្តមកលើរាជរដ្ឋាភិបាល និងគាំទ្រដល់ការបម្រើសេវារបស់ស្ថាប័នសាធារណៈនានា កាត់បន្ថយការរិះគន់ ភាពមន្ទិលសង្ស័យ និងសកម្មភាពតវ៉ាប្រឆាំង ព្រមទាំងបង្កើតបាននូវទំនាក់ទំនងល្អរវាងរដ្ឋនិងប្រជាពលរដ្ឋ ជួយលើកស្ទួយប្រព័ន្ធយុត្តិធម៌សង្គម ពង្រឹងនីតិរដ្ឋ និងលុបបំបាត់អំពើពុករលួយ ព្រមទាំងអំពើអយុត្តិធម៌នានាក្នុងសង្គម

- គុណសម្បត្តិចំពោះប្រព័ន្ធរដ្ឋបាលសាធារណៈរបស់ជាតិ លើកកម្ពស់ការគ្រប់គ្រងអភិបាលកិច្ចតម្លាភាព ការចូលរួម ការទទួលខុសត្រូវ គណនេយ្យភាព ការឆ្លើយតប និងគាំទ្រការកែទម្រង់រដ្ឋបាលគាំទ្រការអភិវឌ្ឍជាតិយូរអង្វែង ធានាការប្រើប្រាស់ធនធានរដ្ឋមានប្រសិទ្ធភាព បង្កើតបរិយាកាសលើការងារវិនិយោគដើម្បីបង្កើនកំណើនសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពសង្គម ព្រមទាំងបង្កភាពស្អាតស្អំនៃរដ្ឋបាលរបស់ជាតិដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃភាពធន់របស់ស្ថាប័នជាតិក្នុងការពង្រឹងខឿនសេដ្ឋកិច្ច ការអភិវឌ្ឍមូលធនមនុស្ស និងការលើកកម្ពស់យុត្តិធម៌សង្គម

- គុណសម្បត្តិជាគំរូនិងវប្បធម៌សង្គមសម្រាប់មន្ត្រីបន្តវេន បណ្តុះវប្បធម៌សុចរិតនិងការទទួលខុសត្រូវខ្ពស់ក្នុងការជំរុញលើកកម្ពស់សេវាសាធារណៈ បង្កើតវិន័យនិងសេចក្តីថ្លៃថ្នូរ គោរពតម្លៃសុចរិត-ភាព មានអាកប្បកិរិយារីជួមានប្រកបដោយក្រមសីលធម៌សង្គមក្នុងវិជ្ជាជីវៈ ព្រមទាំងលើកកម្ពស់វប្បធម៌គោរពច្បាប់សង្គម មានសន្តិភាព សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម កាត់បន្ថយជម្លោះរវាងរដ្ឋជាមួយនឹងប្រជាពលរដ្ឋ និងបង្កើតនូវបរិស្ថានល្អគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមយូរអង្វែង។

### ៤.២.២- គុណសម្បត្តិចំពោះអង្គភាពឬស្ថាប័ន

ក្រមសីលធម៌វិជ្ជាជីវៈ លើកកម្ពស់កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងសង្គម និងបង្កើតភាពជឿទុកចិត្តមកលើអង្គភាពឬស្ថាប័ន តាមរយៈភាពគួរឱ្យគោរពពីប្រជាជន មហាជន។ ជាអង្គភាពឬស្ថាប័នគំរូក្នុងការពង្រឹងអត្តសញ្ញាណនិងកេរ្តិ៍ឈ្មោះ បង្កើនប្រសិទ្ធភាព និងគុណភាពការងារ។

បន្ថែមលើនេះ ក្រមសីលធម៌វិជ្ជាជីវៈធ្វើឱ្យអង្គភាពឬស្ថាប័នដំណើរការដោយតម្លាភាពនិងមានវិន័យច្បាស់លាស់ មានការសម្របសម្រួល និងសហការល្អពីដៃគូអភិវឌ្ឍន៍ ព្រមទាំងកាត់បន្ថយកំហុសឆ្គង ភាពរអាក់រអួលក្នុងការងារ កាត់បន្ថយហានិភ័យផ្នែកច្បាប់ និងការអនុវត្តវិន័យ ព្រមទាំងពង្រឹងភាពរឹងមាំរបស់អង្គភាពឬស្ថាប័ន។

### ៤.៣- គោលការណ៍នៃក្រមសីលធម៌វិជ្ជាជីវៈ

ក្រមសីលធម៌វិជ្ជាជីវៈមានគោលការណ៍គ្រឹះសំខាន់ៗដូចខាងក្រោម៖

**១- គោលការណ៍សុចរិតភាព** សុចរិតភាពជាគុណសម្បត្តិសំខាន់បំផុតសម្រាប់អ្នកមានវិជ្ជាជីវៈ។ មនុស្សដែលមានសុចរិតភាពតែងតែប្រព្រឹត្តដោយស្មោះត្រង់ មិនបោកប្រាស់ ឬប្រើប្រាស់តួនាទីដើម្បីរកអត្ថប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ សុចរិតភាពជាគន្លងឱ្យអ្នកមានវិជ្ជាជីវៈទទួលបានកិត្តិយសនិងភាពជឿជាក់ពីអតិថិជនឬសាធារណជន។

**២- គោលការណ៍ទំនួលខុសត្រូវ** អ្នកមានវិជ្ជាជីវៈត្រូវមានទំនួលខុសត្រូវចំពោះសកម្មភាពនិងសេចក្តីសម្រេចរបស់ខ្លួនដោយត្រូវបំពេញភារកិច្ចដោយប្រុងប្រយ័ត្ន។ ក្នុងនោះត្រូវប្រុងប្រយ័ត្នលើផលប៉ះពាល់ដល់អ្នកដទៃនិងតែងតែធ្វើអ្វីៗដោយគោរពតាមច្បាប់និងបទបញ្ញាផ្សេងៗ។

**៣- គោលការណ៍គោរពច្បាប់និងបទបញ្ញា** ការគោរពច្បាប់ជាគ្រឹះនៃការរស់នៅក្នុងសង្គមស៊ីវិល អ្នកមានវិជ្ជាជីវៈត្រូវប្រព្រឹត្តតាមច្បាប់ បទបញ្ញានិងសេចក្តីណែនាំរបស់អង្គភាពដឹកនាំដើម្បីធានាថាការងារដែលអនុវត្តមានសុពលភាពនិងត្រឹមត្រូវតាមស្តង់ដា។

**៤- គោលការណ៍គោរពសិទ្ធិនិងឯករាជ្យភាពមនុស្ស** មនុស្សគ្រប់រូបមានសិទ្ធិនិងឯករាជ្យភាពដូចគ្នា អ្នកមានវិជ្ជាជីវៈត្រូវគោរពសិទ្ធិមនុស្សនិងអធិបតេយ្យភាពរបស់អ្នកដទៃ មិនប្រកាន់ពូជសាសន៍ភេទ ជំនឿ ឬស្ថានភាពសង្គមឡើយ។ វាជាមាគ៌ាដ៏សំខាន់ក្នុងការរក្សាសមភាពនិងសន្តិភាពនៅកន្លែងបំពេញការងារ។

**៥- គោលការណ៍យុត្តិធម៌** យុត្តិធម៌ជាប្រព័ន្ធផ្តល់ភាពត្រឹមត្រូវ ធ្វើឱ្យការងារមានភាពច្បាស់លាស់ដល់អ្នកមានវិជ្ជាជីវៈដែលត្រូវប្រព្រឹត្តដោយភាពមិនលម្អៀងឬប្រើអំណាចដោយយុត្តិធម៌បំផុត។ គោលការណ៍នេះជួយឱ្យសង្គមមានការជឿជាក់លើស្ថាប័ននិងវិជ្ជាជីវៈនោះ។

**៦- គោលការណ៍រក្សាការសម្ងាត់** ក្នុងការបំពេញភារកិច្ច អ្នកមានវិជ្ជាជីវៈជាច្រើនតែងតែទទួលបានព័ត៌មានសម្ងាត់ដែលទាក់ទងនឹងអតិថិជនឬអង្គភាព។ ការរក្សាការសម្ងាត់ជាកិច្ចការសំខាន់ដើម្បីបង្កើតការជឿជាក់និងការគោរពជាបុគ្គលិកមានវិជ្ជាជីវៈពិតប្រាកដ។

**៧- គោលការណ៍ជំនាញវិជ្ជាជីវៈ** អ្នកមានវិជ្ជាជីវៈត្រូវរក្សានិងអភិវឌ្ឍជំនាញរបស់ខ្លួនជានិច្ចដោយការសិក្សាបណ្តុះបណ្តាលនិងអនុវត្តឱ្យទាន់សម័យ។ ជំនាញល្អជួយឱ្យការងារមានប្រសិទ្ធភាពនិងអាចបំពេញតាមតម្រូវការរបស់សង្គម។

**៨- គោលការណ៍សេវាកម្មសាធារណៈ** អ្នកមានវិជ្ជាជីវៈមិនត្រូវធ្វើការដើម្បីអត្ថប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តោតលើប្រយោជន៍សាធារណៈនិងការរីកចម្រើនរបស់សង្គមទាំងមូល។

ការបំពេញការងារដោយចិត្តស្មោះត្រង់និងអនុវត្តតាមគោលការណ៍សីលធម៌នាំឱ្យសមត្ថភាពវិជ្ជាជីវៈមានតម្លៃនិងអភិវឌ្ឍបានយូរអង្វែង។

## ៤.៤- តារាងប្រៀបធៀបរវាងអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈ

| ល.រ. | ចំណុចប្រៀបធៀប | អភិសមាចារ | ក្រមសីលធម៌វិជ្ជាជីវៈ |
|---|---|---|---|
| ១ | និយមន័យ | សីលធម៌ខ្ពស់កើតចេញពីចិត្តនិងចរិតល្អផ្ទាល់ខ្លួន | បទប្បញ្ញត្តិឬស្តង់ដាដែលអង្គភាពកំណត់ដើម្បីដឹកនាំអនុវត្ត |
| ២ | គោលបំណង | បណ្តុះស្មារតីនិងភាពស្មោះត្រង់ | ជានាឱ្យមានស្តង់ដាពិសេសក្នុងវិស័យការងារ |
| ៣ | លក្ខណៈ | មិនសរសេរជាច្បាប់តែជាអារម្មណ៍សីលធម៌ខាងក្នុង | សរសេរជាឯកសារផ្លូវការ ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិរបស់អង្គភាព |
| ៤ | កម្រិតអនុវត្ត | ផ្ទាល់ខ្លួននិងស្មារតីវិជ្ជាជីវៈ | ផ្លូវការតាមអង្គភាពឬស្ថាប័ន |
| ៥ | ការអនុវត្ត | តាមចរិតលក្ខណៈនិងឆន្ទៈមនសិការ | តាមបទប្បញ្ញត្តិនិងក្រមសីលធម៌របស់អង្គភាព |
| ៦ | ឧទាហរណ៍ | មន្ត្រីបំពេញការងារដោយស្មោះត្រង់ទោះគ្មានអ្នកសង្កេត | មន្ត្រីអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈរបស់នគរបាល |



សីលធម៌នៃការគោរពប្រតិបត្តិចំពោះឪពុកម្តាយ




ក្រមសីលធម៌នៃការគោរពប្រតិបត្តិចំពោះថ្នាក់ដឹកនាំ





# ផ្នែកទី៣
# មូលដ្ឋានគ្រឹះនៃអភិសមាចារនិងក្រមសីលធម៌មន្ត្រីនគរបាល

## ១- មូលដ្ឋានគ្រឹះនៃអភិសមាចារមន្ត្រីនគរបាល

### ១.១- មនសិការវិជ្ជាជីវៈ

#### ១.១.១- ឆន្ទៈបំពេញការងារ

ឆន្ទៈម្ចាស់ការគឺជាដំណើរការមួយដែលជំរុញ តម្រង់ទិស និងថែរក្សានូវឥរិយាបថមនុស្សទៅក្នុងទិសនៃការសម្រេចគោលបំណងណាមួយ។ កត្តាសំខាន់ដែលនាំឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលឬអង្គភាពមួយទទួលជោគជ័យគឺកត្តាឆន្ទៈបម្រើការងាររបស់បុគ្គលឬសមាជិកនៅក្នុងក្រុមឬអង្គភាពនោះ។

ឆន្ទៈបម្រើការងារនេះផ្តើមចេញពីមនសិការរបស់បុគ្គលឬក្រុមមិនមែនជាកត្តាកំណត់ឬជាការចាប់បង្ខំនោះទេ ក៏ប៉ុន្តែជាទូទៅតម្លៃរបស់មនុស្សគឺផ្សារភ្ជាប់ទៅនឹងការងារនិងរបៀបនៃការប្រតិបត្តិ។

ខាងក្រោមនេះជាកត្តាមួយចំនួនដែលមន្ត្រីបំពេញការងារគួរប្រតិបត្តិដើម្បីភាពជោគជ័យរបស់អង្គភាពនិងបុគ្គលខ្លួនឯង។

**ក- ទឹកចិត្តស្រលាញ់ការងារ**

មន្ត្រីនគរបាលគ្រប់រូបមានកាតព្វកិច្ចការងារដែលត្រូវបំពេញក្នុងសង្គម ហើយត្រូវមានទឹកចិត្តស្រលាញ់ការងារនិងអង្គភាពរបស់ខ្លួន ពីព្រោះការងារនេះហើយជាមុខរបរពិតប្រាកដដែលខ្លួនបានជ្រើសរើស។ មានន័យថាមន្ត្រីនគរបាលម្នាក់ៗត្រូវដឹងថាការងារជាអ្នកកំណត់អំពីជោគវាសនានិងអនាគតរបស់ខ្លួន។ ការធ្វេសប្រហែសណាមួយឬការមិនយកចិត្តទុកដាក់ណាមួយទៅលើការងារ ពិតជាមានន័យស្មើនឹងការធ្វេសប្រហែសឬការមិនយកចិត្តទុកដាក់ទៅលើអនាគតរបស់ខ្លួនដូច្នោះដែរ។

គ្រប់ថ្នាក់ដឹកនាំស្ថាប័នទាំងអស់ តែងតែឱ្យតម្លៃទៅលើមន្ត្រីបំពេញការងារណាដែលមានឆន្ទៈបម្រើការងារដោយទឹកចិត្តស្មោះត្រង់ ហើយខិតខំបំពេញការងារឱ្យមានប្រសិទ្ធភាពនិងឈានទៅសម្រេចជោគជ័យដើម្បីធ្វើឱ្យអង្គភាពឬស្ថាប័នមានការរីកចម្រើន ហើយការរីកចម្រើនការវិវឌ្ឍអាជីពរបស់មន្ត្រីបំពេញការងារក៏ផ្អែកលើការងារដែលមន្ត្រីទាំងនោះបានបំពេញផងដែរ ។

**ខ- ការមានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត**

ក្រៅពីបំពេញកាតព្វកិច្ចតាមផែនការដែលអង្គភាពឬស្ថាប័នបានដាក់ចេញមន្ត្រីនគរបាលអនុវត្តការងារត្រូវខិតខំសិក្សាឈ្វេងយល់នូវគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត ក្នុងគោលបំណងកែលម្អសកម្មភាពការងាររបស់ខ្លួនសំដៅធ្វើឱ្យការបំពេញការងារមានប្រសិទ្ធភាពនិងរីកចម្រើនឆាប់រហ័ស។ ការមាននូវគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត គឺជាចក្ខុវិស័យដែលកើតឡើងនៅពេលមន្ត្រីបំពេញការងារទាំងអស់ចេះស្រលាញ់ការងារ ចេះស្រលាញ់វិជ្ជាជីវៈនិងមានគោលដៅច្បាស់លាស់ ចង់ឱ្យការងារទទួលជោគជ័យចង់ឱ្យអង្គភាពឬស្ថាប័នរបស់ខ្លួនមានការរីកចម្រើននិងមានកិត្យានុភាព ជាពិសេសការរៀបចំផែនការដើម្បីអនាគតរបស់ខ្លួនផ្ទាល់ផងដែរ។

### គ- ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម

ការបំពេញការងារក្នុងស្មារតីជាក្រុម ចាំបាច់មន្ត្រីនគរបាលត្រូវមានទស្សនៈទូលំទូលាយនិងចេះរួមសហការគ្នាបំពេញការងារក្នុងគោលដៅរួមតែមួយគឺការធ្វើឱ្យអង្គភាពបានសម្រេចលទ្ធផលខ្ពស់ ការធ្វើការងាររួមជាក្រុមនេះ គឺជាគោលគំនិតដ៏មានសារៈសំខាន់គ្រប់កាលៈទេសៈ ហើយគោលគំនិតនេះជាមូលដ្ឋាននាំដល់ការកាត់បន្ថយនូវគម្លាតរវាងកម្រិតអ្នកដាក់ចេញគោលនយោបាយនិងកម្រិតអ្នកអនុវត្តនិងរវាងមន្ត្រីអនុវត្តនិងមន្ត្រីអនុវត្តដូចគ្នា។ ជាពិសេសបានកាត់បន្ថយរាល់កំហុសឆ្គងផ្សេងៗឬការខ្វែងគំនិតគ្នានៅក្នុងអង្គភាពឬស្ថាប័ន។ ករណីនេះនាំឱ្យអ្នកអនុវត្តឬមន្ត្រីនគរបាលបំពេញការងារចេះគោរពស្រលាញ់រាប់អានគ្នា រួមគ្នាគិត រួមគ្នាធ្វើ រួមគ្នាទទួលខុសត្រូវ និងមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម ។

### ឃ- ស្មារតីពុះពារនឹងការងារ

មន្ត្រីនគរបាលត្រូវចេះយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់និងដោយស្មារតីទទួលខុសត្រូវខ្ពស់នូវភារកិច្ចដែលថ្នាក់លើប្រគល់ឱ្យនិងភារកិច្ចជំនាញរបស់ខ្លួន។ ក្រោយពីបានទទួលភារកិច្ចទាំងនោះហើយគប្បីខិតខំបំពេញការងារ មិនគួរទុកពេលវេលាឱ្យទំនេរចោលឥតប្រយោជន៍នោះទេ គឺត្រូវមានគំនិតចង់ចេះចង់ដឹងថែមទៀតដោយស្វះស្វែងរកការងារបន្ថែមដោយខ្លួនឯង មិនត្រូវអង្គុយចាំឱ្យការងាររត់មករកយើងនោះទេ។ នេះគឺជាការបណ្តុះនូវមនសិការការងារនិងស្មារតីភ្ញាក់រឭករបស់មន្ត្រីនគរបាលបំពេញការងារម្នាក់ៗគ្រប់ពេលវេលា។ បន្ថែមលើនេះមិនត្រូវខ្លាចនឿយហត់នៅពេលមានការងារច្រើនពេកឬភ័យបារម្ភចំពោះការងារលំបាកឡើយ ត្រូវតែយល់ថាមានតែភាពអំណត់ព្យាយាមជានិច្ចនិរន្តរ៍នោះទេទើបធ្វើឱ្យការងារគ្រប់យ៉ាងនឹងសម្រេចជោគជ័យតាមបំណងប្រាថ្នាដែលខ្លួនចង់បាន។ ផ្ទុយមកវិញភាពខ្ជិលខ្ជាធ្វើឱ្យរួចតែពីដៃដោយមិនគិតអំពីលទ្ធផលការងារ មិនគិតពីផលប្រយោជន៍រួមគឺជាប្រការដែលត្រូវចៀសវាងឱ្យខាងតែបាន។ ភាពមានការងារធ្វើជាប្រចាំគឺជាគុណតម្លៃរបស់មនុស្សដែលធ្វើឱ្យមន្ត្រីនគរបាលដែលកំពុងបំពេញការងារម្នាក់ៗពង្រឹងបាននូវសមត្ថភាពរបស់ខ្លួន ព្រមទាំងទទួលបានបទពិសោធ ចំណេះដឹង ចំណេះធ្វើ និងជំនឿទុកចិត្តពីថ្នាក់ដឹកនាំថែមទៀតផង។

### ង- ការជម្នះឧបសគ្គ

ជាទូទៅគ្មានការងារណាដែលមិនជួបឧបសគ្គនោះទេ ប៉ុន្តែឧបសគ្គមិនមែនជារបាំងដែលមករាំងស្ទះការងាររបស់យើងគ្រប់ពេលនោះដែរ។ ម្យ៉ាងទៀតគ្រប់ឧបសគ្គទាំងអស់មិនមែនសុទ្ធតែអាក្រក់នោះដែរ ឧបសគ្គខ្លះផ្តល់នូវបទពិសោធដ៏កម្រសម្រាប់យើងម្នាក់ៗផងដែរ។ ដូច្នេះមន្ត្រីនគរបាលបំពេញការងារទាំងអស់ត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវខ្ពស់ ហើយត្រៀមខ្លួនគ្រប់ពេលដើម្បីកាត់បន្ថយនូវបញ្ហានិងជម្នះរាល់ឧបសគ្គទាំងឡាយដែលកើតមាន មិនត្រូវញញើតភ័យខ្លាច រួញរា និងជាពិសេសមិនត្រូវបោះបង់ចោលភារកិច្ចរបស់ខ្លួនដែលត្រូវបំពេញជាដាច់ខាត ។

ក្រៅពីចំណុចទាំងឡាយដូចបានរៀបរាប់ខាងលើ នៅមានចំណុចសំខាន់ៗមួយចំនួនទៀតដែលមន្ត្រីនគរបាលត្រូវតែប្រកាន់ខ្ជាប់ជានិច្ចដូចជា **ទីមួយ**- មានស្មារតីតស៊ូអំណត់ព្យាយាមនិងមិនរួញរាចំពោះភារកិច្ច **ទីពីរ**- ផ្តល់បទពិសោធនិងចំណេះដឹងជំនាញដល់អ្នករួមការងារ **ទីបី**- មានទឹកចិត្តនិងស្មារតីចេះជួយអ្នកដទៃ **ទីបួន**- មានការតាំងចិត្តមកធ្វើការពិតប្រាកដដើម្បីការងារមិនមែនគ្រាន់តែមក

កន្លែងធ្វើការកំដរពេលវេលាហើយមិនធ្វើការនោះទេ **ទីប្រាំ-** មានការគិតទុកជាមុននិងមានការលះបង់ខ្ពស់ដើម្បីបុព្វហេតុរួម **ទីប្រាំមួយ-** ត្រូវចាត់ទុកថាខ្លួនឯងថាជាពលរដ្ឋរស់នៅក្នុងសង្គមត្រូវតែបំពេញកាតព្វកិច្ចបម្រើផលប្រយោជន៍សង្គមឱ្យបានច្រើនទើបជាការល្អប្រសើរ។

**១.១.២- ការលះបង់**

ក្នុងបរិបទមូលដ្ឋានគ្រឹះនៃអភិសមាចារ «ការលះបង់» មិនមែនមានន័យថាជាការធ្វើឱ្យបាត់បង់អត្ថប្រយោជន៍ផ្ទាល់ខ្លួនដោយគ្មានគោលការណ៍ច្បាស់លាស់នោះទេ ហើយក៏មិនមែនថាជាការទទួលរងទុក្ខលំបាកណាមួយដោយគ្មានហេតុផលនោះក៏ទេដែរ។ ប៉ុន្តែជាការបង្ហាញពីអត្ថន័យនៃការលើកស្ទួយនូវការដាក់ផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងកិត្តិយសវិជ្ជាជីវៈឱ្យលើសពីផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងការអនុវត្តភារកិច្ចត្រឹមត្រូវតាមច្បាប់ សីលធម៌ និងវិន័យជាដើម។

ការលះបង់នេះជាផ្នែកមួយនៃគុណតម្លៃអភិសមាចារដែលបង្ហាញពីស្មារតីនៃការទទួលខុសត្រូវក្នុងការបម្រើសេវាសាធារណៈនិងសេចក្តីស្មោះត្រង់របស់មន្ត្រីនគរបាលចំពោះតួនាទី ភារកិច្ចដែលខ្លួនត្រូវបំពេញ។ ឧទាហរណ៍ដូចជាការមិនទទួលអំណោយឬអត្ថប្រយោជន៍មិនសមស្របណាមួយ មិនបានប្រើតួនាទីនិងអំណាចដើម្បីរកផលប្រយោជន៍ផ្ទាល់ខ្លួនឬគ្រួសារនិងការមិនជ្រើសរើសការងារដោយលម្អៀងតាមការទំនាក់ទំនងផ្ទាល់ខ្លួន សុទ្ធតែជាការបង្ហាញពីសុចរិតភាពនិងភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈរបស់ខ្លួនដែលកំពុងកាន់អំណាចនិងបានប្រើអំណាចដ៏ត្រឹមត្រូវ។

ជាងនេះទៀត «ការលះបង់» មិនត្រឹមតែបង្ហាញពីសុចរិតភាពនិងភាពស្មោះត្រង់ប៉ុណ្ណោះទេ ប៉ុន្តែវាជាការប្តេជ្ញាចិត្តផ្នែកផ្លូវអារម្មណ៍និងអភិសមាចារផ្លូវចិត្ត ដើម្បីលះបង់នូវពេលវេលានិងសេចក្តីសុខព្រមទាំងសុវត្ថិភាពផ្ទាល់ខ្លួនផងដែរ។ សរុបសេចក្តីទៅ «ការលះបង់» ក្នុងន័យអភិសមាចារនិងក្រមសីលធម៌របស់មន្ត្រីនគរបាលបំពេញការងារមានន័យថា ការប្តេជ្ញាចិត្តបម្រើសាធារណៈដោយដាក់តម្លៃសុចរិតភាពកិត្តិយសនិងផលប្រយោជន៍រួមលើសពីអត្ថប្រយោជន៍ផ្ទាល់ខ្លួនដែលជាគុណតម្លៃស្នូលធ្វើឱ្យមន្ត្រីនគរបាលដែលបំពេញការងារក្លាយជាអ្នកមានវិជ្ជាជីវៈពិតប្រាកដនិងជាគំរូល្អសម្រាប់សង្គម។

**១.១.៣- សុចរិតភាព**

សុចរិតភាពគឺជាមូលដ្ឋានគ្រឹះប្រកបដោយសីលធម៌របស់មន្ត្រីនគរបាល។ នៅកម្ពុជាគោលគំនិតនៃសុចរិតភាពគឺស្របទៅនឹងពាក្យខ្មែរ «សុចរិត» ដែលមានន័យថា ភាពបរិសុទ្ធខាងសីលធម៌និងការប្រព្រឹត្តត្រឹមត្រូវ។ វាឆ្លុះបញ្ចាំងពីគុណធម៌ព្រះពុទ្ធសាសនានៃ «កម្មន្តៈដ៏ត្រឹមត្រូវ» ដែលទាមទារឱ្យមានការប្រព្រឹត្តស្មោះត្រង់ តម្លាភាព និងដឹកនាំដោយសតិសម្បជញ្ញៈ។ ចំពោះមន្ត្រីនគរបាលសុចរិតភាពមិនត្រឹមតែជាតម្រូវការវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែជាកាតព្វកិច្ចដ៏ពិសិដ្ឋចំពោះជាតិនិងប្រជាពលរដ្ឋ។

សុចរិតភាពមានន័យថាមន្ត្រីត្រូវតែមានភាពស៊ីសង្វាក់គ្នារវាងអ្វីដែលពួកគេនិយាយនិងអ្វីដែលពួកគេធ្វើ។ ជំហរខាងសីលធម៌របស់មន្ត្រីម្នាក់ មិនមែនត្រូវបានវិនិច្ឆ័យដោយពាក្យសំដីនោះទេ តែដោយទង្វើ។ សុចរិតភាពទាមទារឱ្យមានការបដិសេធនូវអំពើពុករលួយគ្រប់ទម្រង់ ទោះបីជាមានសម្ពាធសង្គម ឬនយោបាយលួងលោមក៏ដោយ។ វាទាមទារយុត្តិធម៌ក្នុងការអនុវត្តច្បាប់ ភាពស្មោះត្រង់ក្នុងការសរសេររបាយការណ៍ និងភក្តីភាពចំពោះរដ្ឋធម្មនុញ្ញ មិនមែនចំពោះបុគ្គលឬបក្ខពួកណាមួយឡើយ។

នៅពេលដែលសាធារណជនបានឃើញសុចរិតភាពក្នុងឯកសណ្ឋាន ប្រាកដណាស់ពួកគេនឹងឃើញភាពស្របច្បាប់នៅក្នុងសង្គម។ ផ្ទុយមកវិញពេលសង្គមបាត់បង់ភាពស្របច្បាប់ពេលនោះសុចរិតភាពត្រូវបរាជ័យ ហើយជំនឿទុកចិត្តក៏ត្រូវកាត់បន្ថយនាំឱ្យស្ថាប័ននគរបាលក៏មិនអាចដំណើរការបាននោះឡើយ។

**១.១.៤- ភាពស្មោះត្រង់**

ភាពស្មោះត្រង់ជាសេចក្ដីត្រូវការដែលមនុស្សក្នុងសង្គមអរិយធម៌ត្រូវតែប្រកាន់ខ្ជាប់ដើម្បីលើកតម្កើងកិត្តិយសនិងសេចក្ដីថ្លៃថ្នូរ ទាំងក្នុងនាមបុគ្គលនិងក្នុងនាមស្ថាប័នដែលខ្លួនកំពុងបម្រើការងារ។ ភាពស្មោះត្រង់នេះ ទោះបីជាពុំមានចែងនៅក្នុងច្បាប់ឬបញ្ញត្តិផ្សេងៗ ឬក៏ជាកាតព្វកិច្ចក៏ដោយ ក៏វាជាគុណតម្លៃខាងចរិយាធម៌របស់មនុស្សក្នុងបរិបទអកិសមាចារនិងក្រមសីលធម៌ផងដែរ។ ការណ៍នេះបង្ហាញឱ្យឃើញតាមរបៀបនៃការគិតនិងការប្រតិបត្តិរបស់បុគ្គលនីមួយៗដែលសកម្មភាពទាំងនេះស្ដែងចេញនូវសេចក្ដីថ្លៃថ្នូរ ការទទួលខុសត្រូវ និងផលប្រយោជន៍របស់អង្គភាពឬស្ថាប័ន។ ជាទូទៅមិនថាតែក្នុងវិស័យសាធារណៈរបស់រដ្ឋនោះទេ សូម្បីតែក្នុងវិស័យឯកជនក៏ត្រូវទាមទារស្វែងរកបុគ្គលដែលមានភាពស្មោះត្រង់ឱ្យមកបម្រើការងារដែរ។ ហេតុដូចនេះ ការស្វែងរកភាពស្មោះត្រង់មិនមែនជាសកម្មភាពបុគ្គលទេ ប៉ុន្តែជាដំណើរការសង្គម ស្ថាប័ន និងអង្គភាពនៃវិជ្ជាជីវៈដែលតម្រូវឱ្យបង្កើតប្រព័ន្ធការងារមួយមានតម្លាភាពនិងទំនុកចិត្ត ដើម្បីទទួលបានការឆ្លើយតបដោយការពេញចិត្តដែលចេញពីចរិតខាងក្នុង។

នៅពេលដែលភាពស្មោះត្រង់បានបំពេញបន្ថែមជាមួយសុចរិតភាពគឺជាគុណសម្បត្តិដ៏មានសារៈសំខាន់ដែលបានធានាថាមន្ត្រីបំពេញការងារត្រូវប្រព្រឹត្តដោយការពិតចំពោះថ្នាក់លើនិងថ្នាក់ក្រោមព្រមទាំងសាធារណជនផងដែរ។ ការកុហកនិងការបោកបញ្ឆោតអាចលាក់បាំងទង្វើខុសឆ្គងបានជាបណ្ដោះអាសន្ន ប៉ុន្តែវាបំផ្លាញជំនឿទុកចិត្តជាអចិន្ត្រៃយ៍ដែលជាតម្លៃសីលធម៌នៃកិច្ចការនគរបាល។ ដូចដែលក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់ (ឆ្នាំ១៩៧៩ មាត្រា៨) បានចែងថា មន្ត្រីត្រូវតែរាយការណ៍អំពីការរំលោភបំពានក្រមសីលធម៌ឬភាពមិនស្របច្បាប់ណាមួយដែលពួកគេបានឃើញ។ ជាក់ស្ដែងថ្មីៗនេះមានឯកសារគតិយុត្តជាបទវិន័យមន្ត្រីនគរបាលជាតិរបស់ក្រសួងមហាផ្ទៃ (ឆ្នាំ២០២៤) បានពង្រឹងចំណុចខាងលើនេះតាមរយៈគោលការណ៍ក្រមសីលធម៌ដែលមានចែងនៅក្នុងជំពូក៣ ក្នុងប្រការ៩ដែលសង្កត់ធ្ងន់ទៅលើភាពស្មោះត្រង់និងសុចរិតភាពចំពោះរាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋ។ មន្ត្រីនគរបាលដែលប្រព្រឹត្តដោយភាពស្មោះត្រង់និងសុចរិតភាពគឺជាកញ្ចក់ឆ្លុះបញ្ចាំងអំពីសីលធម៌សង្គមប្រកបដោយកិត្តិយសនិងសេចក្ដីថ្លៃថ្នូរ។

**១.១.៥- ការទទួលខុសត្រូវចំពោះសង្គម**

មន្ត្រីនគរបាលជាគំរូខាងសីលធម៌នៅក្នុងសង្គម ឥរិយាបថរបស់ពួកគេបង្កើតអាកប្បកិរិយាជាសាធារណៈចំពោះយុត្តិធម៌ ច្បាប់ និងសីលធម៌។ នៅពេលមន្ត្រីបង្ហាញមេត្តាធម៌ ភាពរាបសា និងភាពស្មោះត្រង់ ពួកគេបានលើកកម្ពស់សីលធម៌របស់សង្គមខ្លួនឯង។ ផ្ទុយទៅវិញនៅពេលពួកគេប្រព្រឹត្តអំពើពុករលួយ ពួកគេធ្វើឱ្យអំពើពុករលួយក្លាយជាទង្វើនៃវប្បធម៌សង្គម។

ទំនួលខុសត្រូវសង្គមនៅក្នុងកិច្ចការនគរបាលលាតសន្ធឹងហួសពីការគ្រប់គ្រងឧក្រិដ្ឋកម្ម។ មន្ត្រីនគរបាលគួរចូលរួមក្នុងការផ្សព្វផ្សាយអប់រំ ការណែនាំយុវជននិងគំនិតផ្តួចផ្តើមសុខដុមរមនាសង្គម។ កម្មវិធីផ្សព្វផ្សាយដល់សហគមន៍របស់នគរបាល ក្នុងយុទ្ធនាការប្រឆាំងគ្រឿងញៀននិងការអប់រំសុវត្ថិភាពចរាចរណ៍បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដែលជាសីលធម៌ខ្ពស់បំផុតមួយ។ សកម្មភាពទាំងនេះនឹងពង្រឹងរូបភាពរបស់នគរបាលជាអ្នកការពារនិងអ្នកអប់រំដោយមិនមែនគ្រាន់តែជាអ្នកគោរពនិងអនុវត្តច្បាប់ប៉ុណ្ណោះទេ។

នៅក្នុងន័យព្រះពុទ្ធសាសនាវិញ ចំណុចទាំងនេះបានបង្ហាញពីគុណធម៌នៃ «ក្តីមេត្តា» (សេចក្តីស្រលាញ់) និង «ករុណា» (មេត្តាធម៌ចំពោះទុក្ខវេទនា)។ ដូច្នេះមន្ត្រីនគរបាលក្លាយជាអ្នកការពារច្បាប់ផងនិងជាអ្នកលើកកម្ពស់គុណធម៌ផងដើម្បីជួយសង្គមឱ្យរីកចម្រើនខាងផ្លូវសីលធម៌និងដួងព្រលឹង។

**១.១.៦- ការបង្កើតទំនុកចិត្តសាធារណៈ**

ទំនុកចិត្តកើតចេញពីទំនួលខុសត្រូវខាងសីលធម៌ដែលតម្រូវឱ្យមន្ត្រីនគរបាលធ្វើសកម្មភាពដោយភាពស្មោះត្រង់ ការយល់ចិត្ត និងការទប់ស្កាត់ខ្លួនឯង។ រាល់ការសម្រេចចិត្តរបស់មន្ត្រីនគរបាលមិនថាត្រូវអន្តរាគមន៍សម្របសម្រួលចាប់ខ្លួនឬប្រើកម្លាំងនោះទេសុទ្ធតែមានផលវិបាកខាងក្រមសីលធម៌ ក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់ (ឆ្នាំ១៩៧៩) បានសង្កត់ធ្ងន់ថាមន្ត្រីនគរបាលត្រូវតែបម្រើសហគមន៍និងការពារមនុស្សទាំងអស់ឱ្យរួចផុតពីអំពើខុសច្បាប់ដោយការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសេចក្តីថ្លៃថ្នូរនិងសិទ្ធិមនុស្ស (មាត្រា១-២)។ បន្ថែមលើនេះតម្លាភាពនិងគណនេយ្យភាពក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាទំនុកចិត្តផងដែរ។ ការងារនគរបាលសម័យទំនើបបានទទួលស្គាល់ថាមន្ត្រីនគរបាលមិនមែនត្រឹមតែជាអ្នកអនុវត្តច្បាប់ប៉ុណ្ណោះទេប៉ុន្តែក៏ជា «ភ្នាក់ងារសីលធម៌» ដែលបង្ហាញពីភាពមានយុត្តិធម៌ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនផងដែរ។

នៅពេលដែលមន្ត្រីនគរបាលប្រាស្រ័យទាក់ទងដោយស្មោះត្រង់ ទទួលស្គាល់កំហុស និងរក្សាភាពយុត្តិធម៌ សូម្បីតែក្នុងស្ថានភាពស្មុគស្មាញ ពួកគេបានលើកកម្ពស់ភាពថ្លៃថ្នូរខាងសីលធម៌នៃស្ថាប័នទាំងមូលផងដែរ។ ទំនុកចិត្តសាធារណៈងាយនឹងបាត់បង់ទៅនៅពេលមានទង្វើអសីលធម៌ណាមួយកើតឡើង។ ដូច្នេះដើម្បីដោះស្រាយវិបត្តិនេះ មន្ត្រីនគរបាលត្រូវចំណាយពេលវេលាច្រើនឆ្នាំខិតខំស្តារ និងកសាងសីលធម៌និងភាពស្មោះត្រង់ដើម្បីកសាងទំនុកចិត្តទាំងនោះឡើងវិញ។ សរុបសេចក្តីមក កាតព្វកិច្ចខាងការកសាងសីលធម៌របស់មន្ត្រីនគរបាលនឹងត្រូវពង្រីកវិសាលភាពឱ្យបានធំទូលាយជាងការអនុវត្តច្បាប់ដើម្បីរក្សាទំនុកចិត្តសាធារណៈកុំឱ្យបាត់បង់។

**១.១.៧- ការអភិវឌ្ឍសមត្ថភាព (ជំនាញនិងច្បាប់)**

មន្ត្រីនគរបាលគ្រប់រូប គ្រប់កម្រិតត្រូវមានទស្សនៈទូលំទូលាយដោយត្រូវឈ្វេងយល់ថាក្រៅពីចំណេះដឹងជាមូលដ្ឋានរបស់ខ្លួនចាំបាច់ត្រូវធ្វើការសិក្សានិងឈ្វេងយល់នូវការវិវត្តនៃសភាពការណ៍ជុំវិញខ្លួននិងសភាពការណ៍វិវត្តន៍ក្នុងសង្គមនិងពិភពលោក ជាពិសេសការវិវត្តរីកចម្រើនក្នុងការអនុវត្តនូវកម្មវិធីនយោបាយ គោលនយោបាយ និងការដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងការរក្សាសន្តិភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ការឈ្វេងយល់ពីសភាពការណ៍សង្គមគឺជាការបង្កើននូវ

ការអភិវឌ្ឍសមត្ថភាពខាងផ្នែកចំណេះដឹងជំនាញ ច្បាប់ និងគោលនយោបាយរបស់រដ្ឋដោយផ្តល់ជំនឿស្មារតីទទួលខុសត្រូវខាងចំណេះដឹងនិងការផ្តួចផ្តើមគំនិតដើម្បីជំរុញកិច្ចប្រតិបត្តិការរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ម្យ៉ាងទៀតក្នុងបរិបទសង្គមនិងសកលលោកបច្ចុប្បន្ននេះ ខាងផ្នែកបច្ចេកវិទ្យាឌីជីថលមានការវិវឌ្ឍយ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំដែលទាមទារឱ្យមន្ត្រីនគរបាលទទួលបន្ទុកការងារនៅតាមអង្គភាពឬស្ថាប័នត្រូវមានសមត្ថភាពទាំងចំណេះដឹងជំនាញនិងអាកប្បកិរិយាល្អទៅតាមតួនាទីភារកិច្ចដែលពួកគេទទួលខុសត្រូវ។ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈក្នុងក្របខណ្ឌនគរបាលជាតិគឺជាភាពចាំបាច់បំផុតដែលត្រូវតែមានការសិក្សាស្រាវជ្រាវបង្កើនសមត្ថភាពចំណេះដឹង ជំនាញ និងក្រមសីលធម៌ឱ្យបានទូលំទូលាយប្រែក្លាយជាមូលធនមនុស្សប្រកបដោយថាមពលនៅក្នុងស្ថាប័នមន្ត្រីអនុវត្តច្បាប់។

### ១.២- វប្បធម៌នៃការបម្រើសេវា

ជានិច្ចកាលការបម្រើសេវាសាធារណៈរបស់មន្ត្រីនគរបាលប្រកបដោយគុណភាពនិងប្រសិទ្ធភាពទាមទារឱ្យមានភក្តីភាពជានិច្ចចំពោះប្រទេសជាតិនិងថ្នាក់ដឹកនាំ។ ភក្តីភាពជាផ្នត់គំនិតសីលធម៌នៃអភិសមាចារនិងក្រមសីលធម៌ដែលជាមាគ៌ាតម្រង់ទិសដល់មន្ត្រីនគរបាលជាតិឱ្យអនុវត្ត ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលដើម្បីបម្រើសេវាសន្តិសុខនិងសេវាសាធារណៈជូនប្រជាពលរដ្ឋ។ ភក្តីភាពនេះជាមូលដ្ឋានចាំបាច់ដែលមន្ត្រីនគរបាលគ្រប់រូបត្រូវប្រកាន់ខ្ជាប់គ្រប់កាលៈទេសៈនិងគ្រប់ទីកន្លែងដែលខ្លួនបំពេញការងារអាចនិយាយបានថាជាគុណធម៌របស់មន្ត្រីនគរបាលគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់ដោយចីរភាពក្លាយជាវប្បធម៌ក្នុងការបំពេញការងារស្នូលរបស់ខ្លួន។

#### ១.២.១- ការសម្របសម្រួលផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយា

ការបម្រើសេវាជាមួយនឹងប្រជាពលរដ្ឋមិនមែនមានន័យថាជាការគ្រប់គ្រងទេ ប្រសិនបើមានការយល់បែបនេះគឺជាការយល់ច្រឡំដ៏ធំមួយ។ ហេតុនេះហើយ មន្ត្រីនគរបាលចាំបាច់ត្រូវកែប្រែឥរិយាបថនិងរបៀបរបបនៃការធ្វើទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវាប្រកបដោយសេចក្តីថ្លៃថ្នូរមានភាតរភាពនិងការទទួលខុសត្រូវខ្ពស់។ ការផ្លាស់ប្តូរឥរិយាបថនិងអាកប្បកិរិយារបស់នគរបាលគឺជាកត្តាចាំបាច់ដើម្បីឱ្យមន្ត្រីនគរបាលគ្រប់រូបបំពេញតួនាទីជាអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ មានន័យថា ត្រូវផ្លាស់ប្តូរពីភាពជា «អ្នកគ្រប់គ្រងគេ» ទៅជា «អ្នកផ្តល់សេវាឱ្យគេ» វិញ។ ការងារនេះវាមិនហួសកម្រិតដែលមិនអាចធ្វើបាននោះទេឱ្យតែព្យាយាមប្រឹងប្រែងធ្វើទាំងអស់គ្នា។

មន្ត្រីនគរបាលគ្រប់រូបត្រូវបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ មានមនសិការវិជ្ជាជីវៈខ្ពស់ក្នុងគោលដៅធ្វើឱ្យការកសាងទំនុកចិត្តសង្គមមានការរីកចម្រើន។ មន្ត្រីទាំងអស់ត្រូវបង្ហាញឱ្យឃើញថាខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។ បន្ថែមលើនេះមន្ត្រីនគរបាលគ្រប់រូបមិនត្រូវធ្វើឱ្យអាប់ឱនប៉ះពាល់ដល់កិត្តិយសកិត្យានុភាពរបស់ក្រសួង ស្ថាប័ន អង្គភាព ឬថ្នាក់ដឹកនាំរបស់ខ្លួនឡើយ។ និយាយរួមត្រូវរក្សានូវពាក្យសំដីដែលបាននិយាយចេញទៅឬក៏បានធ្វើការផ្សព្វផ្សាយទៅដោយភាពប្រុងប្រយ័ត្នខ្ពស់បំផុត ពីព្រោះនៅពេលដែលយើងបានព្យាយាមខិតខំកសាងបាននូវទំនុកចិត្តសាធារណៈរួចហើយ នគរបាលត្រូវដឹងថាការរក្សាទំនុកចិត្តសាធារណៈពិតជាមិនត្រូវមើលរំលងនូវ «ឧបសគ្គឬហានិភ័យ» ទាំងឡាយដែលអាចនឹងកើតឡើងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ហើយត្រូវបានបំផ្លាញចោលទាំងស្រុងដោយទង្វើអសីលធម៌ណាមួយដែលមិនបានប្រុងប្រយ័ត្ន។

**១.២.២- ការបម្រើសេវា**

ការធ្វើទំនាក់ទំនងនិងរបៀបរបបធ្វើការងារក្នុងការផ្តល់សេវាត្រូវផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា។ សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវានោះហើយដែលជាអាទិភាពនិងជាកាតព្វកិច្ចដែលមន្ត្រីនគរបាលជាអ្នកផ្តល់សេវាដល់ពួកគាត់និងត្រូវឆ្លើយតបប្រកបដោយមនសិការវិជ្ជាជីវៈនិងសេចក្តីថ្លៃថ្នូរ។ មន្ត្រីនគរបាលមិនត្រូវប្រើប្រាស់តួនាទីនិងមុខតំណែងរបស់ខ្លួនធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកឬមានការភ័យខ្លាចទេ។ ប៉ុន្តែផ្ទុយទៅវិញត្រូវផ្តល់នូវជំនឿទុកចិត្ត បំបាត់ភាពភ័យខ្លាច ផ្តល់ភាពកក់ក្តៅ រាក់ទាក់ ការគោរពនិងធ្វើឱ្យប្រជាពលរដ្ឋពេញចិត្តចំពោះសកម្មភាពការងារនិងអត្តចរិតរបស់មន្ត្រីនគរបាលឬអង្គភាពដែលជាអ្នកផ្តល់សេវា។

ក្នុងន័យនេះមន្ត្រីនគរបាលគ្រប់រូបត្រូវរ៉ាប់រងការងារឬសេវាទាំងឡាយដែលអង្គភាពឬថ្នាក់ដឹកនាំប្រគល់ជូន ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ ព្រោះការងារដែលមន្ត្រីនគរបាលទទួលយកទៅអនុវត្តគឺជាការងាររដ្ឋ ការងារសាធារណៈដែលបានបែងចែកនិងកំណត់ច្បាស់លាស់ចំពោះមន្ត្រីម្នាក់ៗហើយតម្រូវការចាំបាច់ឱ្យមន្ត្រីនគរបាលត្រូវមានវត្តមានជាប្រចាំ ដើម្បីបំពេញការងារទាំងនោះដែលជាតំណាងនៃអំណាចសាធារណៈ។ ក្រៅពីបំពេញកាតព្វកិច្ចក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន មន្ត្រីទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវវប្បធម៌ជា «អ្នកផ្តល់សេវានិងអ្នកប្រើសេវា» ពីព្រោះប្រជាពលរដ្ឋជាអតិថិជនអចិន្ត្រៃយ៍ដែលផ្សារភ្ជាប់ទៅនឹងសកម្មភាពការងាររបស់មន្ត្រីនគរបាលគ្រប់រូប ទោះដោយចំពោះឬមិនចំពោះក្តី។

មន្ត្រីនគរបាលគ្រប់រូបត្រូវយកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួននិងត្រូវកំណត់ថា តើសេវាមួយណាជាសេវាអាទិភាពចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់សេវាដូចជាសេវាតម្រូវការនិងសេវាសំណូមពរដោយត្រូវធ្វើយ៉ាងណាបង្កើតសេវានៃការដោះស្រាយការងារផ្សេងៗឱ្យកៀកនឹងប្រជាពលរដ្ឋ។

**១.២.៣- ការផ្សព្វផ្សាយ**

ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយ ផ្តល់ព័ត៌មាន និងពន្យល់ឱ្យបានច្បាស់ដល់ប្រជាពលរដ្ឋអំពីនីតិវិធី របៀបរបប និងបែបបទផ្សេងៗនៃការផ្តល់សេវាសាធារណៈ។ សំណួររបស់ប្រជាពលរដ្ឋត្រូវតែមានចម្លើយឆ្លើយតបយ៉ាងសមរម្យមិនត្រូវបង្ហាញនូវអាកប្បកិរិយាធុញទ្រាន់ ក្រអឺតក្រទម រើសអើងរវាងអ្នកតូចនិងអ្នកធំ រវាងអ្នកក្រនិងអ្នកមាន រវាងអ្នកស្រែនិងអ្នកក្រុងឡើយ ពីព្រោះគ្រប់សំណួរឬចម្ងល់ទាំងអស់របស់ពលរដ្ឋបង្ហាញឱ្យឃើញនូវសេចក្តីត្រូវការនិងការចង់ចេះចង់ដឹងរបស់ពួកគាត់ដែលជាអ្នកទទួលសេវា។ កត្តាទាំងអស់នេះមានសារៈសំខាន់ចំពោះការប្រតិបត្តិការងាររបស់នគរបាលផ្ទាល់និងធ្វើការកែលម្អសំដៅឱ្យសេវាដែលបានផ្តល់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានទូលំទូលាយនិងទាន់ពេល។

**១.២.៤- ការសម្របសម្រួល**

យន្តការសម្របសម្រួលមានសារៈសំខាន់ដល់ការផ្តល់សេវានិងការទទួលយកសេវាទៅប្រើប្រាស់ពីព្រោះវាបានជួយកាត់បន្ថយគម្លាតរវាងអ្នកផ្តល់សេវានិងអ្នកប្រើប្រាស់សេវានិងចៀសវាងការយល់

ប្រទាំឬការខ្វែងគំនិតគ្នា។ ជាពិសេសយន្តការសម្របសម្រួលរបស់នគរបាលជាប្រព័ន្ធនៃវិធានការរៀបធ្វើការនិងការសហការគ្នាជាមួយនឹងអង្គភាពពាក់ព័ន្ធដើម្បីធានាថា ការផ្តល់សេវាសាធារណៈមានភាពប្រទាក់ក្រឡាគ្នា ប្រសព្វគ្នា ឆាប់រហ័ស មានតម្លាភាព និងប្រសិទ្ធភាព។

ទន្ទឹមនេះយន្តការសម្របសម្រួលសំខាន់ៗដែលត្រូវអនុវត្តផ្ទៃក្នុងរបស់អង្គភាពនគរបាលគឺត្រូវចេះធ្វើការបែងចែកតួនាទីនិងភារកិច្ចឱ្យច្បាស់លាស់ ដោយត្រូវប្រើប្រាស់ប្រព័ន្ធបញ្ជានិងទំនាក់ទំនងផ្ទៃក្នុងលើការផ្លាស់ប្តូរព័ត៌មាននិងទិន្នន័យរវាងផ្នែកជំនាញនីមួយៗ។ ជាងនេះទៅទៀតក៏ត្រូវមានការសម្របសម្រួលជាមួយនឹងអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធដូចជាអាជ្ញាធរដែនដី (ឃុំ សង្កាត់ ក្រុង ខេត្ត) តុលាការ អយ្យការនិងស្ថាប័នយុត្តិធម៌ជាមួយនឹងស្ថាប័នសេវាសាធារណៈផ្សេងៗទៀតដូចជាសុខាភិបាល អប់រំ និងសង្គមកិច្ចផងដែរ។ អ្វីដែលសំខាន់ជាងនេះទៀតត្រូវសម្របសម្រួលជាមួយសហគមន៍និងប្រជាពលរដ្ឋដោយផ្អែកលើគោលការណ៍ «នគរបាលនិងសហគមន៍» លើការទទួលសំណើ បណ្តឹង និងមតិយោបល់ពីសាធារណជនព្រមទាំងការបង្កើតបណ្តាញទំនាក់ទំនងជាមួយនឹងមេភូមិ មេឃុំ និងអង្គការសង្គមស៊ីវិល។

ការណ៍នេះអាចនឹងត្រូវមានការប្រើប្រព័ន្ធបច្ចេកវិទ្យាប្រើប្រាស់ប្រព័ន្ធព័ត៌មាននិងឌីជីថលក្នុងការផ្តល់សេវានៃការចុះបញ្ជី និងតាមដានសេវាតាមប្រព័ន្ធអេឡិចត្រូនិកលើប្រភេទសេវាដែលមានជាលក្ខណៈរួមៗដូចជាសេវាឯកសាររដ្ឋបាល (លិខិតបញ្ជាក់ អត្តសញ្ញាណបណ្ណ) សេវាទទួលបណ្តឹងនិងដោះស្រាយវិវាទ សេវាការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ សេវាជួយសង្គ្រោះ និងធ្វើអន្តរាគមន៍បន្ទាន់ជាដើម។ ក្នុងន័យនេះយន្តការសម្របសម្រួលល្អនឹងជួយឱ្យនគរបាលអនុវត្តភារកិច្ចដោយមានប្រសិទ្ធភាព ស្មោះត្រង់ តម្លាភាព និងទទួលខុសត្រូវជាកត្តានាំឱ្យការផ្តល់សេវាសាធារណៈកាន់តែមានគុណភាពនិងឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋនិងសង្គម។

### ១.៣- ស្មារតីសាមគ្គីភាព

មន្ត្រីនគរបាលទាំងអស់ត្រូវមានសាមគ្គីភាពចំពោះគ្នាមានការព្រមព្រៀងគ្នាដោយឆន្ទៈចេះធ្វើការជាមួយគ្នាដោយមនសិការវិជ្ជាជីវៈជាកត្តានាំមកនូវការសម្រេចរាល់ភារកិច្ចទាំងឡាយនិងជាកម្លាំងចលករដ៏ខ្លាំងក្លាប្រកបដោយសក្តានុពលដែលអាចកសាងសេចក្តីសុខចម្រើនលូតលាស់គ្រប់វិស័យ។

មាគ៌ាឬគោលធម៌ដែលត្រូវសក្រាយផ្លូវនាំឱ្យកើតមានសាមគ្គីភាពមានដូចខាងក្រោម៖

#### ១.៣.១- ការបង្កើតឱ្យមានក្រមសីលធម៌គិតពីគោលបំណងរបស់ស្ថាប័ន

នៅក្នុងអង្គភាពឬស្ថាប័ននគរបាលដែលមានភារកិច្ចអនុវត្តច្បាប់និងបម្រើសង្គម ការមានស្មារតីសាមគ្គីភាពដែលផ្អែកលើគោលបំណងរបស់ស្ថាប័នពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការធានាបាននូវសុខសន្តិភាព សណ្តាប់ធ្នាប់ និងប្រសិទ្ធភាពការងារ។ ការគិតពីគោលបំណងរបស់ស្ថាប័ន មានន័យថា មន្ត្រីគ្រប់រូបត្រូវដាក់អាទិភាពលើអត្ថប្រយោជន៍រួមនិងបំពេញភារកិច្ចដោយស្មោះត្រង់ ទទួលខុសត្រូវនិងគោរពវិន័យ។ ក្នុងន័យនេះស្មារតីសាមគ្គីភាពមិនត្រឹមតែជាការសហការទេប៉ុន្តែជាការរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចគោលបំណងរួម ដោយគ្មានការបែងចែក ឬប្រកួតប្រជែងណាមួយដែលនាំឱ្យមានការបែកបាក់ផ្ទៃក្នុងនោះទេ។ ដូច្នេះ ការអភិវឌ្ឍនិងពង្រឹងស្មារតីសាមគ្គីភាពដោយការយកចិត្តទុកដាក់លើគោលបំណងរួមរបស់ស្ថាប័ន គឺជាគន្លឹះសំខាន់មួយសម្រាប់ការអភិវឌ្ឍស្ថាប័នឱ្យមានភាពរឹងមាំ

និងមានប្រសិទ្ធភាពយូរអង្វែង។ ដូចគ្នានេះដែរ ការចែករំលែកភោគផលដល់គ្នាដោយយុត្តិធម៌ដោយស្មើភាព ដោយយកចិត្តទុកដាក់ជួយគ្នានិងអនុគ្រោះគ្នាត្រូវតែព្យាយាមបង្កើតឱ្យមានវប្បធម៌បែបនេះ ទាំងបទពិសោធការងារ ទាំងការទំនាក់ទំនងទើបជាការប្រសើរបំផុតក្នុងការគាំទ្រជួយគ្នាទៅវិញទៅមក។

**១.៣.២- ការបង្កើតឱ្យមានក្រមសីលធម៌គិតពីឧត្តមប្រយោជន៍របស់ស្ថាប័ន**

ស្មារតីសាមគ្គីភាព មិនមែនកើតឡើងដោយចៃដន្យឡើយ ប៉ុន្តែកើតឡើងពីការយល់ដឹងនិងការប្រតិបត្តិរបស់មន្ត្រីនគរបាលនៅក្នុងអង្គភាពឬស្ថាប័នដោយបានទទួលស្គាល់ថា ឧត្តមប្រយោជន៍រួមរបស់ស្ថាប័នមានតម្លៃលើសអត្តប្រយោជន៍ផ្ទាល់ខ្លួន។ ការតម្កល់អត្តប្រយោជន៍រួមមានន័យថា បុគ្គលម្នាក់ៗត្រូវចេះបោះបង់ឬកាត់បន្ថយអារម្មណ៍ផ្ទាល់ខ្លួនខ្លះៗដើម្បីរក្សាភាពរួបរួមនិងស្ថិរភាពរបស់អង្គ-ភាព។ នៅក្នុងបរិបទនេះមន្ត្រីនឹងមិនប្រកួតប្រជែងគ្នាដោយអវិជ្ជមានឬស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនដែលប៉ះពាល់ដល់ក្រុមទេ ប៉ុន្តែជួយគ្នាដើម្បីសម្រេចគោលដៅដូចគ្នា។ លើសពីនេះការដាក់អត្តប្រយោជន៍រួមជាមុន ក៏ជួយបង្កើតទំនុកចិត្តនិងការគោរពគ្នាទៅវិញទៅមកក្នុងក្រុមផងដែរ។ នៅពេលសមាជិកមានការជឿជាក់ថា មនុស្សគ្រប់រូបកំពុងធ្វើការដើម្បីគោលដៅដូចគ្នា នោះការសហការនឹងកាន់តែរលូននិងមានប្រសិទ្ធភាពខ្ពស់។ ដូចនេះ នៅពេលដែលមន្ត្រីនគរបាលគ្រប់រូបយកចិត្តទុកដាក់លើផលប្រយោជន៍រួមរបស់អង្គភាពឬស្ថាប័ន ពួកគេនឹងមានទំនោរធ្វើការសហការគ្នា ជួយគ្នា ជួយបង្រួបបង្រួមកម្លាំងនិងគោរពគ្នាទៅវិញទៅមកដែលជាមូលដ្ឋានសំខាន់បង្កើតឱ្យមានសាមគ្គីភាពបង្កើនប្រសិទ្ធភាពការងារនិងជានាភាពជោគជ័យយូរអង្វែងរបស់អង្គភាព។

**១.៣.៣- ការបង្កើតឱ្យមានក្រមសីលធម៌និងគុណធម៌**

ក្រមសីលធម៌និងគុណធម៌មានប្រភពចេញពីទ្រឹស្តីក្រមសីលធម៌ (Nicomachean) របស់លោក «អារីស្តូត» (សតវត្សទី៤មុនគ.ស) ក្រមសីលធម៌នេះផ្តោតលើចរិតលក្ខណៈរបស់អ្នកប្រព្រឹត្តខាងសីលធម៌មិនមែនលើច្បាប់ឬលទ្ធផលនោះទេ។ ទ្រឹស្តីនេះបានសង្កត់ធ្ងន់លើផ្លូវគុណធម៌ដែលសំដៅលើភាពក្លាហាន ភាពត្រឹមត្រូវ ភាពអត់ធ្មត់ ភាពស្មោះត្រង់ និងមេត្តាធម៌ (Pagon, 2000)។

មន្ត្រីនគរបាលដែលមានគុណធម៌ តែងតែអនុវត្តការវិនិច្ឆ័យ តាមរបៀបភាពចាស់ទុំខាងសីលធម៌ដោយប្រើការសម្រេចចិត្តប្រកបដោយប្រាជ្ញាបង្ហាញការយល់ចិត្តចំពោះមន្ត្រីនិងរក្សាភាពថ្លៃថ្នូរនៅក្នុងអំណាច។ ក្នុងន័យនេះក្រមសីលធម៌និងគុណធម៌បានផ្សារភ្ជាប់នូវភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធក្នុងផ្នត់គំនិតនៃជាតិសាសន៍ខ្មែរ ដោយបានបង្កប់នូវសុចរិតភាពដែលជាឥរិយាបថខាងក្រមសីលធម៌ឆ្លុះបញ្ចាំងពីសេចក្តីល្អនៃចិត្តគំនិតខាងក្នុងដើម្បីសំដែងចេញនូវសកម្មភាពអនុវត្តខាងក្រៅ។

**១.៣.៤- ការគោរពច្បាប់និងសិទ្ធិសេរីភាពអ្នកដទៃ**

ការគោរពច្បាប់និងសិទ្ធិសេរីភាពអ្នកដទៃបានដល់ការបដិបត្តិតាមច្បាប់របស់រដ្ឋ បទបញ្ជា ឬបទវិន័យផ្សេងៗរបស់ស្ថាប័ន និងគោរពសិទ្ធិសេរីភាពរបស់បុគ្គលគ្រប់រូប។ ជានិច្ចកាលមន្ត្រីនគរបាលត្រូវតែស្មោះត្រង់ចំពោះគោលការណ៍ច្បាប់ មិនមែនចំពោះបុគ្គលណាម្នាក់នោះទេ។ការអនុវត្តច្បាប់ដោយស្របច្បាប់ គឺជាការបង្ហាញចុងក្រោយនៃវិន័យខាងក្រមសីលធម៌។ ការគោរពសិទ្ធិអ្នកដទៃសំដៅដល់ការទទួលស្គាល់នូវអនុវត្តអាកប្បកិរិយាដែលមិនរំលោភឬប៉ះពាល់ដល់សិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ

និងតម្លៃមនុស្សឬក៏របស់អ្នកដទៃមិនថាជារូបវន្តបុគ្គលឬជានីតិបុគ្គលឡើយ។ ការប្រព្រឹត្តរបស់នគរបាលត្រូវទទួលស្គាល់តម្លៃមនុស្សស្មើគ្នា ដោយគប្បីយល់ថាមនុស្សគ្រប់រូបមានតម្លៃ និងសិទ្ធិស្មើគ្នាមិនថាមានភេទ អាយុ ជំនឿ ជាតិ ឬស្ថានភាពសង្គមខុសគ្នាក៏ដោយ មិនត្រូវបង្ខិតបង្ខំ គំរាមកំហែង រារាំង ការគិត ការនិយាយ និងការរស់នៅស្របច្បាប់របស់មនុស្សឡើយ ផ្ទុយមកវិញត្រូវមានក្រមសីលធម៌បង្ហាញអាកប្បកិរិយាសុភាពនិងការគោរព ប្រើពាក្យសមរម្យ ស្ដាប់មតិយោបល់គ្នាទៅវិញទៅមក ទោះបីមានការយល់ឃើញខុសគ្នាក៏ដោយជាពិសេសត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនដោយត្រូវដឹងថាសកម្មភាពឬពាក្យសម្ដីរបស់ខ្លួនអាចប៉ះពាល់ដល់អ្នកដទៃ ហើយក៏ត្រូវប្រុងប្រយ័ត្នមិនឱ្យបង្កការរងគ្រោះណាមួយនោះឡើយ។

**១.៣.៥- ការបង្រួបបង្រួមទស្សនៈ**

ការបង្រួបបង្រួមទស្សនៈ សំដៅដល់ការយល់ឃើញស្របគ្នាការគិតក្នុងគោលដៅដូចគ្នាសង្រួមគំនិតឱ្យត្រូវគ្នា ស្វែងរកចំណុចរួម និងរក្សាទុកចំណុចផ្សេងៗរបស់គ្នានិងគ្នាដោយមិនគួរប្រកាន់ខ្ជាប់តែការយល់ឃើញរបស់ខ្លួនជាធំ តែត្រូវចេះស្ដាប់មតិយោបល់របស់អ្នកដទៃ។ នៅពេលដែលអង្គភាពឬស្ថាប័នអនុវត្តច្បាប់មួយ ដែលត្រូវបានសាធារណជនជឿទុកចិត្តដោយសេចក្ដីគោរពក៏ព្រោះតែគេយល់ថា រាល់ការប្រព្រឹត្តរបស់មន្ត្រីក្នុងស្ថាប័នសុទ្ធតែប្រកបដោយភាពរួបរួមសាមគ្គីគ្នាជាផ្លូងមួយផ្អែកតាមទស្សនវិស័យរួមដែលបានកំណត់ជាក់លាក់។

ក្នុងន័យនេះតាមសិក្សាគោលធម៌ទាំង៦របស់ព្រះពុទ្ធសាសនាដែលនាំឱ្យមានការរួបរួមចិត្តគំនិតហៅថា «សារាណីយធម៌៦»។ សារាណីយធម៌ទាំង៦ជាគោលធម៌ដែលធ្វើឱ្យមនុស្សរស់នៅជាមួយគ្នាដោយសាមគ្គីភាព ភាពសុខសាន្តនិងរួបរួមចិត្តគំនិតគ្នា អនុលោមតាមគោលធម៌សំខាន់ៗដូចតទៅ៖ **ទីមួយ**- មេត្តាកាយកម្ម (ការប្រព្រឹត្តអំពើល្អដោយកាយចំពោះគ្នា ជួយគ្នា) **ទីពីរ**- មេត្តាវចីកម្ម (និយាយពាក្យល្អសុភាពរាបសា ស្មោះត្រង់) **ទីបី**- មេត្តាមនោកម្ម (មានចិត្តល្អចង់ឱ្យអ្នកដទៃបានសុខមិនគិតអាក្រក់) **ទីបួន**- សាធារណភោគី (ចែករំលែកផលប្រយោជន៍និងទ្រព្យសម្បត្តិដោយត្រឹមត្រូវ) **ទីប្រាំ**- សីលសាមញ្ញតា (មានសីលធម៌ស្មើគ្នា គោរពវិន័យ ឬបទប្បញ្ញត្តិដូចគ្នា) និង**ទីប្រាំមួយ**- ទិដ្ឋិសាមញ្ញតា (មានទស្សនៈនិងគោលបំណងស្របគ្នា យល់ឃើញទៅក្នុងទិសដៅដូចគ្នា ដើម្បីប្រយោជន៍រួម)។

សរុបមកគោលធម៌ទាំង៦ចំណុចខាងលើនេះជួយសាងសាមគ្គីភាពនិងស្ថិរភាពឱ្យកើតឡើងក្នុងអង្គភាព ស្ថាប័ន និងសង្គមដែលជាហេតុនាំមកនូវសុខ សន្តិភាព ស្ថិរភាព និងវឌ្ឍនភាព។

**១.៣.៦- បង្កើតភាពជាអ្នកដឹកនាំប្រកបដោយសីលធម៌និងការធ្វើជាគំរូ**

ភាពជាអ្នកដឹកនាំក្នុងក្រមសីលធម៌នគរបាលមិនត្រូវបានកំណត់ដោយឋានៈតួនាទីនោះទេ ប៉ុន្តែគឺដោយសារតែការប្រតិបត្តិសីលធម៌តែប៉ុណ្ណោះ។ អ្នកដឹកនាំប្រកបដោយសីលធម៌ជំរុញឱ្យមានវិន័យនិងប្រតិបត្តិវិន័យបានល្អ មិនមែនតាមរយៈការភ័យខ្លាចនោះទេ ប៉ុន្តែតាមរយៈភាពជាគំរូរបស់អ្នកដឹកនាំ។ ដើម្បីឆ្លុះបញ្ចាំងពីការពិតនេះមានសុភាសិតខ្មែរមួយបានលើកឡើងថា «អ្នកល្អធ្វើឱ្យអ្នកអាក្រក់ប្រសើរឡើង»។ នៅពេលថ្នាក់លើបង្ហាញភាពរួសរាយ រាក់ទាក់ ទន់ភ្លន់ សមធម៌ និងមេត្តាធម៌ អ្នកក្រោមបង្គាប់នឹងយកតម្រាប់តាមគុណតម្លៃទាំងនោះដោយធម្មជាតិនិងដោយក្រមសីលធម៌។

ភាពជាអ្នកដឹកនាំប្រកបដោយអភិសមាចារទាមទារឱ្យការសម្រេចចិត្តដោយយុត្តិធម៌ តម្លាភាព និងការយល់ចិត្ត។ ដូច្នេះមេដឹកនាំត្រូវតែចៀសវាងការពេញចិត្តនិងការពារអ្នកក្រោមបង្គាប់ដែលប្រព្រឹត្ត អំពើអយុត្តិធម៌និងអសីលធម៌។ ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀននិងឧក្រិដ្ឋកម្ម (ឆ្នាំ២០១១) បានសង្កត់ធ្ងន់ថា ភាពជាអ្នកដឹកនាំខាងសីលធម៌កសាងសុចរិតភាពស្ថាប័ន កាត់បន្ថយ អំពើពុករលួយនិងការរំលោភអំណាច។ ដូច្នេះមេដឹកនាំនគរបាលគ្រប់កម្រិតដាច់ខាតត្រូវធ្វើឱ្យមាន តុល្យភាពរវាងអំណាចនិង «ប្រាជ្ញាខាងសីលធម៌» ដោយបញ្ចូលនូវគុណតម្លៃថា «បម្រើ ការពារ សមធម៌ គុណធម៌ ទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត»។

## ២- មូលដ្ឋានគ្រឹះនៃក្រមសីលធម៌មន្ត្រីនគរបាល

ជាការកត់សម្គាល់ផងដែរ ចំពោះក្រមសីលធម៌នៅទីនេះគឺផ្តោតលើក្រមសីលធម៌របស់មន្ត្រី នគរបាលតែម្តង។ ដោយឡែកចំពោះក្រមសីលធម៌ដែលបានលើកឡើងនៅក្នុងផ្នែកទី២ក្រុមការងារ មានបំណងគ្រាន់តែបង្ហាញជូនអំពីសញ្ញាណទូទៅនៃក្រមសីលធម៌គឺមិនចំពោះលើបុគ្គលសាធារណៈ ណាមួយនោះឡើយ។

ការយល់ដឹងអំពីមូលដ្ឋានគ្រឹះខាងក្រមសីលធម៌មន្ត្រីនគរបាល ចាប់ផ្តើមដោយការបំភ្លឺពីគោល គំនិតដែលកំណត់លក្ខណៈឥរិយាបថវិជ្ជាជីវៈ។ សសរស្តម្ភគោលនៃក្រមសីលធម៌មន្ត្រីនគរបាលបាន មកពី **សីលធម៌ សុចរិតភាព និងតម្លៃ**។ ទោះបីជាពាក្យទាំងនេះជារឿយៗត្រូវបានប្រើប្រាស់ជំនួសគ្នា ទៅវិញទៅមកក៏ដោយប៉ុន្តែមានអត្ថន័យខុសៗគ្នាដែលរួមគ្នាបង្កើតបានជាក្របខណ្ឌក្រមសីលធម៌ក្នុង ការអនុវត្តច្បាប់របស់មន្ត្រីនគរបាល។

### ២.១- ក្រមសីលធម៌មន្ត្រីនគរបាល

ក្រមសីលធម៌មន្ត្រីនគរបាល សំដៅលើការសិក្សាជាប្រព័ន្ធអំពីភាពត្រូវនិងខុស ដែលជាគោលការណ៍ ណែនាំដោយកំណត់ថា តើសកម្មភាពអ្វីខ្លះដែលនគរបាលបានអនុវត្តហើយគោរពតាមនិយាមវិជ្ជាជីវៈ ត្រឹមត្រូវដើម្បីទទួលបានទំនុកចិត្តពីសាធារណជន។ នៅក្នុងការងាររបស់នគរបាលក្រមសីលធម៌ផ្តល់ នូវក្របខណ្ឌសម្រាប់ការសម្រេចចិត្តដោយធានាថាមន្ត្រីនគរបាលធ្វើសកម្មភាពមាន ភាពយុត្តិធម៌ ភាព ត្រឹមត្រូវនិងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ក្រមសីលធម៌ដែលបានបង្ហាញខាងលើនេះ មិនត្រឹមតែការប្រកាន់ខ្ជាប់នូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញឱ្យឃើញពីសីលធម៌ក្នុងការអនុវត្ត ច្បាប់របស់នគរបាលក្នុងស្ថានភាពស្មុគស្មាញផងដែរ។

#### ២.១.១- សីលធម៌

សីលធម៌ សំដៅដល់ចំណងទាក់ទងទៅនឹងជំនឿផ្ទាល់ខ្លួន និងបទដ្ឋានសង្គមអំពីភាពខុសនិង ត្រូវ។ វាមានប្រភពចេញពីវប្បធម៌ សាសនា និងចរិតលក្ខណៈផ្ទាល់ខ្លួន ហើយដើរតួជាត្រីវិស័យខាង ក្នុងដែលជះឥទ្ធិពលដល់ការសម្រេចចិត្តខាងក្រមសីលធម៌របស់មនុស្សម្នាក់ៗ។ ខណៈពេលដែលក្រម សីលធម៌ផ្តល់នូវនិយាមវិជ្ជាជីវៈ សីលធម៌ផ្តល់ឱ្យពួកគេនូវដម្រៅអារម្មណ៍ និងវប្បធម៌ដោយធានាថា ឥរិយាបថរបស់មន្ត្រីនគរបាលត្រូវមានទាំង «ភាពស្របច្បាប់និងមនុស្សធម៌»។

**២.១.២- សុចរិតភាព**

សុចរិតភាព សំដៅដល់គុណភាពនៃភាពស្មោះត្រង់ដែលស្ថិតនៅជាប់លាប់ក្នុងគោលការណ៍សីលធម៌និងក្រមសីលធម៌របស់មនុស្ស។ វាបង្កប់ន័យថាជាការធ្វើរឿងត្រឹមត្រូវសូម្បីតែគ្មាននរណាម្នាក់មកតាមដានត្រួតពិនិត្យមើលក៏ដោយ គឺវានៅតែរក្សាភាពស្មោះត្រង់និងតម្លាភាពដែលមិនស្ថិតក្រោមសម្ពាធណាមួយនោះឡើយ។ ក្នុងការងារនគរបាល សុចរិតភាពជាស្នូលដ៏សំខាន់នៃទំនុកចិត្តសាធារណៈ ដោយសារមន្ត្រីនគរបាលត្រូវបានប្រគល់អំណាចនិងការសម្រេចចិត្តច្បាស់លាស់ក្នុងការបំពេញភារកិច្ច។ ក្រមសីលធម៌ណាមួយដែលគ្មានសសរស្តម្ភនៃសុចរិតភាពទេ ក៏មិនមានប្រសិទ្ធភាពពិតប្រាកដបានឡើយ។

**២.១.៣- តម្លៃ**

តម្លៃ សំដៅដល់ជំនឿឬឧត្តមគតិដែលជាគោលការណ៍កំណត់ពីភាពត្រឹមត្រូវ ជាក់លាក់ និងវប្បធម៌ល្អដែលជះឥទ្ធិពលដល់ឥរិយាបថរបស់ មនុស្ស អង្គភាពឬស្ថាប័នតាមការវិភាគវិនិច្ឆ័យត្រឹមត្រូវនិងច្បាស់លាស់។ ចំពោះមន្ត្រីនគរបាល តម្លៃសំដៅដល់ភាពយុត្តិធម៌ ភាពក្លាហាន ការបម្រើ វិន័យ និងការគោរពដែលជាមូលដ្ឋានសីលធម៌ក្នុងកាតព្វកិច្ចប្រចាំថ្ងៃ។ ភាពខ្លាំងនៃស្ថាប័ននគរបាលមិនត្រឹមតែស្ថិតនៅក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងតម្លៃដែលបានទទួលពីការអប់រំបណ្តុះបណ្តាលក្រមសីលធម៌ និងការប្រតិបត្តិជាប្រចាំរបស់មន្ត្រីនគរបាលទាំងអស់ផងដែរ។

សរុបមក ក្រមសីលធម៌កំណត់នូវអ្វីដែល «ត្រឹមត្រូវ» សីលធម៌ជាអ្នក «ជំរុញ» រីឯសុចរិតភាពជាអ្នក «ទ្រទ្រង់» ហើយតម្លៃជាអ្នកកំណត់ឱ្យចេញជាសមិទ្ធផលដែលបានឆ្លងកាត់ការវាយតម្លៃរួចរាល់។

គោលគំនិតទាំងនេះនឹងអាចធានាបានថា អំណាចដែលប្រគល់ឱ្យមន្ត្រីនគរបាលនៅតែចងភ្ជាប់ជាមួយកាតព្វកិច្ចដោយភាពទទួលខុសត្រូវខាងសីលធម៌និងទំនុកចិត្តសាធារណៈដដែល។

**២.២- ក្រមសីលធម៌ក្នុងការបំពេញភារកិច្ច**

**២.២.១- មូលដ្ឋានក្រមសីលធម៌នៃវិន័យ**

ពាក្យថា «វិន័យ» នៅក្នុងកិច្ចការនគរបាល គឺលើសពីប្រព័ន្ធច្បាប់វាគឺជាសណ្តាប់ធ្នាប់សីលធម៌ដែលទ្រទ្រង់ភាពជាវិជ្ជាជីវៈ។ នៅកម្ពុជាពាក្យ «វិន័យ» ត្រូវបានចាក់ឫសយ៉ាងជ្រៅទាំងនៅក្នុងការបង្រៀនរបស់ព្រះពុទ្ធសាសនានិងវប្បធម៌ខ្មែរ។ នៅក្នុងប្រពៃណីព្រះពុទ្ធសាសនាវិន័យតំណាងឱ្យក្រមសីលធម៌ ដែលរក្សាសុខដុមរមនានិងភាពបរិសុទ្ធនៅក្នុងចរិតនិងសកម្មភាពរបស់ព្រះសង្ឃ។ ស្រដៀងគ្នានេះដែរ នៅក្នុងស្ថាប័ននគរបាលវិន័យធានានូវ «ឯកភាព ការគោរពឋានានុក្រម និងការប្រព្រឹត្តស្របច្បាប់» ក្នុងចំណោមមន្ត្រីនគរបាលទូទៅ។

បទវិន័យមន្ត្រីនគរបាល (ឆ្នាំ២០២៤) របស់ក្រសួងមហាផ្ទៃថ្មី បានគូសបញ្ជាក់អំពីការរំពឹងទុកនៃឥរិយាបថនិងអាកប្បកិរិយាសម្រាប់មន្ត្រីនគរបាល ដែលគ្របដណ្តប់ទៅលើភាពស្មោះត្រង់ ការស្តាប់បង្គាប់ ឧស្សាហ៍ព្យាយាម ការគោរពអាជ្ញាធរ និងការបម្រើសាធារណៈ។ វិន័យត្រូវតែមានទាំងឥរិយាបថខាងក្នុងនិងឥរិយាបថខាងក្រៅ។ មានន័យថាវិន័យខាងក្រៅ កើតចេញពីការត្រួតពិនិត្យ បទប្បញ្ញត្តិនិងទណ្ឌកម្ម រីឯវិន័យខាងក្នុងដែលមានលក្ខណៈស្ថិតស្ថិរជាង កើតចេញពីសតិសម្បជញ្ញៈ គុណធម៌និងការគ្រប់គ្រងខ្លួនឯង។

អាស្រ័យហេតុនេះ «វិន័យ» ត្រូវតែបានអនុវត្តយ៉ាងម៉ឺងម៉ាត់ប៉ុន្តែដោយសមធម៌បំផុត។ ដោយឡែកចំពោះទណ្ឌកម្មវិញ គឺជាឧបករណ៍សម្រាប់កែតម្រូវមិនមែនការបន្ទាបបន្ថោកនោះទេ។ កន្លងមកមានឯកសារលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីនគរបាលជាតិ (ឆ្នាំ១៩៩៥) និងបច្ចុប្បន្នមានបទវិន័យមន្ត្រីនគរបាលរបស់ក្រសួងមហាផ្ទៃ (ឆ្នាំ២០២៤) បានបង្កើតជាយន្តការសម្រាប់គណនេយ្យភាពផ្នែករដ្ឋបាលនិងព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក្តីវិន័យប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងការស្តារនីតិ-សម្បទាផងដែរ។ មន្ត្រីដែលទទួលស្គាល់កំហុសនិងស្វែងរកការកែទម្រង់គួរតែត្រូវបានគាំទ្រតាមរយៈការប្រឹក្សាយោបល់ដែលផ្អែកលើមូលដ្ឋាននៃសីលធម៌និងការបណ្តុះបណ្តាលផងដែរ។ វិន័យពិតប្រាកដគឺមានលក្ខណៈកែទម្រង់ចរិតលក្ខណៈមិនមែនគ្រាន់តែដាក់ទណ្ឌកម្មអាកប្បកិរិយាប៉ុណ្ណោះទេ។ ដូចនៅក្នុងក្រមសីលធម៌ព្រះពុទ្ធសាសនាដែរ ការកែប្រែចិត្តគឺជាផ្លូវទៅកាន់ភាពបរិសុទ្ធនិងការបន្តជាថ្មី។

**២.២.២- មូលដ្ឋានគណនេយ្យភាពនិងទំនួលខុសត្រូវ**

គណនេយ្យភាព គឺជាកាតព្វកិច្ចខាងសីលធម៌របស់មន្ត្រីគ្រប់រូបដើម្បីទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួនដោយមានការបើកចំហរនិងអធិប្បាយអំពីសនិទានកម្ម។ វាធានាថាអំណាចដែលបានប្រគល់ឱ្យនគរបាលនឹងមិនក្លាយជាការរំលោភបំពានឡើយ។ នៅកម្ពុជាគណនេយ្យភាពត្រូវបានចែងនៅក្នុងទាំងច្បាប់ស្តីពីលក្ខន្តិកៈនគរបាលជាតិ (ឆ្នាំ១៩៩៥) និងក្របខណ្ឌវិន័យរបស់ក្រសួងមហាផ្ទៃដែលតម្រូវឱ្យមន្ត្រីទាំងអស់ស្ថិតនៅក្រោមការវាយតម្លៃ ការត្រួតពិនិត្យ និងការទទួលខុសត្រូវផ្នែកច្បាប់។

ការទទួលខុសត្រូវមានន័យថា ភាពក្លាហានក្នុងការទទួលស្គាល់កំហុសផងដែរ វាជាកិត្តិយសក្នុងភាពជាគំរូក្នុងការទទួលស្គាល់កំហុសជាជាងការលាក់បាំង។ ជាពិសេសថ្នាក់ដឹកនាំត្រូវតែធ្វើជាគំរូនៃគុណធម៌នេះ ដោយបង្ហាញឱ្យអ្នកក្រោមបង្គាប់ឃើញពីការរក្សាអំណាច ជាជាងការធ្វើឱ្យអំណាចចុះទន់ខ្សោយដែលបណ្តាលមកពីគុណធម៌និងសីលធម៌។ ពាក្យថាទំនួលខុសត្រូវរបស់មន្ត្រីនគរបាលនេះមានលក្ខណៈស្រដៀងគ្នានឹងគណនេយ្យភាពដែរ ប៉ុន្តែវាជាកាតព្វកិច្ចរបស់បុគ្គលនិង/ឬស្ថាប័នរួមបញ្ចូលទាំងទំនួលខុសត្រូវខាងការអនុវត្តច្បាប់និងខាងសីលធម៌ផងដែរ។ មន្ត្រីនគរបាលត្រូវតែចងចាំថាកាតព្វកិច្ចរបស់ពួកគេមិនត្រូវបានកំណត់ត្រឹមការអនុវត្តច្បាប់នោះទេ ប៉ុន្តែលាតសន្ធឹងដល់ការរក្សាសន្តិភាព ការការពារប្រជាពលរដ្ឋការបម្រើសេវា និងការលើកកម្ពស់ភាពសុខដុមរមនាក្នុងសង្គម។ ក្នុងទ្រឹស្តីព្រះពុទ្ធសាសនានៃអាជីវៈដ៏ត្រឹមត្រូវបានលើកទឹកចិត្តបុគ្គល ឱ្យបំពេញកាតព្វកិច្ចរបស់ពួកគេដោយមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃឬកេងប្រវ័ញ្ចតំណែងរបស់ពួកគេឡើយ។ ដូច្នេះគណនេយ្យភាពនិងទំនួលខុសត្រូវក្នុងកិច្ចការនគរបាលជាក្រមសីលធម៌វិជ្ជាជីវៈនិងវិន័យខាងអារម្មណ៍ផ្លូវចិត្តនៃដួងព្រលឹង។

**២.២.៣- មូលដ្ឋានយុត្តិធម៌និងសមធម៌**

**យុត្តិធម៌** គឺជាខ្លឹមសារខាងសីលធម៌នៃកិច្ចការនគរបាល វាជាបញ្ញត្តិស្របច្បាប់ផង និងជាកាតព្វកិច្ចខាងវិញ្ញាណផង។ ការបង្រៀនព្រះពុទ្ធសាសនាស្តីពី «កម្ម» បានរំឮកមន្ត្រីនគរបាលថារាល់ទង្វើទាំងអស់បង្កើតផលវិបាកខាងសីលធម៌។ ការអនុវត្តច្បាប់ដោយអយុត្តិធម៌តាមរយៈការរើសអើងភាពលម្អៀងឬការពេញចិត្តគឺជាការបង្កើតទុក្ខវេទនានិងអយុត្តិធម៌សម្រាប់អ្នកដទៃនិងសម្រាប់ខ្លួនឯង។

នៅកម្ពុជា យុត្តិធម៌ត្រូវតែផ្តល់ឱ្យសង្គមដោយគ្មានការរើសអើង កងកម្លាំងនគរបាលទាំងអស់បម្រើប្រជាពលរដ្ឋដោយស្មើភាពគ្នាមិនគិតពីទ្រព្យសម្បត្តិ និន្នាការនយោបាយឬឋានៈសង្គមឡើយ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៣១-៣២) ជានាភាពស្មើគ្នាចំពោះមុខច្បាប់និងហាមឃាត់ការចាប់ខ្លួនតាមអំពើចិត្ត។ ដូចនេះមន្ត្រីនគរបាលគឺជាអ្នកការពារនិងជាអ្នកបម្រើរាល់សិទ្ធិទាំងនេះ។

**សមធម៌** មានន័យថាការផ្តល់ឱកាសដល់មនុស្សគ្រប់រូបឱ្យបានស្តាប់និងប្រព្រឹត្តដោយការគោរព វាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍នៃយុត្តិធម៌នីតិវិធីដែលសង្កត់ធ្ងន់លើសមធម៌នៃដំណើរការមិនត្រឹមតែលទ្ធផលប៉ុណ្ណោះទេ។ ឧទាហរណ៍ នៅពេលមន្ត្រីនគរបាលពន្យល់ពីការសម្រេចចិត្តរបស់ពួកគេអំពីការផាកពិន័យឬការឆែកឆេរដល់ប្រជាពលរដ្ឋ ពួកគេនឹងត្រូវពន្យល់ហេតុផលឱ្យប្រជាពលរដ្ឋយល់ឃើញអំពីភាពសមធម៌របស់ពួកគេ។ ទោះបីមានប្រជាពលរដ្ឋខ្លះមិនយល់ស្របនឹងលទ្ធផលណាមួយក៏ដោយត្រូវតែព្យាយាមបកស្រាយពន្យល់ដោយឥរិយាបថថ្លៃថ្នូរ សមរម្យដល់ពួកគេ។

នៅក្នុងសង្គមខ្មែរ ឥរិយាបថគំរូនៃភាពចាស់ទុំតែងតែមានឥទ្ធិពលលើទំនាក់ទំនងនៃកិច្ចការនគរបាលក្នុងសីលធម៌វិជ្ជាជីវៈ។ ដូចនេះ នគរបាលត្រូវតែសម្របសម្រួលគ្រប់និន្នាការទាំងអស់ដោយមនសិការវិជ្ជាជីវៈ ដើម្បីជានាភាពមិនលម្អៀងក្នុងការអនុវត្តច្បាប់។ មន្ត្រីនគរបាលត្រូវតែចាំថា យុត្តិធម៌មិនមែនជាឯកសិទ្ធិនោះទេ ប៉ុន្តែជាសិទ្ធិពីកំណើត។ ការប្រព្រឹត្តដោយសមធម៌ គឺដើម្បីគោរពទាំងច្បាប់រដ្ឋនិងច្បាប់ធម៌ ដែលជាច្បាប់សកលនៃសុចរិតភាពមាននៅក្នុងសង្គម។

### ២.២.៤- មូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស

ការគោរពសិទ្ធិមនុស្ស គឺជាសញ្ញាណកំណត់នៃការអនុវត្តច្បាប់របស់កម្លាំងនគរបាលសម័យទំនើប។ រដ្ឋធម្មនុញ្ញកម្ពុជា (ឆ្នាំ១៩៩៣) និងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៤៨) បានបញ្ជាក់ថាមនុស្សទាំងអស់កើតមកមានសេរីភាពនិងសិទ្ធិស្មើៗគ្នាក្នុងសេចក្តីថ្លៃថ្នូរនិងកិត្តិយស។ គោលការណ៍នេះមានន័យថា គ្មាននរណាម្នាក់នៅពីលើច្បាប់នោះទេសូម្បីតែមន្ត្រីនគរបាលខ្លួនឯងដែលជាអ្នកអនុវត្តច្បាប់ក៏ដោយ គឺត្រូវតែគោរពតាមគោលការណ៍នេះដែរ។

ការគោរពសិទ្ធិមនុស្ស មិនបានធ្វើឱ្យកិច្ចការនគរបាលចុះខ្សោយនោះទេ វាធ្វើឱ្យនគរបាលមានភាពស្របច្បាប់។ ក្នុងន័យនេះមន្ត្រីនគរបាលត្រូវតែប្រព្រឹត្តចំពោះជនសង្ស័យ ជនជាប់ឃុំ និងជនរងគ្រោះដោយមនុស្សធម៌ និងមេត្តាធម៌។ ការប្រើកម្លាំងហួសហេតុ ការបន្ទាបបន្ថោក ឬការជេរប្រមាថតាមពាក្យសំដី មិនត្រឹមតែជាការរំលោភបំពានខាងវិន័យប៉ុណ្ណោះទេ តែវាជាការបរាជ័យខាងសីលធម៌ដែលបំផ្លាញកិត្តិយសសេចក្តីថ្លៃថ្នូររបស់អង្គភាពឬស្ថាប័នផងដែរ។

ការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្សដែលបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់បណ្ឌិត្យសភា-នគរបាលជាតិកម្ពុជាចាប់តាំងពីឆ្នាំ២០១០មក បានលើកទឹកចិត្តមន្ត្រីនគរបាលទូទាំងប្រទេសឱ្យយល់ដឹងពីការផ្សារភ្ជាប់រវាងការអនុវត្តច្បាប់និងការអប់រំខាងសីលធម៌។ មន្ត្រីដែលមានវិជ្ជាជីវៈពិតប្រាកដបានអនុវត្តច្បាប់ដោយភាពម៉ឺងម៉ាត់ដោយមិនបានប្រព្រឹត្តអំពើឃោរឃៅនោះឡើយ។ ដូចដែលព្រះពុទ្ធបានផ្តល់ឱវាទប្រៀនប្រដៅមនុស្សលោកថា «ការស្អប់មិនដែលត្រូវបានរំសាយដោយការស្អប់ឡើយ តែដោយសេចក្តីស្រលាញ់ប៉ុណ្ណោះ»។

### ២.២.៥- មូលដ្ឋាននៃការប្រើសិទ្ធិអំណាច

#### ក- លក្ខណៈនៃភាពលំបាកផ្នែកសីលធម៌ក្នុងកិច្ចការនគរបាល

មន្ត្រីនគរបាលតែងតែប្រឈមមុខនឹងភាពលំបាកខាងផ្នែកសីលធម៌។ ស្ថិតក្នុងស្ថានភាពនេះហើយ រាល់ជម្រើសទាំងអស់សុទ្ធតែមានផលវិបាកក្នុងការសម្រេចចិត្ត។ ឧទាហរណ៍ ដូចជាថា តើមន្ត្រី

នគរបាលត្រូវប្រើកម្លាំងក្នុងស្ថានភាពគ្រប់គ្រងជម្លោះឬអំពើហិង្សាដោយរបៀបណា? ហើយត្រូវប្រើរបៀបដោះស្រាយក្នុងការរក្សាព័ត៌មានសម្ងាត់ដូចម្ដេច និងក្នុងស្ថានភាពបែបណា ឬពេលណាដែលត្រូវចាប់ខ្លួនជនល្មើសជាអនីតិជន។ ផលលំបាកផ្នែកសីលធម៌ ទាមទារឱ្យមានការរែកញែកខាងសីលធម៌ មិនមែនត្រឹមតែចំណេះដឹងផ្នែកច្បាប់នោះទេ។ ច្បាប់ប្រាប់មន្ត្រីនគរបាលថា «អ្វីដែលពួកគេអាចធ្វើបាន» ប៉ុន្តែក្រមសីលធម៌សួរថា «អ្វីដែលពួកគេគួរធ្វើ»។ យោងតាមទស្សនៈរបស់លោក Pollock (ឆ្នាំ២០១៤) បានបង្ហាញថា ការសម្រេចចិត្តប្រកបដោយសីលធម៌ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណនូវគុណតម្លៃដ៏ត្រឹមត្រូវក្នុងវិជ្ជាជីវៈនគរបាល។

នៅក្នុងបរិបទប្រទេសកម្ពុជា ភាពលំបាកទាំងនេះតែងតែពាក់ព័ន្ធនឹងការធ្វើឱ្យមានតុល្យភាពរវាងកាតព្វកិច្ចច្បាប់ជាមួយតម្លៃនៃវប្បធម៌។ ឧទាហរណ៍ ការបង្ហាញមេត្តាធម៌ដល់ជនល្មើសដែលក្រីក្រ ឬនៅវ័យក្មេង ក្នុងខណៈពេលដែលការងារមន្ត្រីនគរបាលជាអ្នករកយុត្តិធម៌ជូនជនរងគ្រោះ។ ការណ៍នេះមន្ត្រីត្រូវតែអនុវត្តការវិនិច្ឆ័យតាមប្រាជ្ញារបស់ខ្លួនស្របនឹងគុណធម៌ព្រះពុទ្ធសាសនាដែលរួមបញ្ចូលនូវការយល់ដឹងខាងក្រមសីលធម៌ជាមួយការវិនិច្ឆ័យតាមផ្លូវច្បាប់ជាក់ស្ដែងផងដែរ។

**ខ- គំរូនៃការសម្រេចចិត្តប្រកបដោយសីលធម៌៤ជំហាន**

ដើម្បីជួយមន្ត្រីនគរបាលក្នុងការដោះស្រាយភាពលំបាកខាងផ្នែកសីលធម៌ជាក់ស្ដែងអាចត្រូវបានអនុវត្តតាមគំរូ៤ជំហានដូចខាងក្រោម៖

**១- ការទទួលស្គាល់** (Recognition) កំណត់បញ្ហាសីលធម៌ឱ្យច្បាស់លាស់ តើមានហេតុផលអ្វីខ្លះដែលនាំឱ្យមានជម្លោះ? តើអ្នកណាខ្លះនឹងរងផលប៉ះពាល់ដោយការសម្រេចចិត្តណាមួយ?។

**២- ការឆ្លុះបញ្ចាំង** (Reflection) ពិចារណាគោលការណ៍សីលធម៌ដែលពាក់ព័ន្ធនឹងមេត្តាធម៌ ភាពស្មោះត្រង់ សមធម៌ ភាពស្របច្បាប់ និងចេតនាផ្ទាល់ខ្លួនដែលបានឆ្លុះបញ្ចាំងលើភាពលម្អៀង។

**៣- ការដោះស្រាយ** (Resolution) វាយតម្លៃជម្រើសដែលអាចធ្វើបាន ជ្រើសរើសសកម្មភាពដែលធ្វើឱ្យមានតុល្យភាពល្អបំផុតរវាងកាតព្វកិច្ចសីលធម៌ មេត្តាធម៌ និងផ្លូវច្បាប់។

**៤- ការពិនិត្យឡើងវិញ** (Review) បន្ទាប់ពីឆ្លុះបញ្ចាំងលើលទ្ធផលសម្រេចបានត្រូវសួរថា តើយុត្តិធម៌ត្រូវបានអនុវត្តឬទេ? តើសិទ្ធិមនុស្សត្រូវបានគោរពទេ? តើមានអ្វីខ្លះដែលត្រូវបានកែលម្អ?

គំរូទាំងបួននេះ លើកទឹកចិត្តមន្ត្រីនគរបាលប្រតិបត្តិតាមដោយគំនិត ការគិតទុកជាមុន និងភាពរាបសាទន់ភ្លន់តែម៉ឺងម៉ាត់បំផុត។ គំរូទាំងនេះបានផ្លាស់ប្ដូរភាពច្របូកច្របល់ខាងសីលធម៌ទៅជាភាពច្បាស់លាស់ខាងសីលធម៌និងបានបង្ហាញថា កិច្ចការនគរបាលប្រកបដោយសីលធម៌គឺជាការគិតគូរល្អិតល្អន់មិនមែនការបំផុសគំនិតភ្លាមៗដោយគ្មានវិចារណញ្ញាណនោះទេ។

**គ- ការធ្វើឱ្យមានតុល្យភាពរវាងភក្ដីភាពនិងភាពស្របច្បាប់**

ភាពតានតឹងផ្នែកសីលធម៌ទូទៅនៅក្នុងកិច្ចការនគរបាលកើតឡើងរវាង ភក្ដីភាពចំពោះថ្នាក់លើឬមិត្តរួមការងារនិងភក្ដីភាពចំពោះច្បាប់។ វប្បធម៌នគរបាលកម្ពុជាឱ្យតម្លៃនៃការគោរពចំពោះថ្នាក់ដឹកនាំតាមឋានានុក្រម។ ប៉ុន្តែសុចរិតភាពនៃសីលធម៌ទាមទារឱ្យមន្ត្រីនគរបាលកម្ពុជាត្រូវតែដាក់ច្បាប់ និងផលប្រយោជន៍សាធារណៈនៅពីលើភក្ដីភាពផ្ទាល់ខ្លួនចំពោះថ្នាក់លើ។

ក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិ (មាត្រា៨) និងក្របខណ្ឌវិន័យរបស់ក្រសួងមហាផ្ទៃ (ឆ្នាំ២០១២) សង្កត់ធ្ងន់ថា បញ្ជាមិនស្របច្បាប់មិនត្រូវគោរពតាមឡើយ។ ភក្ដីភាពពិតប្រាកដស្ថិតនៅ

ក្នុងការគោរពគោលការណ៍នៃយុត្តិធម៌និងការការពារកិត្តិយសរបស់ស្ថាប័ន ទោះបីជាវាមានន័យថាការប្រឆាំងនឹងបទបញ្ជាដែលគ្មានសីលធម៌ក៏ដោយ។ ដូចដែលព្រះពុទ្ធបានទូន្មានថា «ពាក្យមួយពាក្យដែលនាំមកនូវសន្តិភាពប្រសើរជាងពាក្យទទេមួយពាន់ពាក្យដែលគ្មានបានការ»។ ជួនកាលពាក្យនោះសំដៅដល់ពាក្យថា «ទេ» ដែលនិយាយដោយការគោរព ប៉ុន្តែម៉ឺងម៉ាត់ក្នុងការការពារអ្វីដែលត្រឹមត្រូវ។

## ២.៣- ការប្រព្រឹត្តខុស ការរំលោភអំណាច និងអំពើពុករលួយ

### ២.៣.១- លក្ខណៈនៃការប្រព្រឹត្តខុស

ការប្រព្រឹត្តខុសនៅក្នុងកិច្ចការនគរបាលមិនមែនគ្រាន់តែជាការបំពានច្បាប់នោះទេគឺជាការក្បត់នឹងជំនឿទុកចិត្តខាងក្រមសីលធម៌។ រាល់ទង្វើនៃភាពមិនស្មោះត្រង់ ការឆ្វេសប្រហែស ការរំលោភបំពានបានបំផ្លាញភាពជឿជាក់នៃស្ថាប័នទាំងមូល។ ក្នុងបរិបទនៅប្រទេសកម្ពុជាការប្រព្រឹត្តខុសរបស់មន្ត្រីតែងមានទម្រង់ដូចជាការប្រើអំណាចខុស ការទទួលសំណូក ការប្រកាន់យកក្រុមបក្ខពួក ឬការធ្វេសប្រហែសក្នុងការបំពេញកាតព្វកិច្ច។ ទង្វើទាំងនេះបានក្បត់ទាំងក្រមសីលធម៌វិជ្ជាជីវៈ (ក្រសួងមហាផ្ទៃ ឆ្នាំ២០២៤) និងច្បាប់ប្រឆាំងអំពើពុករលួយ (ឆ្នាំ២០១០)។ ការប្រព្រឹត្តខុសកើតឡើងនៅពេលមន្ត្រីភ្លេចពីគោលបំណងសីលធម៌នៃអំណាចរបស់ពួកគេ។ ឯកសណ្ឋានមិនមែនជានិមិត្តសញ្ញានៃឯកសិទ្ធិនោះទេប៉ុន្តែវាជាទំនួលខុសត្រូវ។ មន្ត្រីនគរបាលត្រូវតែឆ្លុះបញ្ចាំងជានិច្ចថា តើសកម្មភាពរបស់ខ្លួនបានបម្រើផលប្រយោជន៍អ្វីខ្លះដល់ស្ថាប័ននិងសង្គម?។ ដូចលោកPunch (ឆ្នាំ២០០៩) បានសង្កេតឃើញថា «អំពើពុករលួយរបស់នគរបាលរីកចម្រើននៅកន្លែងដែលភាពស្ងៀមស្ងាត់ខាងសីលធម៌ក្លាយជាវប្បធម៌ស្ថាប័ន»។ មានន័យថាភាពស្ងៀមស្ងាត់ខាងសីលធម៌សំដៅដល់មន្ត្រីដឹងថា មានអំពើខុស តែមិននិយាយ មិនរាយការណ៍ មិនតវ៉ា មិនបដិសេធ មិនមែនមិនដឹងថាខុសទេ ប៉ុន្តែជ្រើសរើសភាពស្ងៀមស្ងាត់ ដែលភាពស្ងៀមស្ងាត់នេះគឺជារបៀប «ការពារខ្លួន» និង «ការពារក្រុម»។ សកម្មភាពនៃភាពស្ងៀមស្ងាត់ទាំងនេះនឹងក្លាយជាវប្បធម៌របស់ស្ថាប័នដែលទទួលយកភាពស្ងៀមស្ងាត់មិននិយាយមិនចោទប្រកាន់និងមិនដាក់ទោស។ ការចោទប្រកាន់ចាប់មនុស្សប្រព្រឹត្តខុសមិនទាន់គ្រប់គ្រាន់ទេ ប៉ុន្តែត្រូវកែប្រែឬបំផ្លាញវប្បធម៌ស្ងៀមស្ងាត់ដោយបង្កើតវប្បធម៌និយាយការពិតនិងការពារអ្នករាយការណ៍។

### ២.៣.២- ការរំលោភអំណាច

ការរំលោភអំណាច គឺជាការរំលោភបំពានសីលធម៌ដ៏ធ្ងន់ធ្ងរបំផុតមួយក្នុងកិច្ចការនគរបាល វាកើតឡើងនៅពេលដែលអំណាចត្រូវបានប្រើប្រាស់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ការសងសឹក និងការគាបសង្កត់។ យោងតាមសន្ធិសញ្ញាអន្តរជាតិមួយរបស់អង្គការសហប្រជាជាតិហៅកាត់ថា ICCPR ដែលមានគោលបំណងលើកស្ទួយសិទ្ធិមូលដ្ឋានរបស់មនុស្សក្នុងវិស័យពលរដ្ឋនិងនយោបាយបានលើកឡើងក្នុង (មាត្រា៧និង៩) និងរដ្ឋធម្មនុញ្ញកម្ពុជាបានហាមឃាត់ការចាប់ខ្លួនតាមអំពើចិត្តនិងការប្រព្រឹត្តហិង្សាដ៏ឃោរឃៅ។ ចំណុចនេះបញ្ជាក់ថាមន្ត្រីអនុវត្តច្បាប់គប្បីប្រព្រឹត្តក្នុងក្របខណ្ឌច្បាប់ជាធរមាន។

បញ្ហាប្រឈមខាងសីលធម៌នៃអំណាចគឺ «ការល្បួងលោម» អំណាចអាចបង្ហាញចរិតលក្ខណៈ ឬធ្វើឱ្យចរិតលក្ខណៈមានគុណវិបត្តិប្រសិនបើការប្រើក្នុងគោលបំណងទុច្ចរិត។ មន្ត្រីប្រកបដោយសីលធម៌បានទទួលស្គាល់ថា «អំណាចពិតមិនស្ថិតនៅក្នុងការគ្រប់គ្រងនោះទេប៉ុន្តែនៅក្នុងការបម្រើ»។ ការប្រើអំណាចដោយឈ្លាសវៃមានន័យថាជាការអនុវត្តច្បាប់ដោយសមធម៌ ការការពារសិទ្ធិនិងការអត់ធ្មត់។

គោលការណ៍ព្រះពុទ្ធសាសនានៃសង្កប្បៈដ៏ត្រឹមត្រូវបានរំឭកមន្ត្រីថា ទង្វើត្រូវតែត្រូវបានជំរុញដោយមេត្តាធម៌ មិនមែនជាកំហឹងឬលោភៈនោះឡើយ។

**២.៣.៣- ទម្រង់នៃអំពើពុករលួយ**

អំពើពុករលួយគឺជាបញ្ហាសង្គមនិងបញ្ហាអភិបាលកិច្ចដ៏ស្មុគស្មាញមួយដែលមានឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍសេដ្ឋកិច្ច សេចក្តីយុត្តិធម៌ និងការជឿទុកចិត្តរបស់សាធារណជនចំពោះស្ថាប័នរដ្ឋ។ ដើម្បីយល់ដឹងអំពីលក្ខណៈនិងវិសាលភាពនៃបញ្ហានេះ ការយល់ដឹងអំពីទម្រង់នៃអំពើពុករលួយមានសារៈសំខាន់ជាពិសេស។ ដូចបានជ្រាបរួចមកហើយ អំពើពុករលួយមិនមែនជាបាតុភូតថ្មីទេ ប៉ុន្តែវាជាបញ្ហាដែលកើតមានក្នុងសង្គមជាច្រើននិងបង្ហាញខ្លួនក្នុងទម្រង់ផ្សេងៗគ្នា។

ការយល់ដឹងអំពីទម្រង់នៃអំពើពុករលួយនឹងជួយឱ្យមន្ត្រីនគរបាលអាចកំណត់អត្តសញ្ញាណនៃបញ្ហាបានច្បាស់ ដើម្បីស្វែងរកវិធានការការពារនិងទប់ស្កាត់បានប្រសើរឡើង។ ក្នុងបរិបទនៃការពង្រឹងអភិបាលកិច្ចល្អនិងនីតិរដ្ឋអំពើពុករលួយត្រូវបានចាត់ទុកថាជាឧបសគ្គដ៏ធំមួយក្នុងការអភិវឌ្ឍស្ថាប័ន។ បញ្ហានេះមិនកើតឡើងតែជាទង្វើបុគ្គលទេប៉ុន្តែអាចបង្ហាញខ្លួនជាទម្រង់ចម្រុះជាប្រព័ន្ធនៅក្នុងអង្គភាពឬស្ថាប័ន។

ដូច្នេះការពិភាក្សាអំពីទម្រង់នៃអំពើពុករលួយគឺជាជំហានដំបូងដ៏ចាំបាច់ដូចខាងក្រោម៖

**- អំពើពុករលួយផ្នែកហិរញ្ញវត្ថុ** ជាទម្រង់នៃអំពើពុករលួយទាក់ទងនឹងការទទួលយកសំណូកធ្វើជាផលប្រយោជន៍ផ្ទាល់ខ្លួនឬ ជាការស្នើសុំសំណូក ព្រមទាំងជាការកិបកេង និងការប្រើប្រាស់ធនធានខុសពីផលប្រយោជន៍រួម

**- អំពើពុករលួយផ្នែកសីលធម៌** ជាទម្រង់នៃការប្រើអំណាចដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឬមិនសមរម្យដូចជាការបង្កើតបក្ខពួក ការរើសអើង និងការរំលោភបំពានសិទ្ធិ ឬឋានៈរបស់អ្នកដទៃ

**- អំពើពុករលួយស្ថាប័ន** ជាទម្រង់បង្ហាញអំពីការអនុវត្តអ្វីមួយនៅក្នុងស្ថាប័ន ដែលជាសកម្មភាពបំពានច្បាប់និងក្រមសីលធម៌នាំឱ្យកើតមានការប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធក្នុងស្ថានភាពដែលស្ថាប័នទទួលយកនូវវប្បធម៌នៃភាពស្ងៀមស្ងាត់ មិននិយាយមិនចោទប្រកាន់ និងមិនដាក់ទោស។

**២.៣.៤- ការបង្ការអំពើពុករលួយ**

នៅក្នុងសង្គមខ្មែរ ការប្រយុទ្ធប្រឆាំងអំពើពុករលួយមិនមែនត្រឹមតែជាផ្នែកច្បាប់ប៉ុណ្ណោះទេ តែជាផ្នែកមួយនៃវប្បធម៌និងសីលធម៌ផងដែរ។ គុណធម៌នៃភាពស្មោះត្រង់និងសុចរិតភាពត្រូវតែដឹកនាំមន្ត្រីទាំងអស់ឱ្យប្រកាន់ខ្ជាប់ជាដរាប។ ការធ្វើឱ្យមានតម្លាភាពតាមរយៈការត្រួតពិនិត្យ និងការប្រកាសទ្រព្យសម្បត្តិនឹងជួយពង្រឹងគណនេយ្យភាពក្នុងការលើកកម្ពស់ ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ ប៉ុន្តែយើងនៅតែការមានការជឿជាក់លើ «សីលធម៌» ដែលអាចធ្វើឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ខាងក្រោមនេះ ជាការបង្ហាញឱ្យបានឈ្វេងយល់អំពីការងារបង្ការតាមវិធានមួយចំនួនដែលថ្នាក់ដឹកនាំនិងមន្ត្រីនគរបាលត្រូវតែប្រកាន់ខ្ជាប់និងអនុវត្តឱ្យខាងតែបាននូវវប្បធម៌សុចរិតភាពដែលគាំទ្រដោយភាពជាអ្នកដឹកនាំនិងការអប់រំ៖

**១- ការបណ្តុះបណ្តាលក្រមសីលធម៌** ការងារនេះត្រូវបានទាមទារឱ្យមានការបណ្តុះបណ្តាលឱ្យបានជាប្រចាំនិងការពង្រឹងផ្នែកសីលធម៌ តាមរយៈការបណ្តុះវប្បធម៌សីលធម៌នៅក្នុងស្ថាប័នឱ្យបាន

ទូលំទូលាយជាប្រចាំក្នុងវគ្គបណ្តុះបណ្តាលរយៈពេលវែង-ខ្លី ក្នុងកម្មវិធីសិក្សារបស់នគរបាលនៅតាមសាលាបណ្តុះបណ្តាលនានា និងនៅក្នុងអង្គភាពឬស្ថាប័នសាមី។

**២- ប្រព័ន្ធតម្លាភាពនៃការដំឡើងឋានៈតួនាទី** ការងារនេះនៅតាមបណ្តាអង្គភាពឬស្ថាប័នត្រូវតែអនុវត្តដោយផ្អែកលើសីលធម៌ គុណធម៌ និងសមធម៌មិនមែនជាការឧបត្ថម្ភនោះទេ។ ជាក់ស្តែងចំពោះការលើកទឹកចិត្តនានាត្រូវផ្អែកលើមូលដ្ឋានគុណភាពបំពេញការងាររបស់មន្ត្រីដែលចាំបាច់ត្រូវវាយតម្លៃឈរលើមូលដ្ឋាននៃគោលការណ៍ «គុណាធិបតេយ្យ Meritocracy» ដែលមានអត្ថន័យថា ជាការវាយតម្លៃផ្អែកលើសមត្ថភាព គុណសម្បទា គុណូបការៈ មិនមែនលើប្រយោជន៍និងឋានៈសង្គមឡើយ។

**៣- អង្គភាពត្រួតពិនិត្យផ្ទៃក្នុង** សំដៅដល់ស្ថាប័នដែលមានអំណាចក្នុងការស៊ើបអង្កេតនិងដាក់ទណ្ឌកម្មលើការរំលោភបំពានច្បាប់និងបទវិន័យតាមសមត្ថកិច្ចដែលរដ្ឋប្រគល់ជូន។ ទន្ទឹមនេះនៅកម្ពុជាមានច្បាប់ប្រឆាំងអំពើពុករលួយ (ឆ្នាំ២០១០) ដើម្បីដាក់ទោសទណ្ឌលើការសូកប៉ាន់ ការកិបកេង និងការរំលោភអំណាចជាដើម។ល។ ដែលតម្រូវឱ្យស្ថាប័នមានសមត្ថកិច្ចអនុវត្តឱ្យមានប្រសិទ្ធភាព។

**៤- ការចូលរួមជាមួយសាធារណជន** សំដៅដល់ការលើកទឹកចិត្តនូវមតិកែលម្អនិងជំនឿទុកចិត្តពីសហគមន៍។ ជំនឿទុកចិត្តរបស់សាធារណជនគឺជាកញ្ចក់ឆ្លុះអំពី «សីលធម៌» ដើម្បីបង្ការនូវរាល់ការប្រព្រឹត្តខុសរបស់មន្ត្រីសាធារណៈ ហើយចំណុចនេះមិនមែនជាទំនួលខុសត្រូវរបស់ថ្នាក់លើតែម្នាក់ឯងនោះទេវាគឺជាកាតព្វកិច្ចរួមរបស់មន្ត្រីគ្រប់រូបដែលឱ្យតម្លៃកិត្តិយសស្ថាប័ននិងស្លាកសញ្ញាស្ថាប័ន។



**ការគោរពក្រមសីលធម៌របស់នគរបាល ពិតជាបម្រើប្រជាពលរដ្ឋដោយ**
**សុចរិតនិងយុត្តិធម៌ពិតប្រាកដនគរបាលមានសីលធម៌ជាគ្រឹះនៃទំនុកចិត្តនិងសន្តិសុខសង្គម**

# ផ្នែកទី៤
# តួនាទីអភិសមាចារនិងក្រមសីលធម៌ វិជ្ជាជីវៈមន្ត្រីនគរបាលជាតិក្នុងកិច្ចប្រតិបត្តិការ

## ១- ការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលជាតិ

មន្ត្រីនគរបាលជាតិគ្រប់ឯកសណ្ឋានជាកងកម្លាំងនគរបាល ជាបុគ្គលដែលត្រូវបានជាតិផ្តល់ទំនុកចិត្តជូនក្នុងការគ្រប់គ្រង ការពារ និងថែរក្សាលើការងារការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ ការផ្តល់ទំនុកចិត្តដ៏ពិសេសនេះ គឺជាបុព្វហេតុនៃកិត្តិយសដ៏មានអត្ថន័យឧត្តុង្គឧត្តមបំផុតដែលតម្រូវឱ្យនគរបាលម្នាក់ៗត្រូវមានឧត្តមគតិជាតិប្រកបដោយជំហរស្មារតី ក្លាហានហ៊ានលះបង់គ្រប់បែបយ៉ាងនិងត្រូវមានការទទួលខុសត្រូវខ្ពស់ចំពោះការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន។

### ១.១- តួនាទីទំនួលខុសត្រូវក្នុងវិជ្ជាជីវៈ

#### ១.១.១- ការគោរពវិន័យនិងបញ្ជាស្របច្បាប់

##### ក- ការគោរពវិន័យ

ការគោរពវិន័យជាផ្នែកមួយគាំទ្រក្នុងការលើកស្ទួយកិច្ចប្រតិបត្តិកិច្ចការរបស់មន្ត្រីនគរបាលឱ្យកាន់តែរឹងមាំនិងឯកភាពគ្នាក្នុងការងារស្ថាប័ន។ ប៉ុន្តែការស្តាប់បង្គាប់ឬគោរពតាមដោយងងឹតងងុលអាច នាំឱ្យមានការដួលរលំខាងផ្នែកសីលធម៌។ មន្ត្រីនគរបាលជាតិត្រូវបានតម្រង់ដោយលក្ខន្តិកៈមន្ត្រីនគរបាលជាតិ (ឆ្នាំ១៩៩៥) និងក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិ (ឆ្នាំ១៩៧៩ មាត្រា៨) ឱ្យគោរពតាមបទវិន័យដែលចែងជាធរមានក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។ ដូចនេះការស្តាប់បង្គាប់ត្រូវតែបានដឹកនាំដោយសតិសម្បជញ្ញៈនិងភាពស្របតាមគោលការណ៍អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈជានិច្ច។ ការណែនាំដែលរំលោភសិទ្ធិមនុស្សឬប្រាសចាកពីសីលធម៌ត្រូវតែបានបដិសេធដោយការថ្លឹងថ្លែងប្រុងប្រយ័ត្ននិងរាយការណ៍តាមខ្សែបណ្តាញដឹកនាំបញ្ជាត្រឹមត្រូវ។ ភាពក្លាហានក្នុងការគោរពតាមបែប «សីលធម៌» គឺជាទម្រង់គំរូខ្ពស់បំផុតនៃភាពជាអ្នកដឹកនាំទាំងអ្នកដឹកនាំនិងមន្ត្រីនគរបាលប្រកប ដោយក្រមសីលធម៌វិជ្ជាជីវៈ។ ដូចពាក្យមួយពោលថា «មន្ត្រីនគរបាលដែលគ្មានវិន័យ គឺដូចជាកងកម្លាំងដែលគ្មានកិត្តិយស» មន្ត្រីនគរបាលត្រូវតែហ្វឹកហាត់បណ្តុះបណ្តាលវិន័យខ្លួនឯងក្នុងការនិយាយ ការធ្វើសកម្មភាព និងការសម្រេចចិត្តដោយធានាថាការប្រព្រឹត្តរបស់ខ្លួនឆ្លុះបញ្ចាំងពីសេចក្តីថ្លៃថ្នូរចំពោះឯកសណ្ឋានដែលរដ្ឋបំពាក់ឱ្យ។

##### ខ- ការគោរពបញ្ជាស្របច្បាប់

បញ្ជាជាអាជ្ញាដែលថ្នាក់ដឹកនាំដាក់ចេញ ដើម្បីដឹកនាំអង្គភាពឱ្យដំណើរការដើម្បីសម្រេចគោលបំណងឬគោលដៅណាមួយ។ ដូច្នេះក្នុងពេលបញ្ជាតែងតែផ្សារភ្ជាប់ជាមួយនឹងការដឹកនាំដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ព្រោះក្នុងពេលបញ្ជាត្រូវតែមានការដឹកនាំឬក្នុងពេលដឹកនាំក៏ត្រូវតែមានបញ្ជាដែរ។ បើពិនិត្យមើលអំពីព្រំខណ្ឌដះតទិ្ធពលនៃរូបភាពនៃ «បញ្ជា» ស្តែងឡើងខុសពីការងារដឹកនាំត្រង់ចំណុចបញ្ជាផ្សារភ្ជាប់ជាមួយនឹងសកម្មភាពដាក់ស្តែងជាភារកិច្ចបន្ទាន់ តឹងតែង ប្រថុចញ៉ុច និងចាំបាច់ត្រូវប្រមូលផ្តុំកម្លាំងកាយ កម្លាំងចិត្ត គំនិតប្រាជ្ញាដើម្បីអនុវត្តនៅក្នុងរយៈពេលមួយជាកំណត់។ ក្នុងពេលមានបញ្ជារបស់ថ្នាក់ដឹកនាំឬមេបញ្ជាការ អ្នកទទួលបញ្ជាអនុវត្តត្រូវម្ចាស់ការប្រតិបត្តិតាមជាដាច់ខាត។

មន្ត្រីនគរបាលអាចគោរពនិងអនុវត្តតាមបញ្ជា អាស្រ័យដោយបញ្ជានោះស្របតាមលក្ខខណ្ឌគតិយុត្តដែលត្រូវបានដឹងថាបញ្ជានោះពិតជាអនុលោមតាមក្របខណ្ឌនីតិប្បញ្ញត្តិនិងនីតិវិធីប្រតិបត្តិជាធរមាន ឬផ្អែកតាមស្ថានភាពជាក់ស្តែងណាមួយដែលត្រូវវិនិច្ឆ័យថាជាភាពត្រឹមត្រូវក្នុងក្របខណ្ឌនៃក្រមសីលធម៌វិជ្ជាជីវៈរបស់នគរបាល។

**១.១.២- ការរក្សាការសម្ងាត់នៃព័ត៌មានសន្តិសុខ**

មន្ត្រីនគរបាលជាទូទៅតែងតែដោះស្រាយព័ត៌មានស៊ើបអង្កេតអំពីជនរងគ្រោះ ជនសង្ស័យពាក់ព័ន្ធការងារសន្តិសុខជាតិដែលត្រូវបានណែនាំឱ្យរក្សាការសម្ងាត់ប្រកបដោយក្រមសីលធម៌ក្នុងវិជ្ជាជីវៈរបស់ខ្លួនដើម្បីការពារសេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងយុត្តិធម៌។ ការលេចធ្លាយឬលក់ព័ត៌មានដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនបង្កើតបានជាកំហុសធ្ងន់ធ្ងរនិងរំលោភបំពានទាំងបទវិន័យមន្ត្រីនគរបាលរបស់ក្រសួងមហាផ្ទៃ (ឆ្នាំ២០២៤) និងស្តង់ដាសីលធម៌អន្តរជាតិ (ឆ្នាំ២០១៧)។ ការរក្សាការសម្ងាត់ឆ្លុះបញ្ចាំងពីទំនុកចិត្តដ៏ឧត្តុង្គឧត្តមនិងបញ្ជាក់ពីសីលធម៌របស់មន្ត្រីនគរបាលដែលបានការពារកិត្តិយសនិងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈរបស់ខ្លួនផងដែរ។

ការរក្សាការសម្ងាត់របស់មន្ត្រីនគរបាលគឺជាសុចរិតភាពនៃវិជ្ជាជីវៈក្នុងនាមជាអ្នកការពារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ ហេតុនេះដាច់ខាតមិនត្រូវធ្វើអ្វីៗឱ្យខូចឬអាប់ឱនកិត្យានុភាពរបស់ក្រសួង ស្ថាប័ននោះទេ។ មន្ត្រីនគរបាលត្រូវចេះលាក់នូវអាថ៌កំបាំងខ្លឹមសារព័ត៌មាននិងគោរពលាក់ការណ៍ការងារដែលខ្លួនកំពុងអនុវត្ត។ មានន័យថាត្រូវចេះរក្សាពាក្យសំដីដែលនិយាយចេញទៅឬសរសេរចេញទៅដោយភាពប្រុងប្រយ័ត្ន ដោយមិនត្រូវនិយាយឬសរសេរនូវអ្វីដែលធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិយស កិត្យានុភាពរបស់អង្គភាព ក្រសួង ស្ថាប័ន ឬថ្នាក់ដឹកនាំរបស់ខ្លួនឡើយ។ ការរក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈនគរបាលដាច់ខាតមិនត្រូវបង្ហាញអាថ៌កំបាំងផ្ទៃក្នុងឬអាថ៌កំបាំងការងារឱ្យបែកធ្លាយចេញទៅក្រៅឡើយ។ ទោះក្នុងរូបភាពណាក៏ដោយ រាល់ឯកសារ ព័ត៌មាន ឬហេតុផលផ្សេងៗដែលខ្លួនបានដឹង បានឮត្រូវមានមនសិការក្នុងវិជ្ជាជីវៈខ្ពស់បំផុតមិនត្រូវឱ្យបែកធ្លាយចេញក្រៅឬតាមរយៈមិត្តភក្តិ សាច់ញាតិ បងប្អូនជាទីទុកចិត្តក៏ដោយ លុះត្រាតែមានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួន ប្រសិនបើគ្មានការអនុញ្ញាតពីថ្នាក់លើឬគ្មានការកំណត់ដោយច្បាប់នោះ ហើយនៅតែប្រព្រឹត្តដោយមិនបានពិចារណាឱ្យបានដិតដល់នោះគឺជាសកម្មភាពក្បត់មនសិការវិជ្ជាជីវៈនិងត្រូវទទួលទោសទណ្ឌជាកំហិត។

ការសម្ងាត់នៃវិជ្ជាជីវៈ មើលពីខាងក្រៅហាក់ដូចជាមានលក្ខណៈផ្ទុយគ្នានឹងគោលការណ៍តម្លាភាព គោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិប្រជាពលរដ្ឋដូចដែលមានចែងក្នុងមាត្រា៣៥នៃរដ្ឋធម្មនុញ្ញដែលសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏មានការងារមួយចំនួនតម្រូវឱ្យរដ្ឋត្រូវតែរក្សាការសម្ងាត់ ជាពិសេសព័ត៌មានដែលអាចធ្វើឱ្យប៉ះពាល់ដល់វិស័យសន្តិសុខជាតិនិងកិត្យានុភាពសង្គម។

ការសម្ងាត់វិជ្ជាជីវៈ មិនត្រឹមតែត្រូវអនុវត្តចំពោះមន្ត្រីនគរបាលប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តចំពោះគ្រប់មន្ត្រីទាំងអស់ផងដែរទោះបីអ្នកដែលមិនមានសមត្ថកិច្ចទាំងអស់ត្រូវក៏ដឹងអំពីការងារនោះផងដែរ។ ខាងក្រោមនេះជាវិធានមួយចំនួន ដែលមន្ត្រីនគរបាលគ្រប់រូប គ្រប់កម្រិតត្រូវប្រតិបត្តិដើម្បីរក្សាការសម្ងាត់ឱ្យបានល្អប្រសើរនិងមានប្រសិទ្ធភាព៖

- ដាច់ខាតត្រូវតែរក្សាការសម្ងាត់រដ្ឋ ព័ត៌មានសម្ងាត់អង្គភាព និងសំណុំរឿងដែលខ្លួនទទួលខុសត្រូវ ក៏មិនត្រូវឱ្យបែកធ្លាយទៅក្រៅទោះបីជាមិត្តភក្តិឬសាច់ញាតិក៏ដោយ

- មិនត្រូវផ្សព្វផ្សាយរាល់ព័ត៌មានសម្ងាត់តាមបណ្តាញព័ត៌មានសង្គមឬមធ្យោបាយផ្សេងទៀត

- ត្រូវប្រើប្រាស់ឯកសារព័ត៌មានស្របតាមកម្រិតនៃសិទ្ធិអនុញ្ញាតដើម្បីម្ចាស់ការ

ត្រូវចាំថាមន្ត្រីនគរបាលតែម្នាក់មិនអាចធ្វើឱ្យអង្គភាពឬស្ថាប័នទាំងមូលជោគជ័យបានឡើយ ប៉ុន្តែមន្ត្រីនគរបាលម្នាក់អាចធ្វើឱ្យអង្គភាពឬស្ថាប័នទាំងមូលបរាជ័យនិងអាស្រូវកេរ្តិ៍ឈ្មោះបានតាមរយៈការបំពានបទបញ្ញានិងក្រមសីលធម៌វិជ្ជាជីវៈដែលជាកំហុសវិន័យត្រូវចាត់ទុកថាជាបទល្មើសដែលត្រូវទទួលនូវការផ្តន្ទាទោសតាមច្បាប់កំណត់។

**១.១.៣- ការគោរពសិទ្ធិនិងឯករាជ្យភាពរបស់បុគ្គល**

ការគោរពសិទ្ធិមនុស្សត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះក៏បានកំណត់ពីសិទ្ធិរបស់រូបវន្តបុគ្គលនិងនីតិបុគ្គលដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញគ្រង់ជំពូក៣និងច្បាប់ជាធរមានផងដែរ។ រូបវន្តបុគ្គលនិងនីតិបុគ្គលមានអត្ថន័យជាគោលដូចខាងក្រោម៖

**១- រូបវន្តបុគ្គល** គឺជាមនុស្សម្នាក់ៗដែលមានសិទ្ធិធម្មជាតិតាំងពីកំណើតដូចជាសិទ្ធិរស់រានមានជីវិត សេរីភាព សេចក្តីថ្លៃថ្នូរ និងឯកជនភាព។

**២- នីតិបុគ្គល** គឺជាអង្គភាពស្របច្បាប់ (ស្ថាប័ន ក្រុមហ៊ុន អង្គការ) ដែលមានសិទ្ធិនិងមានកាតព្វកិច្ចតាមផ្លូវច្បាប់។

ផ្តើមចេញពីនេះ ការឱ្យតម្លៃសិទ្ធិមិនមែនជាឧបសគ្គនោះទេ ប៉ុន្តែជាគ្រឹះសំខាន់នៃនីតិរដ្ឋក្នុងការបង្កើតទំនុកចិត្តសង្គមនិងរួមចំណែកពង្រឹងសន្តិសុខសង្គមថែមទៀតផង។ មន្ត្រីនគរបាលក៏ត្រូវបានច្បាប់អនុញ្ញាតឱ្យប្រើសិទ្ធិនិងកម្លាំងដោយសមហេតុផល ក្នុងស្ថានភាពចាំបាច់ដើម្បីការពារខ្លួននិងការពារអ្នកដទៃពីគ្រោះមហន្តរាយផ្សេងៗនិងគ្រោះថ្នាក់ដល់ជីវិតផងដែរ។ ដូចនេះមន្ត្រីនគរបាលដែលមានតួនាទីតំណាងឱ្យអំណាចរដ្ឋនិងជាអ្នកអនុវត្តច្បាប់ដើម្បីបម្រើសង្គម ចាំបាច់ត្រូវយកចិត្តទុកដាក់ដល់ការគោរពសិទ្ធិនិងឯករាជ្យភាពរបស់បុគ្គលដូចខាងក្រោម៖

-ត្រូវគោរពសេចក្តីថ្លៃថ្នូរនិងបុគ្គលភាព ពីព្រោះមនុស្សគ្រប់រូបមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់ ហើយគេមិនត្រូវទទួលរងនូវអំណាចឬឥទ្ធិពលគាបសង្កត់ ចាប់បង្ខំនិងរំលោភសិទ្ធិបុគ្គលនោះឡើយ

- ត្រូវអនុវត្តច្បាប់ត្រឹមត្រូវ គោរពសិទ្ធិ និងមានសមធម៌ដោយប្រើតែវិធានការត្រឹមត្រូវ សមស្រប និងចាំបាច់ក្នុងគោលបំណងដើម្បីតែបុព្វហេតុផលប្រយោជន៍សាធារណៈប៉ុណ្ណោះ

- ត្រូវការពារសិទ្ធិនីតិបុគ្គលនិងសកម្មភាពស្របច្បាប់នានា ចូលរួមដោះស្រាយបញ្ហាវិវាទដោយយុត្តិធម៌ស្របតាមនីតិវិធីនិងច្បាប់បានកំណត់

-ត្រូវមានទំនួលខុសត្រូវនិងគណនេយ្យភាពចំពោះសកម្មភាពរបស់ខ្លួន បើកចំហទទួលយកការត្រួតពិនិត្យ រិះគន់ស្ថាបនា កែតម្រូវកំហុសដោយស្មោះត្រង់ មានតម្លាភាព ដើម្បីបង្កើតទំនុកចិត្តនៃភាពជាដៃគូរជាមួយសង្គម

- ត្រូវដើរតួនាទីជាគំរូក្នុងការគោរពសិទ្ធិ គោរពច្បាប់ ដើម្បីធ្វើឱ្យខ្លួនឯងនិងសង្គមកើតមានវប្បធម៌សុចរិតភាព សាមគ្គីភាព និងគុណភាព

- ត្រូវចូលរួមបណ្តុះគំនិតយល់ដឹងជាប់ជាប្រចាំឱ្យបានខ្ជាប់ខ្ជួនអំពីការគោរពសិទ្ធិមនុស្សក្នុងអង្គភាពនិងក្នុងសហគមន៍។

**១.១.៤- ការបម្រើសេវានិងផលប្រយោជន៍សាធារណៈ**

នៅគ្រប់កាលៈទេសៈ មន្ត្រីនគរបាលត្រូវចងចាំថា «រដ្ឋ» បានលើកតម្កើងផ្តល់កិត្តិយសនិងទំនុកចិត្តប្រគល់ភារកិច្ចជូន ដើម្បីឱ្យអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់លើការងាររក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមប្រកបដោយភាពក្លាហាន ឈ្លាសវៃ ស្មោះត្រង់និងម៉ឺងម៉ាត់និងយុត្តិធម៌។

ការឆ្លើយតបនឹងបំណងប្រាថ្នានិងទំនុកចិត្តដ៏ឧត្តុង្គឧត្តមនេះ គឺជាកិច្ចសច្ចាប្រណិធានមួយតម្រូវឱ្យមន្ត្រីនគរបាលម្នាក់ៗត្រូវតែយល់ដឹងឱ្យបានច្បាស់ ដើម្បីសម្លឹងមើលគោលដៅបានជាក់លាក់និងត្រូវតម្រង់ទិសប្រតិបត្តិឱ្យបានត្រឹមត្រូវ សមស្រប ដោយត្រូវតស៊ូលះបង់អ្វីៗគ្រប់យ៉ាងដែលជាប្រយោជន៍សង្គមជាតិ។

ក្នុងន័យនេះ ការប្តេជ្ញាចិត្តរបស់នគរបាលក្នុងការបម្រើសេវានិងការពារផលប្រយោជន៍ជាតិត្រូវប្រតិបត្តិដូចខាងក្រោម៖

- ត្រូវស្មោះត្រង់ការពាររបបគ្រប់គ្រង អាយុជីវិតប្រជាពលរដ្ឋ ទ្រព្យសម្បត្តិបុគ្គលនិងសាធារណៈ ដោយការប្រតិបត្តិធ្វើគំរូល្អ មានឥរិយាបថសីលធម៌វិជ្ជាជីវៈ (ប្រកាន់សុចរិត តម្លាភាព យុត្តិធម៌ មិនពុករលួយ មិនប្រើអំណាចខុសគោលដៅ) គោរពច្បាប់ បទបញ្ជា និងគោលនយោបាយរដ្ឋទុកជាអាទិភាព
- ត្រូវការពារជនស្លូតត្រង់ឱ្យរួចផុតពីអំពើរំលោភបំពានច្បាប់និងហានិភ័យនានាដែលបង្កដោយអំពើល្មើសនិងយកចិត្តទុកដាក់ពង្រឹងសេវាបម្រើប្រជាពលរដ្ឋទុកជាគោលដៅសំខាន់ ព្រមទាំងទទួលយកសំណូមពររបស់ប្រជាពលរដ្ឋមកធ្វើការដោះស្រាយឱ្យបានសមស្រប ទាន់ពេល និងសន្តិភាពខាងផ្លូវកាយផ្លូវចិត្តពីគ្រប់ភាគីទាំងអស់
- ត្រូវគោរពសិទ្ធិមនុស្ស (ដូចចែងក្នុងមាត្រា៣៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា) ដោយមានឥរិយាបថល្អ ទន់ភ្លន់ ប៉ុន្តែម៉ឺងម៉ាត់ក្នុងភារកិច្ចដើម្បីធ្វើជាគំរូល្អដល់អ្នកដទៃផងនិងសក្តិសមជាមន្ត្រីនគរបាលមានវិជ្ជាជីវៈផង
- ត្រូវអភិវឌ្ឍសមត្ថភាពទាំងចំណេះដឹងជំនាញនិងក្រមសីលធម៌វិជ្ជាជីវៈឱ្យបានរឹងមាំព្រមទាំងមានការអភិវឌ្ឍជាបន្តបន្ទាប់ដោយធ្វើឱ្យមាននវានុវត្តន៍តាមរយៈសិក្សាស្រាវជ្រាវច្បាប់ថ្មី បច្ចេកទេសថ្មីនិងវិធីសាស្ត្រថ្មីៗឱ្យស្របតាមបរិបទសង្គម ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការស្វ័យគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម
- មិនត្រូវធ្វើអ្វីៗដោយខ្វះការទទួលខុសត្រូវឬប្រើអារម្មណ៍ក្នុងការសម្រេចចិត្តនោះឡើយ ពីព្រោះការសម្រេចចិត្តនិងសកម្មភាពរបស់នគរបាលបង្ហាញពីឥរិយាបថ សកម្មភាព និងលទ្ធផលដែលបានជះឥទ្ធិពលទៅលើអង្គភាពនិងសង្គម។

អាស្រ័យដូចនេះ មន្ត្រីនគរបាលគ្រប់រូបត្រូវប្រតិបត្តិដោយស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះការងារ គោលនយោបាយនគរបាលសហគមន៍ និងអភិវឌ្ឍន៍គំនិតច្នៃប្រឌិតស្របតាមបរិបទថ្មីទើបជួយឱ្យការងារមានគុណភាព ប្រសិទ្ធភាព និងភាពរីកចម្រើន។

### ១.១.៥- ការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ

ការប្រាស្រ័យទាក់ទងដោយការគោរព ចាប់ផ្តើមដោយការទទួលស្គាល់ថាមនុស្សគ្រប់រូបមិនថាឋានៈសង្គម មុខរបរ និងប្រវត្តិបែបណានោះទេគឺសុទ្ធតែសក្តិសមនឹងទទួលបាននូវសេចក្តីថ្លៃថ្នូរនិងសុជីវធម៌ ស្របតាមមាត្រា «១និង២» នៃក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់នៅឆ្នាំ១៩៧៩ដែលសង្កត់ធ្ងន់លើការគោរពសិទ្ធិមនុស្សនិងការបម្រើប្រជាជនគ្រប់រូប។

នៅក្នុងបរិបទវប្បធម៌កម្ពុជា ការគោរពត្រូវបានបង្ហាញតាមរយៈការនិយាយទន់ភ្លន់ កាយវិការសមរម្យនិងការស្តាប់ដោយយកចិត្តទុកដាក់។ មន្ត្រីនគរបាលដែលស្វាគមន៍ពលរដ្ឋដោយកាយវិការសុភាពរាបសាបានបង្ហាញនូវការបើកបេះដូងដ៏ទូលំទូលាយដោយមិនបានបង្ហាញអវិភាពនិងការប្រើពាក្យសំដីដោយស្ងប់ស្ងាត់បង្ហាញពីភាពមានវិជ្ជាជីវៈក្នុងការទំនាក់ទំនងនិងមានវិន័យខាងអភិសមាចារនិងក្រមសីលធម៌។ សុភាសិតខ្មែរមួយបានពោលថា «និយាយល្អស្មើនឹងធ្វើល្អ» ពំនោលនេះបានរំឭកដល់មន្ត្រីនគរបាលជាភាសាជាតិខ្លួនឯងអំពីទង្វើនៃគុណធម៌របស់មន្ត្រីសាធារណៈ។

ដូចគ្នានេះ ការប្រាស្រ័យទាក់ទងដោយការគោរពក៏ពាក់ព័ន្ធនឹងតម្លាភាពនិងភាពច្បាស់លាស់ផងដែរ។ ពលរដ្ឋមានសិទ្ធិយល់ពីហេតុផលនៃសកម្មភាពរបស់មន្ត្រីនគរបាលមិនថា ការឃាត់ខ្លួន ការសាកសួរឬការចាប់ខ្លួននោះទេ។ ការពន្យល់អំពីនីតិវិធីច្បាប់ជាភាសាធម្មតាក្នុងការកសាងទំនុកចិត្តនិងបានកាត់បន្ថយការភ័យខ្លាចនិងបង្កើនជំនឿក្នុងការទំនាក់ទំនង។ ឧទាហរណ៍ នគរបាលនិយាយថា «ខ្ញុំកំពុងឃាត់អ្នកដើម្បីធានាសុវត្ថិភាពដល់មនុស្សគ្រប់គ្នា» ប្រយោគនេះបានផ្លាស់ប្តូរការអនុវត្តទៅជាការធានាដ៏មានប្រសិទ្ធភាពដែលធ្វើឱ្យភាគីម្ខាងទៀតគិតពិចារណានិងផ្លាស់ប្តូរគំនិត។

ដូចនេះ សុជីវធម៌មិនគួរត្រូវបានយល់ច្រឡំថាជាភាពទន់ខ្សោយឡើយ ការប្រើសំឡេងទន់ភ្លន់តែម៉ឺងម៉ាត់បានទទួលនូវការគោរពជារឿយៗរបស់គ្រប់ភាគី ប្រសើរជាងការប្រើអំណាចដោយការស្រែកគំហក។ មន្ត្រីនគរបាលគួរចៀសវាងការនិយាយចំអក ការគំរាមកំហែង ឬការមើលងាយដែលធ្វើឱ្យខូចសេចក្តីថ្លៃថ្នូរនៃភាគី «អ្នកនិយាយនិងអ្នកស្តាប់»។ ការប្រាស្រ័យទាក់ទងដោយការគោរពគួរត្រូវបានបង្វែរអំណាចទៅជាភាពជាដៃគូនិងបានផ្លាស់ប្តូរឥរិយាបថមិនទំនងទៅជាកិច្ចសហការដ៏ល្អមួយ។

### ១.១.៦- ការទាក់ទងជាមួយជនងាយរងគ្រោះ (កុមារ ស្ត្រី វ័យចំណាស់ និងជនពិការ)

នៅទីនេះមានទឡ្ហីករណ៍ ដែលបានណែនាំតម្រង់ទិសឱ្យមន្ត្រីនគរបាលមានក្រមសីលធម៌ត្រូវតែបង្ហាញភាពជាអ្នកបម្រើសេវាពិសេសដែលមានក្រមសីលធម៌ក្នុងវិជ្ជាជីវៈនៅពេលមានអន្តរកម្មជាមួយនឹងជនងាយរងគ្រោះដែលពួកគេទាំងនោះរួមមាន «កុមារ ស្ត្រី វ័យចំណាស់ និងបុគ្គលដែលមានពិការភាពឬបញ្ហាផ្លូវចិត្ត» ក្រុមនីមួយៗនៅពេលជួបទំនាក់ទំនងតម្រូវឱ្យមានការយល់ចិត្ត ការអត់ធ្មត់ និងការយល់ដឹងខ្ពស់។

#### ក- ចំពោះកុមារភាព

ជារឿយៗកុមារតែងមានការភ័យខ្លាចមន្ត្រីដែលស្លៀកពាក់ឯកសណ្ឋាន។ ការប្រាស្រ័យទាក់ទងជាមួយនឹងអនីតិជនត្រូវតែមានភាពស្ងប់ស្ងាត់ សាមញ្ញ និងធានាភាពលួងលោម។ មន្ត្រីនគរបាលគួរតែលុតជង្គង់ប្រកបដោយឥរិយាបថទន់ភ្លន់ទៅរកកុមារដោយត្រូវចៀសវាងការប្រើកាយវិការគំរាមកំហែងនិងត្រូវចេះប្រើភាសាដោយភាពទន់ភ្លន់ត្រូវចំណុចរបស់កុមារ។ នៅពេលសាកសួរកុមារជាសាក្សីឬជន

រងគ្រោះ មន្ត្រីនគរបាលត្រូវតែអនុវត្តតាមគោលការណ៍យុត្តិធម៌គិតដល់កុមារត្រូវបានធានាសុវត្ថិភាព ឯកជនភាពនិងការលួងលោមផ្លូវចិត្ត។ នៅប្រទេសកម្ពុជាការគោរពវប្បធម៌ចំពោះកុមារដែលមានភាពរឹងមាំគឺជាការប្រព្រឹត្តដោយសប្បុរសក៏អាចបំពេញនូវគុណធម៌ព្រះពុទ្ធសាសនានៃ «មេត្តា» ផងដែរ។ ប្រសិនបើការទំនាក់ទំនងជាមួយនឹងកុមារដោយវិជ្ជាជីវៈ ពិតណាស់កុមារនឹងនិយាយពិតពីអ្វីដែលគេបានដឹង។

**ខ- ចំពោះស្ត្រីភេទ**

មន្ត្រីនគរបាល ត្រូវតែប្រព្រឹត្តចំពោះស្ត្រីដោយការគោរពតាមក្រមសីលធម៌និងការយល់ដឹងអំពីយេនឌ័រ។ ករណីនេះគឺរួមបញ្ចូលទាំងការចៀសវាងភាសារើសអើង ការរក្សាឯកជនភាពក្នុងអំឡុងពេលស៊ើបអង្កេតនិងការធានានូវវត្តមានរបស់មន្ត្រីនគរបាលជាស្ត្រីក្នុងពេលវេលាសមស្រប។ ច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) និងគោលនយោបាយយេនឌ័រជាតិ (ឆ្នាំ២០១៤-២០២៣) សុទ្ធតែសង្កត់ធ្ងន់លើកាតព្វកិច្ចក្រមសីលធម៌របស់មន្ត្រីក្នុងការការពារនូវសេចក្តីថ្លៃថ្នូររបស់ស្ត្រី។ ការប្រាស្រ័យទាក់ទងប្រកបដោយក្រមសីលធម៌ត្រូវធ្វើឡើងដោយការស្តាប់ប្រកបដោយសុភវិនិច្ឆ័យនិងផ្តល់ការធានាជាក់លាក់ឡើងវិញជាជាងការប្រើអំណាច។

**គ- ចំពោះមនុស្សវ័យចំណាស់និងជនពិការ**

ពលរដ្ឋដែលមានវ័យចំណាស់សមនឹងទទួលបានការអត់ធ្មត់និងសុជីវធម៌បន្ថែមលើការទំនាក់ទំនងជាមួយនឹងពួកគាត់។ មន្ត្រីនគរបាលគួរប្រើការពាក្យសំដីក្នុងការនិយាយដោយយឺតៗមួយៗនិងច្បាស់ៗព្រមទាំងធានាការយល់ដឹងពីស្ថានភាពនិងបរិយាកាសមុនពេលធ្វើការប្រាស្រ័យទាក់ទង។

ដោយឡែក ចំពោះជនពិការវិញដូចជាជនដែលមានបញ្ហាក្នុងការស្តាប់ ការមើលមិនឃើញ ឬពិការភាពអវយវៈ មន្ត្រីនគរបាលត្រូវតែកែសម្រួលវិធីសាស្ត្រប្រាស្រ័យទាក់ទងដោយប្រើកាយវិការ ឬត្រូវមានអ្នកបកប្រែឬឧបករណ៍ជំនួយនៅពេលចាំបាច់ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD, ឆ្នាំ២០០៦) ដែលបានផ្តល់សច្ចាប័ន។

ចាប់តាំងពីឆ្នាំ២០១២មក កម្ពុជាបានជំរុញឱ្យមន្ត្រីនគរបាលធានាការទទួលបាននិងការគោរពនៅពេលមានទំនាក់ទំនងជាមួយនឹងជនងាយរងគ្រោះប្រកបដោយមេត្តាធម៌គឺមិនមែនជម្រើសទេ តែវាជាកាតព្វកិច្ចខាងក្រមសីលធម៌ទៅវិញទេ។ មន្ត្រីនគរបាលដែលមានការប្រាស្រ័យទាក់ទងដោយសុភាពរាបសាជាមួយនឹងអ្នកដែលមិនអាចការពារខ្លួនបានគឺពិតជាបានបង្ហាញអំពីការប្រើអំណាចនៃអភិសមាចារនិងក្រមសីលធម៌ពិតៗ។ សកម្មភាពបែបនេះបានបំពេញទាំងស្មារតីបដិសណ្ឋារកិច្ចខ្មែរផងនិងស្តង់ដាសកលនៃក្រមសីលធម៌វិជ្ជាជីវៈផង។

**១.២- តួនាទីប្រតិបត្តិក្នុងវិស័យសន្តិសុខជាតិ**

បរិបទពិភពលោកបានជះឥទ្ធិពលដល់សភាពការណ៍សង្គមធ្វើឱ្យមានការវិវត្តប្រែប្រួលយ៉ាងខ្លាំងដោយផ្ទាល់និងប្រយោលទៅលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។

ការថែរក្សាសន្តិភាពឱ្យគង់វង្សមានស្ថិរភាពដល់សព្វថ្ងៃមិនមែនជាភាពចៃដន្យនោះទេ។ វាគឺជាសមិទ្ធិផលដែលនគរបាលជាតិចូលរួមចំណែកធ្វើពលីកម្មគ្រប់បែបយ៉ាងដោយការប្តេជ្ញាចិត្តខ្ពស់ជូនជាតិក្នុងស្មារតីម្ចាស់ការទទួលខុសត្រូវដោយបានលើកកម្ពស់គុណតម្លៃវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការអនុវត្ត

តួនាទីស្របតាមច្បាប់និងគោលការណ៍របស់ថ្នាក់លើសំដៅការពារប្រកបដោយចីរភាពនូវសន្តិភាពនិងជីវភាពរស់នៅរបស់ប្រជាជនដោយសេចក្តីសុខសាន្ត។

ដើម្បីបំពេញបេសកកម្មស្នូលរបស់ខ្លួនក្នុងវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល មន្ត្រីនគរបាលត្រូវតែប្រកាន់ខ្ជាប់នូវចំណុចសំខាន់ៗដូចខាងក្រោម៖

**១.២.១- វិធានជាមូលដ្ឋានដែលត្រូវប្រតិបត្តិ**

- ត្រូវយកច្បាប់គោលធ្វើជាមូលដ្ឋានមានន័យថាមន្ត្រីនគរបាលមិនគ្រាន់តែជាអ្នកអនុវត្តច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកប្តេជ្ញាចិត្តទទួលខុសត្រូវខ្ពស់ក្នុងការបម្រើសេវាសន្តិសុខនិងសេវាសង្គមដោយគោរពតាមច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានក្រោមច្បាប់នានាធ្វើជាត្រីវិស័យតម្រង់ទិសផងដែរ
- ត្រូវមានសង្គតិភាពរវាងអ្នកដឹកនាំបញ្ជានិងអ្នកអនុវត្តដើម្បីបង្កើតបានភាពរឹងមាំរបស់កងកម្លាំងនៅក្នុងអង្គភាពឬស្ថាប័ន (អ្នកបញ្ជាធ្វើជាគំរូ ឯអ្នកអនុវត្តត្រូវស្តាប់បង្គាប់)
- ត្រូវគិតគូរយកចិត្តទុកដាក់ជាអាទិភាពលើការងារបង្ការ ទប់ស្កាត់ ដើម្បីសុវត្ថិភាពជាចម្បងជាជាងធ្វើការងារបង្ក្រាប (ការងារបង្ក្រាបគ្រាន់តែជាជំនួយ)។ ដូចនេះត្រូវស្គាល់ស្ថានភាពពិតរបស់ក្នុងមូលដ្ឋាននិងយកប្រជាជនធ្វើជាដៃគូ (ប្រជាជនម្នាក់ជានគរបាលម្នាក់) ដើម្បីរក្សាការពារសន្តិសុខបានរឹងមាំនិងយូរអង្វែង
- ត្រូវមានសុចរិតភាពនិងស្អាតស្អំក្នុងអាជីពការងារ គិតគូរពីប្រយោជន៍ជាតិ និងប្រជាជនជាចម្បងដើម្បីបំពេញបំណងប្រាថ្នារបស់សង្គមនិងពង្រឹងភាពជឿជាក់របស់ពួកគេចំពោះមន្ត្រីនគរបាល និងត្រូវចងចាំថា «គុណតម្លៃរបស់នគរបាល» មិនមែនដោយសារឯកសណ្ឋាននិងឥទ្ធិពលអំណាចទេ ប៉ុន្តែគឺដោយសារតែមានសីលធម៌ យុត្តិធម៌ គុណធម៌ សុចរិតភាព តម្លាភាព និងការបម្រើសេវាសង្គមដោយឆន្ទៈនិងមនសិការក្នុងវិជ្ជាជីវៈ។

**១.២.២- ការរក្សាសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម**

**ក- ការបង្ការនិងការស៊ើបអង្កេតឧក្រិដ្ឋកម្ម**

ការបង្ការទប់ស្កាត់និងការស៊ើបអង្កេតឧក្រិដ្ឋកម្មជាទង្វើសីលធម៌នៃការគិតទុកជាមុន។ ការងារនេះពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណនៃហានិភ័យដែលនឹងអាចកើតមាននៅក្នុងមូលដ្ឋាន។ ការយល់ដឹងមុនអំពីហានីភ័យសហគមន៍និងការដោះស្រាយមូលហេតុមុនពេលមានឧក្រិដ្ឋកម្មកើតឡើងគឺជាការអនុវត្តស្របតាមគំនិតព្រះពុទ្ធសាសនានៃ «សង្កប្បៈធម៌ដ៏ត្រឹមត្រូវ» ក្នុងការប្រព្រឹត្តចេញពីសុច្ឆន្ទៈនិងប្រាជ្ញាជាជាងប្រតិកម្មឬការផ្តន្ទាទោស។

ម្យ៉ាងវិញទៀតការស៊ើបអង្កេតទាមទារសុចរិតភាពនិងការពិត មន្ត្រីនគរបាលគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់នូវនីតិវិធីត្រឹមត្រូវហើយធានាថាភស្តុតាងត្រូវបានប្រមូលដោយស្របច្បាប់និងការសារភាពត្រូវបានទទួលដោយក្រមសីលធម៌។ រាល់ការបង្ខិតបង្ខំ ការបំភិតបំភ័យ ឬការក្លែងបន្លំរំលោភបំពានទាំងឡាយសុទ្ធតែជាទង្វើផ្ទុយទៅនឹងច្បាប់អន្តរជាតិ (ICCPR, មាត្រា៧) និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧)។ ភាពជឿជាក់នៃយុត្តិធម៌ គឺអាស្រ័យលើការស៊ើបអង្កេតដោយការពិតមិនមែនភស្តុតាងក្លែងក្លាយនោះទេ។ នៅពេលមន្ត្រីនគរបាលស៊ើបអង្កេតដោយសុចរិតភាព ពួកគេមិនត្រឹមតែដោះស្រាយឧក្រិដ្ឋកម្មនោះទេ គឺពួកគេថែមទាំងបានរក្សាសណ្តាប់ធ្នាប់សីលធម៌នៃសង្គមជាតិផងដែរ។

**ខ- ការពារអាយុជីវិតនិងទ្រព្យសម្បត្តិ**

យោងតាមគោលព្រះធម៌របស់ព្រះពុទ្ធបានទូន្មានថា «**សព្វេ សត្តា ភវន្តុ សុខិតា សូមឱ្យសត្វលោកទាំងអស់បានសុខ**» គោលធម៌នេះបានរំឭកមន្ត្រីនគរបាលគ្រប់រូបឈ្វេងយល់អំពីជីវិតដ៏មានតម្លៃដ៏ពិសិដ្ឋមិនអាចកាត់ថ្លៃបាន។ ផ្អែកតាមឱវាទដ៏មានសារៈសំខាន់នេះ មន្ត្រីនគរបាលតោងដឹងថាសូម្បីតែនៅពេលប្រឈមមុខនឹងគ្រោះថ្នាក់ក៏ដោយមន្ត្រីនគរបាលត្រូវតែខិតខំ ព្យាយាម តស៊ូ អត់ធ្មត់ក្លាហានមិនរួញរាចំពោះបញ្ហាគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិនិងប្រជាជន។ កត្តាទាំងនេះគឺជាកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់នគរបាលដែលត្រូវបានផ្តល់ថាជាគុណតម្លៃដ៏ពិសេសបំផុត។

ក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិ (ឆ្នាំ១៩៧៩ មាត្រា៣) ចែងថាមន្ត្រីអនុវត្តច្បាប់អាចប្រើកម្លាំងបានលុះត្រាតែចាំបាច់បំផុត។ ជាមួយគ្នានេះមន្ត្រីនគរបាលត្រូវដឹងថាអាវុធគឺជាឧបករណ៍សម្រាប់ធ្វើជាមធ្យោបាយចុងក្រោយមិនមែនជាឧបករណ៍នៃការបំភិតបំភ័យនោះទេ។ តម្លៃដ៏ពិសិដ្ឋនៃជីវិតមិនមែនមានតម្លៃតែលើប្រជាជនធម្មតានោះទេ ប៉ុន្តែតម្លៃនេះបានលាតសន្ធឹងភ្ជាប់ដល់ជនសង្ស័យនិងជនល្មើសផងដែរ។ គោលបំណងអភិសមាចារនិងសីលធម៌នៃកិច្ចការនគរបាលមិនមែនដើម្បីដាក់ទណ្ឌកម្មនោះទេ ប៉ុន្តែដើម្បីការពារនិងការកែតម្រូវដ៏ត្រឹមត្រូវមួយ ការអត់ធ្មត់របស់មន្ត្រីនគរបាលប្រដាប់អាវុធត្រូវបង្ហាញពីកម្លាំងនៃការប្រតិបត្តិក្រមសីលធម៌ដែលមិនមែនជាអំពើហិង្សានោះទេ។

យោងមាត្រា៣២នៃរដ្ឋធម្មនុញ្ញកម្ពុជាបានធានាសិទ្ធិរស់រានមានជីវិត ការការពារអាយុជីវិតជាបញ្ញត្តិខាងសីលធម៌ ខណៈដែលក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិ (មាត្រា២) ក៏បានពង្រឹងថាមន្ត្រីអនុវត្តច្បាប់ត្រូវតែការពារជីវិតមនុស្សទាំងអស់និងប្រឆាំងនឹងអំពើខុសច្បាប់នានា។

ក្នុងន័យនេះ មន្ត្រីនគរបាលមូលដ្ឋានត្រូវយល់ថា រាល់ការលើកទូរសព្ទតាមរយៈការហៅទូរសព្ទសុំជំនួយរបស់ប្រជាជនក្នុងគ្រាមានអាសន្ននិងរាល់ការល្បាតការពារនៅមូលដ្ឋានទាំងយប់ទាំងថ្ងៃពិតជាបានឆ្លុះបញ្ចាំងពីការបំពេញកាតព្វកិច្ចដ៏ពិសិដ្ឋក្នុងការការពារអាយុជីវិតមនុស្សនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ដូចនេះ មន្ត្រីនគរបាលត្រូវតែបំពេញកាតព្វកិច្ចនេះដោយភាពអង់អាចក្លាហាន លើកកម្ពស់ការប្រុងប្រយ័ត្ននិងចិត្តមេត្តាធម៌ផងដែរ។ ប៉ុន្តែទោះបីយ៉ាងណាក្តីនៅពេលមានបញ្ហាកើតឡើងនគរបាលត្រូវចាត់វិធានការភ្លាមៗដើម្បីជួយសង្គ្រោះជនរងគ្រោះ ការពារគ្រោះថ្នាក់ និងធានាសុវត្ថិភាពរបស់ជនងាយរងគ្រោះដទៃទៀតជាពិសេសកុមារ ស្ត្រី និងមនុស្សចាស់។

**គ- សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម**

សណ្តាប់ធ្នាប់សាធារណៈ សំដៅលើកិច្ចការដែលតម្រូវឱ្យពលរដ្ឋគ្រប់រូបត្រូវចូលរួមអនុវត្តរក្សាបានអំពីរបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ សោភណភាព អនាម័យ ភាពស្ងប់ស្ងាត់ និងសុវត្ថិភាពបុគ្គល ដើម្បីធានាដល់ការរស់នៅក្នុងភាពសុខសាន្តនិងរក្សាការពារទ្រព្យសម្បត្តិរដ្ឋនិងឯកជនដោយផ្អែកលើមូលដ្ឋានច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ រីឯសុវត្ថិភាពសង្គមសំដៅលើកិច្ចការដែលត្រូវយកចិត្តទុកដាក់ អំពីសកម្មភាពនិងល្បិចកលទាំងឡាយដែលមានចរិតលក្ខណៈជាបទល្មើសបង្កអសន្តិសុខសង្គមធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងជីវភាពរស់នៅដោយសុខសាន្តរបស់ប្រជាជន។

ផ្អែកលើអត្ថន័យទាំងពីរនេះ រាល់ការទទួលខុសត្រូវរបស់នគរបាលទាមទារឱ្យនគរបាលធ្វើការងាររបស់ខ្លួនឱ្យដើរទន្ទឹមគ្នាជាមួយសណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងសេចក្តីសុខសុវត្ថិភាពរបស់បុគ្គលគ្រប់រូប ហើយធានាថាសណ្តាប់ធ្នាប់ និងសុវត្ថិភាពត្រូវបានសម្រេចដោយគ្មានការគាបសង្កត់និងអំពើហិង្សាឡើយ។ ជាមួយគ្នានេះនៅក្នុងបរិបទលទ្ធិប្រជាធិបតេយ្យដែលកំពុងអភិវឌ្ឍនៅប្រទេសកម្ពុជាក៏បានឱ្យតម្លៃថា «តុល្យភាពរវាងសន្តិភាពនិងសេរីភាពបុគ្គល» គឺជាគុណតម្លៃដ៏សំខាន់និងពិសេសបំផុត។

ឧទាហរណ៍ មានការប្រមូលផ្តុំគ្នាធ្វើបាតុកម្មរបស់មហាជនដែលមានចរិតនយោបាយឬជម្លោះសហគមន៍ មន្ត្រីនគរបាលត្រូវតែដោះស្រាយដោយវិជ្ជាជីវៈ ផ្អែកលើមូលដ្ឋានច្បាប់និងការអត់ធ្មត់ខ្ពស់បំផុត។ ផ្អែកលើគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធ (ឆ្នាំ១៩៩០) បានសង្កត់ធ្ងន់លើ «សមាមាត្រនិងភាពចាំបាច់» នេះផងដែរ។ ដូចគ្នានេះគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃចំពោះមន្ត្រីនគរបាលជាតិកម្ពុជាក៏ទាមទារឱ្យប្រើប្រាស់កម្លាំងអប្បបរមាត្រឹមតែជាមធ្យោបាយចុងក្រោយប៉ុណ្ណោះ។ មន្ត្រីដែលមានវិន័យយល់ថា ភាពជាអ្នកដឹកនាំដ៏អត់ធ្មត់អាចដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពជាងភាពឆេវឆាវនិងការប្រើអំពើហិង្សា។

ការរក្សាសណ្តាប់ធ្នាប់មិនមែនជាការគ្រប់គ្រងមនុស្សនោះទេ វាជាការការពារនូវលក្ខខណ្ឌនានាដើម្បីសន្តិភាពនិងរបៀបរៀបរយសង្គម។ នៅពេលនគរបាលរក្សាសណ្តាប់ធ្នាប់សង្គមដោយសមធម៌មានន័យថាពួកគេបានចូលរួមពង្រឹងអំណាចសីលធម៌សេចក្តីថ្លៃថ្នូររបស់រដ្ឋបានដោយជោគជ័យ។

**១.២.៣- ការស្វែងរកវត្ថុតាងដោយក្រមសីលធម៌វិជ្ជាជីវៈ**

ភាពយុត្តិធម៌ទាមទារនូវការពិតដែលជាសច្ចៈភាពសង្គម ការអនុវត្តការងារជំនាញរបស់មន្ត្រីនគរបាលក្នុងការប្រមូលភស្តុតាងត្រូវតែស្របទៅនឹងច្បាប់និងដោយភាពទៀងទាត់ជានិច្ច។ ការបង្ខិតបង្ខំ ការបំភិតបំភ័យ និងការក្លែងបន្លំត្រូវបានហាមឃាត់ដោយ ICCPR (មាត្រា៧និង១៤) និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧)។ រាល់ការដោះស្រាយបញ្ហាជាមួយនឹងជនសង្ស័យដោយក្រមសីលធម៌ មានន័យថា នគរបាលបានការពារសេចក្តីថ្លៃថ្នូររបស់ពួកគេ ទោះបីជាពួកគេមានទោសក៏ដោយ។

អ្នកស៊ើបអង្កេតប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការប្រមូលវត្ថុតាងឬភស្តុតាងក្នុងគ្រប់រូបភាពណាក៏ដោយគឺជាការស្វែងរកការពិតមិនមែនការសារភាពនោះទេ។ ការការពារសិទ្ធិជនសង្ស័យគឺជាការទ្រទ្រង់សុចរិតភាពនៃប្រព័ន្ធយុត្តិធម៌ទាំងមូលនិងធានាថា យុត្តិធម៌នៅតែជាសីលធម៌មិនមែនជាយន្តការនោះទេ។

**១.២.៤- តុល្យភាពនៃការប្រើកម្លាំងនិងអាវុធ**

## ក- គោលការណ៍សីលធម៌ដែលគ្រប់គ្រងការប្រើប្រាស់កម្លាំង

ការប្រើប្រាស់កម្លាំង គឺជាទិដ្ឋភាពមួយដែលងាយរងគ្រោះខាងសីលធម៌បំផុតនៃកិច្ចការរបស់នគរបាល។ វាជាការសាកល្បងតុល្យភាពរវាងអំណាចនិងមនុស្សជាតិ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធ (ឆ្នាំ១៩៩០) និងបទវិន័យមន្ត្រីនគរបាលរបស់ក្រសួងមហាផ្ទៃ (ឆ្នាំ២០២៤) បានសង្កត់ធ្ងន់ថាកម្លាំងគួរតែត្រូវប្រើប្រាស់នៅពេលចាំបាច់បំផុតនិងសមាមាត្រទៅនឹងការគំរាមកំហែងគ្រប់រូបភាព។

មូលដ្ឋានគ្រឹះក្រមសីលធម៌វិជ្ជាជីវៈ ផ្តោតលើគោលការណ៍នៃការគោរពអាយុជីវិត។ រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា៣២) បានធានាសិទ្ធិរស់រានមានជីវិត ហើយក្រមសីលធម៌របស់ព្រះពុទ្ធសាសនាចាត់ទុកការសម្លាប់ជីវិតជាអំពើបាបដ៏ធ្ងន់ធ្ងរ។ ដូច្នេះរាល់ការប្រើកម្លាំងត្រូវតែដឹកនាំពង្រឹងដោយភាពចាំបាច់លើសមាមាត្រនិងភាពអត់ធ្មត់បំផុត។ គោលដៅនៃកិច្ចប្រតិបត្តិការរបស់កងកម្លាំងនគរបាលមិនមែនដើម្បីធ្វើបាបទេ ប៉ុន្តែដើម្បីរក្សាសន្តិភាពនិងការពារសិទ្ធិ អាយុជីវិតរបស់មនុស្សជាតិ។

កិច្ចការនគរបាលប្រកបដោយសីលធម៌វិជ្ជាជីវៈមានន័យថា មន្ត្រីត្រូវតែពិចារណាជានិច្ចថា តើការប្រើកម្លាំងចាំបាច់ដែរឬទេ? តើវាត្រូវសមាមាត្រកម្រិតណា? និងសួរថាតើមានមធ្យោបាយផ្សេងទៀតឬទេ?» សមត្ថភាពក្នុងការឆ្លើយសំណួរទាំងនេះប្រកបដោយសីលធម៌វិជ្ជាជីវៈអាស្រ័យលើស្ថានភាពនៃបទល្មើស។ ដូចនេះការសម្រេចចិត្តរបស់មន្ត្រីនគរបាលក្នុងក្រមសីលធម៌វិជ្ជាជីវៈផ្អែកលើការដឹកនាំបញ្ជាដ៏ត្រឹមត្រូវមួយ។

### ខ- សមាមាត្រនិងភាពចាំបាច់

ពាក្យថាសមាមាត្រ មានន័យថាជាកម្រិតនៃកម្លាំងត្រូវតែមានតុល្យភាពគ្នាទៅនឹងកម្រិតនៃការគំរាមកំហែង។ ការតស៊ូក្នុងកិច្ចប្រតិបត្តិការដែលមិនមានលក្ខណៈធ្ងន់ធ្ងរមិនគួរប្រើហេតុផលដោយខ្វះការពិចារណាសម្រាប់ប្រើវិធានការតឹងតែងនាំឱ្យមានមនុស្សស្លាប់នោះទេ។ ភាពចាំបាច់ក្នុងឧត្តមគតិខ្ពស់បំផុតនោះ កម្លាំងគួរតែត្រូវបានប្រើប្រាស់តែនៅពេលដែលគ្រប់មធ្យោបាយទាំងអស់ប្រឈមនឹងភាពបរាជ័យ។ គោលការណ៍ទាំងនេះមិនត្រឹមតែទាមទារជាការអប់រំប៉ុណ្ណោះទេ ប៉ុន្តែវាជាការវិនិច្ឆ័យខាងសីលធម៌ដែលត្រូវបណ្តុះបណ្តាលកងកម្លាំងជាមន្ត្រីប្រដាប់អាវុធតាមរយៈការពង្រឹងវិន័យនិងក្រមសីលធម៌ដើម្បីគ្រប់គ្រងខ្លួនឯង។

ក្នុងន័យនេះ មន្ត្រីនគរបាលត្រូវបានបណ្តុះបណ្តាលឱ្យចេះប្រើការព្រមានជាពាក្យសំដីនៅក្នុងព្រឹត្តិការណ៍នៃកិច្ចប្រតិបត្តិការជំហានបឋមណាមួយដោយប្រើប្រាស់វិធីសាស្ត្រមិនបណ្តាលឱ្យមនុស្សស្លាប់និងអនុវត្តជំនាញបច្ចេកទេសកាត់បន្ថយភាពតានតឹងមុនពេលងាកទៅរកការប្រើអាវុធ។ រាល់ការសម្រេចចិត្តប្រើប្រាស់កម្លាំងត្រូវតែបានរាយការណ៍និងពិនិត្យឡើងវិញ ព្រមទាំងបញ្ជាក់ពីភាពត្រឹមត្រូវសមស្របដែលឆ្លុះបញ្ចាំងពីគោលការណ៍សីលធម៌ ដែលអំណាចត្រូវតែមានការទទួលខុសត្រូវជានិច្ច។

### គ- គណនេយ្យភាពក្នុងការប្រើប្រាស់កម្លាំង

គណនេយ្យភាព ធានាឱ្យមានយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋនិងមន្ត្រីនគរបាល។ ឧប្បត្តិហេតុនៃការប្រើប្រាស់កម្លាំងនីមួយៗត្រូវតែត្រូវបានស៊ើបអង្កេតដើម្បីកំណត់ «ភាពស្របច្បាប់» «សមាមាត្រ» និង «ភាពចាំបាច់»។ ការខកខានក្នុងការបង្ហាញនៅក្នុងរបាយការណ៍ឬលាក់បាំងការពិតបង្កើតបានជាការប្រព្រឹត្តខុសធ្ងន់ធ្ងររបស់មន្ត្រីនគរបាល។

ការអនុវត្តល្អបំផុតរបស់អន្តរជាតិ ណែនាំឱ្យបង្កើតយន្តការត្រួតពិនិត្យឯករាជ្យ ខណៈដែលស្ថាប័នអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាមានអង្គភាពស៊ើបអង្កេតផ្ទៃក្នុងរួចហើយ។ ទោះជាយ៉ាងណាក៏ដោយ គណនេយ្យភាពយូរអង្វែង គឺអាស្រ័យលើវប្បធម៌ សីលធម៌មិនមែនត្រឹមតែផ្អែកតែលើនីតិវិធីនោះទេ។ នៅពេលដែលមន្ត្រីនគរបាលជឿជាក់លើតម្លាភាពខាងសីលធម៌ពួកគេនឹងប្រព្រឹត្តនៅក្នុងដែនកំណត់នៃសតិសម្បជញ្ញៈនិងច្បាប់ដោយធម្មជាតិ។

### ឃ- ភាពវៃឆ្លាតផ្នែកអារម្មណ៍និងការគ្រប់គ្រងដោយសីលធម៌

ក្រៅពីគោលនយោបាយនិងច្បាប់ការប្រើប្រាស់កម្លាំងប្រកបដោយសីលធម៌ទាមទារភាពវៃឆ្លាតផ្នែកអារម្មណ៍។ មន្ត្រីនគរបាលដែលយល់ពីអារម្មណ៍របស់ពួកគេអាចគ្រប់គ្រងប្រតិកម្មរបស់ពួកគេក្នុងអំឡុងពេលជួបនឹងស្ថានភាពតានតឹងខ្ពស់។ កំហឹង ការភ័យខ្លាច និងមោទនភាពគឺជាកម្លាំងជំរុញរបស់មនុស្ស ប៉ុន្តែពួកគេត្រូវតែត្រូវបានទប់ស្កាត់ដោយហេតុផលនិងមេត្តាធម៌។

ទ្រឹស្តីរបស់ព្រះពុទ្ធសាសនាបានលើកឡើងពី «សតិ» មានន័យថាជាសេចក្តីនឹកឃើញមិនបំភ្លេច ឬអាចនិយាយបានថាជាដំណើរនៃសេចក្តីភ្ញាក់រឭកដ៏រុងរឿងនៃគំនិតដែលអាចត្រូវបានអនុវត្តជាឧបករណ៍ចិត្តសាស្ត្រនិងសីលធម៌ជួយឱ្យមន្ត្រីនគរបាលរក្សាភាពស្ងប់ស្ងាត់និងដឹងពីចេតនាពិតរបស់ពួកគេ។ មន្ត្រីដែលមាន «សតិ» បានធ្វើកំហុសតិចតួចណាស់ដោយបានគោរពនិងឱ្យតម្លៃអាយុជីវិតមនុស្សនិងបញ្ញាបន្ទូវអំណាចក្រមសីលធម៌ពិតប្រាកដ។

## ២- ការបំពេញតួនាទីក្នុងភាពជាអ្នកដឹកនាំបញ្ជា

### ២.១- ការដឹកនាំ

អ្នកដឹកនាំឬមេបញ្ជាការ ដើម្បីដឹកនាំបានទាល់តែមានការគ្រប់គ្រង ហើយការគ្រប់គ្រងពេលណាក៏បានជះឥទ្ធិពលទៅលើការចាត់តាំងមន្ត្រីអនុវត្តដោយមានទិសដៅកំណត់និងគោលដៅនៃកម្មវត្ថុដែលត្រូវគ្រប់គ្រង។ ជាទូទៅការដឹកនាំមានច្រើនបែបច្រើនយ៉ាងផ្សេងៗពីគ្នាចាប់ពីការដឹកនាំកម្រិតខ្ពស់រហូតដល់ការដឹកនាំកម្រិតទាប។ មានន័យថាទីកន្លែងណាក៏មានការដឹកនាំដែរមានការដឹកនាំច្រើនកាលណាគឺល្អកាលនោះដោយអាស្រ័យលើអ្នកដឹកនាំទទួលបានបទពិសោធការងារច្រើន។

ការដឹកនាំ គឺជាការណែនាំ ការបញ្ជាសមូហភាព និងបុគ្គលឱ្យមានសកម្មភាពដើម្បីសម្រេចបាននូវគោលដៅមួយដែលបានកំណត់ក្នុងក្របខណ្ឌពេលវេលាដ៏ជាក់លាក់។ ក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត មានន័យទូលំទូលាយថា «ការដឹកនាំ» គឺជាការនាំផ្លូវនិងចង្អុលផ្លូវណែនាំរាល់សកម្មភាពណាមួយដើម្បីដល់គោលដៅដែលបានកំណត់។

តាមន័យវិទ្យាសាស្ត្រ «ការដឹកនាំ» គឺជាការជះឥទ្ធិពលដល់សកម្មភាពរបស់មនុស្សនិងសង្គមដើម្បីសម្រេចគោលបំណងជាក់លាក់ដែលបានគ្រោងទុក។ ម្យ៉ាងទៀតគឺជាដំណើរការលើកទឹកចិត្តជាមួយនឹងចំណងទាក់ទងជាមូលដ្ឋានដែលជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមកគឺអ្នកបញ្ជានិងអ្នកអនុវត្ត។

មុខសញ្ញាដែលត្រូវដឹកនាំ ជាកងកម្លាំងដែលជាមន្ត្រីបុគ្គលិកក្រោមឱវាទកំពុងបម្រើការងារនៅក្នុងអង្គភាពឬស្ថាប័ន។ ពួកគាត់ជាអ្នកអនុវត្តការងារក្នុងការបំពេញបេសកកម្មដ៏ពិសិដ្ឋរបស់នគរបាលបម្រើប្រជាពលរដ្ឋតាមផែនការកំណត់។ ទោះបីយ៉ាងណាការដឹកនាំក៏ត្រូវបានជំរុញលើកទឹកចិត្តនិងផ្សារភ្ជាប់ជាមួយនឹងការត្រួតពិនិត្យវាយតម្លៃរកឃើញចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម។

### ២.២- ការបញ្ជា

ការបញ្ជា គឺជាដំណើរការជះឥទ្ធិពលដល់អ្នកក្រោមបង្គាប់និងមានការកំណត់ទិសដ៏ត្រឹមត្រូវតាមការដឹកនាំ។ ប៉ុន្តែសកម្មភាពទាំងនេះវាបានផ្សារភ្ជាប់ជាមួយនឹងសកម្មភាពជាក់ស្តែងដែលមានចរិតដាច់ខាត ម៉ឺងម៉ាត់ និងជាបន្ទាន់ដែលអ្នកទទួលបញ្ជាត្រូវតែទទួលយកទៅប្រតិបត្តិតាម ។ គេអាចគោរពតាមបទបញ្ជាបានអាស្រ័យដោយបទបញ្ជានោះវាស្របទៅតាមលក្ខខណ្ឌគតិយុត្តិឬក៏ត្រូវបានគេដាក់

បញ្ចូលទៅក្នុងក្របខណ្ឌនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ។ អ្នកបញ្ជានិងអ្នកអនុវត្តបញ្ជាត្រូវមានស្មារតីទទួលខុសត្រូវនូវរាល់ការដាក់ចេញបញ្ជានិងការអនុវត្តបញ្ជារបស់ខ្លួនឱ្យបានច្បាស់លាស់ចំពោះមុខច្បាប់។

ប្រសិនបើការបញ្ជាឱ្យមន្ត្រីថ្នាក់ក្រោមអនុវត្ត ហើយដោយពិនិត្យឃើញថាបញ្ជានោះត្រូវបានពិចារណាថាមិនត្រឹមត្រូវស្របទៅនឹងនីតិវិធីរបស់កងកម្លាំងឬមិនស្របទៅនឹងច្បាប់ បទវិន័យដែលមានចែងនោះធ្វើឱ្យអ្នកអនុវត្តបញ្ជាមានការរារែកឬក៏ត្រូវអនុវត្តនូវបទបញ្ជានោះដោយបង្ខំចិត្ត។ ករណីនេះសបញ្ជាក់ឱ្យឃើញថា ទាំងអ្នកបញ្ជានិងអ្នកអនុវត្តបញ្ជាមិនមែនជាមន្ត្រីកងកម្លាំងមានវិជ្ជាជីវៈពិតប្រាកដនោះទេ។ កត្តាទាំងនេះវាបានរារាំងដល់ការពង្រឹងតួនាទីរបស់នគរបាលក្នុងភាពជាអ្នកដឹកនាំបញ្ជា។ ដូចនេះអ្នកដឹកនាំឬមេបញ្ជាការ មុននឹងសម្រេចធ្វើកិច្ចការអ្វីមួយក្នុងតួនាទីដឹកនាំរបស់ខ្លួនត្រូវផ្អែកតាមផ្លូវច្បាប់ឬបទដ្ឋានគតិយុត្តិនានា ធ្វើជាមូលដ្ឋានសម្រាប់ដាក់ចេញនូវសេចក្តីសម្រេច បទបញ្ជានៅក្នុងអង្គភាពឬស្ថាប័នសំដៅពង្រឹងតួនាទីរបស់ខ្លួនឱ្យកាន់តែរឹងមាំនិងមានប្រសិទ្ធភាពថែមទៀត។

**២.៣- ដំណើរការនៃការបញ្ជា**

ក្នុងដំណើរការបញ្ជាឱ្យអនុវត្តកិច្ចប្រតិបត្តិការណាមួយ អ្នកដឹកនាំឬអ្នកបញ្ជាត្រូវទទួលបាននូវសិទ្ធិទទួលខុសត្រូវពិសេសនិងមានសិទ្ធិប្រើប្រាស់ដោយឯករាជ្យម្ចាស់ការ។ រាល់ការបញ្ជារបស់អ្នកដឹកនាំឬមេបញ្ជាការអាចជាការចាប់បង្ខំឱ្យថ្នាក់ក្រោមត្រូវអនុវត្តដោយគ្មានលក្ខខណ្ឌ។ រីឯអ្នកទទួលបញ្ជាអនុវត្តប្រសិនជាទទួលមិនទាន់ច្បាស់ជាក់លាក់ក្នុងករណីណាមួយមានសិទ្ធិសួរឡើងវិញឬប្រសិនបើឃើញថាមិនទាន់សមស្របដោយត្រូវជូនយោបល់ដល់អ្នកបញ្ជា។ ក្នុងហេតុផលនេះក្នុងភាពចាំបាច់នៅពេលដែលអ្នកបញ្ជាមិនផ្លាស់ប្តូរបញ្ជាទេ អ្នកទទួលបញ្ជានៅតែគោរពនិងប្រតិបត្តិតាមយ៉ាងម៉ឺងម៉ាត់ សកម្មភាពនេះបញ្ជាក់ពីការគោរពវិន័យដោយវិជ្ជាជីវៈក្នុងនាមជាកងកម្លាំងអនុវត្តច្បាប់របស់ជាតិ។

ដោយឡែក ផ្អែកលើគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើកម្លាំងនិងអាវុធដោយមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធនឹងទំនួលខុសត្រូវជាបុគ្គលរបស់មន្ត្រីនគរបាលទាក់ទងនឹងការដាក់ចេញបញ្ជានិងអនុវត្តបញ្ជាក៏បានចែងច្បាស់លាស់ផងដែរ (សូមអាននៅផ្នែកទី៦ ទំព័រទី៧៧)។

ទោះជាយ៉ាងណាក្តី ប្រសិនបើយើងពិនិត្យអំពីលក្ខខណ្ឌនៃការជះឥទ្ធិពលរវាងអ្នកដឹកនាំនិងកងកម្លាំងមន្ត្រីក្រោមបង្គាប់ក្នុងរូបភាពនៃការបំពេញការងារ គឺការបញ្ជាខុសប្លែកពីការដឹកនាំនៅត្រង់ថាការបញ្ជាផ្សារភ្ជាប់ជាមួយនឹងសកម្មភាពជាក់ស្តែងជាមួយភារកិច្ចចាំបាច់ដែលត្រូវប្រមូលផ្តុំបញ្ញាញាណដើម្បីអនុវត្តក្នុងពេលវេលាដ៏សំខាន់មួយជាកំណត់ដែលមានចរិតជាបន្ទាន់និងប្រញាប់ប្រញាល់បំផុត។

**២.៤- ខ្លឹមសារការដឹកនាំបញ្ជា**

ក្នុងការងារជាក់ស្តែង «ការដឹកនាំនិងការបញ្ជា» ត្រូវបានផ្សារភ្ជាប់គ្នាមិនអាចផ្តាច់ចេញពីគ្នាបានទេ។ គេអាចយល់ឃើញថា ការងារដឹកនាំបញ្ជាគឺជាការដាក់ចេញនូវគោលការណ៍ផែនការ ការចាត់តាំងនិងការជំរុញលើកទឹកចិត្តតាមរយៈការបំពាក់គ្រឿងឧបករណ៍សម្ភារៈគ្រប់គ្រាន់ដើម្បីធានាបាននូវការបំពេញភារកិច្ចរបស់កងកម្លាំងឱ្យមានការឯកភាពគ្នាដើម្បីសម្រេចគោលដៅរបស់អង្គភាពឬស្ថាប័ន។

ការដឹកនាំបញ្ជាកងកម្លាំងគឺជាការទទួលខុសត្រូវនិងភាពម្ចាស់ការរបស់អ្នកដឹកនាំដើម្បីអនុវត្តឱ្យបានជោគជ័យក្នុងការដឹកនាំប្រតិបត្តិការបម្រើសេវាសន្តិសុខនិងសេវាសាធារណៈជូនប្រជាពលរដ្ឋ។

អ្នកដឹកនាំឬមេបញ្ជាការនៃអង្គភាពនគរបាលអាចបញ្ជាដោយផ្ទាល់ឬដោយប្រយោលដល់មន្ត្រីកងកម្លាំងក្រោមបង្គាប់របស់ខ្លួនទៅតាមនីតិវិធីនិងវិធានការជាច្រើនផ្សេងៗពីគ្នា។ សកម្មភាពដឹកនាំបញ្ជាកងកម្លាំងត្រូវឆ្លងកាត់ការគ្រប់គ្រងអារម្មណ៍ផ្លូវចិត្តរបស់មន្ត្រីក្រោមបង្គាប់ដោយត្រូវបណ្តុះឆន្ទៈមនសិការវិជ្ជាជីវៈតាមស្មារតីអភិសមាចារនិងក្រមសីលធម៌ក្នុងការបំពេញភារកិច្ចរបស់ពួកគេ។ ការពង្រឹងធនធានមនុស្សក្នុងក្រមសីលធម៌វិជ្ជាជីវៈគឺជាមូលដ្ឋានគ្រឹះចាំបាច់បំផុតដើម្បីផ្សារភ្ជាប់ចំណងទាក់ទងជាមួយនឹងប្រព័ន្ធគ្រប់គ្រងដឹកនាំបញ្ជា។ អ្នកដឹកនាំឬមេបញ្ជាការអង្គភាពជាអ្នកច្នៃប្រឌិតនិងបង្កើតចេញនូវប្រព័ន្ធដឹកនាំបញ្ជាមួយនេះប្រកបដោយសីលធម៌ គុណធម៌ យុត្តិធម៌ និងតម្លាភាព ហើយមន្ត្រីនគរបាលទាំងអស់ត្រូវចំណុះឱ្យប្រព័ន្ធដ៏មានសារៈសំខាន់នេះ។

មេបញ្ជាការកងកម្លាំងនគរបាលត្រូវចងចាំថា «អំណាចមិនមែនជាឯកសិទ្ធិទេ» វាគឺជាបន្ទុកនៃការទទួលខុសត្រូវ។ ការប្រើអំណាចខុសសីលធម៌ដើម្បីសងសឹកឬដើម្បីផលប្រយោជន៍គឺជាការក្បត់នឹងឧត្តមគតិរបស់ខ្លួនក្នុងវិជ្ជាជីវៈ។ ការសម្រេចចិត្តត្រឹមត្រូវបានផ្លាស់ប្តូរពីការអនុវត្តច្បាប់ទៅជាភាពជាអ្នកដឹកនាំខាងសីលធម៌គួរឱ្យគោរពនិងជឿជាក់តាមធម្មានុរូប។

ការសម្រេចចិត្តរបស់អ្នកដឹកនាំឬមេបញ្ជាការនគរបាលគប្បីអនុញ្ញាតឱ្យមន្ត្រីយល់ឃើញថាជាភាពត្រឹមត្រូវស្របតាមច្បាប់គ្រប់ស្ថានភាពនិងកាលៈទេសៈផ្សេងៗគ្នា ទោះជាយ៉ាងណាក៏ដោយការសម្រេចចិត្តដោយគ្មានសីលធម៌នាំឱ្យមានការរំលោភបំពាន។ ក្នុងន័យនេះទាំងមេបញ្ជាការ ទាំងមន្ត្រីត្រូវតែអនុវត្តអំណាចដោយមេត្តាធម៌ សមធម៌ និងការអត់ធ្មត់ គុណតម្លៃវប្បធម៌ខ្មែរសង្កត់ធ្ងន់លើ «សេចក្តីអាណិតអាសូរ» ដែលជាគោលការណ៍គួរតែត្រូវបានសម្របសម្រួលរាល់សកម្មភាពអនុវត្តច្បាប់របស់មន្ត្រីនគរបាលតាមហេតុផលសមស្រប។

### ២.៥- លក្ខណៈពិសេសនៃការដឹកនាំបញ្ជា

ការងារដឹកនាំបញ្ជាកងកម្លាំង គឺជាការដឹកនាំបញ្ជាមានចរិតម៉ឺងម៉ាត់បម្រើឱ្យគោលនយោបាយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ការគោរពច្បាប់របស់រដ្ឋ ការគោរពសិទ្ធិមនុស្ស ការការពារផលប្រយោជន៍សង្គមនិងប្រជាជន។ អាស្រ័យហេតុនេះការដឹកនាំបញ្ជាកងកម្លាំងត្រូវប្រកាន់ចរិតជាកងកម្លាំងគោរពវិន័យនិងក្រមសីលធម៌វិជ្ជាជីវៈក្នុងកិច្ចប្រតិបត្តិការដូចខាងក្រោម៖

- ការចាត់តាំងត្រូវមានភាពវៃឆ្លាតជិតស្និទ្ធជានាឱ្យការបញ្ជាមានភាពប្រមូលផ្តុំនិងឯកភាពគ្នា
- ការដឹកនាំបញ្ជាត្រូវមានភាពរស់រវើក គោរពវិន័យ គោរពបទបញ្ជា ធានាមានប្រសិទ្ធភាព
- អ្នកដឹកនាំបញ្ជាត្រូវមានឥរិយាបថនិងរបៀបធ្វើការដាច់ណាត់ រហ័សរហួន គោរពវិន័យជាគំរូ
- ក្តាប់ឱ្យបានច្បាស់អំពីតួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ខ្លួនដែលកំពុងទទួលខុសត្រូវ
- អនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍គោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា
- ចាត់តាំងសកម្មភាពទប់ទល់បញ្ហាប្រឈមនិងហានិភ័យនានាដែលបម្រុងកើតមាន
- ធានាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងអនុវត្តច្បាប់ដោយយុត្តិធម៌
- ត្រូវចេះក្តាប់ឱកាសនិងត្រូវចេះជ្រើសរើសបញ្ហាជាអាទិភាពដើម្បីរកដំណោះស្រាយ
- ចេះប្រើប្រាស់នូវរាល់ចំណងទាក់ទងរវាងកត្តាអត្តនោម័តនិងកត្តាសត្យានុម័ត
- មានគំនិតច្នៃប្រឌិតរស់រវើកក្នុងការដឹកនាំបញ្ជានិងចាប់យកឱកាសដើម្បីភាពជោគជ័យ

- ចេះប្រើមនុស្សដើម្បីផលប្រយោជន៍បុគ្គលនិងផលប្រយោជន៍សមូហភាព
- ថ្នាក់ដឹកនាំត្រូវធ្វើជាគំរូល្អក្នុងការងារ ការអភិវឌ្ឍសមត្ថភាព ការពង្រឹងវិន័យ មានចរិតសុភាពរាបសា ទន់ភ្លន់ ម៉ឺងម៉ាត់ និងអនុវត្តការងារត្រួតពិនិត្យជាប្រចាំ។

## ៣- ការកសាងសាមគ្គីភាព សុខដុមនីយកម្ម

គោលបំណងនៃជីវភាពរស់នៅក្នុងសង្គមជាតិមួយគឺ «ការចង់បាននូវសន្តិភាព» មានសន្តិភាពប្រទេសជាតិមានការរីកចម្រើន មានការអភិវឌ្ឍលើគ្រប់វិស័យ។ ការណ៍នេះបានមកពីការបង្កើតឱ្យមានភាពវិជ្ជមានតាមរយៈកត្តាសាមគ្គីភាព ការយោគយល់ និងភាពអធ្យាស្រ័យគ្នាទៅវិញទៅមកប្រកបដោយសុខដុមនីយកម្មជាមួយគ្នារវាងថ្នាក់ដឹកនាំនិងប្រជាជន រវាងប្រជាជននិងមន្ត្រីរាជការ និងរវាងប្រជាជនជាមួយគ្នា ប្រជាជនដូចគ្នា។ ការរក្សាសាមគ្គីភាពនេះ មន្ត្រីនគរបាលទាំងអស់ត្រូវធ្វើជាគំរូក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ដើម្បីបង្ហាញពីការរួបរួមគ្នា ព្រមព្រៀងគ្នា ចុះសម្រុងគ្នា និងចេះធ្វើការជាមួយគ្នាដោយសុខដុមនីយកម្មនិងត្រូវធ្វើឱ្យគោលបំណងនេះក្លាយទៅជាវប្បធម៌របស់អង្គភាព។

មាគ៌ានាំឱ្យកើតមានសាមគ្គីភាព រស់នៅដោយសុខដុមរមនារួមមាន៖

- ត្រូវមានចិត្តមេត្តាសំដៅដល់ការគិតល្អ ការមើលគ្នាក្នុងផ្លូវល្អ មានចេតនាដោយបំណងល្អចំពោះគ្នា ស្រលាញ់រាប់អានគ្នា ជួយស្ដាបនាគ្នាដោយមិនច្រណែនឈ្នានីសឬព្យាបាទគ្នា និងត្រូវចេះឱ្យឱកាសនិងការអភ័យទោសចំពោះគ្នា

- ត្រូវប្រព្រឹត្តដោយមេត្តា សំដៅដល់ការប្រព្រឹត្តប្រកបដោយការអធ្យាស្រ័យគ្នា ធ្វើល្អចំពោះគ្នា គោរពគ្នា ជួយជ្រោមជ្រែងគ្នាទាំងកម្លាំងកាយ ចិត្ត និងទ្រព្យធន និងការមិនបៀតបៀនគ្នាទៅវិញទៅមកនិងត្រូវគោរពច្បាប់និងសិទ្ធិសេរីភាពអ្នកដទៃសំដៅដល់ការបដិបត្តិតាមច្បាប់រដ្ឋ បទបញ្ជា និងបទវិន័យផ្សេងៗរបស់អង្គភាពឬស្ថាប័ន

- ត្រូវសម្របសម្រួលទស្សនៈ តាមរយៈការតម្រង់ទិសឱ្យមានការយល់ឃើញស្របគ្នានិងគោលដៅដូចគ្នា សង្រួមគំនិតឱ្យត្រូវគ្នាដោយមិនត្រូវប្រកាន់យកទស្សនៈរបស់ខ្លួនជាធំនិងត្រូវចេះស្ដាប់ដោយការពិចារណាលើមតិយោបល់របស់អ្នកដទៃ (មិនគម្ពីរនិយម) និងត្រូវមានស្មារតី ឆន្ទៈមនសិការចាត់ទុកអង្គភាពជាផ្ទះកំណើតរបស់ខ្លួន និងតម្កល់ផលប្រយោជន៍រួមដើម្បីបុព្វហេតុជាតិនិងប្រជាជន

- ត្រូវស្គាល់ពីខ្លួនឯង ការព្យាយាមគ្រប់គ្រងខ្លួនឯងជាបញ្ហាចម្បងជួយយើងឱ្យស្គាល់និងយល់ពីសន្ដានចិត្តរបស់អ្នកដទៃ។ មានន័យថាត្រូវស្គាល់ពីដើមកំណើត ចំណុចខ្លាំង ចំណុចខ្សោយរបស់ខ្លួន និងដឹងថាខ្លួនកំពុងនៅទីណា? ត្រូវការអ្វី? ស្រលាញ់អ្វី? និងមិនចូលចិត្តអ្វី?

- ត្រូវមានទិសដៅប្រាស្រ័យទាក់ទងសហការជិតស្និទ្ធច្បាស់លាស់ ស្មោះត្រង់ មានការទុកចិត្តគ្នាទៅវិញទៅមកជាមួយនឹងដៃគូជាតិនិងអន្តរជាតិនិងចាត់ទុកជាដៃគូរឹងមាំក្នុងវិស័យសន្តិសុខជាតិ។

# ផ្នែកទី៥

# ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

## ១- តួនាទីក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ក្នុងយុគសម័យទំនើប នាំមកនូវបញ្ហាប្រឈមផ្នែកសីលធម៌ថ្មីៗនៃបទឧក្រិដ្ឋតាមអ៊ីនធឺណិត និងការឃ្លាំមើលតាមប្រព័ន្ធឌីជីថល បញ្ញាសិប្បនិម្មិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ បច្ចេកវិទ្យាទាំងនេះទោះបីជាមានអានុភាពខ្លាំងក្លាក៏ដោយ ប៉ុន្តែវាអាចជាការរំលោភលើឯកជនភាព សិទ្ធិមនុស្ស និងសន្តិសុខជាតិ ប្រសិនបើត្រូវបានប្រើប្រាស់ខុស។ ដូច្នេះកិច្ចការនគរបាលប្រកបដោយសីលធម៌ក្នុងយុគសម័យឌីជីថលត្រូវតែធ្វើឱ្យមានតុល្យភាពរវាងនវានុវត្តន៍និងសុចរិតភាព។

អង្គភាពប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនិងកោសល្យវិច័យឌីជីថលនៅកម្ពុជាត្រូវតែគោរពការការពារទិន្នន័យ តម្លាភាព និងគណនេយ្យភាពក្នុងការប្រតិបត្តិការនីមួយៗ។ នៅពេលដែលការប្រើបញ្ញាសិប្បនិម្មិត (AI) និងការឃ្លាំមើល ព្រមទាំងគោលការណ៍ណែនាំនៅតែមិនផ្លាស់ប្តូរទេ បច្ចេកវិទ្យាត្រូវតែបម្រើមនុស្សជាតិដោយមិនមែនជំនួសដោយសីលធម៌ទេ។

ក្រមសីលធម៌បច្ចេកវិទ្យាស្រដៀងគ្នានឹងគោលការណ៍នៃក្រមសីលធម៌មន្ត្រីដែរ។ ក្រមសីលធម៌បច្ចេកវិទ្យាគឺជាគោលការណ៍ដែលកំណត់ពីគុណតម្លៃនៃការប្រើប្រាស់បច្ចេកវិទ្យារបស់មនុស្សឬស្ថាប័នដើម្បីនាំឱ្យបច្ចេកវិទ្យាក្នុងពិភពលោកមានការវិវឌ្ឍទៅមុខដោយវិជ្ជមាន។ ក្នុងពេលបច្ចុប្បន្នក្រមសីលធម៌បច្ចេកវិទ្យាកំពុងត្រូវបានអ្នកជំនាញនាំគ្នាសិក្សានិងអភិវឌ្ឍជាបន្តបន្ទាប់ឥតឈប់ឈរ នោះដោយសារតែបច្ចេកវិទ្យាកំពុងមានការវិវឌ្ឍយ៉ាងរហ័ស។ ដោយហេតុនេះហើយទើបក្រមសីលធម៌បច្ចេកវិទ្យាត្រូវតែមានការអភិវឌ្ឍក្នុងល្បឿនឱ្យស្របទៅនឹងការលេចឡើងនៃបច្ចេកវិទ្យាថ្មីៗ។ តួយ៉ាងដូចជាបច្ចេកវិទ្យា AI (Artificial Intelligence) ជាដើម។ បច្ចេកវិទ្យានេះត្រូវបានបង្កើតឡើងក្នុងគោលដៅដើម្បីសម្រួលដល់ការរស់នៅនិងធ្វើការងារប្រចាំថ្ងៃរបស់មនុស្សតាមរយៈមុខងារដែលមានប្រយោជន៍នានា។ ប៉ុន្តែក្នុងពេលជាមួយគ្នា វាក៏ត្រូវបានគេយកទៅប្រើប្រាស់ដោយជនទុច្ចរិតក្នុងការបង្កើតមាតិកាក្លែងក្លាយឬអំពើទុច្ចរិតផ្សេងទៀត ហើយយកទៅផ្សព្វផ្សាយជាសាធារណៈតាមបណ្តាញសង្គមដែលបង្កឱ្យមានការប៉ះពាល់ដល់សិទ្ធិឯកជននិងការភាន់ច្រឡំក្នុងសង្គមជាដើម។ ក្រៅពីនេះមានឧទាហរណ៍ជាក់ស្តែងដែលកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ន នោះគឺការបោកបញ្ឆោត ការចាប់ជំរិត និងការប្រព្រឹត្តអំពើខុសច្បាប់នានាតាមប្រព័ន្ធបច្ចេកវិទ្យាដែលសុទ្ធសឹងជាបញ្ហាដែលត្រូវទប់ស្កាត់និងលុបបំបាត់ដើម្បីរក្សាសុវត្ថិភាពនិងសេចក្តីសុខក្នុងសង្គម។ អំពើទាំងនេះអាចកើតឡើងដោយសារការមិនប្រកាន់ខ្ជាប់នូវក្រមសីលធម៌បច្ចេកវិទ្យានេះឯង។

ផ្អែកលើបរិបទខាងលើ រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តោតការយកចិត្តទុកដាក់ចេញនូវបញ្ជាលេខ០១បប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីយុទ្ធនាការបោសសម្អាតការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងគោលបំណងដើម្បីបង្ការទប់ស្កាត់និងប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាឱ្យមានប្រសិទ្ធភាពខ្ពស់សំដៅចូលរួមចំណែកថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដោយបានដាក់ចេញនូវបទបញ្ជាមាន៩ចំណុចជាអាទិភាពដែលតម្រូវឱ្យគ្រប់ក្រសួង

ស្ថាប័ន គណៈកម្មាធិការជាតិពាក់ព័ន្ធនានានិងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្តនិងសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តបទបញ្ជាខាងលើឱ្យបានម៉ឺងម៉ាត់បំផុតនិងមានប្រសិទ្ធភាពខ្ពស់។

ដូចនេះ មនុស្សគ្រប់រូបត្រូវមានក្រមសីលធម៌ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដែលនឹងធ្វើឱ្យសង្គមក្លាយជាសង្គមជាតិមួយប្រកបដោយសេចក្ដីសុខ សុវត្ថិភាព និងសុភមង្គល។

ខាងក្រោមនេះជាសេចក្ដីណែនាំអំពីការប្រើបណ្ដាញសង្គមជានាឱ្យការប្រើប្រាស់ប្រកបដោយសីលធម៌វិជ្ជាជីវៈ អភិសមាចារ ច្បាប់ កិត្តិយស សុវត្ថិភាព និងភាពអព្យាក្រឹតរបស់អង្គភាពនគរបាលក្នុងការបង្ការការលេចធ្លាយព័ត៌មាននិងការបំពានវិន័យរបស់នគរបាល។ សេចក្ដីណែនាំនេះអាចអនុវត្តចំពោះមន្ត្រីនគរបាលគ្រប់លំដាប់ថ្នាក់និងការប្រើបណ្ដាញសង្គមទាំងផ្លូវការ ទាំងផ្ទាល់ខ្លួនសម្រាប់ការប្រើប្រាស់ (Facebook, Telegram, TikTok, X, YouTube,)។ល។

### ១.១- សីលធម៌វិជ្ជាជីវៈក្នុងការប្រើប្រាស់បណ្ដាញសង្គម

នៅក្នុងក្រមសីលធម៌វិជ្ជាជីវៈក្នុងការប្រើប្រាស់បណ្ដាញសង្គមដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងអភិសមាចារនិងកងកម្លាំងនគរបាលនេះ គឺមានលក្ខណៈសំខាន់ៗដូចជា៖

#### ១.១.១- ការគោរពសេចក្ដីថ្លៃថ្នូរវិជ្ជាជីវៈ

- មិនបង្ហោះឬចែករំលែកមាតិកាដែលប៉ះពាល់ដល់កិត្តិយស ស្ថាប័ន ឬវិជ្ជាជីវៈរបស់ខ្លួន
- ប្រើភាសាសមរម្យ មិនប្រមាថ ឬមិនជេរប្រមាថ និងមិនបង្កការខឹងសម្បា
- ករណី (អភិសមាចារ) មានន័យថា បង្ហាញអាកប្បកិរិយាសុភាពរាបសានិងមានវិន័យ។

#### ១.១.២-ការគោរពច្បាប់និងបទបញ្ជាស្ថាប័ន

- មិនបង្ហោះព័ត៌មានសម្ងាត់ ឯកសារផ្លូវការ ឬព័ត៌មានកំពុងស៊ើបអង្កេត
- មិនប្រើបណ្ដាញសង្គមដើម្បីធ្វើសកម្មភាពខុសច្បាប់ឬបំភាន់សាធារណៈ
- ករណី (អភិសមាចារ) មានន័យថា ស្គាល់ព្រំដែនតួនាទីនិងការទទួលខុសត្រូវ។

#### ១.១.៣- ភាពទទួលខុសត្រូវចំពោះមាតិកា

- គិតមុនបង្ហោះ (Think Before Post)
- ត្រូវដឹងថា «ការបង្ហោះ» អាចប៉ះពាល់ដល់សង្គមនិងស្ថាប័នយូរអង្វែង
- ត្រូវទទួលខុសត្រូវលើពាក្យសំដីនិងរូបភាពរបស់ខ្លួន
- ករណី (អភិសមាចារ) មានន័យថា មានសុចរិតភាពនិងការគ្រប់គ្រងខ្លួនឯង។

#### ១.១.៤- មិនលាយបញ្ចូលរវាងជីវិតផ្ទាល់ខ្លួន និងវិជ្ជាជីវៈ

- មិនប្រើស្លាកសញ្ញាឬឋានៈក្នុងវិជ្ជាជីវៈដើម្បីបង្ហាញមតិផ្ទាល់ខ្លួន
- មិនធ្វើឱ្យសាធារណជនយល់ច្រឡំថាជាមតិផ្លូវការរបស់អង្គភាព
- ករណី (អភិសមាចារ) មានន័យថា ស្គាល់តួនាទីនិងការបង្ហាញខ្លួនឱ្យសមស្រប។

#### ១.១.៥- ការគោរពសិទ្ធិ និងឯកជនភាពអ្នកដទៃ

- មិនបង្ហោះរូបភាពឬព័ត៌មានអ្នកដទៃដោយគ្មានការអនុញ្ញាត
- មិនរំលោភសិទ្ធិជនរងគ្រោះឬជនសង្ស័យ
- ករណី (អភិសមាចារ) មានន័យថា មានមនុស្សធម៌និងការគោរពគ្នាទៅវិញទៅមក។

**១.១.៦- ចៀសវាងការបង្កោះមាតិកាបង្កការបែកបាក់សង្គម**

- មិនញុះញង់ មិនបង្កភាពស្អប់ខ្ពើម មិនប្រកាន់ពូជសាសន៍ សាសនា ឬនយោបាយ
- រក្សាអព្យាក្រឹតភាព ជាពិសេសសម្រាប់មន្ត្រីសាធារណៈ
- ករណី (អភិសមាចារ) មានន័យថា រក្សាសន្តិភាពនិងភាពជាអ្នកមានវិជ្ជាជីវៈ។

**១.១.៧- ជាគំរូល្អដល់សង្គម**

- ប្រើបណ្តាញសង្គមដើម្បីអប់រំ ផ្សព្វផ្សាយច្បាប់ និងតម្លៃវិជ្ជាជីវៈ
- បង្ហាញអាកប្បកិរិយាដែលគួរឱ្យគោរព
- ករណី (អភិសមាចារ) មានន័យថា ជាគំរូនៃសុចរិតភាពនិងវិន័យ។

**១.២- ការរក្សាព័ត៌មានសម្ងាត់**

ចំពោះការរក្សាព័ត៌មានសម្ងាត់នេះ គឺជាកាតព្វកិច្ចសីលធម៌ និងជាច្បាប់ដ៏សំខាន់មួយសម្រាប់ការលាក់ការជាពិសេស សម្រាប់មន្ត្រីសាធារណៈនិងកងកម្លាំងនគរបាល។

ខាងក្រោមនេះគឺជាចំណុចសំខាន់ៗនៃការរក្សាព័ត៌មានសម្ងាត់ដែលអាចប្រើសម្រាប់ណែនាំឬធ្វើជានីតិវិធីប្រតិបត្តិការស្តង់ដា (SOP) មានលក្ខណៈដូចខាងក្រោម៖

**១.២.១- ប្រភេទព័ត៌មានត្រូវរក្សាការសម្ងាត់**

- ព័ត៌មានស៊ើបអង្កេតនិងករណីកំពុងដំណើរការ
- ព័ត៌មានផ្ទាល់ខ្លួន (អត្តសញ្ញាណ លេខទូរសព្ទ អាសយដ្ឋាន)
- ឯកសារផ្លូវការនិងរបាយការណ៍មិនទាន់ប្រកាស
- ព័ត៌មានសន្តិសុខជាតិនិងផែនការប្រតិបត្តិការ
- ព័ត៌មានជនរងគ្រោះ សាក្សី និងជនសង្ស័យ។

**១.២.២- គោលការណ៍សំខាន់ក្នុងការរក្សាព័ត៌មានសម្ងាត់**

នៅក្នុងគោលការណ៍សំខាន់ក្នុងការរក្សាព័ត៌មានសម្ងាត់នេះមានពីរចំណុច៖

**ក- គោលការណ៍ដែលត្រូវដឹង**

+ បង្ហាញព័ត៌មានសម្រាប់តែអ្នកមានភារកិច្ចពាក់ព័ន្ធប៉ុណ្ណោះ
+ មិនត្រូវចែករំលែកព័ត៌មានដោយគ្មានការអនុញ្ញាត។

**ខ- សិទ្ធិពិសេសឬសិទ្ធិតិចតួចដែលអាចចូលប្រើ**

+ ផ្តល់សិទ្ធិចូលប្រើតិចតួចតាមតួនាទីនិងភារកិច្ច
+ កំណត់សិទ្ធិច្បាស់លាស់ក្នុងការចូលប្រើ។

មានន័យថា ជាគោលការណ៍សុវត្ថិភាពដ៏សំខាន់ក្នុងការការពារទិន្នន័យមិនឱ្យមានការចូលប្រើដោយអ្នកដែលមិនមានសិទ្ធិ។

**១.២.៣- វិធានការរក្សាការសម្ងាត់**

នៅក្នុងវិធានការរក្សាសម្ងាត់នេះគឺមានបីចំណុច៖

**ក- វិធានការរដ្ឋបាល**

+ មាននីតិវិធីប្រតិបត្តិការស្តង់ដា (SOP) និងក្រមសីលធម៌
+ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្ងាត់ NDA (ឬកិច្ចសន្យារក្សាការសម្ងាត់)
+ ការបណ្តុះបណ្តាលជាប្រចាំ។

**ខ- វិធានការបច្ចេកទេស**

+ ប្រើពាក្យសម្ងាត់ដោយម៉ត់ចត់និងប្រុងប្រយ័ត្នខ្ពស់
+ ប្រើកូនសោសម្ងាត់ (បច្ចេកទេសបម្លែងព័ត៌មានពីអត្ថបទធម្មតាទៅជាអត្ថបទសម្ងាត់នៅលើឯកសារ / Email / USB ជាដើម)
+ កំណត់សិទ្ធិ Login និង Audit Log
+ មិនប្រើ Wi-Fi សាធារណៈសម្រាប់ព័ត៌មានសម្ងាត់។

**ឃ- វិធានការរដ្ឋបាលផ្លូវការ**

+ ទុកឯកសារនៅក្នុងទូសុវត្ថិភាពឱ្យបានល្អ
+ គ្រប់គ្រងការចេញចូលក្នុងការិយាល័យឱ្យបានប្រសើរ
+ មិនថតរូបឯកសារផ្លូវការដោយទូរសព្ទផ្ទាល់ខ្លួនទេ។

**១.២.៤- ការប្រុងប្រយ័ត្នពេលប្រើបណ្តាញសង្គម**

- មិនបង្ហោះព័ត៌មានស៊ើបអង្កេតឬរូបភាពទីកន្លែងប្រតិបត្តិការ
- មិននិយាយអំពីករណីកំពុងធ្វើការ
- មិនបង្ហាញឯកសារឬអេក្រង់កុំព្យូទ័រ
- ត្រូវគិតថា បណ្តាញសង្គមមិនមែនជាកន្លែងរក្សាសម្ងាត់។

**១.២.៥- ការទទួលខុសត្រូវនិងវិន័យ**

- ការបំពានព័ត៌មានសម្ងាត់ត្រូវទទួលទោសជាធរមាន
- វិន័យរដ្ឋបាលឬអប់រំណែនាំជាផ្លូវការ
- ទោសព្រហ្មទណ្ឌឬទោសផ្សេងទៀតតាមអង្គភាពនីមួយៗ។

ការបំពេញកិច្ចការនេះគឺអាចលុបបំបាត់នូវទំនុកចិត្តពីសាធារណជន។

**១.២.៦- គំរូនៃការអនុវត្តល្អ**

- គិតមុននិយាយនិងមុនបង្ហោះ
- Lock Screen និង Logout រាល់ពេល
- បំផ្លាញឯកសារដែលមិនប្រើ (Shred)
- រាយការណ៍ភ្លាមៗប្រសិនបើព័ត៌មានលេចធ្លាយ។

សរុបមក ការរក្សាព័ត៌មានសម្ងាត់ជាស្នូលនៃសីលធម៌វិជ្ជាជីវៈ អភិសមាចារ និងសន្តិសុខព័ត៌មាន មន្ត្រីល្អមិនត្រឹមតែធ្វើការល្អទេ ប៉ុន្តែរក្សាព័ត៌មានឱ្យបានល្អត្រឹមត្រូវផងដែរ។

### ១.៣- ចៀសវាងការប្រើព័ត៌មានខុសច្បាប់

ការចៀសវាង ការប្រើព័ត៌មានខុសច្បាប់គឺជាផ្នែកដ៏សំខាន់នៃសីលធម៌វិជ្ជាជីវៈ អភិសមាចារ និងការគោរពច្បាប់ ជាពិសេស សម្រាប់មន្ត្រីសាធារណៈនិងកងកម្លាំងនគរបាល។

ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលគួរយកចិត្តទុកដាក់៖

#### ១.៣.១- អ្វីទៅជា «ព័ត៌មានខុសច្បាប់»

ព័ត៌មានខុសច្បាប់គឺជាព័ត៌មានឬមាតិកាដែល៖

- ផ្សាយដោយគ្មានការអនុញ្ញាតតាមច្បាប់
- បំពានសិទ្ធិ ឬប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- បង្កការយល់ច្រឡំឬបំពានកិត្តិយសអ្នកដទៃ។

ឧទាហរណ៍៖ ព័ត៌មានក្លែងក្លាយ (Fake News) ព័ត៌មានបំភាន់ ឬព័ត៌មានមិនទាន់បញ្ជាក់ការផ្សាយផ្លូវការ (ឧ. ព័ត៌មានស៊ើបអង្កេតមុនពេលប្រតិបត្តិការ)

- ការថតនិងការផ្សាយដោយគ្មានការអនុញ្ញាត
- មាតិកាបង្កភាពស្អប់ខ្ពើមឬញុះញង់ឱ្យមានការមិនទុកចិត្តបង្កើតបានភាពចលាចល។

នៅក្នុងខ្លឹមសារខាងលើនេះគឺមានបីចំណុចសំខាន់ៗដូចខាងក្រោម៖

**ក- ផ្ទៀងផ្ទាត់ប្រភព (Verify the Source)**

+ ប្រើព័ត៌មានពីប្រភពផ្លូវការនិងគួរឱ្យទុកចិត្ត
+ មិនជឿឬចែករំលែកព័ត៌មានមិនច្បាស់ប្រភព។

**ខ- គិតមុនចែករំលែក (Think Before Share)**

+ សួរខ្លួនឯង៖ ព័ត៌មាននេះពិតទេ? ត្រឹមត្រូវទេ? ស្របច្បាប់ទេ?
+ បើមិនទាន់ប្រាកដ សូមកុំចែករំលែក។

**គ- គោរពច្បាប់និងបទបញ្ញាស្ថាប័ន**

+ អនុវត្តច្បាប់របស់អង្គភាពឬស្ថាប័នឱ្យបានដាក់លាក់
+ អនុវត្តតាមច្បាប់សារព័ត៌មាននិងច្បាប់បច្ចេកវិទ្យាព័ត៌មាន
+ មិនប្រើព័ត៌មានផ្ទាល់ខ្លួនដើម្បីផ្សាយមតិផ្លូវការរបស់អង្គភាព។

#### ១.៣.២- ការប្រុងប្រយ័ត្នពេលប្រើបណ្តាញសង្គម

- មិន Like / Share ព័ត៌មានខុសច្បាប់
- មិន Comment ជាលក្ខណៈញុះញង់ឬប្រមាថ
- មិនផ្សាយរូបភាពជនរងគ្រោះឬជនសង្ស័យ
- មិន Live ឬផ្សាយហេតុការណ៍ដោយគ្មានការអនុញ្ញាត
- ករណី (អភិសមាចារ) មានន័យថា ត្រូវសុភាពរាបសា អព្យាក្រឹត និងគ្រប់គ្រងខ្លួនឯង។

#### ១.៣.៣- ការប្រើព័ត៌មានឱ្យបានត្រឹមត្រូវ

- ចែករំលែកតែព័ត៌មានអប់រំ ឬព័ត៌មានផ្លូវការ
- ប្រើភាសាសមរម្យ និងមានទំនួលខុសត្រូវ

- បែងចែកឱ្យបានច្បាស់លាស់រវាងមតិផ្ទាល់ខ្លួន និងមតិផ្លូវការ
- រាយការណ៍ព័ត៌មានខុសច្បាប់ទៅអាជ្ញាធរឬសមត្ថកិច្ចពាក់ព័ន្ធ។

### ១.៣.៤- ទណ្ឌកម្មនិងផលប៉ះពាល់

ការប្រើឬចែករំលែកព័ត៌មានខុសច្បាប់អាចនាំឱ្យមាន៖

- ទោសព្រហ្មទណ្ឌ
- វិន័យរដ្ឋបាល
- បាត់បង់ទំនុកចិត្តសាធារណៈ
- ប៉ះពាល់ដល់កិត្តិយសស្ថាប័ន។

## ២- សីលធម៌នៃការរក្សាឯកសារនិងភស្តុតាង

សីលធម៌នៃការរក្សាឯកសារនិងភស្តុតាង គឺជាស្នូលសំខាន់នៃវិជ្ជាជីវៈស៊ើបអង្កេតនិងការអនុវត្តច្បាប់ព្រោះវាពាក់ព័ន្ធផ្ទាល់ទៅនឹងយុត្តិធម៌ សុចរិតភាព និងទំនុកចិត្តសាធារណៈ។

### ២.១- នីតិវិធីប្រតិបត្តិការតាមស្តង់ដា

ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលអាចប្រើសម្រាប់ណែនាំឬធ្វើជានីតិវិធីប្រតិបត្តិការស្តង់ដា (SOP) បាន។ ចំពោះសីលធម៌នៃការរក្សាឯកសារនិងភស្តុតាងនេះគឺមានចំណុចសំខាន់ៗដូចខាងក្រោម៖

#### ២.១.១- គោលការណ៍សីលធម៌មូលដ្ឋាន

នៅក្នុងគោលការណ៍សីលធម៌មូលដ្ឋាននេះ មានបីចំណុចសំខាន់ៗដូចខាងក្រោម៖

**ក- សុចរិតភាព**

+ មិនកែប្រែ មិនបម្លែង មិនបំផ្លាញឯកសារឬភស្តុតាង
+ ត្រូវរក្សាសភាពដើមជានិច្ច។

**ខ- ភាពអព្យាក្រឹត**

+ រក្សាភស្តុតាងដោយគ្មានលម្អៀងនិងសនិទានភាព
+ មិនជ្រើសរើសភស្តុតាងតាមអត្ថប្រយោជន៍ផ្ទាល់ខ្លួន។

**គ- ភាពទទួលខុសត្រូវ**

+ អ្នកទទួលខុសត្រូវអាចបង្ហាញប្រភពនិងដំណើរការកាន់កាប់ភស្តុតាងឱ្យបានច្បាស់លាស់
+ មានមនសិការទទួលខុសត្រូវក្នុងវិជ្ជាជីវៈរបស់ខ្លួន។

#### ២.១.២- ការរក្សាភស្តុតាងឱ្យបានត្រឹមត្រូវពីរចំណុច

**ក- ខ្សែចង្វាក់នៃការគ្រប់គ្រងរក្សាទុក**

+ កត់ត្រាលម្អិតនូវចំណុចពាក់ព័ន្ធ
    - អ្នករកឃើញ
    - ពេលវេលានិងទីតាំង
    - អ្នកទទួលបន្ត។

+ មិនឱ្យមាន «ចន្លោះប្រហោង» ក្នុងការកាន់កាប់រក្សាឯកសារនិងភស្តុតាង

**ខ- ការដាក់ស្លាកនិងកត់ត្រា**

+ ដាក់លេខសម្គាល់ (ID)

+ កត់សម្គាល់កាលបរិច្ឆេទ និងការចុះហត្ថលេខា

+ ប្រើទម្រង់ផ្លូវការ។

**២.១.៣- វិធានការរក្សាសុវត្ថិភាព**

នៅក្នុងវិធានការរក្សាសុវត្ថិភាពនេះ គឺមានពីរចំណុចសំខាន់ៗដូចខាងក្រោម៖

**ក- សន្តិសុខរូបវន្ត**

+ ទុកក្នុងទូសុវត្ថិភាពឬបន្ទប់គ្រប់គ្រង

+ កំណត់សិទ្ធិចូលប្រើ

+ មិនអនុញ្ញាតឱ្យអ្នកមិនពាក់ព័ន្ធប៉ះពាល់។

**ខ- ភស្តុតាងបច្ចេកទេសឌីជីថល**

+ រក្សាទុកក្នុងប្រព័ន្ធមានការការពារសុវត្ថិភាព

+ រៀបចំត្រៀមបម្រុងទុក (Backup) ជាប្រចាំ

+ មិនចម្លងឬបញ្ជូនដោយឧបករណ៍ផ្ទាល់ខ្លួន។

**២.១.៤- ការគោរពសិទ្ធិនិងឯកជនភាព**

- មិនបង្ហាញឯកសារ ឬភស្តុតាងជាសាធារណៈ
- ការបង្ហាញត្រូវមានការអនុញ្ញាតតាមគោលការណ៍ច្បាប់
- ការពារសិទ្ធិជនរងគ្រោះនិងជនសង្ស័យ។

**២.១.៥- ការប្រើប្រាស់និងការបង្ហាញភស្តុតាង**

- ប្រើតែសម្រាប់គោលបំណងផ្លូវការ
- មិនប្រើសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន
- មិនបង្ហាញលើបណ្តាញសង្គម។

**២.១.៦- វិន័យនិងទណ្ឌកម្ម**

ការរំលោភសីលធម៌ក្នុងការរក្សាឯកសារនិងភស្តុតាងអាចនាំឱ្យ៖

- ភស្តុតាងអសុពលភាពនៅក្នុងតុលាការ
- ទទួលវិន័យរដ្ឋបាលឬទោសព្រហ្មទណ្ឌ
- បាត់បង់ទំនុកចិត្តសាធារណៈ។

**២.១.៧- គំរូនៃការអនុវត្តល្អ**

- ប្រើ Checklist និង SOP (ស្តង់ដាប្រតិបត្តិការតាមនីតិវិធី)
- រៀបចំពាក់ស្រោមដៃនៅពេលប៉ះពាល់ភស្តុតាង ឯកសារឱ្យមានប្រព័ន្ធគ្រប់គ្រងត្រឹមត្រូវ
- រាយការណ៍ភ្លាមៗប្រសិនបើមានបញ្ហាកើតឡើង។

**២.២- ការលេចធ្លាយព័ត៌មានរបស់នគរបាល**

ខាងក្រោមនេះគឺជាការវិភាគករណី «ការលេចធ្លាយព័ត៌មានរបស់នគរបាល» ដោយផ្អែកលើសីលធម៌វិជ្ជាជីវៈ អភិសមាចារ ច្បាប់ និងការគ្រប់គ្រងសន្តិសុខព័ត៌មានដែលអាចប្រើប្រាស់សម្រាប់ណែនាំបណ្តុះបណ្តាលឬពិភាក្សាជាក្រុមដើម្បីរកឱ្យឃើញចំណុចវិជ្ជមាន៖

**២.២.១- សេចក្តីពិពណ៌នាករណី (Case Description)**

មានមន្ត្រីនគរបាលម្នាក់បានថតរូបឯកសារស៊ើបអង្កេតនិងចែករំលែកតាមរយៈ Telegram/ Facebook ទៅក្រុមមិត្តភក្តិ។ ព័ត៌មាននោះត្រូវបានបន្តចែករំលែកទូលំទូលាយដែលបណ្តាលឱ្យ៖

- ជនសង្ស័យដឹងខ្លួនមុន
- សាក្សីមានការភ័យខ្លាច
- កិច្ចប្រតិបត្តិការទទួលបរាជ័យ។

**២.២.២- ប្រភេទព័ត៌មានដែលបានបែកធ្លាយ**

- ព័ត៌មានស៊ើបអង្កេតកំពុងដំណើរការ
- អត្តសញ្ញាណជនសង្ស័យនិងសាក្សី
- ផែនការប្រតិបត្តិការនិងពេលវេលា។

ទាំងអស់នេះគឺជាព័ត៌មានសម្ងាត់ (Confidential / Restricted Information)។

**២.២.៣- វិភាគតាមសីលធម៌វិជ្ជាជីវៈ**

នៅក្នុងការវិភាគតាមសីលធម៌វិជ្ជាជីវៈនេះមានបីចំណុចដូចខាងក្រោម៖

**ក- ការបំពានសុចរិតភាព**

+ មិនគោរពកាតព្វកិច្ចរក្សាការសម្ងាត់
+ ប្រើព័ត៌មានផ្លូវការដោយគ្មានការអនុញ្ញាត។

**ខ- ការបំពានអភិសមាចារ**

+ ខ្វះការគ្រប់គ្រងខ្លួនឯង
+ មិនស្គាល់ព្រំដែននៃតួនាទីក្នុងវិជ្ជាជីវៈ។

**គ- ខ្វះភាពទទួលខុសត្រូវ**

+ មិនគិតពីផលប៉ះពាល់ជាសាធារណៈ
+ មិនរាយការណ៍តាមខ្សែបណ្តាញឬតាមខ្សែរយៈដឹកនាំបញ្ជា។

**២.២.៤- វិភាគតាមច្បាប់និងបទបញ្ជា**

ការលេចធ្លាយព័ត៌មានអាចបំពានលើ៖

- ច្បាប់ស្តីពីការរក្សាការសម្ងាត់របស់រដ្ឋ
- ច្បាប់បច្ចេកវិទ្យាព័ត៌មាននិងសារព័ត៌មាន
- បទបញ្ជាផ្ទៃក្នុងរបស់អង្គភាពនគរបាល
- ភស្តុតាងអាចអសុពលភាពនៅក្នុងតុលាការ។

### ២.២.៥- ផលប៉ះពាល់ពាក់ព័ន្ធ

នៅក្នុងផលប៉ះពាល់ពាក់ព័ន្ធនេះ គឺមានបីចំណុចដូចខាងក្រោម៖

**ក- ចំពោះករណីស្រាវជ្រាវ**

+ ករណីត្រូវស្រាវជ្រាវបរាជ័យឬត្រូវពន្យារពេល
+ ភស្តុតាងខូចសុពលភាព។

**ខ- ចំពោះអង្គភាព**

+ បាត់បង់ទំនុកចិត្តសាធារណៈ
+ ខូចកិត្តិយសអង្គភាពឬស្ថាប័ន។

**គ- ចំពោះមន្ត្រីត្រូវទទួល**

+ វិន័យរដ្ឋបាល (ព្រមានឬដកតំណែង)
+ ទោសព្រហ្មទណ្ឌ (បើធ្ងន់ធ្ងរ)។

### ២.២.៦- មូលហេតុជាចម្បងនាំឱ្យមានផលវិបាក

- ខ្វះការយល់ដឹងសីលធម៌ឌីជីថល
- មិនមានស្តង់ដាប្រតិបត្តិការតាមនីតិវិធី (SOP) ច្បាស់លាស់
- ប្រើទូរសព្ទផ្ទាល់ខ្លួនសម្រាប់ការងារ
- វប្បធម៌ «ចែករំលែកដោយមិនចេះគិត»។

### ២.២.៧- វិធានការកែតម្រូវនិងការពារ

នៅក្នុងវិធានកែតម្រូវនិងការពារនេះមានបីចំណុចដូចខាងក្រោម៖

**ក- កម្រិតបុគ្គល**

+ បណ្តុះបណ្តាលសីលធម៌និងសន្តិសុខព័ត៌មាន
+ គិតមុនទើបបញ្ជូនចែករំលែក។

**ខ- កម្រិតអង្គភាព**

+ ដាក់ឱ្យមានស្តង់ដាប្រតិបត្តិការតាមនីតិវិធី (SOP) រក្សាព័ត៌មានសម្ងាត់
+ អនុវត្តតាមគោលការណ៍ដែលត្រូវដឹង
+ គ្រប់គ្រងឱ្យបានត្រឹមត្រូវល្អប្រសើរនូវឧបករណ៍ឌីជីថល។

**គ- កម្រិតប្រព័ន្ធ**

+ កំណត់ត្រានិងការត្រួតពិនិត្យ (Log & Audit ) ក្នុងការចូលប្រើព័ត៌មាន
+ មានវិន័យច្បាស់លាស់និងតម្លាភាព។

### ២.២.៨- មេរៀនសំខាន់សម្រាប់ពិចារណា

- សូម្បីតែព័ត៌មានតូចមួយក៏អាចបង្កផលប៉ះពាល់ធំបានដែរ
- បណ្តាញសង្គម ≠ កន្លែងសុវត្ថិភាព
- សីលធម៌ល្អ = ការការពារអង្គភាព។

សរុបសេចក្តីមក ក្រមសីលធម៌វិជ្ជាជីវៈក្នុងការប្រើបណ្តាញសង្គមគឺជាការណែនាំឱ្យចៀសវាងការប្រើព័ត៌មានខុសច្បាប់និងសីលធម៌នៃការរក្សាឯកសារនិងភស្តុតាង។ គឺជាការបង្ហាញអត្តសញ្ញាណ អភិសមាចារ វិន័យ សុចរិតភាព និងការទទួលខុសត្រូវក្នុងពិភពឌីជីថល។ ដូចនេះក្នុងដំណើរការជាក់ស្តែងមន្ត្រីល្អមិនត្រឹមតែបំពេញភារកិច្ចបានល្អទេ ប៉ុន្តែចេះប្រើព័ត៌មានបានត្រឹមត្រូវផងដែរ។ ទាំងនេះគឺជាការរួមបញ្ចូលរវាងសុចរិតភាព វិន័យ អភិសមាចារ និងច្បាប់។

ដូចគ្នានេះដែរមានពាក្យសុភាសិតមួយបានពោលថា «ភស្តុតាងត្រឹមត្រូវ = យុត្តិធម៌ត្រឹមត្រូវ» ដោយឡែកចំពោះការលេចធ្លាយព័ត៌មានរបស់នគរបាលមិនមែនជាបញ្ហាបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាសីលធម៌ អភិសមាចារ និងវិន័យវិជ្ជាជីវៈ។ នគរបាលដែលមានវិជ្ជាជីវៈត្រូវរក្សាការសម្ងាត់ដូចជាការការពារអាយុជីវិតជាដើម។ ក្នុងន័យនេះដើម្បីរក្សាបាននូវការប្រតិបត្តិអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈបានត្រឹមត្រូវក្នុងការងារបច្ចេកវិទ្យាឌីជីថលគឺត្រូវបង្កើតនូវសេចក្តីណែនាំអំពីការប្រើបណ្តាញសង្គមសម្រាប់នគរបាលដែលជាករណីយកិច្ចមួយតម្រូវឱ្យកងកម្លាំងនគរបាលត្រូវអនុវត្តដើម្បីកសាងនិងបង្កើនសីលធម៌ អភិសមាចារ និងទំនុកចិត្តពីប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ។

ដូចនេះយើងត្រូវឈ្វេងយល់នូវខ្លឹមសារប្រយោគចំនួនបីដូចខាងក្រោម៖

- បណ្តាញសង្គមគឺជាឧបករណ៍មានអានុភាព
- នគរបាលមានវិជ្ជាជីវៈត្រូវប្រើដោយប្រាជ្ញា វិន័យ និងសីលធម៌
- បង្ហោះមួយដងអាចប៉ះពាល់មួយអង្គភាព។







# ផ្នែកទី៦
# គោលការណ៍សកលនៃកិច្ចប្រតិបត្តិការនិងក្រមសីលធម៌នគរបាល

ក្រមសីលធម៌មន្ត្រីនគរបាល សំដៅដល់គោលការណ៍និងស្តង់ដានៃសីលធម៌ ដែលណែនាំអំពីទង្វើ និងអាកប្បកិរិយា ការធ្វើសេចក្តីសម្រេចចិត្ត និងការទំនាក់ទំនងរបស់មន្ត្រីអនុវត្តច្បាប់ជាមួយនឹងសាធារណជន។ ការអនុវត្តការងាររបស់មន្ត្រីនគរបាលប្រកបដោយសីលធម៌គឺជាមូលដ្ឋានសម្រាប់លទ្ធិប្រជាធិបតេយ្យ ទំនុកចិត្តសង្គម និងនីតិរដ្ឋ។ ការប្រតិបត្តិការងារនេះចាំបាច់ត្រូវមានវិធីសាស្ត្ររួមបញ្ចូលនូវភាពជាអ្នកដឹកនាំ ការហ្វឹកហ្វឺនបណ្តុះបណ្តាល ការត្រួតពិនិត្យតាមដាន តម្លាភាព និងការចូលរួមពីសហគមន៍។

កងកម្លាំងនគរបាល ត្រូវបានប្រគល់អំណាចយ៉ាងសំខាន់ រួមទាំងអំណាចប្រើប្រាស់កម្លាំង ការចាប់ខ្លួន និងការប្រើវិចារណញ្ញាណក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលអាចប៉ះពាល់ដល់អាយុជីវិតរបស់មនុស្ស។ ដោយហេតុនេះសីលធម៌របស់កងកម្លាំងក្លាយជាកត្តាស្នូលនៅគ្រប់ទិដ្ឋភាពនៃការងាររបស់នគរបាល។ ឥរិយាបថប្រកបដោយសីលធម៌ជួយការពារសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដើម្បីបង្កើនទំនុកចិត្តសហគមន៍និងពង្រឹងនីតិរដ្ឋប្រទេស (Banks, 2018)។ ផ្ទុយទៅវិញឥរិយាបថដែលអសីលធម៌បានបំផ្លាញលទ្ធិប្រជាធិបតេយ្យនិងប៉ះពាល់ដល់ក្រុមមនុស្សងាយរងគ្រោះ។

ក្នុងន័យនេះក្រមប្រតិបត្តិនិងក្រមសីលធម៌ គឺជាមូលដ្ឋានសម្រាប់ការធានាឱ្យមានភាពស្របគ្នានៃទង្វើនិងឥរិយាបថសីលធម៌របស់មន្ត្រីនគរបាល។ ក្រមទាំងនេះមានគោលបំណងផ្តល់ជាគោលការណ៍ណែនាំអំពីអាកប្បកិរិយា ការអន្តរាគមន៍ និងឥរិយាបថដែលគួរមាននៅពេលមន្ត្រីនគរបាលបំពេញភារកិច្ចរបស់ខ្លួន។

## ១- ក្រមប្រតិបត្តិអង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេច លេខ៣៤/១៦៩ ដែលបានអនុម័តក្រមប្រតិបត្តិមួយដែលបានស្ថាបនាឡើង ដោយក្រុមអ្នកជំនាញផ្នែកអនុវត្តច្បាប់ទូទាំងពិភពលោកដើម្បីប្រើប្រាស់ជាគោលការណ៍ណែនាំសម្រាប់ស្ថាប័ននគរបាលទាំងអស់ ក្នុងក្របខណ្ឌនៃច្បាប់ឬការអនុវត្តកម្រិតជាតិ។ ក្រមនេះមាន៨មាត្រា ហើយមាត្រានីមួយៗមានសេចក្តីអធិប្បាយពន្យល់ភ្ជាប់មកជាមួយ។ ក្រមនេះអាចប្រើជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍក្រមប្រតិបត្តិនិងក្រមសីលធម៌ថ្មីៗឬកែលម្អក្រមដែលមានស្រាប់។

ក្រៅពីប្រភពអំណាចផ្លូវការពីអង្គការសហប្រជាជាតិ ក្រមនេះមិនមែនជារឿងចម្លែកសម្រាប់សេវាកម្មនគរបាលក្នុងបណ្តាប្រទេស Commonwealth ទេ ព្រោះជាទូទៅវាបង្ហាញពីស្តង់ដានិងបទដ្ឋាននៃអាកប្បកិរិយាដែលមាននៅក្នុងប្រព័ន្ធច្បាប់ទូទៅ (Common Law) ច្បាប់បន្ថែម (by-laws) បទបញ្ជា និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងនគរបាល។ ទោះជាយ៉ាងណានៅតែមានអ្វីជាច្រើនទៀតដែលអាចធ្វើបានដើម្បីបង្កើនការយល់ដឹងអំពីបទប្បញ្ញត្តិនានានៃក្រមនេះនិងរបៀបដែលវាពាក់ព័ន្ធជាមួយនឹងការអនុវត្តជាក់ស្តែងនិងសំណួរពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

ពាក្យ «**មន្ត្រីអនុវត្តច្បាប់**» មានន័យរួមបញ្ចូលមន្ត្រីទាំងអស់ដែលអនុវត្តច្បាប់ មិនថាត្រូវបានតែងតាំងឬត្រូវបានបោះឆ្នោតជ្រើសតាំងនោះឡើយ ដែលអាចប្រើប្រាស់អំណាចនគរបាលជាពិសេសអំណាចក្នុងការចាប់ខ្លួនឬឃុំខ្លួនដោយរួមបញ្ចូលទាំងមន្ត្រីនគរបាល ទាំងមន្ត្រីពន្ធនាគារ។

**មាត្រា១៖** មន្ត្រីអនុវត្តច្បាប់ត្រូវបំពេញភារកិច្ច ដែលច្បាប់បានកំណត់ឱ្យជានិច្ច ដោយបម្រើសហគមន៍និងការពារមនុស្សគ្រប់រូបពីអំពើខុសច្បាប់នានាស្របតាមស្តង់ដាទំនួលខុសត្រូវកម្រិតខ្ពស់នៃការតម្រូវរបស់វិជ្ជាជីវៈរបស់ពួកគេ។

**មាត្រា២៖** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីអនុវត្តច្បាប់ត្រូវគោរពនិងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយរក្សានិងលើកកម្ពស់សិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប។

**មាត្រា៣៖** មន្ត្រីអនុវត្តច្បាប់អាចប្រើកម្លាំងបានតែក្នុងករណីដែលចាំបាច់យ៉ាងតឹងរ៉ឹងប៉ុណ្ណោះ និងតាមកម្រិតដែលចាំបាច់សម្រាប់ការបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៤៖** កត្តាលាក់ការនៃព័ត៌មានដែលមន្ត្រីអនុវត្តច្បាប់ទទួលបានត្រូវរក្សាការសម្ងាត់ជានិច្ច លើកលែងតែមានការតម្រូវចំពោះការបំពេញភារកិច្ចឬតម្រូវការរបស់តុលាការ។

**មាត្រា៥៖** មន្ត្រីអនុវត្តច្បាប់មិនអាចប្រព្រឹត្ត ឬញុះញង់ ឬអនុញ្ញាតឱ្យមានអំពើទារុណកម្ម ឬការប្រព្រឹត្តឃោរឃៅ មិនមានមនុស្សធម៌ ឬបន្ទាបបន្ថោកកិត្តិយសដោយការព្យាបាទ ឬទណ្ឌកម្មណាមួយឡើយ ហើយក៏មិនអាចមានមន្ត្រីអនុវត្តច្បាប់ណាមួយអះអាងយកបទបញ្ជាពីអ្នកលើកំពូលឬស្ថានការណ៍ពិសេស ដូចជាស្ថានភាពសង្គ្រាមឬការគំរាមកំហែងសង្គ្រាម ការគំរាមកំហែងដល់សន្តិសុខជាតិ ភាពអស្ថិរភាពនយោបាយផ្ទៃក្នុងឬស្ថានភាពអាសន្នសាធារណៈណាមួយផ្សេងទៀតមកធ្វើជាហេតុផលដើម្បីធ្វើទារុណកម្ម ឬការប្រព្រឹត្តឃោរឃៅមិនមានមនុស្សធម៌ ឬបន្ទាបបន្ថោកកិត្តិយសដោយការព្យាបាទ ឬទណ្ឌកម្មឡើយ។

**មាត្រា៦៖** មន្ត្រីអនុវត្តច្បាប់ត្រូវធានាឱ្យមានការការពារពេញលេញចំពោះសុខភាពរបស់មនុស្សដែលស្ថិតក្រោមការឃុំឃាំងឬស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ហើយជាពិសេសត្រូវចាត់វិធានការភ្លាមៗដើម្បីធានាឱ្យមានការទទួលបានសេវាថែទាំវេជ្ជសាស្ត្រនៅពេលណាដែលមានការចាំបាច់។

**មាត្រា៧៖** មន្ត្រីអនុវត្តច្បាប់មិនត្រូវប្រព្រឹត្តអំពើពុករលួយណាមួយឡើយ។ ពួកគេត្រូវប្រឆាំងនិងប្រយុទ្ធប្រឆាំងយ៉ាងតឹងរ៉ឹងចំពោះអំពើបែបនេះទាំងអស់។

**មាត្រា៨៖** មន្ត្រីអនុវត្តច្បាប់ត្រូវគោរពច្បាប់និងក្រមប្រតិបត្តិនេះ។ ពួកគេត្រូវខិតខំផងដែរទៅតាមសមត្ថភាពអតិបរមារបស់ខ្លួន ដើម្បីការពារនិងប្រឆាំងយ៉ាងតឹងរ៉ឹងចំពោះការរំលោភបំពានណាមួយចំពោះក្រមប្រតិបត្តិនេះ។

## ២- វិជ្ជាជីវៈនិងអាកប្បកិរិយាប្រកបដោយសីលធម៌របស់មន្ត្រីអនុវត្តច្បាប់

### ២.១- អាកប្បកិរិយាដោយសីលធម៌

ក្រមប្រតិបត្តិគឺជាមូលដ្ឋានសម្រាប់ទង្វើឬអាកប្បកិរិយាដែលបង្ហាញអំពីវិជ្ជាជីវៈនិងសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ទាំងអស់។ គ្រប់សកម្មភាពទាំងអស់របស់មន្ត្រីនគរបាលគួរត្រូវតែឱ្យស្របតាមគោលការណ៍ដូចខាងក្រោម៖

- ការគោរពនិងស្តាប់បង្គាប់ច្បាប់ដែលចែង
- ការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស
- ការគោរពនិងការការពារសិទ្ធិមនុស្ស។

សំណួរសួរថា តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ? ដែលអាចប្រើដើម្បីវាស់វែងទង្វើឬអាកប្បកិរិយាមន្ត្រីនគរបាលណាម្នាក់ថាអាចទទួលយកបាននិងមានវិជ្ជាជីវៈ?

តាមការកំណត់ជាសកល គោលការណ៍ (Principles) បទដ្ឋាន (norms) និងគុណតម្លៃ (values) ដូចខាងក្រោមអាចប្រើជាមាត្រដ្ឋានសម្រាប់វាស់វែងអាកប្បកិរិយាមន្ត្រីនគរបាលថាមានសីលធម៌និងវិជ្ជាជីវៈរួមមាន៖

**១- ការគោរពសេរីភាពនិងសមភាពរបស់មនុស្សគ្រប់រូប** (DIGNITY AND EQUALITY)

មនុស្សគ្រប់រូបត្រូវបានកំណត់ថាមានសេរីភាពនិងភាពស្មើគ្នាចំពោះមុខច្បាប់។ សាធារណជនទាំងឡាយត្រូវបានការពារពីការចាប់ខ្លួននិងការឃុំខ្លួនដោយខុសច្បាប់ឬដោយគ្មានអ្នកការពារ។ មន្ត្រីនគរបាលមិនត្រូវធ្វើការបែងចែកឬរើសអើងក្នុងការបម្រើមិនថារវាងអ្នកមាននិងអ្នកក្រ មនុស្សចាស់ឬក្មេង សាសនាផ្សេងៗ ជនជាតិផ្សេងៗ ឬរវាងបុរសនិងស្ត្រីឡើយ។

**២- ការគោរពចំពោះទ្រព្យសម្បត្តិ** (PROPERTY)

មន្ត្រីនគរបាលត្រូវគោរពទ្រព្យសម្បត្តិរបស់មនុស្សគ្រប់រូប។ នៅពេលបំពេញភារកិច្ចរបស់ខ្លួនពួកគេត្រូវតែខិតខំធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិប្រជាជនតិចបំផុតតាមដែលអាចធ្វើបាន។

**៣- ការគោរពចំពោះជីវិតមនុស្ស** (LIFE)

មន្ត្រីនគរបាលត្រូវគោរពជីវិតរបស់មនុស្សគ្រប់រូប។ នៅពេលប្រើកម្លាំងនិងអាវុធត្រូវប្រកាន់យកគោលការណ៍នៃការប្រើកម្លាំងអប្បបរមាមកពិចារណាជាប់ខ្លួនជានិច្ច។

**៤- បម្រើ** (SERVICE)

មន្ត្រីនគរបាលគួរផ្តល់ការបម្រើប្រកបដោយវិជ្ជាជីវៈដល់សហគមន៍។ ស្ថាប័ននគរបាលគួរតែខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីកែលម្អគុណភាពនៃការផ្តល់សេវាកម្មដល់សហគមន៍ ហើយគួរអនុវត្តវិធានការដើម្បីវាយតម្លៃសេវាកម្មរបស់ខ្លួន។

**៥- ការពិត** (TRUTH)

មន្ត្រីនគរបាលគួរតែស្វែងរកការពិតជានិច្ច។ ការពិតទាំងនេះគឺជាមគ្គុទ្ទេសក៍សម្រាប់ការស៊ើបអង្កេតបទល្មើសនិងវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់។

**២.២- បញ្ហាប្រឈមនៃក្រមសីលធម៌នគរបាល** (Ethical Challenges)

មន្ត្រីនគរបាលប្រឈមមុខនឹងបញ្ហាសីលធម៌ជាច្រើនដូចជា៖

១- ការប្រើប្រាស់កម្លាំងអតុល្យភាពរវាងការគិតអំពីសុវត្ថិភាពនិងភាពសមាមាត្រនៃកម្លាំងអន្តរាគមន៍ (Lum et al., 2020)។

២- អំពើពុករលួយ ការទទួលសំណូកសូកប៉ាន់ ការប្រព្រឹត្តដោយមនោសញ្ចេតនាស្រលាញ់ស្អប់និងការជ្រៀតចូលរបស់បណ្តាញអង្គការឧក្រិដ្ឋកម្ម (Punch, 2009)។

៣- ការលម្អៀងនិងការរើសអើង គឺជាការប្រព្រឹត្តចំពោះមនុស្សមិនស្មើភាពគ្នាតាមពូជសាសន៍ ភេទ ឬឋានៈសង្គម។

៤- ការប្រើវិចារណញ្ញាណខុសបំណងគឺជាការអនុវត្តអំណាចមិនស្មើឬដោយចិត្តអាក្រក់។

៥- ការរំលោភអំណាចគឺជាការគំរាមកំហែង ការឃុំខ្លួនខុសច្បាប់ ឬការគ្រប់គ្រងលើសកម្រិត។

៦- ទន់ជ្រាយលើទំនួលខុសត្រូវគឺជាការជ្រៀតជ្រែកនយោបាយឬការគ្រប់គ្រងផ្ទៃក្នុងមិនល្អ។

៧- សីលធម៌បច្ចេកវិទ្យាគឺជាបញ្ហារក្សាឯកជនភាពនៅពេលតាមដានឃ្លាំមើលបញ្ហា AI និងការប្រមូលទិន្នន័យ (Joh, 2016)។

**២.៣- យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សីលធម៌** (Strategies for Strengthening Ethics)

ការធ្វើឱ្យប្រសើរឡើងនូវសីលធម៌មន្ត្រីនគរបាលតម្រូវឱ្យ៖

- ការជ្រើសរើសមន្ត្រីដោយផ្អែកលើអ្នកមានចរិតលក្ខណៈ សីលធម៌ល្អប្រពៃ
- ហ្វឹកហ្វឺនបណ្តុះបណ្តាលលើការគោរពសិទ្ធិមនុស្ស ភាពមិនរើសអើងបុគ្គល
- ភាពជាអ្នកដឹកនាំ មេដឹកនាំប្រកបដោយសីលធម៌បង្កើតឱ្យមានវប្បធម៌នៅក្នុងអង្គភាព (Schafer, 2010)
- ការគ្រប់គ្រងត្រួតពិនិត្យតាមដាននិងទំនួលខុសត្រូវមានក្រុមប្រឹក្សាត្រួតពិនិត្យផ្ទៃក្នុង
- តម្លាភាពផ្សព្វផ្សាយទិន្នន័យជាសាធារណៈ និងកំណត់ត្រាវិន័យរបស់មន្ត្រី
- ការធ្វើជានគរបាលសហគមន៍ចាប់ដៃគូជាមួយនឹងប្រជាពលរដ្ឋមូលដ្ឋាន
- អភិបាលកិច្ចបច្ចេកវិទ្យាដាក់ឱ្យប្រើប្រាស់ឧបករណ៍កាមេរ៉ាតាមដាននិងឌីជីថល
- កំណែទម្រង់ច្បាប់ បង្កើតស្តង់ដានៃការប្រើប្រាស់កម្លាំងដែលមានសង្គតិភាព។

## ៣- គោលការណ៍សីលធម៌នៃមន្ត្រីនគរបាល

ជាគោលការណ៍សកល សមាជិកទាំងអស់នៃកងកម្លាំងនគរបាលត្រូវ៖

- **ប្រតិបត្តិការដោយយុត្តិធម៌និងសុចរិតភាព** ដោយអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹតនិងស្មោះត្រង់ជានិច្ច
- **អនុវត្តភារកិច្ចដោយការខិតខំប្រឹងប្រែង** និងប្រើប្រាស់ការវិនិច្ឆ័យនិងអំណាចឆន្ទានុសិទ្ធិច្បាស់លាស់ដោយសមស្របតាមស្ថានការណ៍
- **បង្ហាញការគ្រប់គ្រងខ្លួនឯង ការអត់ធ្មត់ ការយល់ដឹង និងសុភាពរាបសា** ក្នុងការទំនាក់ទំនងជាមួយនឹងមនុស្សគ្រប់រូបទាំងនៅក្នុងនិងក្រៅកងកម្លាំងនគរបាល
- **គោរពនិងការពារសិទ្ធិមនុស្សមូលដ្ឋាន** ដោយប្រព្រឹត្តចំពោះមនុស្សគ្រប់រូបជាបុគ្គលឯករាជ្យនិងបង្ហាញការគោរពនិងមេត្តាករុណា
- **គាំទ្រមិត្តរួមការងារ** ក្នុងការអនុវត្តភារកិច្ចស្របច្បាប់និងប្រឆាំងយ៉ាងសកម្មដោយរាយការណ៍និងបង្ហាញចំពោះអំពើខុសឆ្គងឬអំពើអសុចរិតណាមួយ
- **គោរពភាពសម្ងាត់នៃព័ត៌មាន** ជាមួយនឹងការយល់ដឹងអំពីព័ត៌មានដែលទទួលបានក្នុងពេលអនុវត្តភារកិច្ចចាំបាច់ត្រូវរក្សាការសម្ងាត់និងអាចបង្ហាញបាននៅពេលដែលច្បាប់ឬភារកិច្ចតម្រូវប៉ុណ្ណោះ

- **ប្រើកម្លាំងតែពេលចាំបាច់និងស្របច្បាប់** ហើយប្រើតែអប្បបរមានៃកម្លាំងដែលចាំបាច់ដើម្បីសម្រេចគោលបំណងស្របច្បាប់និងស្តារសន្តិភាពឡើងវិញ
- **អនុវត្តត្រឹមត្រូវតាមច្បាប់ជានិច្ច** ដោយយល់ថា មន្ត្រីនគរបាលមិនមានសិទ្ធិបំពានលើនីតិវិធីច្បាប់និងមិនអាចអនុវត្តតាមបញ្ជាណាដែលផ្ទុយនឹងច្បាប់បានឡើយ
- **ប្រើប្រាស់ធនធានសាធារណៈដោយមានទំនួលខុសត្រូវ** ដើម្បីផ្តល់អត្ថប្រយោជន៍អតិបរមាដល់សាធារណជន
- **ទទួលខុសត្រូវចំពោះការអភិវឌ្ឍខ្លួនឯងជាបន្តបន្ទាប់** ដោយស្វែងរកការកែលម្អចំណេះដឹង ជំនាញ និងវិធីសាស្ត្របម្រើសហគមន៍ឱ្យកាន់តែប្រសើរ
- **ទទួលយកការទទួលខុសត្រូវផ្ទាល់ខ្លួន** ចំពោះសកម្មភាពនិងការខកខានរបស់ខ្លួន។

## ៤- បទដ្ឋានគតិយុត្តអន្តរជាតិអំពីភាតព្វកិច្ចមន្ត្រីនគរបាល

នៅក្នុងប្រទេសដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ ទោះបីអង្គភាពត្រូវទទួលខុសត្រូវចំពោះអំពើរបស់មន្ត្រីនគរបាលក៏ដោយ ប៉ុន្តែមន្ត្រីនគរបាលម្នាក់ៗក៏ត្រូវទទួលខុសត្រូវចំពោះទង្វើនិងសកម្មភាពរបស់ខ្លួនផងដែរ។ ទំនួលខុសត្រូវរបស់មន្ត្រីនគរបាលត្រូវបានបញ្ជាក់និងកំណត់នៅក្នុងឯកសារដែលមានលក្ខណៈអន្តរជាតិជាច្រើន។ ជាក់ស្តែងឯកសារគតិយុត្តមួយចំនួនស្តែងអំពីទំនួលខុសត្រូវជាបុគ្គលរបស់មន្ត្រីនគរបាលឬមេដឹកនាំនគរបាលមានដូចខាងក្រោម៖

**១- អនុសញ្ញាអន្តរជាតិប្រឆាំងទារុណកម្មនិងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកកិត្តិយសដោយការព្យាបាទឬទណ្ឌកម្ម** ( Convention against Torture-CAT )

ក្នុងច្បាប់អន្តរជាតិហាមឃាត់ចំពោះទារុណកម្មយ៉ាងដាច់ខាត។ មិនមានមន្ត្រីនគរបាលណាម្នាក់ ឬមន្ត្រីសាធារណៈ ឬបុគ្គលដែលបំពេញភារកិច្ចជាផ្លូវការអាចប្រព្រឹត្តអំពើទារុណកម្មបានឡើយ ទោះបីមានបញ្ជាពីថ្នាក់លើក៏ដោយ។ ក្នុងមាត្រា២នៃអនុសញ្ញានេះបានចែងយ៉ាងច្បាស់ថា «បទបញ្ជាពីថ្នាក់លើឬពីអាជ្ញាធរសាធារណៈមិនអាចយកមកធ្វើជាសម្អាងឬជាហេតុផលដើម្បីអនុញ្ញាតឱ្យធ្វើទារុណកម្មបានឡើយ»។ ប្រការនេះបង្ហាញពីគោលការណ៍មួយដែលត្រូវបានទទួលស្គាល់ទូទៅនៅក្នុងច្បាប់អន្តរជាតិ ហើយបានអនុវត្តតាំងពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនៅ Nuremberg និង Tokyo ក្នុងឆ្នាំ១៩៤៥មកម្ល៉េះ។ ដូច្នេះមន្ត្រីណាម្នាក់នឹងត្រូវទទួលខុសត្រូវជាបុគ្គលចំពោះសកម្មភាពរបស់ខ្លួនប្រសិនបើបានប្រព្រឹត្តអំពើទារុណកម្ម។ ជាមួយគ្នានេះដែរគោលការណ៍នៃ «**ទំនួលខុសត្រូវតាមខ្សែបញ្ជាដឹកនាំ**» ក៏អាចនាំឱ្យមេបញ្ជាការទទួលខុសត្រូវចំពោះសកម្មភាពរបស់មន្ត្រីក្រោមបង្គាប់របស់ខ្លួនក្នុងករណីខ្លះផងដែរ។

**២- ក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់**

នៅក្នុងមាត្រា៥ នៃក្រមប្រតិបត្តិនេះបានបញ្ជាក់ឡើងវិញអំពីការហាមឃាត់ទារុណកម្មនិងទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់មន្ត្រីនគរបាល។ ក្រមនេះបានចែងថា មន្ត្រីអនុវត្តច្បាប់មិនអាចយកបទបញ្ជាពីមន្ត្រីថ្នាក់លើមកធ្វើជាហេតុផលដើម្បីប្រព្រឹត្តអំពើទារុណកម្មបានឡើយ។

**៣- គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើកម្លាំងនិងអាវុធដោយមន្ត្រីអនុវត្តច្បាប់**

នៅក្នុងគោលការណ៍មូលដ្ឋានស្តីពីការប្រើកម្លាំងនិងអាវុធមានគោលការណ៍ចំនួន៣ ដែលពាក់ព័ន្ធនឹងទំនួលខុសត្រូវជាបុគ្គលរបស់មន្ត្រីនគរបាល។

- **គោលការណ៍ទី២៤៖** ទាមទារឱ្យរដ្ឋាភិបាលនិងស្ថាប័នអនុវត្តច្បាប់ធានាថា មេដឹកនាំនគរបាលត្រូវទទួលខុសត្រូវប្រសិនបើពួកគេដឹងថា មន្ត្រីក្រោមបង្គាប់របស់ខ្លួនកំពុងប្រើឬបានប្រើកម្លាំងនិងអាវុធជាតិផ្ទុះដោយខុសច្បាប់ ហើយមិនបានចាត់វិធានការគ្រប់យ៉ាងដែលស្ថិតក្នុងដែនសមត្ថភាពរបស់ខ្លួនក្នុងការបង្ការទប់ស្កាត់ឬរាយការណ៍អំពីការប្រើប្រាស់នោះ។
- **គោលការណ៍ទី២៥៖** តម្រូវឱ្យរដ្ឋាភិបាលនិងស្ថាប័នអនុវត្តច្បាប់ធានាថាមិនមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យណាមួយត្រូវដាក់លើមន្ត្រីអនុវត្តច្បាប់ដែលអនុវត្តតាមក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់និងគោលការណ៍មូលដ្ឋានទាំងនេះដោយបដិសេធមិនអនុវត្តបទបញ្ជាឱ្យប្រើកម្លាំងនិងអាវុធជាតិផ្ទុះឬដែលរាយការណ៍អំពីការប្រើប្រាស់បែបនេះដោយមន្ត្រីផ្សេងទៀត។
- **គោលការណ៍ទី២៦៖** បញ្ជាក់ថា ការស្តាប់បង្គាប់បទបញ្ជាពីមន្ត្រីថ្នាក់លើ មិនអាចយកមកធ្វើជាសំអាងការពារបានឡើយប្រសិនបើមន្ត្រីអនុវត្តច្បាស់ដឹងថា បទបញ្ជាឱ្យប្រើកម្លាំងនិងអាវុធជាតិផ្ទុះដែលបណ្តាលឱ្យមានការស្លាប់ឬរបួសធ្ងន់ធ្ងររបស់បុគ្គលណាម្នាក់គឺជាបទបញ្ជាខុសច្បាប់យ៉ាងច្បាស់ ហើយមានឱកាសសមហេតុផលដើម្បីបដិសេធមិនអនុវត្ត។ ក្នុងករណីណាក៏ដោយ ទំនួលខុសត្រូវក៏ស្ថិតលើមន្ត្រីថ្នាក់លើដែលបានចេញបទបញ្ជាដោយខុសច្បាប់នោះផងដែរ។

**៤- គោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីការបង្ការនិងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនៃការឃាត់ក្រៅច្បាប់ ការឃាត់ដោយចិត្តអាក្រក់ និងការប្រតិបត្តិឃាត់ដោយសង្ខេប**

គោលការណ៍ទាំងនេះរួមមានគោលការណ៍ចំនួន២ដែលមួយៗមានបទប្បញ្ញត្តិជាច្រើនពាក់ព័ន្ធនឹងទំនួលខុសត្រូវជាបុគ្គលដូចខាងក្រោម៖

- **គោលការណ៍ទី៣៖** ទាមទារឱ្យរដ្ឋាភិបាលហាមឃាត់បទបញ្ជាពីមន្ត្រីថ្នាក់លើឬអាជ្ញាធរសាធារណៈដែលអនុញ្ញាតឬញុះញង់ឱ្យបុគ្គលផ្សេងទៀតអនុវត្តប្រតិបត្តិឃាត់ក្រៅច្បាប់ ការប្រតិបត្តិឃាត់ដោយចិត្តអាក្រក់ ឬការប្រតិបត្តិឃាត់ដោយសង្ខេប។ គោលការណ៍នេះក៏ទាមទារផងដែរថា មនុស្សគ្រប់រូបមានសិទ្ធិនិងកាតព្វកិច្ចក្នុងការបដិសេធមិនអនុវត្តបទបញ្ជាបែបនេះហើយកំណត់ថា ការបណ្តុះបណ្តាលនគរបាលត្រូវផ្តោតសំខាន់លើបទប្បញ្ញត្តិទាំងនេះ។
- **គោលការណ៍ទី១៩៖** ចែងថា ដោយមិនប៉ះពាល់ដល់គោលការណ៍ទី៣ បទបញ្ជាពីមន្ត្រីថ្នាក់លើឬអាជ្ញាធរសាធារណៈ មិនអាចយកមកធ្វើជាហេតុផលដើម្បីប្រព្រឹត្តការប្រតិបត្តិឃាត់បែបនេះបានឡើយ។ គោលការណ៍នេះក៏អនុញ្ញាតឱ្យមន្ត្រីថ្នាក់លើឬមន្ត្រីសាធារណៈផ្សេងទៀតត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលបានប្រព្រឹត្តដោយមន្ត្រីក្រោមអំណាចរបស់ខ្លួន ប្រសិនបើពួកគេមានឱកាសសមហេតុផលក្នុងការបង្ការមិនឱ្យមានសកម្មភាពបែបនេះកើតឡើង។

ខ្លឹមសារខាងលើនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់មន្ត្រីនគរបាលគ្រប់រូបក្នុងការយល់ដឹងថា វិជ្ជាជីវៈនិងឥរិយាបថសីលធម៌ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងអាកប្បកិរិយា គោល

បំណង និងលក្ខណសម្បត្តិដែលកំណត់អត្តសញ្ញាណអនុវត្តច្បាប់ទាំងអស់។ អាកប្បកិរិយាមិនសមស្រប របស់មន្ត្រីតាមសីលធម៌នឹងមិនត្រូវបានអនុញ្ញាតឡើយ ហើយបុគ្គលអាចត្រូវបានដាក់បន្ទុកឱ្យទទួល ខុសត្រូវចំពោះសកម្មភាពខុសច្បាប់របស់ខ្លួន។

## ៥- បញ្ហានៃសីលធម៌ក្នុងវិជ្ជាជីវៈនគរបាល

បញ្ហាសីលធម៌ក្នុងវិជ្ជាជីវៈនគរបាល គឺជាបញ្ហាសីលធម៌នៅក្នុងការអនុវត្ត ការបំពេញភារកិច្ច និងការងារនគរបាលដែលទាមទារឱ្យមន្ត្រីនគរបាលធ្វើសេចក្តីសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ ស្ថានភាព ទាំងនេះអាចបង្កើតការប៉ះទង្គិចផ្លូវចិត្តរបស់មន្ត្រីនគរបាល។ បញ្ហានេះអាចធ្វើឱ្យមន្ត្រីមានអារម្មណ៍ ដូចជាត្រូវបានអូសចូលក្នុងច្រវាក់មួយយ៉ាងយឺត ហើយក៏អាចធ្វើឱ្យមន្ត្រីមានអារម្មណ៍ ដូចជាត្រូវ បានចាប់ស្នាក់នៅក្នុងផ្លូវវង្វេងដែលមិនដឹងថាគួរចេញទៅផ្លូវណា។ ការដាក់សម្ពាធពីក្រុមការងារ ការ ខ្វះភាពអព្យាក្រឹត និងការយល់ដឹងថា តើនរណាម្នាក់នឹងរងផលប៉ះពាល់អវិជ្ជមានពីសេចក្តីសម្រេច ចិត្តរបស់ខ្លួនធ្វើឱ្យការសម្រេចចិត្តដោយស្ងប់ស្ងាត់ប្រកបដោយវិចារណញ្ញាណកាន់តែពិបាកជាងមុន។

បញ្ហាសីលធម៌ គឺជាផ្នែកមួយនៃកាតព្វកិច្ចនិងការងារនគរបាល។ សេរីភាពដែលមន្ត្រីនគរបាល មានក្នុងការសម្រេចចិត្តក៏បង្កើតឱកាសឱ្យបញ្ហាស្រដៀងនឹងបញ្ហា ដែលបានពិពណ៌នាខាងលើកើត មានឡើងផងដែរ។ ពេលខ្លះមន្ត្រីនគរបាលអាចជួបប្រទះបញ្ហាសីលធម៌ដោយមិនបានរំពឹងទុក។ ជាក់ ស្តែងមន្ត្រីនគរបាលម្នាក់នឹងត្រូវប្រឈមមុខនឹងបញ្ហាសីលធម៌ជាច្រើនក្នុងអំឡុងពេលបំពេញអាជីព ការងាររបស់ខ្លួនក្នុងវិស័យនគរបាល ហើយត្រូវបង្ខំចិត្តឱ្យធ្វើសេចក្តីសម្រេចចិត្តដ៏លំបាកមួយ។ ឧទាហរណ៍ បញ្ហាសីលធម៌ដូចខាងក្រោមអាចជួយឱ្យមន្ត្រីនគរបាលយល់ដឹងអំពីការធ្វើសេចក្តីសម្រេចចិត្តតាមផ្លូវ សីលធម៌ ប៉ុន្តែក្នុងករណីខ្លះក៏អាចបង្កើតជាការរំលោភសិទ្ធិមនុស្សផងដែរ។

### ៥.១- សីលធម៌និងការប្រើកម្លាំងនិងអាវុធជាតិផ្ទុះ

ការប្រើកម្លាំងដោយមន្ត្រីអនុវត្តច្បាប់ គឺជាបញ្ហាដែលបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ទាំង សាធារណជន ទាំងមន្ត្រីអនុវត្តច្បាប់ខ្លួនឯង។ មន្ត្រីនគរបាលត្រូវជួបប្រទះការប៉ះពាល់និងការទំនាក់ ទំនងជាច្រើនប្រភេទជាមួយនឹងមនុស្សជារៀងរាល់ថ្ងៃ ហើយនៅពេលដែលមានភាពចាំបាច់ ពួកគេអាច ប្រើកម្លាំងក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។ ការប្រើប្រាស់កម្លាំង (បណ្តាលឱ្យស្លាប់ជីវិតមនុស្ស) ដោយនគរបាលគួរតែអនុវត្តតែក្នុងគោលបំណងការពារជីវិតមនុស្សរួមទាំងការពារជីវិតរបស់មន្ត្រីនគរ-បាលឬជីវិតរបស់អ្នកដទៃពីការវាយប្រហារដោយជនសង្ស័យប៉ុណ្ណោះ។ មន្ត្រីនគរបាលត្រូវទទួល បានការយល់ដឹងនិងការយល់ឃើញយ៉ាងពិតប្រាកដអំពីដែនសមត្ថកិច្ចនៃអំណាចរបស់ខ្លួន ជាពិសេស ទាក់ទងនឹងការទប់ស្កាត់ការតវ៉ាឬការតស៊ូពីអ្នកដែលពួកគេមានទំនាក់ទំនងជាផ្លូវការ។ ការគោរព និងតម្លៃនៃជីវិតមនុស្សនិងសេចក្តីថ្លៃថ្នូររបស់មនុស្សគួរតែត្រូវបានលើកស្ទួយនិងផ្តោតសំខាន់ចាប់ តាំងពីការចាប់ផ្តើមបណ្តុះបណ្តាលដំបូងតទៅ។ វាជារឿងមិនយុត្តិធម៌ទេក្នុងការផ្ញើមន្ត្រីនគរបាល ចូលបម្រើការងារដោយគ្មានការបណ្តុះបណ្តាលប្រតិបត្តិការពេញលេញអំពីការប្រើកម្លាំងនិងអាវុធជាតិ ផ្ទុះក៏ដូចជាការយល់ដឹងអំពីផ្នែកច្បាប់ផងដែរ។

**ទិដ្ឋភាពសីលធម៌និងសិទ្ធិមនុស្សពាក់ព័ន្ធនឹងការប្រើកម្លាំងផ្លូវការ** គេមិនអាចរំពឹងឱ្យមន្ត្រី នគរបាលគោរពនិងបំពេញស្តង់ដាសិទ្ធិមនុស្សបានឡើយ ប្រសិនបើគ្មានការបណ្តុះបណ្តាលនិងកម្មវិធី លើកកម្ពស់ការយល់ដឹងអំពីការគោរពសិទ្ធិមនុស្សដែលមានការរៀបចំច្បាស់លាស់និងជាប្រព័ន្ធ។

### ៥.២- អំពើហិង្សារបស់នគរបាលនិងការរើសអើង

មន្ត្រីនគរបាលដែលកាន់អំណាចស្របច្បាប់ក្នុងការអនុវត្តភារកិច្ច មានទីតាំងដែលអាចនាំឱ្យមានការប្រើប្រាស់អំណាចខុសបំណង។ ពាក្យថា «**អំពើហិង្សារបស់នគរបាល**» ជាទូទៅមានន័យថា ការប្រើកម្លាំងលើផ្លូវកាយនិងផ្លូវចិត្តដែលមិនចាំបាច់លើសកម្រិតនិងមិនសមហេតុផលដែលជាញឹកញាប់កើតមានឡើងក្នុងអំឡុងពេលចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយ។ ទោះជាយ៉ាងណាអំពើហិង្សារបស់នគរបាលមិនត្រូវបានកំណត់ត្រឹមតែការចាប់ខ្លួន ការឃុំខ្លួន និងការសួរចម្លើយប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងគ្រប់ទម្រង់នៃការប្រើកម្លាំងលើផ្លូវកាយនិងផ្លូវចិត្តដែលមានការចូលរួមពីមន្ត្រីនគរបាលផងដែរ។

ក្រៅពីការប្រើកម្លាំងលើផ្លូវកាយ សកម្មភាពដែលអាចកើតមានជាទូទៅក្នុងការអនុវត្តការងាររបស់នគរបាលរួមមានករណីដែលមន្ត្រីនគរបាលបង្ហាញអាកប្បកិរិយាមិនសមរម្យដូចជាភាពច្រងេងច្រងាង អំនួត ការស្អប់ខ្ពើម និងការបង្ខិតបង្ខំឬការឆែកឆេរខ្លួនមនុស្សឬទ្រព្យសម្បត្តិរបស់ពួកគេដោយមិនសមរម្យ។

ទម្រង់មួយនៃ «**អំពើហិង្សារបស់នគរបាល**» ដែលកើតមានជាញឹកញាប់នៅក្នុងសហគមន៍ដែលមានវប្បធម៌ចម្រុះគឺ «ការរើសអើង»។ មន្ត្រីនគរបាលត្រូវបានចាត់ទុកថាបានរើសអើងប្រសិនបើនគរបាលនោះសម្រេចចិត្តអនុវត្តច្បាប់ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ជំនឿសាសនា ឬលក្ខណៈណាមួយផ្សេងទៀតដែលមិនមែនផ្អែកលើគុណសម្បត្តិបុគ្គល។ ទាំងអំពើហិង្សា ទាំងការរើសអើងក៏អាចកើតមានឡើងនៅក្នុងអង្គភាពនគរបាលផ្ទាល់ក្នុងករណីដែលមានការគំរាមកំហែង ការបៀតបៀន ឬករណីដែលសមាជិកម្នាក់ៗត្រូវបានបង្ខូចឱកាសឬប្រព្រឹត្តចំពោះដោយមិនសមរម្យដោយសារពូជសាសន៍ ជនជាតិ សាសនា ភាសា ឬភេទរបស់មនុស្ស។

### ៥.៣- សីលធម៌និងវិធានការប្រឆាំងអំពើពុករលួយ

អំពើពុករលួយរបស់នគរបាល អាចបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះនិងភាពជឿជាក់របស់ស្ថាប័ននគរបាល។ ក្រមប្រតិបត្តិបានកំណត់យ៉ាងច្បាស់ថា មន្ត្រីអនុវត្តច្បាប់មិនត្រូវប្រព្រឹត្តអំពើពុករលួយណាមួយឡើយ ហើយត្រូវទប់ស្កាត់និងប្រយុទ្ធប្រឆាំងយ៉ាងតឹងរ៉ឹងចំពោះអំពើបែបនេះ។ ជាអកុសល នៅទូទាំងពិភពលោកនៅតែមានមន្ត្រីនគរបាលខ្លះដែលស្វែងរកលេសផ្សេងៗដើម្បីប្រព្រឹត្តនិងលើកហេតុផលត្រឹមត្រូវដើម្បីអំពើពុករលួយ។ មូលហេតុដែលត្រូវបានលើកយកមកប្រើញឹកញាប់បំផុតមួយគឺការអះអាងថា នគរបាលទទួលបានប្រាក់ខែទាប។ អំពើពុករលួយរបស់នគរបាលកើតមានឡើងនៅពេលដែលមន្ត្រីនគរបាលប្រើប្រាស់និងរំលោភលើតួនាទី ទំនុកចិត្ត និងអំណាចដែលត្រូវបានផ្តល់ឱ្យដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ អំពើពុករលួយរបស់នគរបាលអាចកើតមានទាំងក្នុង «ទម្រង់អកម្ម» និង «ទម្រង់សកម្ម»។

អំពើពុករលួយអកម្ម កើតមានឡើងនៅពេលដែលមន្ត្រីនគរបាល ត្រូវបានអ្នកជិតស្និទ្ធស្នើសុំឬសុំពឹងពាក់ឱ្យជួយ។ ឧទាហរណ៍មានជនម្នាក់ផ្តល់ប្រាក់ជាអំណោយឬស្រាជាថ្នូរនឹងការជួយពីមន្ត្រីនគរបាលដូចជាជួយលាក់បាំងអំពើល្មើសរបស់គេ។ ក្នុងករណីអំពើពុករលួយអកម្ម មន្ត្រីនគរបាលអាចទទួលបានអត្ថប្រយោជន៍ដោយមិនបានស្វែងរកដោយចេតនានោះទេ។ ក្នុងករណីបែបនេះគេអាចនិយាយថាមន្ត្រីនគរបាលត្រូវបាន «ទិញ»។

អំពើពុករលួយសកម្មកើតមានឡើងនៅពេលដែលមន្ត្រីនគរបាលទៅរកបុគ្គលណាម្នាក់ដោយមានគោលបំណងលក់ការជួយឬអំណោយ។ អំពើនេះធ្វើឡើងតាមរយៈការគំរាមកំហែង ការប្រមាថ ឬការបង្ខិតបង្ខំដើម្បីបង្ខំឱ្យបុគ្គលនោះទទួលយក។ ក្នុងអំពើពុករលួយសកម្ម មន្ត្រីនគរបាលមានតួនាទីដូចជា «អ្នកប្រមាញ់» ដែលចង់បង្ខំឱ្យនរណាម្នាក់ទទួលយកការជួយ។ ក្នុងករណីនេះមន្ត្រីនគរបាលចង់ «**លក់**» តួនាទីនៃអំណាចរបស់ខ្លួន។ ទាំងអំពើពុករលួយសកម្ម ទាំងអំពើពុករលួយអកម្មសុទ្ធតែជាអាកប្បកិរិយាមិនសមស្របតាមក្រមសីលធម៌ទាំងអស់។ សហគមន៍រំពឹងឱ្យមន្ត្រីនគរបាលអនុវត្តច្បាប់ដោយអព្យាក្រឹតនិងគ្មានអភិលោភភាពនៅពេលមន្ត្រីនគរបាលរំលោភបំពានអំណាចដែលត្រូវបានផ្តល់ឱ្យជាថ្នូរនឹងប្រយោជន៍ផ្ទាល់ខ្លួននោះ មានន័យថា គេបានបាត់បង់សមត្ថភាពក្នុងការបម្រើសហគមន៍ដោយយុត្តិធម៌រួចទៅហើយ។ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន នគរបាលណាម្នាក់បានដាក់ខ្លួនឯងក្នុងស្ថានភាពមួយទាក់ទងនឹងសហគមន៍ដែលធ្វើឱ្យគាត់មិនអាចបម្រើសហគមន៍បានដោយគ្មានអភិលោភភាព។

**ឧទាហរណ៍នៃអំពើពុករលួយរបស់នគរបាលរួមមាន៖**

- បញ្ឈប់រថយន្តតាក់ស៊ីឯកជនមួយនៅចំណុចត្រួតពិនិត្យឬកន្លែងផ្សេងទៀត មានអ្នកបើកបរប្រព្រឹត្តបទល្មើសចរាចរណ៍បែរជាទទួលយកប្រាក់និងអនុញ្ញាតឱ្យបុគ្គលនោះបើកបរទៅមុខដោយសេរី
- ចាប់ខ្លួនបុគ្គលម្នាក់ពីបទល្មើសចរាចរណ៍ឬបទល្មើសតូចតាច បន្ទាប់មកលែងឱ្យបុគ្គលនោះវិញជាថ្នូរនឹងទឹកប្រាក់មួយចំនួន
- ទទួលយកប្រាក់ឬអំណោយជាថ្នូរនឹងការសម្រាលឬការអនុគ្រោះពិសេស
- មិនអើពើចំពោះបនល្បែងខុសច្បាប់ឬរង្គសាលដែលគ្មានអាជ្ញាបណ្ណជាថ្នូរនឹងទឹកប្រាក់ឬស្រា
- គំរាមកំហែងឬបង្ខិតបង្ខំស្ត្រីពេស្យា ដើម្បីទទួលបានប្រាក់ឬសេវាផ្លូវភេទ
- លក់សារធាតុញៀនដែលត្រូវបានដកហូតរឹបអូសបាន
- ផ្តល់ភស្តុតាងក្លែងក្លាយដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។

**វិធានខ្លះៗនៃនីតិវិធីនិងបទប្បញ្ញត្តិដែលគួរអនុវត្តដើម្បីប្រឆាំងអំពើពុករលួយរួមមាន៖**

- នៅក្នុងប្រទេសជាច្រើន មន្ត្រីនគរបាលមិនមានសិទ្ធិចូលរួមក្នុងសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិជ្ជាជីវៈណាមួយដែលពាក់ព័ន្ធឬអាចត្រូវបានប៉ះពាល់ដោយតួនាទីនិងភារកិច្ចរបស់ខ្លួន
- នៅក្នុងប្រទេសខ្លះ មន្ត្រីអនុវត្តច្បាប់មិនត្រូវបានអនុញ្ញាតឱ្យទទួលយកអំណោយណាមួយពីភាគីទីបីឡើយ
- នៅប្រទេសខ្លះទៀត សូម្បីតែសកម្មភាពនៃការផ្តល់អំណោយក៏ត្រូវបានចាត់ទុកថាជាការផ្តល់សំណូកឬការប៉ុនប៉ងផ្តល់សំណូកផងដែរ
- នៅក្នុងប្រទេសខ្លះ មន្ត្រីនគរបាលមានកាតព្វកិច្ចរាយការណ៍អំពីអំណោយណាមួយដែលទទួលបានពីភាគីទីបីប្រសិនបើតម្លៃអំណោយនោះលើសពីចំនួនតម្លៃកំណត់មួយ
- នៅក្នុងប្រទេសខ្លះ ច្បាប់ប្រឆាំងអំពើពុករលួយត្រូវបានអនុវត្តដោយផ្តោតលើមន្ត្រីរដ្ឋាភិបាលរួមទាំងមន្ត្រីនគរបាលផងដែរ

- អង្គភាពពិសេសប្រឆាំងអំពើពុករលួយឬការិយាល័យស៊ើបអង្កេតត្រូវបានបង្កើតនិងអនុវត្ត នៅក្នុងប្រទេសខ្លះៗ
- នៅក្នុងប្រទេសខ្លះមាននីតិវិធីស៊ើបអង្កេតឯករាជ្យដើម្បីពិនិត្យពាក្យបណ្ដឹងឬការចោទប្រកាន់ អំពីអំពើពុករលួយប្រឆាំងនឹងមន្ត្រីអនុវត្តច្បាប់
- ជាទូទៅនីតិវិធីវិន័យផ្ទៃក្នុងត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាអំពើពុករលួយដោយទណ្ឌកម្ម រួមមានចាប់ពីការផាកពិន័យ ការបញ្ចុះឋានៈ ការកាត់បន្ថយប្រាក់បៀវត្ស ការបណ្ដេញចេញពីការងារ ការផ្អាកការងារ ឬការឃុំខ្លួនក្នុងពន្ធនាគារ។

ហេតុដូច្នេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ថាប័ននគរបាលក្នុងការអនុវត្តនីតិវិធីនិងវិធានការដើម្បីប្រឆាំងនិងទប់ស្កាត់អំពើពុករលួយ។ ការអនុវត្តការងារនគរបាលដោយផ្អែកលើសិទ្ធិមនុស្សមិនអាចទទួលបានជោគជ័យពេញលេញបានឡើយនៅក្នុងបរិយាកាសដែលមានអំពើពុករលួយ និងអាកប្បកិរិយាមិនសមស្របតាមក្រមសីលធម៌របស់មន្ត្រីនគរបាល។

### ៥.៤- សីលធម៌និងទារុណកម្ម

ទារុណកម្ម គឺជាទិដ្ឋភាពមួយទៀតនៃការងារនគរបាល ដែលបង្កើតជាបញ្ហាសីលធម៌សម្រាប់មន្ត្រីនគរបាល។ ទារុណកម្មកើតមានឡើង នៅពេលដែលមន្ត្រីនគរបាលខ្លះមានអារម្មណ៍ថា ពួកគេមានសិទ្ធិដាក់សម្ពាធបន្ថែមឬប្រើវិធីសាស្ត្រខុសច្បាប់ ដើម្បីបង្ខំយកព័ត៌មានពីជនសង្ស័យ។ ទោះយ៉ាងណាមានការហាមឃាត់ទារុណកម្មយ៉ាងដាច់ខាត។ លើសពីការពិតដែលថា ទារុណកម្មគឺជាការប្រព្រឹត្តបែបអមនុស្សធម៌និងរំលោភបំពានសិទ្ធិមនុស្សមូលដ្ឋានរបស់ជនសង្ស័យ ហើយក៏មានហេតុផលមួយទៀតសម្រាប់ការហាមឃាត់ទារុណកម្ម គឺមន្ត្រីនគរបាលមិនអាចយកការប្រព្រឹត្តបទល្មើសមួយមកធ្វើជាមធ្យោបាយដើម្បីដោះស្រាយបទល្មើសមួយផ្សេងទៀតបានឡើយ។



# សេចក្តីសន្និដ្ឋាន

អត្ថន័យដ៏មានតម្លៃនៃអភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលដែលមានថ្លែងនៅក្នុងខ្លឹមសារសៀវភៅនេះ បានបង្ហាញអំពីទំនួលខុសត្រូវវិជ្ជាជីវៈពិសេសរបស់មន្ត្រីនគរបាលលើកិច្ចប្រតិបត្តិការក្នុងការបម្រើរបស់នគរបាលជូនសង្គមជាតិនិងប្រជាពលរដ្ឋ ផ្នែកសេវាសន្តិសុខនិងសេវាសាធារណៈ។ ដូចគ្នានេះ ស្តង់ដាសិទ្ធិមនុស្សអន្តរជាតិក្នុងវិស័យនគរបាលនឹងត្រូវបានលើកកម្ពស់បានល្អបំផុតនៅពេលមានការយកចិត្តទុកដាក់អនុវត្តនូវគោលការណ៍អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីនគរបាល។ កាតព្វកិច្ចរបស់មន្ត្រីនគរបាលត្រូវបានរំពឹងទុកជានិច្ចចំពោះការបំពេញភារកិច្ចដែលច្បាប់បានកំណត់ឱ្យដើម្បីបម្រើសហគមន៍និងការពារមនុស្សគ្រប់រូបចាកផុតពីអំពើល្មើសច្បាប់នានាស្របទៅតាមទំនួលខុសត្រូវកម្រិតខ្ពស់ផ្អែកតាមការប្រតិបត្តិជំនាញវិជ្ជាជីវៈរបស់ពួកគេ។

ក្នុងន័យនេះ គេមិនអាចបង្កើតច្បាប់សម្រាប់គ្រប់ស្ថានភាពបាននោះទេ ហើយក៏មិនអាចធ្វើការដឹកនាំត្រួតពិនិត្យនៅគ្រប់ពេលវេលានោះដែរ។ ដូច្នេះហើយគោលការណ៍អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈទាំងនេះនឹងបម្រើដល់ការគ្រប់គ្រងដឹកនាំគ្រប់កម្រិតក្នុងស្ថានភាពនៃការបំពេញភារកិច្ចរបស់បណ្តាអង្គភាពឬស្ថាប័ននគរបាលចំណុះក្រសួងមហាផ្ទៃ។ ក្រៅពីសារៈសំខាន់នៃសៀវភៅនេះតួនាទីរបស់សាស្ត្រាចារ្យ គ្រូនគរបាលជាតិក៏មានសារៈសំខាន់ដូចគ្នា ដើម្បីយកខ្លឹមសារសៀវភៅនេះទៅអនុវត្តបំពេញឱ្យការបង្ហាត់បង្រៀនអប់រំបណ្តុះបណ្តាលទទួលបានជោគជ័យនិងមានប្រសិទ្ធភាព។

ហេតុដូចនេះ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់សាស្ត្រាចារ្យ គ្រូនគរបាលជាតិក្នុងការចែករំលែកចំណេះដឹងអំពីទិដ្ឋភាពទូទៅនៃការងារនគរបាល ដោយមិនត្រឹមតែបញ្ចូលសមាសធាតុសិទ្ធិមនុស្សនៃប្រធានបទនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្ហាញផងដែរអំពីក្រមសីលធម៌វិជ្ជាជីវៈនគរបាលពាក់ព័ន្ធជាមួយនឹងការងាររបស់ពួកគេ។ ក្នុងបរិបទនេះដោយសារកត្តាសីលធម៌នគរបាលគឺជាកិច្ចការចាំបាច់មិនអាចមើលរំលងបាន ទើបថ្នាក់ដឹកនាំក្រសួងមហាផ្ទៃណែនាំឱ្យមានការពិនិត្យឡើងវិញនិងត្រូវស្ថាបនាកែលម្អដើម្បីឱ្យមានលក្ខណៈឆ្លើយតបសមស្របតាមភាពចាំបាច់នៃការងារជាក់ស្តែង។

សៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាល» បានផ្តល់គោលការណ៍ណែនាំជាមូលដ្ឋានតម្រង់ទិសលើអាកប្បកិរិយានិងឥរិយាបថមន្ត្រីនគរបាលជាតិឱ្យមានសីលធម៌ល្អក្នុងការបំពេញបេសកកម្មបម្រើជាតិនិងប្រជាពលរដ្ឋ សក្តិសមជាមន្ត្រីនគរបាលជាតិមានវិជ្ជាជីវៈពិតប្រាកដនិងជាឧត្តមប្រយោជន៍សម្រាប់បម្រើឱ្យវិស័យអប់រំបណ្តុះបណ្តាលស្របតាមស្តង់ដាគុណភាពសំដៅពង្រឹងភាពធន់នៃស្ថាប័ននគរបាលជាតិទាំងមូល។

សមិទ្ធផលសៀវភៅដែលសម្រេចបានដ៏មានសារៈសំខាន់នេះគឺដោយសារមានការណែនាំតម្រង់ទិសយ៉ាងត្រឹមត្រូវពីក្រសួងមហាផ្ទៃ ដើម្បីបង្កើតឱ្យមានសៀវភៅនេះឡើងនិងមានការសម្របសម្រួលពីឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **ឯក មនោសែន** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជាជាប្រធានក្រុមការងារស្រាវជ្រាវរៀបចំតាក់តែងព្រមទាំងការចូលរួមសហការយ៉ាងសកម្មពីសមាជិកក្រុមការងារទាំងអស់ដែលបានខិតខំស្រាវជ្រាវប្រមូលធាតុចូល មកបំពេញខ្លឹមសារឱ្យមានអត្ថន័យគ្រប់ជ្រុងជ្រោយប្រកបដោយស្មារតីទទួលខុសត្រូវនិងសាមគ្គីភាពខ្ពស់បំផុត៕

# សារចងចាំនិងរូបភាព

# គំរូវីរភាពរបស់វីរកងកម្លាំងស្នេហាជាតិជួរមុខ










# សារសំណេះដ៏មានអត្ថន័យរបស់វីរកងកម្លាំងស្នេហាជាតិក្នុងសមរភូមិប្រយុទ្ធ

**( សំដីមាសរបស់វីរជន កេត សុកក្រា )**

ស្លាប់ក្នុងភ្លើងសង្គ្រាម គឺជាកិត្តិយស ជាមោទនភាពរបស់កងទ័ព
ជីវិតនេះមិនមែនជារបស់ខ្ញុំទេ គឺជារបស់ប្រទេសជាតិ និងជារបស់បងប្អូនប្រជាពលរដ្ឋ
ជីវិតជូនជាតិ ធាតុជូនម្ដាយ រូបកាយទុកឱ្យគ្រួសារបូជា លះបង់ដើម្បីប្រទេសជាតិ គឺជាតម្លៃ
សម្រាប់ខ្ញុំទោះជាស្លាប់ក៏ឥតស្ដាយដែរ។














នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ





មិត្តរួមលេណដ្ឋាន...មិត្តរួមអាវុធ..គឺជាមិត្តរួមជីវិតរបស់ខ្ញុំ

# គំរូវីរភាពនៃការលះបង់របស់ប្អូនៗយុវជនកងកម្លាំងស្នេហាជាតិ







យុវជន រ័ត្ន មុន្នី    យុវជន គុង ប៊ុនធៀន

ស្មារតីអង់អាចក្លាហានរបស់យុវជនកម្ពុជា តស៊ូលះបង់ជីវិតដើម្បីជាតិនិងទឹកដី





ស៊ូបាត់បង់ភ្នែកមិនឱ្យបាត់បង់ទឹកដី (វីរជន បេ សុផាត ពិការភ្នែក)



ខ្ញុំគ្មានបងប្អូនទេ ដូច្នេះជីវិតខ្ញុំទោះរស់ក៏ដូចងងឹត ប៉ុន្តែលោកពូនៅសល់ប្រពន្ធកូន
ហើយមានភារកិច្ចការពារជាតិបន្តទៀត ខ្ញុំសុខចិត្ត «បរិច្ចាគកែវភ្នែករបស់ខ្ញុំ»
ជូនលោកពូដោយស្មោះស្មគ្រអស់ពីដួងចិត្តដើម្បីជាតិខ្ញុំ។

# គំរូវីរភាពដ៏អង់អាចក្លាហានរបស់វីរកងកម្លាំងស្នេហាជាតិ






បងដើររួចឬអត់? -ឥតរួចទេ! - ចុះដៃបងបាញ់កើតអត់?- បងបាញ់បាន!
អ៊ីចឹងចាំខ្ញុំអៀវបង តែបងជួយបាញ់ការពារផង យើងនៅជាមួយគ្នាណាបង ដើម្បីការពារជាតិយើង







ប្រពន្ធប្រាប់ឱ្យទៅផ្ទះ បងទៅមិនបានទេ ចោលបងប្អូនយើងនៅទីនេះ
សូមយកខ្សែកឱ្យប្រពន្ធបងផង ណា ណា....!

# គំរូវីរនារីប្រកបដោយទឹកចិត្តមនសិការដើម្បីបុព្វហេតុជាតិមាតុភូមិ

ចាប់តាំងពីនាងបានមកនៅជួរមុខជាមួយនឹងខ្ញុំ នាងមិនត្រឹមតែជាប្រពន្ធដែលគាំទ្រប៉ុណ្ណោះទេ ថែមទាំងបានក្លាយជាផ្នែកសំខាន់មួយនៃបេសកកម្មទៀតផង។ នាងបានជួយខ្ញុំផ្ទុកគ្រាប់រំសេវ រៀបចំមីន គ្រាប់កាំភ្លើងត្បាល់ និងកាំភ្លើង RPC ដើម្បីគាំទ្រយុទ្ធមិត្តរបស់យើងក្នុងសមរភូមិ។ ខ្ញុំស្រលាញ់នាង ហើយខ្ញុំពិតជាដឹងគុណនាងណាស់។ នាងគឺជាស្ត្រីដ៏ក្លាហានម្នាក់និងជាភរិយាល្អរបស់ខ្ញុំ ព្រមទាំងជាផ្នែកមួយនៃកងទ័ពដ៏ខ្លាំងក្លាដែលកំពុងប្រយុទ្ធការពារមាតុភូមិនៃយើង។
















# សារសំណេះចេញពីបេះដូង
# របស់ប្រជាពលរដ្ឋគាំទ្ររាជរដ្ឋាភិបាលនិងវីរកងកម្លាំងស្នេហាជាតិ




- យើងទាំងអស់គ្នាទុកចិត្តលើរាជរដ្ឋាភិបាលនិងកម្លាំងប្រដាប់អាវុធរបស់យើង
- យើងទាំងអស់គ្នាជឿជាក់លើវីរភាពកងទ័ពនិងកងកម្លាំងនគរបាលជាតិកម្ពុជាយើង
- ដោយសេចក្តីគោរពនិងថ្លែងនូវការកោតសរសើររបស់យើងខ្ញុំនៅខាងក្រោយចំពោះវីរកងទ័ព យ៉ាងធំគ្មានអ្វីប្រៀបផ្ទឹមបាន
- ប្រជាពលរដ្ឋកម្ពុជាទាំងអស់ជឿជាក់និងលើកទឹកចិត្តដល់វីរកងទ័ពដ៏អង់អាចក្លាហានរបស់យើង ដែលកំពុងប្រយុទ្ធតស៊ូយ៉ាងខ្លាំងក្លានៅគ្រប់សមរភូមិទាំងអស់
- យើងខ្ញុំរួបរួមគាំទ្ររាជរដ្ឋាភិបាលនិងវីរកងកម្លាំងស្នេហាជាតិជួរមុខក្នុងការការពារអធិបតេយ្យ និងបូរណភាពដែនដីព្រះរាជាណាចក្រកម្ពុជា
- វីរកងទ័ពខ្មែរឈរលើមូលដ្ឋានស្មារតីស្នេហាជាតិមិនត្រឹមតែការពារទឹកដីតែប៉ុណ្ណោះទេ ប៉ុន្តែ បានការពារកិត្តិយសនិងអនាគតកូនចៅជំនាន់ក្រោយរបស់ខ្មែរផងដែរ
- សូមគោរពទៅដល់វិញ្ញាណក្ខន្ធវីរកងទ័ពខ្មែរដែលបានពលីនៅក្នុងសមរភូមិដើម្បីការពារប្រជាជាតិ មាតុភូមិ
- អ្នកនៅវ័យក្មេងខ្លាំងណាស់ តែអ្នកស្មគ្រប្រយុទ្ធសម្រាប់មនុស្សខ្មែរគ្រប់រូបដោយបូជាភាពយុវវ័យ របស់អ្នកដោយគ្មានស្តាយស្រណោះដើម្បីបុព្វហេតុជាតិមាតុភូមិកម្ពុជាយើង
- អ្នកជាកូនប្រុសពិតនៃទឹកដីអង្គរយ៉ាងប្រាកដ! សូមអ្នកទទួលយកនូវគារវកិច្ចដោយកាយវិការ លំឱនកាយគោរពដល់ព្រលឹងអ្នកពីចម្ងាយដោយក្តីស្មោះស្មគ្រអស់ពីដួងចិត្ត

- ពេលរាត្រីស្ងប់ស្ងាត់បេះដូងខ្មែរទាំងមូលតែងតែនឹករឭកដល់វីរកងទ័ពដែលកំពុងធ្វើជារនាំងការពារប្រទេសមិនឱ្យចោរចូលឈ្លានពានបាន
- ខ្ញុំពិតជាស្ដាយដែលខ្ញុំអាយុជ្រេទៅហើយ ប្រសិនបើជាតិត្រូវការខ្ញុំស្មគ្រចិត្តបម្រើទ័ពភ្លាមដើម្បីប្ដូរជីវិតជាមួយនឹងចោរឈ្លានពានដោយមិនរួញរាឡើយ
- សូមឱ្យជាតិក្រោយខ្ញុំបានកើតជាខ្មែរជាជនរួមជាតិសាសន៍ជាមួយនឹងបងប្អូនវីរជនយើងទៀត
- គ្មានថ្ងៃណាយើងអាចបំភ្លេចវីរភាពរបស់អ្នកបានឡើយ តំណក់ឈាមស្រស់របស់អ្នកនេះហើយដែលបានហូរស្រោចធរណី ហើយបានក្លាយជាទឹកខ្មៅពណ៌ក្រហមគូសបន្ទាត់ព្រំដែនកម្ពុជា ថៃ បានច្បាស់លាស់និងពិតប្រាកដសម្រាប់ការចងចាំរបស់ខ្ញុំ។










ទោះក្នុងតម្លៃណាក៏ដោយ បងប្អូនប្រជាពលរដ្ឋរួមទាំងព្រះសង្ឃជាតិសាសន៍ខ្មែរទាំងអស់សូមគាំទ្រយ៉ាងពេញទំហឹងនិងនៅជាមួយនឹងបងប្អូនវីរកងទ័ពនិងវីរនគរបាលដ៏អង់អាចក្លាហានដើម្បីបុព្វហេតុជាតិមាតុភូមិ

# ទឹកចិត្តរបស់ក្មួយៗ
# សិស្សានុសិស្សដឹងគុណនិងជូនពរដល់វីរកងកម្លាំងស្នេហាជាតិ

### ជូនចំពោះពូៗវីរកងទ័ព

ខ្ញុំបាទឈ្មោះ ម៉ូច មឿល ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យបៀលប្រាយ សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទេវតាម្ចាស់ទឹកម្ចាស់ដីជួយថែរក្សាការពារពូៗដែលជាវីរកងទ័ពដ៏អង់អាចក្លាហានរួចផុតពីពួកសត្រូវដែលបានព្យាយាមចូលមកយាយីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំក៏មានការដឹងគុណយ៉ាងក្រៃលែងដល់ពូៗវីរកងទ័ពដែលពលីជីវិតដើម្បីការពារទឹកដី។ ខ្ញុំសូមអរគុណដល់ពូៗវីរកងទ័ពចេញពីទឹកចិត្តដែលមានចិត្តក្លាហានក្នុងការធ្វើសង្គ្រាមជាមួយនឹងពួកចោរសៀមដែលបានឈ្លានពានទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសូមចូលរួមសោកស្តាយចំពោះប្រាសាទព្រះវិហារនិងប្រាសាទតាក្របីដែលទទួលរងការខ្ទេចខ្ទីដោយពួកចោរចង្រៃសៀម។ ខ្ញុំសូមឱ្យវិញ្ញាណក្ខន្ធពូៗជាវីរកងទ័ពដែលបានពលីទៅកាន់សុគតិភព។ ជាចុងក្រោយសូមឱ្យពូៗវីរកងទ័ពនិងបងប្អូនពូមីងនិងយាយតាដែលជាជនភៀសសឹកមានសុវត្ថិភាពទាំងអស់គ្នា។

កម្ពុជាត្រូវការសន្តិភាព ប្រទេសកម្ពុជាត្រូវការសន្តិភាព

(កម្ពុជាឈ្នះៗ)



### ព័ត៌មានត្រលប់

កាលពីថ្ងៃទី០៩.១២.២០២៥ ប្រទេសថៃបានបើកការវាយប្រហារមកលើកម្ពុជា ហើយខ្ញុំក៏បានជូនពរទៅពូៗនិងតាដែលជាទាហាននៅជួរមុខនិងជួរក្រោយទាំងអស់។ ខ្ញុំសូមឱ្យមានសុខភាពល្អអាចយកឈ្នះសត្រូវទាំងអស់ ហើយមានអាយុវែងអាចរស់នៅជាមួយនឹងជាតិនិងក្រុមគ្រួសារបានរហូត។ សូមប្រាប់ទៅប្រទេសថៃថាកុំចង់បានប្រទេសគេពីព្រោះយើងយកទឹកដីគេទៅ យើងក៏នឹងមិនទទួលបានល្អដែរ វានឹងទទួលបានបាប។ សូមប្រាប់ថា កម្ពុជាស្រលាញ់កម្ពុជា ហើយកម្ពុជាស្រលាញ់សន្តិភាព។

មួយទៀតខ្ញុំក៏សូមឱ្យគ្រួសារអ្នកភៀសខ្លួនជួបតែក្តីសុខទៅណាមកណាទទួលបានសុខសុវត្ថិភាព។ ហើយខ្ញុំក៏បារម្ភផងដែរពីការភៀសខ្លួនរបស់ប្រជាជនខ្មែរនិងពូៗអ៊ំៗតាៗដែលកំពុងតែមានការស្វះស្វែងរកវិធីដោះស្រាយសង្គ្រាមនេះផងដែរ។ ប៉ុន្តែខាងប្រទេសសៀមមិនមានបទឈប់បាញ់ទេពីព្រោះពួកវាពិតជាចង់បានប្រទេសកម្ពុជាយើងណាស់។ ហើយនាងខ្ញុំដែលជាកុមារកំពុងសិក្សាសូមបួងសួងឱ្យព្រលឹងដូនតាសក្តិសិទ្ធិបុរាណរបស់កម្ពុជា សូមជួយតាមថែរក្សាវីរកងទ័ពកម្ពុជាដ៏អង់អាចក្លាហានរបស់មាតុភូមិយើង។



**ថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥**

**កំណត់ត្រាប្រចាំថ្ងៃ**

ខ្ញុំបាទឈ្មោះកាន់ វាសនា សូមជូនពរពួកបងៗវីរៈកងទ័ពដែលឈរជើងនៅជួរមុខឬជួរក្រោយសូមឱ្យពួកបងៗ ជួបនូវសុវត្ថិភាពនឹងត្រូវតែជួបនូវការឈ្នះការជោគជ័យ។ បងៗទាហានត្រូវចេះការពារខ្លួនពីពួកសៀមបាញ់ ឬទម្លាក់គ្រាប់ ពួកវាបានឈ្លានពានមកលើខ្មែរមកតាំងពីថ្ងៃទី២៤ ខែកក្កដា រហូតដល់ថ្ងៃទី១៧ខែធ្នូ។ ពួកវាមិនទាន់ឈប់ឈ្លានពានទេហើយវាបានធ្វើឱ្យអ្នកស្រុកភូមិជាច្រើន ដែលនៅជិតព្រំដែនភ័យរត់បែកជើងគ្នា ពួកបងៗទាហានគឺត្រូវតែតស៊ូការពារទឹកដីដើម្បីយកជ័យជំនះ ដើម្បីឱ្យពួកអ្នកដែលភៀសសឹកបានត្រលប់ទៅផ្ទះវិញ។ ហើយខ្ញុំនឹងខិតខំរៀនសូត្រដើម្បីប្រទេសជាតិ។ ចា ! ពួកយើងត្រូវតែខិតខំរៀន។

ខ្មែរឈ្នះៗៗៗៗៗ !



**ថ្ងៃពុធ ទី១ ខែធ្នូ ឆ្នាំ២០២៥**

**កំណត់ត្រាប្រចាំថ្ងៃ**

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ចោរសៀមបានបាញ់មកលើស្រុកស្រីស្នំធ្វើឱ្យប្រជាជនមួយចំនួនរងរបួសនិងប្រជាជនខ្លះបានស្លាប់។ ចោរសៀមបានបាញ់ខ្មែរដោយយន្តហោះ F16។ ហើយចោរសៀមបានទម្លាក់គ្រាប់បែកនៅស្រុកស្រីស្នំនេះធ្វើឱ្យទាហានខ្មែរខឹងចោរសៀមជាខ្លាំងដែលទាហានថៃបានធ្វើបែបនេះដាក់ប្រទេសកម្ពុជា។ ខ្ញុំសូមជូនពរអ៊ំៗបងៗពូៗនិងមាៗទាំងអស់ឱ្យមានសុខភាពល្អ ហើយឱ្យឈ្នះលើមារសត្រូវដែលចូលមកយាយីប្រទេសកម្ពុជារបស់យើង។ ខ្ញុំមានពាក្យមួយម៉ាត់ថា «**សុខសប្បាយណាពូៗនិងបងៗកងទ័ពទាំងជួរមុខនិងជួរក្រោយ**» ស៊ូឡើងបងៗអ៊ំៗពូៗ ហើយពួកខ្ញុំជាអ្នកសិក្សារៀនសូត្រដើម្បីប្រទេសជាតិដូចគ្នាត្រូវស៊ូៗឡើង ប្រទេសកម្ពុជាត្រូវតែឈ្នះសត្រូវ ជយោ! ជយោ! ជយោ! កងទ័ពខ្មែរត្រូវតែឈ្នះ ជយោ! ជយោ!។

ជាចុងក្រោយខ្ញុំសូមអរគុណវីរកងទ័ពដែលជួយប្រទេសខ្មែរឱ្យបានសន្តិភាព។ ហើយសូមឱ្យព្រះតាមថែរក្សាបងៗពូៗអ៊ំៗនិងមាៗទាំងអស់គ្នា។ «**អរគុណវីរកងទ័ព**»



**ថ្ងៃព្រហស្បតិ៍ ទី១៨ ខែធ្នូ ឆ្នាំ២០២៥**

**សាលាបឋមសិក្សាសសស្តម្ភ**

**កំណត់ត្រាប្រចាំថ្ងៃ**

ឈ្មោះ ថាន់ ជានុន

ប៉ុន្មានថ្ងៃនេះថៃបានបាញ់សម្រុកមកលើប្រទេសកម្ពុជាយើង។ ហើយជនជាតិថៃបាញ់ផ្លោងខ្លាំងណាស់បណ្តាលឱ្យប្រជាជនយើងនៅមិនបាន។ ខ្ញុំសូមឱ្យបងវីរកងទ័ពជួរមុខទាំងអស់មានសុខភាពល្អ ឈ្នះអស់មារសត្រូវ។ ខ្ញុំជាកូនខ្មែរម្នាក់ ខ្ញុំសោកស្តាយណាស់ពេលឃើញថៃបាញ់ប្រាសាទព្រះវិហារនេះដែលទុកតាំងពីសម័យបុរាណមកម្ល៉េះតែពេលនេះវាផ្លោងខ្ទេចអស់។ ខ្ញុំសូមឱ្យបងវីរកងទ័ពអង់អាចក្លាហានកម្ចាត់អាចោរសៀមឱ្យលោយសាបសូន្យនិងសូមឱ្យព្រលឹងដូនតាជាស់ស្មារតីមកវិញឱ្យរឹងមាំនៅមាតុភូមិខ្ញុំ និងសូមជូនពរឱ្យខ្មែរឈ្នះ។ «**ខ្មែរឈ្នះ ខ្មែរត្រូវការសន្តិភាព**» «**សូមវីរកងទ័ពខ្មែរមានសុវត្ថិភាពឈ្នះអស់មារសត្រូវ**»។



**ថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥**

កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ទាហានថៃបានទម្លាក់គ្រាប់បែកនៅខាងស្រុកក្រឡាញ់ ខេត្តសៀមរាបធ្វើឱ្យអ្នកភៀសខ្លួននិងប្រជាជនមានការភ័យខ្លាចជាខ្លាំងដែលទាហានថៃបានទម្លាក់គ្រាប់បែកធ្វើឱ្យទាហានខ្មែរខឹងសម្បារជាខ្លាំងដែលទាហានថៃបានធ្វើបែបនេះដាក់ប្រទេសខ្មែរ។ (ចារជាសំណេរដ៏មានអត្ថន័យ) (គុណវីរកងទ័ពដែលបានជួយប្រទេសខ្មែរឱ្យបានរុងរឿង)

(អរគុណវីរកងទ័ព)




**ថ្ងៃព្រហស្បតិ៍ ទី១៨ ខែធ្នូ ឆ្នាំ២០២៥**

ថ្ងៃនេះខ្ញុំមានពាក្យដែលគួរនិយាយគឺសូមឱ្យវីរ-កងទ័ពប្រុងប្រយត្នជាពិសេសវីរកងទ័ពដែលនៅជួរមុខសូមប្រុងប្រយត្ន។ ព្រោះថៃបានបង្កប់គ្រាប់មីននិងទម្លាក់ដ្រូនមកលើអ្នកភៀសខ្លួនដែលកំពុងជួបទុក្ខលំបាកជាខ្លាំងដែលថៃបានធ្វើបែបនេះដាក់ប្រទេសខ្មែរ។ ហើយខ្ញុំសូមមានពាក្យជូនពរដល់វីរកងទ័ពឱ្យគាត់មានសុខភាពល្អនិងឈ្នះសត្រូវទាំងឡាយ។

(មូលវិចារអ្នកគ្រូ)

សូមវីរកងទ័ពមានសុវត្ថិភាព សន្តិភាពត្រលប់មកវិញឆាប់ៗ !








Cambodia need peace!


cambodia
Cambodia Need Peace!












Leak K168
ខ្ញុំនឹកសាលា
ខ្ញុំចង់ទៅសាលារៀន



# ស្លាកដែងកជាប្រវត្តិសាស្ត្រនៃការរួបរួមគ្នា របស់សិល្បករ៥០រូបបង្កើតផ្ទាំងគំនូរខ្នាតយក្ស៣០ម៉ែត្រនៅកណ្តាលក្រុងសៀមរាប








អត្ថន័យផ្ទាំងគំនូររៀបរាប់ពីសេចក្តីទុក្ខសោករបស់ប្រជាជនខ្មែរដែលរងគ្រោះដោយសារសង្គ្រាម បង្ហាញពីការបាត់បង់សមាជិកគ្រួសារ ក្មេងៗមិនបានចូលរៀន គ្មានមន្ទីរពេទ្យ វត្តអារាម និង ការភៀសខ្លួនពីភូមិឋាន ផ្ទះសំបែងដែលត្រូវបានបំផ្លាញដោយសារស្នាដៃទាហានថៃ។

# រាជរដ្ឋាភិបាលនិងវីរកងកម្លាំងស្នេហាជាតិ ព្រមទាំងប្រជាជនកម្ពុជារួមគ្នាជាធ្លុងមួយ ការពារទឹកដី អធិបតេយ្យភាពជាតិដោយអង់អាចក្លាហានមិនខាកទោះក្នុងតម្លៃណាក៏ដោយ









# បទចម្រៀងរំឭកដល់គំរូវីរភាពអង់អាចក្លាហានរបស់កងកម្លាំងស្នេហាជាតិ

## សាមគ្គីជាតិជាកម្លាំង

### បកស្រាយដោយ កញ្ញា អនុសេនីយ៍ត្រី ម៉ូ ម៉ាន់ធីតា



- វីរភាពអង់អាចក្លាហានឥតរា កងកម្លាំងកម្ពុជា
ដេញចោរសៀមចង្រៃ បង្កសង្គ្រាមឈ្លានពានទឹកដី
សាងអំពើព្រៃផ្សៃឧក្រិដ្ឋកម្មសង្គ្រាម។

- សូមកុលបុត្រខ្មែរពួតដៃសាមគ្គី ចូលរួមគ្រប់ទិសទី
ពង្រឹងគ្រប់ខ្សែត្រៀម ជួរមុខប្រយុទ្ធខាងក្រោយមិនស្ងៀម
ជាកម្លាំងរួមឈាមសក្តិសមពូជខ្មែរអង្គរ។

- ទង់បក់រវិច... ចាំមិនភ្លេច រំលេចរាប់រយគំណរ
ដង្ហែក្បួនអង្រួនចិត្តថៃទឹកដីបវរ ចិត្តស្មោះសរសាងកិត្តិយសឧត្តម។

- សូមព្រលឹងបុព្វបុរសខ្មែរ បារមីខ្លាំងពូកែជួយថែកងកម្លាំង
ទាំងថ្នាក់ដឹកនាំប្រជារាស្ត្រយើង សូមឱ្យបានចុំច្រើង
ខ្មែរបានសុខសាន្តរៀងអើយ។

- ទង់បក់រវិច... ចាំមិនភ្លេច រំលេចរាប់រយគំណរ
ដង្ហែក្បួនអង្រួនចិត្តថៃទឹកដីបវរ ចិត្តស្មោះសរសាងកិត្តិយសឧត្តម។

- សូមព្រលឹងបុព្វបុរសខ្មែរ បារមីខ្លាំងពូកែជួយថែកងកម្លាំង
ទាំងថ្នាក់ដឹកនាំប្រជារាស្ត្រយើង សូមឱ្យបានចុំច្រើង
ខ្មែរបានសុខសាន្តរៀងអើយ។

# បទចម្រៀងនៃការនឹករឭកលំនៅឋានរបស់កុមារី ចាន់ត្រា

## ផ្ទះចាស់នឹកខ្ញុំ
## បកស្រាយដោយកុមារី ចាន់ត្រា



- យប់ថ្ងៃថ្ងៃយប់ទឹកភ្នែកខ្ញុំហូរ គ្រាប់ផ្ទុះលាន់ខ្លាំងជាងផ្គរ
ស្នូរស្មូររំពងពេញព្រៃ មើលជំរំម៉ែអំរងាចិត្តក្រៃ
សូមព្រះរតនត្រៃ ជួយថែរក្សាឃុំគ្រង។

- សង្គ្រាមមិនស្គាល់ពាក្យថាកុមារ សង្គ្រាមនាំទុក្ខខ្លោចផ្សា
ទុក្ខម្នេញដល់រាស្ត្រប្រជា រស់មិនសុខក្នុងចិត្តចំបែងរងា
អាសូរវីរយោធា ពុះពារស៊ូលះខ្លួនក្ស័យ។

- ចិត្តខ្ញុំស្លុត ស្លុតចិត្តក្តុកក្តួលអាណិត ពេលស្តាប់បណ្តាំជីវិត
រៀបរាប់រឿងពិតហូរហែ បងសុំលាអូនរូបកូនសូមលាពុកម៉ែ
ពេលនេះត្រូវរួមគ្នាថៃ ដីខ្មែរឱ្យបានគង់វង្ស។

- ផ្សែងពុលយន្តហោះកាំភ្លើងតូចធំ បំផ្ទុះគ្រាប់ក្សែរជំរំ
បំផ្លាញបំបាក់ស្មារតី ផ្ទះកម្សត់នឹកម្ចាស់ឱ្យឆាប់វិលវៃ
ភូមិស្រុកលែងហាស្តី ព្រោះតែម្ចាស់ថ្លៃឃ្លាតឆ្ងាយ។

- សាលារៀនតើអ្នកសុខទុក្ខយ៉ាងណា អក្សរសរសេរជាប់ក្តារ
ថ្ងៃមួយខ្ញុំនឹងវិលវិញ ផ្ទះចាស់ខ្ញុំអើយ
ចិត្តខ្ញុំមិនចង់ចាកចេញ ព្រោះតែសង្គ្រាមបណ្តេញ
ខាំធ្មេញស៊ូសង្កត់ចិត្ត។

- អរគុណកម្លាំងមហាសាមគ្គី ខ្មែររួមដៃគ្រប់ទិសទី
ប្រមូលម្ហូបស្បៀងអាហារ ពួតដៃគ្នាអង់អាចមិនខ្លាចមរណា
លះបង់ក្តីសុខអាត្មា ប្រាថ្នាជាតិខ្មែរសន្តិភាព៕

# ឯកសារពិគ្រោះ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា៩១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិ
- អនុក្រឹត្យលេខ១៩៤អនក្រ.បក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ស្តីពីការកំណត់លក្ខណ-សម្បត្តិនិងឋានៈគ្រូនគរបាលជាតិកម្ពុជា
- ប្រកាសលេខ៤៤៩ប្រ.ក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩៧ស្តីពីការរៀបចំឋានន្តរសក្តិក្នុងកងកម្លាំងនគរបាលជាតិ
- ប្រកាសលេខ៤៧៧៣ប្រ.ក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ស្តីពីការប្រគល់សិទ្ធិការងារតែងតាំងមុខតំណែង ដំឡើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ពន្ធ
- ប្រកាសលេខ២៨៤ប្រ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ស្តីពីនីតិវិធីនៃការដំឡើងឋានន្តរសក្តិមន្ត្រីនគរបាលជាតិកម្ពុជា
- អនុក្រឹត្យលេខ៧៥ អនក្រ.បក ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលជាតិពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩
- លក្ខន្តិកៈសមាគមមិត្តនគរបាលជាតិកម្ពុជា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧
- អនុក្រឹត្យលេខ០៨អនក្រ.បករបស់រាជរដ្ឋាភិបាលស្តីពីឯកសណ្ឋាននិងផ្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យលេខជស/រកត/១០៩៥/០១ ស្តីពីការគ្រាស់បង្គាប់ឱ្យប្រើប្រាស់គ្រឿងឥស្សរិយយសចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥
- អនុក្រឹត្យលេខ១៤អនក្រ.បកស្តីពីការកែសម្រួលឯកសណ្ឋាននិងស្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០
- ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨នគរបាលជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រី
- សារាចរណែនាំស្តីពីការបំផុសចលនាសណ្តាប់ធ្នាប់សុវត្ថិភាពសង្គមបង្កើតស្នាដៃអបអរសាទរមិទ្ទីងខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ១៦ ឧសភា ១៩៤៥ លេខ០០១ សរចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ១៦៨អនក្រ.បកស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤
- ប្រកាសលេខ៨៧៣ប្រក.ស្តីពីបទវិន័យនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ឆ្នាំ២០២៤

- ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ២០០១ ព្រះបរមរាជវាំង
- អនុក្រឹត្យលេខ១២៦/០៨ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ៥៩/១៤ ក្រមសីលធម៌គិលានុបដ្ឋាក រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៤
- សេចក្តីប្រកាសមហាសន្និបាតក្រមសីលធម៌មន្ត្រីប្រតិបត្តិច្បាប់ អង្គការសហប្រតិបត្តិ ឆ្នាំ១៩៧៩
- សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧
- ព្រឹត្តិបត្រ១-១០ ក្រុមប្រឹក្សាជាតិភាសាខ្មែរ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៤
- ឡេង បូរាណ ក្រមសីលធម៌របស់នគរបាលក្នុងប្រព័ន្ធបច្ចេកវិទ្យា អគ្គនាយកដ្ឋានឌីជីថល
- ក្រុមការងារនិពន្ធសៀវភៅវិទ្យាសាស្រ្តដឹកនាំបញ្ជាបណ្ឌិត្យសភានគរបាលកម្ពុជា ឆ្នាំ២០២៣
- ឯកសារអនុម័តរួច ក្រមសីលធម៌ចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ២០០៧
- អនុក្រឹត្យ៦១/០៣ ក្រមសីលធម៌គ្រូពេទ្យ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣
- ឯកឧត្តម សុខ អាន គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៩
- លោក ឈុន ផាវ៉េង មូលដ្ឋានសីលធម៌ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១២
- លោក ឌុច សុន សីលធម៌ ជំនឿ ទំនៀមទម្លាប់ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០០៥
- លោកសាស្រ្តាចារ្យរង នួន វិទ្យាស័ក ភាពជាអ្នកដឹកនាំបញ្ជា បណ្ឌិត្យសភានគរបាលកម្ពុជា ២០១៧
- ឡាយ សុបញ្ញា គោលការណ៍សកលក្រមសីលធម៌ ន.បជបណ្ឌិត្យសភានគរបាលកម្ពុជា ឆ្នាំ២០២៥
- កែប ប៊ុនលី ទស្សនៈអភិសមាចាររបស់អ្នកប្រាជ្ញ បណ្ឌិត្យសភានគរបាលកម្ពុជា ឆ្នាំ២០២៥
- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ឆ្នាំ២០០៣
- Banks, C. (2016). Criminal justice ethics: Theory and practice (4th ed.). Thousand Oaks, CA: SAGE Publications.
- College of Policing. (2020). Code of ethics. United Kingdom: College of Policing. College of Policing
- Delattre, E. J. (2011). Character and cops: Ethics in policing (2nd ed.). Washington, DC: AEI Press.
- Goldsmith, A. (2005). Police reform and the problem of trust. Theoretical Criminology, 9(4), 443–470. https://doi.org/10.1177/1362480605057727
- Goleman, D. (1995). Emotional intelligence: Why it can matter more than IQ. New York: Bantam Books.
- International Association of Chiefs of Police. (2020). Law enforcement code of ethics. Alexandria, VA: IACP.
  International Association of Chiefs of Police
- INTERPOL. (2021). Ethical considerations in the use of artificial intelligence in law enforcement. Lyon: INTERPOL.
  INTERPOL
- Kleinig, J. (1996). The ethics of policing. Cambridge: Cambridge University Press.
- Ministry of Interior. (Cambodia). Law on the general statute of the national police. Phnom Penh: Royal Government of Cambodia.
  Ministry of Interior
- Ministry of Interior. (Cambodia). Internal regulations and disciplinary code of the Cambodian National Police. Phnom Penh: Royal Government of Cambodia.
  Ministry of Interior

- National Police Agency of Japan. (2019). Police ethics and discipline in Japan. Tokyo: NPA.
  National Police Agency of Japan
- OECD. (2020). Public integrity handbook. Paris: OECD Publishing.
  OECD
- Office of the United Nations High Commissioner for Human Rights. (2014). Human rights and law enforcement: A manual on human rights training for the police. New York & Geneva: United Nations.
  Office of the United Nations High Commissioner for Human Rights
- Pollock, J. M. (2017). Ethical dilemmas and decisions in criminal justice (9th ed.). Boston, MA: Cengage Learning.
- Prenzler, T. (2009). Police corruption: Preventing misconduct and maintaining integrity. Boca Raton, FL: CRC Press.
- Royal Government of Cambodia. (1993). The Constitution of the Kingdom of Cambodia. Phnom Penh.
- Singapore Police Force. (2020). Code of conduct and ethics. Singapore: SPF.
  Singapore Police Force
- Terrill, W. (2016). Police use of force: A global perspective. New York: Springer.
- Tyler, T. R. (2006). Why people obey the law. Princeton, NJ: Princeton University Press.
- United Nations. (1948). Universal declaration of human rights. New York: United Nations.
  United Nations
- United Nations. (1966). International covenant on civil and political rights. New York: United Nations.
  United Nations
- United Nations. (1979). Code of conduct for law enforcement officials. General Assembly Resolution 34/169. New York: United Nations.
  United Nations
- United Nations. (1990). Basic principles on the use of force and firearms by law enforcement officials. New York: United Nations.
  United Nations
- United Nations Office on Drugs and Crime. (2011). Handbook on police accountability, oversight and integrity. Vienna: UNODC.
  United Nations Office on Drugs and Crime
- ASEAN. (2015). ASEAN human rights declaration. Jakarta: ASEAN Secretariat.
  ASEAN

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៨៣៧៣ ប្រ.ក

# ប្រកាស
## ស្តីពី
## បទវិន័យនគរបាលជាតិកម្ពុជា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/០៨៣ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីរូបភាពលំដាប់ស័ក្តិរបស់កងកម្លាំងនគរបាលជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលឯកសណ្ឋាននិងស្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣០៣ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ១២៦៧២ ប្រ.ក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើសៀវភៅគោលស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.–**

ប្រកាសនេះ មានគោលដៅកំណត់អំពីបទវិន័យនគរបាលជាតិកម្ពុជា ក្នុងគោលបំណងលើកកម្ពស់សីលធម៌ តម្លៃ សេចក្តីថ្លៃថ្នូរ ជំនឿទុកចិត្ត ឧត្តមភាព កិត្តិយស និងប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីនគរបាលជាតិ ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រទេសជាតិ និងប្រជាពលរដ្ឋ។

**ប្រការ២.–**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជា។

**ប្រការ៣.–**

បទវិន័យនគរបាលជាតិកម្ពុជា សំដៅដល់ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យដែលជាសំណុំវិធាន ឬបទប្បញ្ញត្តិដឹកនាំ ណែនាំ អប់រំ និងទូន្មានមន្ត្រីនគរបាលជាតិ ដើម្បីលើកកម្ពស់សីលធម៌ តម្លៃ សេចក្តីថ្លៃថ្នូរ ឧត្តមភាព កិត្យានុភាព ជំនឿទុកចិត្ត ព្រមទាំងណែនាំតម្រង់ទិសដល់មន្ត្រីនគរបាលជាតិ ឱ្យប្រព្រឹត្តអំពើល្អត្រឹមត្រូវ ក្នុងការបំពេញភារកិច្ចរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រទេសជាតិ និងប្រជាពលរដ្ឋ។

## ជំពូកទី ២

## សិទ្ធិនិងកាតព្វកិច្ច

**ប្រការ៤.–**

មន្ត្រីនគរបាលជាតិកម្ពុជា មានសិទ្ធិនិងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ៥.–**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគោរពសិទ្ធិ កាតព្វកិច្ច និងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ដូចមានចែងក្នុងជំពូកទី៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា។

## ជំពូកទី ៣

## បទវិន័យនគរបាលជាតិកម្ពុជា

### ផ្នែកទី ១

### ក្រមសីលធម៌វិជ្ជាជីវៈ

**ប្រការ៦.–**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ និងអង់អាចក្លាហាន ហ៊ានធ្វើពលិកម្មនៅគ្រប់កាលៈទេសៈទាំងអស់ ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋ។

២/១៤

**ប្រការ៧._**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវចងចាំថាខ្លួនជាបុគ្គលដែលសាធារណជនតែងតែឃ្លាំមើលជាប្រចាំ។ មន្ត្រីនគរបាលជាតិ ត្រូវកំណត់នូវសេរីភាពនិងឆន្ទៈផ្ទាល់ខ្លួនឱ្យបានសមស្រប ដើម្បីឱ្យប្រជាពលរដ្ឋមើលឃើញឧត្តមភាព កិត្តិយស និងតម្លៃរបស់មន្ត្រីនគរបាលជាតិ។

**ប្រការ៨._**

មន្ត្រីនគរបាលជាតិកម្ពុជា ជាកងកម្លាំងប្រដាប់អាវុធ ដែលមានតួនាទីជាមន្ត្រីអនុវត្តច្បាប់។ ក្នុងការងារប្រចាំថ្ងៃ និងក្នុងកិច្ចប្រតិបត្តិការ មន្ត្រីនគរបាលជាតិត្រូវអនុវត្តបទបញ្ជានិងគោរពច្បាប់។

**ប្រការ៩._**

ក្នុងការបំពេញភារកិច្ចទទួលខុសត្រូវរបស់ខ្លួនដើម្បីបម្រើប្រជាពលរដ្ឋ មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវ៖

១- គោរពនិងប្រតិបត្តិដោយស្មោះត្រង់ចំពោះរាជរដ្ឋាភិបាល និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំប្រកបដោយសុច្ចរិតភាព។

២- ផ្តល់សេវាជូនប្រជាពលរដ្ឋ ទាក់ទងនឹងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដោយប្រកាន់ខ្ជាប់នូវអាកប្បកិរិយា ឥរិយាបថល្អ ប្រកបដោយសីលធម៌ ភាពស្មោះត្រង់ យុត្តិធម៌ និងភាពមិនលម្អៀងក្នុងពេលបំពេញភារកិច្ច។

៣- រក្សាកិត្តិយស ឥស្សរភាព និងសេចក្តីថ្លៃថ្នូរ របស់មន្ត្រីនគរបាលជាតិ ក្នុងការបំពេញភារកិច្ច។

៤- រក្សាការសម្ងាត់របស់ជាតិ ក្រសួង និងអង្គភាពខ្លួន ទាក់ទងនឹងហេតុការណ៍ ឯកសារ និងព័ត៌មានដែលខ្លួនបានដឹង។

៥- មានអព្យាក្រឹត្យភាពក្នុងការបំពេញតួនាទី និងភារកិច្ច។

៦- បញ្ចេញមតិយោបល់ដោយប្រុងប្រយ័ត្ន ព្រមទាំងគិតដល់ការប្រតិកម្មតបនូវទង្វើនិងពាក្យសម្តីរបស់ខ្លួនពីសាធារណជន។

៧- បំពេញភារកិច្ចក្នុងការផ្តល់សេវា ដោយឈរលើគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ គោរពសិទ្ធិមនុស្ស និងភាពមិនរើសអើង ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

៨- មានមនសិការការងារ ការទទួលខុសត្រូវ និងគណនេយ្យភាពក្នុងអាជីពរបស់ខ្លួន ដើម្បីទទួលបានការពេញចិត្ត និងការជឿទុកចិត្តពីប្រជាពលរដ្ឋ។

៩- មានការប្តេជ្ញាចិត្ត ឆន្ទៈមោះមុត ទឹកចិត្តអង់អាច ក្លាហាន ម៉ឺងម៉ាត់ ហ្មត់ចត់ ទន់ភ្លន់ និងសុភាពរាបសារ ក្នុងកិច្ចប្រតិបត្តិការបំពេញភារកិច្ច និងបេសកកម្មបម្រើប្រជាពលរដ្ឋ។

១០- ខិតខំអភិវឌ្ឍនិងពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល និងការដកស្រង់បទពិសោធល្អៗពីអ្នកពាក់ព័ន្ធ ដើម្បីយកជាមូលដ្ឋានក្នុងការបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព។

១១- មានគំនិតច្នៃប្រឌិត ឧស្សាហ៍ព្យាយាម សាមគ្គីភាព សហការ និងទំនាក់ទំនងល្អក្នុងការងារបម្រើប្រជាពលរដ្ឋ។

៧/១៤

១២- ធ្វើទំនាក់ទំនងជាមួយព្រះសង្ឃ លោកអាចារ្យ ដូនជី ចាស់ព្រឹទ្ធាចារ្យ និងប្រជាពលរដ្ឋទូទៅ ជានិច្ចកាលត្រូវរួសរាយរាក់ទាក់ សុភាពរាបសា មានសុជីវធម៌ និងគោរពប្រពៃណីទំនៀមទម្លាប់។

១៣- ចាត់ទុកនិមិត្តសញ្ញាឬសញ្ញានៃអង្គភាព និងមុខតំណែងរបស់ខ្លួន ជានិមិត្តរូបនៃសេចក្តីស្មោះត្រង់ និងការជឿទុកចិត្តរបស់សាធារណជនជាដរាប។

១៤- ប្រើសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការបំពេញភារកិច្ច ដើម្បីបម្រើសង្គមជាតិនិងសហគមន៍ ប្រកបដោយប្រសិទ្ធភាព។

១៥- ប្រើកម្លាំងក្នុងកាលៈទេសៈចាំបាច់ណាមួយ ហើយស្ថិតនៅក្នុងវង្វង់ដែនសមត្ថកិច្ចនិងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ១០.–**

ក្នុងការបំពេញភារកិច្ចទទួលខុសត្រូវរបស់ខ្លួនដើម្បីបម្រើប្រជាពលរដ្ឋ មន្ត្រីនគរបាលជាតិកម្ពុជា មិនត្រូវ៖

១- ប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់កិត្តិយស តម្លៃ និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីនគរបាលជាតិ ក្នុងការបំពេញអាជីពរបស់ខ្លួន។

២- ធ្វើឱ្យបាត់បង់មនសិការវិជ្ជាជីវៈក្នុងការបំពេញករណីយកិច្ចនិងកាតព្វកិច្ចរបស់ខ្លួន ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

៣- ពាក់ព័ន្ធនិងឃុបឃិតជាមួយជនល្មើសក្នុងការប្រព្រឹត្តនូវរាល់អំពើខុសច្បាប់ ក្នុងអាជីពជាមន្ត្រីនគរបាលជាតិ មានភារកិច្ចបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

៤- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួន ដែលជាហេតុធ្វើឱ្យប្រសិទ្ធភាពការងារធ្លាក់ចុះ និងជះឥទ្ធិពលមិនល្អដល់សង្គមជាតិ។

៥- សំឡុតគំរាមកំហែងបំពានសិទ្ធិពលរដ្ឋ យកឥទ្ធិពល ឬអំណាចនៅក្នុងមុខងារ ឬយកមន្ត្រីនគរបាលជាតិនៅក្រោមបង្គាប់របស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ។

៦- ចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល គ្រប់គ្រងក្រុមហ៊ុនឯកជន ឬធ្វើអាជីវកម្មដោយផ្ទាល់ ឬដោយប្រយោល ដែលជាហេតុធ្វើឱ្យមានទំនាស់ផលប្រយោជន៍។

៧- ប្រើមុខងារបំពេញភារកិច្ច និងប្រើប្រាស់មធ្យោបាយសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាព និងផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយឡើយ។

៨- ប្រព្រឹត្តអំពើពុករលួយតាមគ្រប់រូបភាព បទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន លេងល្បែងស៊ីសង និងប្រព្រឹត្តបទល្មើសគ្រប់ប្រភេទ។

៩- ទទួលទានគ្រឿងស្រវឹង ឬស្រវឹងក្នុងពេលម៉ោងរដ្ឋបាល ឬក្នុងពេលបំពេញបេសកកម្ម។

១០- សមគំនិតឬផ្តល់មធ្យោបាយ ដើម្បីធ្វើសកម្មភាពអ្វីមួយ ដែលធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សង្គម ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍រួម។

១១- ថ្លែងឬបកស្រាយជាសាធារណៈអំពីកិច្ចការផ្ទាល់ខ្លួន ជំនឿ សាសនា គណបក្សនយោបាយ ឬការសម្ងាត់របស់នគរបាលជាតិ ដោយប្រើតួនាទីក្នុងអង្គភាពឬឈ្មោះអង្គភាព ទោះក្នុងឯកសណ្ឋានមន្ត្រីនគរបាលជាតិឬក្នុងឯកសណ្ឋានស៊ីវិល។

៤/១៤

១២- លក់ឬផ្តល់រូបភាព វីដេអូ ខ្សែអាត់សំឡេង ព័ត៌មានទាក់ទងទៅនឹងសកម្មភាពឬកិច្ចការនគរបាលជាតិ ទៅឱ្យអ្នកដទៃ។

១៣- ធ្វើឱ្យមានការអាក់ខាន ការយឺតយ៉ាវ ឬរាំងស្ទះដល់កិច្ចប្រតិបត្តិការ ឬការងារប្រចាំថ្ងៃរបស់អង្គភាព។

១៤- ប្រព្រឹត្តឬញុះញង់បណ្តាលឱ្យមានការធ្វើទារុណកម្ម ការប្រព្រឹត្តអំពើឃោរឃៅ និងអមនុស្សធម៌ ឬទណ្ឌកម្មឯទៀត។

១៥- ពាក់ស័ក្តិ គ្រឿងឥស្សរិយយស ឬសញ្ញាសម្គាល់ ដែលមិនបានផ្តល់ជូនដល់សាមីខ្លួន តាមសេចក្តីសម្រេច ប្រកាស អនុក្រឹត្យ ឬព្រះរាជក្រឹត្យ ដោយមិនស្របច្បាប់ឬមិនត្រឹមត្រូវតាមការកំណត់។

១៦- បង្កជម្លោះ ប្រើអំពើហិង្សាក្នុងអង្គភាព ឬក្នុងពេលបំពេញបេសកកម្ម។

១៧- ធ្វើសកម្មភាពឬផ្សព្វផ្សាយក្នុងអង្គភាព ទោះក្នុងរូបភាពណាក៏ដោយ ដែលនាំឱ្យបែកបាក់សាមគ្គីភាពផ្ទៃក្នុង និងប៉ះពាល់ដល់ទឹកចិត្តមន្ត្រីនគរបាលជាតិ។

## ផ្នែកទី ២
## វិន័យ

**ប្រការ១១.-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគោរពនិងអនុវត្តតាមបញ្ជាថ្នាក់ដឹកនាំ តាមឋានានុក្រម ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ការគោរពបញ្ជា គឺជាកាតព្វកិច្ចចាំបាច់របស់មន្ត្រីនគរបាលជាតិក្រោមបង្គាប់ ដែលមានការទទួលខុសត្រូវបន្តតាមឋានានុក្រម។

**ប្រការ១២.-**

ការអនុវត្តនូវបទបញ្ជាដោយបំពានច្បាប់ឬខុសឆ្គងនឹងបញ្ញត្តិច្បាប់ជាធរមាន ទោះជាប្រធានអង្គភាពទទួលខុសត្រូវឬមិនទទួលខុសត្រូវ សាមីខ្លួនត្រូវតែទទួលទណ្ឌកម្មតាមការកំណត់។

**ប្រការ១៣.-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគោរពឋានានុក្រមនិងមានទំនាក់ទំនងការងារ ដូចខាងក្រោម៖

១- នៅពេលមកជួបថ្នាក់ដឹកនាំឬមន្ត្រីថ្នាក់លើក្នុងអង្គភាព មន្ត្រីនគរបាលជាតិត្រូវគោះទ្វារ ដើម្បីសុំការអនុញ្ញាតជាមុន។ ពេលបានការអនុញ្ញាតហើយ ទើបអាចចូលបាន។ មន្ត្រីនគរបាលជាតិត្រូវគោរពគំនាប់បើមានមួក និងប្រើកាយវិការប្រុងបើគ្មានមួក។ មន្ត្រីនគរបាលជាតិធ្វើទំនាក់ទំនងគ្នាដោយប្រើពាក្យតាមគោរមងារនិងឋានន្តរស័ក្តិ។

២- ក្នុងករណីជួបថ្នាក់ដឹកនាំដែលមិនមែនជាថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន សាមីខ្លួនត្រូវរាយការណ៍បង្ហាញខ្លួនអំពីឋានន្តរស័ក្តិ ឈ្មោះ អត្តលេខ តួនាទី និងអង្គភាពប្រតិបត្តិការ រួចទើបរាយការណ៍អំពីខ្លឹមសារការងារ។ ពេលរាយការណ៍ចប់ ត្រូវរង់ចាំបញ្ជានិងត្រូវគោរពគំនាប់នៅពេលចប់ការងារទំនាក់ទំនង។

៥/១៤

៣- មន្ត្រីនគរបាលជាតិដែលមានឋានន្តរស័ក្តិខ្ពស់ជាងឬមុខតំណែងខ្ពស់ជាង មានសិទ្ធិណែនាំដល់មន្ត្រីនគរបាលជាតិឯទៀតដែលមានឋានន្តរស័ក្តិទាបជាងខ្លួនឬមុខតំណែងទាបជាង ដែលបានប្រព្រឹត្តល្មើសនឹងបទវិន័យ ឬក្នុងករណីចាំបាច់ អាចនាំខ្លួនមន្ត្រីនោះមកប្រគល់ឱ្យអង្គភាពមានសមត្ថកិច្ចឬអង្គភាពសាមី។

៤- ជាគោលការណ៍ មន្ត្រីនគរបាលជាតិដែលមានមុខតំណែងទាបជាង ប៉ុន្តែមានឋានន្តរស័ក្តិខ្ពស់ជាងឬស្មើ ត្រូវគោរពមន្ត្រីនគរបាលជាតិដែលមានមុខតំណែងខ្ពស់ជាង។ ក្នុងករណីដែលមិនស្គាល់គ្នា មន្ត្រីនគរបាលជាតិណាដែលមានឋានន្តរស័ក្តិទាបជាង ត្រូវគោរពមន្ត្រីនគរបាលជាតិដែលមានឋានន្តរស័ក្តិខ្ពស់ជាង។

៥- មន្ត្រីនគរបាលជាតិ ត្រូវបង្កលក្ខណៈងាយស្រួលដល់កិច្ចប្រតិបត្តិការត្រួតពិនិត្យរបស់ក្រុមតម្រួតបទបញ្ជា។ ក្រុមតម្រួតបទបញ្ជា ត្រូវបំពេញតួនាទីនិងភារកិច្ចទទួលខុសត្រូវឱ្យមានប្រសិទ្ធភាព ដោយមិនត្រូវធ្វើសកម្មភាពណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីនគរបាលជាតិឡើយ។

៦- ថ្នាក់ដឹកនាំនគរបាលជាតិ មិនត្រូវយកមុខតំណែងឬឋានន្តរស័ក្តិ ទៅសម្លុតឬគំរាមកំហែងមន្ត្រីនគរបាលជាតិថ្នាក់ទាបជាងខ្លួនឡើយ។

៧- មន្ត្រីនគរបាលជាតិ ត្រូវអនុវត្តតាមបទបញ្ជាគ្រប់កាលៈទេសៈ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ប្រសិនបើការចាត់តាំងនោះបណ្តាលឱ្យជួបការលំបាក ដែលចាំបាច់ត្រូវការឧបត្ថម្ភ អង្គភាពគ្រប់ថ្នាក់ដែលមានសមត្ថកិច្ច ត្រូវជានាផ្តល់ឱ្យទៅតាមប្រភេទនៃការលំបាកនោះ។

**ប្រការ១៤._**

បន្ទាប់ពីទទួលបញ្ជារបស់ប្រធានអង្គភាព ហើយមិនអនុវត្តតាម ដោយធ្វេសប្រហែសឬមានភាពខ្ជីខ្ជា ដែលនាំឱ្យមានការខកខាន ឬខូចខាតណាមួយកើតឡើង សាមីខ្លួនត្រូវទទួលកំហុសនិងទណ្ឌកម្មតាមការកំណត់។

**ប្រការ១៥._**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគោរពនិងអនុវត្តរាល់បញ្ជាដោយស្មារតីទទួលខុសត្រូវនិងគ្មានតវ៉ាជេញដោលរកហេតុផល។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែត ផ្ទុយពីច្បាប់ជាតិឬច្បាប់អន្តរជាតិ ត្រូវហាមឃាត់។ ក្នុងករណីនេះ អ្នកបញ្ជាឬអ្នកអនុវត្តបញ្ជា ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ប្រធានអង្គភាពនគរបាលជាតិគ្រប់ថ្នាក់ ត្រូវទទួលខុសត្រូវចំពោះបញ្ជារបស់ខ្លួននិងលទ្ធផលនៃការអនុវត្តបញ្ជារបស់មន្ត្រីក្រោមបង្គាប់ទោះជោគជ័យឬបរាជ័យ។

ការដាក់បញ្ជាត្រូវធ្វើឡើងឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តឱ្យបានចំគោលដៅនិងមានប្រសិទ្ធភាព។

អ្នកទទួលបញ្ជា ត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្តបញ្ជាជូនប្រធានអង្គភាពដែលដាក់បញ្ជា។

**ប្រការ១៦._**

ថ្នាក់ដឹកនាំនិងមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគោរពតាមការចាត់បញ្ជូនទៅបណ្តុះបណ្តាល លើកលែងតែសាមីខ្លួនមានករណីចាំបាច់ ដោយមានមូលហេតុច្បាស់លាស់និងសមស្រប។

៦/១៤

**ប្រការ១៧**.-

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តការគោរពគំនាប់គ្នាទៅវិញទៅមក ដូចខាងក្រោម៖

១- មន្ត្រីនគរបាលជាតិ ក្នុងពេលបម្រើការងារនិងក្នុងពិធីផ្លូវការ ត្រូវគោរពគំនាប់ដល់មន្ត្រីនគរបាលជាតិដែលមានឋានន្តរស័ក្តិឬមុខតំណែងខ្ពស់ជាងខ្លួន។

២- ពេលជួបគ្នា អ្នកមានឋានន្តរស័ក្តិទាបជាង ត្រូវគោរពគំនាប់មុន ហើយអ្នកមានឋានន្តរស័ក្តិខ្ពស់ត្រូវគោរពគំនាប់តបវិញឬផ្តល់សញ្ញាឆ្លើយតប។ ចំពោះអ្នកមានឋានន្តរស័ក្តិស្មើគ្នា អ្នកឃើញមុនត្រូវគោរពគំនាប់មុន ហើយមន្ត្រីនគរបាលជាតិម្នាក់ទៀតត្រូវគោរពគំនាប់តបវិញ។

៣- ក្នុងករណីមានគណៈប្រតិភូឬថ្នាក់ដឹកនាំជាន់ខ្ពស់ អញ្ជើញមកទស្សនកិច្ច សួរសុខទុក្ខនៅអង្គភាព ឬនៅពេលមានកិច្ចប្រជុំ បើនៅក្នុងទីធ្លា អ្នកមានឋានន្តរស័ក្តិខ្ពស់ជាងគេ ត្រូវស្រែកបញ្ជាថា «ប្រុង» បើនៅក្នុងបន្ទប់ត្រូវស្រែកបញ្ជាថា «តាមកន្លែងគោរព» ដើម្បីឱ្យអ្នកដទៃទៀត អនុវត្តកាយវិការប្រុង ឬគោរពបានស្រុះគ្នានិងទាន់ពេលវេលា។

៤- មន្ត្រីនគរបាលជាតិដែលមានភារកិច្ចតាមដងផ្លូវនិងប្រចាំការតាមគោលដៅការពារ ត្រូវគោរពគំនាប់ពេលមានក្បួនរថយន្តប្រតិភូផ្លូវការឬមន្ត្រីជាន់ខ្ពស់ឆ្លងកាត់។

៥- ពេលប្រតិបត្តិការត្រួតពិនិត្យនិងឆែកឆេរ មន្ត្រីនគរបាលជាតិត្រូវគោរពគំនាប់ចំពោះមុខសញ្ញាដែលខ្លួនបម្រុងស្នើសុំត្រួតពិនិត្យឬឆែកឆេរ។

៦- មន្ត្រីនគរបាលជាតិមិនបាច់គោរពគំនាប់ ចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

- ពេលកំពុងធ្វើដំណើរដោយកង់ ម៉ូតូ រថយន្ត ឬមធ្យោបាយធ្វើដំណើរផ្សេងទៀត
- ពេលកំពុងបញ្ជាចរាចរណ៍
- ពេលកំពុងសង្គ្រោះបន្ទាន់
- ពេលកំពុងការពារកន្លែងកើតហេតុ
- ពេលកំពុងពន្លត់អគ្គិភ័យ
- ពេលកំពុងប្រតិបត្តិការតាមចាប់ជនល្មើស
- ពេលកំពុងបំពេញភារកិច្ចផ្នែកសន្តិសុខតម្រូវឱ្យបែរមុខទៅកេសាធារណជន ឬទិសដៅបានកំណត់
- ពេលកំពុងបំពេញភារកិច្ចចាំបាច់។

៧- ពេលធ្វើដំណើរជួបពិធីគោរពទង់ជាតិ មន្ត្រីនគរបាលជាតិត្រូវឈរគោរព ដោយបែរមុខឱ្យចំទង់ជាតិ។

៨- ពេលគោរពទង់ជាតិក្នុងពិធីផ្លូវការ មន្ត្រីនគរបាលជាតិដែលពាក់មួកត្រូវធ្វើកាយវិការ «គោរពគំនាប់» អ្នកដែលគ្មានមួកត្រូវឈរត្រង់ខ្លួនក្នុងកាយវិការ «ប្រុង» តាំងពីពេលចាប់ផ្តើមគោរពទង់ជាតិរហូតដល់ចប់។

៩- ពេលមានថ្នាក់ដឹកនាំហៅមន្ត្រីនគរបាលជាតិណាម្នាក់ដែលមានតួនាទីឬឋានន្តរស័ក្តិទាបជាងទៅជួប អ្នកទៅជួបត្រូវធ្វើកាយវិការ «គោរពគំនាប់» ក្នុងករណីមានមួក និងធ្វើកាយវិការ «ប្រុង» ក្នុងករណីគ្មានមួក ហើយថ្នាក់ដឹកនាំនោះ ត្រូវគោរពគំនាប់ឬធ្វើសញ្ញាឆ្លើយតបវិញដោយសមរម្យ។

១០- មន្ត្រីនគរបាលជាតិត្រូវអនុវត្តកាយវិការគោរពគំនាប់ ស្របតាមប្រកាសលេខ១២៦៧២ ប្រ.ក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើសៀវភៅគោល ស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា។

៧/១៤

១១- ក្នុងពេលបំពេញភារកិច្ចឬក្នុងពិធីផ្លូវការ មន្ត្រីនគរបាលជាតិដែលស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ មិនត្រូវលើកដៃសំពះដើម្បីសម្ដែងគារវកិច្ច លើកលែងអង្គព្រះមហាក្សត្រនិងព្រះសង្ឃព្រះពុទ្ធសាសនា។

**ប្រការ១៨**._

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ ដូចខាងក្រោម៖

១- ត្រូវស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិរួមទាំងស្លាកសញ្ញា តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងពេលបំពេញភារកិច្ច ក្នុងពិធីផ្លូវការ ក្នុងពេលចុះប្រតិបត្តិការ ឬក្នុងពេលបំពេញបេសកកម្ម លើកលែងតែក្នុងករណីដែលមានការកំណត់ផ្សេងពីនេះ។

២- ហាមដាច់ខាតចូលកម្សាន្តក្នុងរង្គសាល ក្នុងសម្លៀកបំពាក់ឯកសណ្ឋាននគរបាលជាតិ លើកលែងករណីបំពេញបេសកកម្ម។

៣- ហាមទទួលទានអាហារតាមទីសាធារណៈឬភោជនីយដ្ឋាន ក្នុងសម្លៀកបំពាក់ឯកសណ្ឋាននគរបាលជាតិ ដោយពាក់ស័ក្តិ។

៤- ហាមស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ ក្នុងពេលចូលរួមដោះស្រាយវិវាទ ក្រៅដែនសមត្ថកិច្ចរបស់ខ្លួន។

៥- មន្ត្រីនគរបាលជាតិជាបុរស ត្រូវកាត់សក់ឱ្យខ្លី កោរពុកមាត់ ពុកចង្កា និងកាត់ក្រចកដៃ។

៦- មន្ត្រីនគរបាលជាតិ មិនត្រូវពាក់វ៉ែនតាខ្មៅក្នុងពេលបំពេញភារកិច្ច លើកលែងតែមានការណែនាំឬការកំណត់ដោយឡែក។

**ប្រការ១៩**._

មន្ត្រីនគរបាលជាតិកម្ពុជា អាចស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននៅក្រោយពេលបម្រើការងារ ឬក្រៅម៉ោងរដ្ឋបាល ឬក្រៅអង្គភាពនគរបាលជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស ឬពេលចុះប្រត្តិបត្តិការដែលមិនអនុញ្ញាតឱ្យស្លៀកពាក់ស៊ីវិលបាន។

អាចអនុញ្ញាតឱ្យស្លៀកពាក់ឯកសណ្ឋានស៊ីវិលជាបណ្ដោះអាសន្នពេលបំពេញភារកិច្ច ក្នុងកាលៈទេសៈតម្រូវចាំបាច់ណាមួយ។

ប្រភេទមុខងារពិសេសមួយចំនួនរបស់មន្ត្រីនគរបាលជាតិ អាចអនុញ្ញាតឱ្យស្លៀកពាក់ឯកសណ្ឋានស៊ីវិលក្នុងពេលបំពេញភារកិច្ច តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ណាមួយ ប្រធានអង្គភាពអាចណែនាំឱ្យមន្ត្រីក្រោមឱវាទ ស្លៀកពាក់ឯកសណ្ឋានស៊ីវិលពេលម៉ោងរដ្ឋបាល ក្នុងមួយរយៈពេលកំណត់តែប៉ុណ្ណោះ។

មន្ត្រីនគរបាលជាតិ ដែលស្លៀកពាក់ឯកសណ្ឋានស៊ីវិល មិនអាចប្រើតួនាទីឬអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការផាកពិន័យ ឆែកឆេរ ឃាត់ខ្លួន ឬឃាត់មធ្យោបាយ លើកលែងតែការបំពេញបេសកកម្មឬចុះប្រត្តិបត្តិការមួយចំនួន តាមការកំណត់។

ក្រៅម៉ោងរដ្ឋបាល មន្ត្រីនគរបាលជាតិដែលស្នាក់នៅក្នុងអង្គភាពនគរបាលជាតិ អាចអនុញ្ញាតឱ្យស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាន។

ហាមដាច់ខាតចំពោះការពាក់អាវជាឯកសណ្ឋាននគរបាលជាតិ និងស្លៀកខោស៊ីវិលលាយឡំគ្នា។

៨/១៤

ក្នុងករណីស្លៀកពាក់ឯកសណ្ឋានស៊ីវិល មន្ត្រីនគរបាលជាតិត្រូវស្លៀកពាក់ឱ្យបានសមរម្យ និងរក្សាបានសេចក្តីថ្លៃថ្នូរ។

មន្ត្រីនគរបាលជាតិ ដែលមានបេសកកម្មជាផ្លូវការឬទៅសិក្សានៅក្រៅប្រទេស អាចស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិក្នុងពេលធ្វើដំណើរទៅកាន់ប្រទេសណាមួយ។

**ប្រការ២០.–**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនិងទៀងទាត់តាមម៉ោងរដ្ឋបាល ក្នុងការបំពេញភារកិច្ចក្នុងថ្ងៃធ្វើការ កំណត់ដូចខាងក្រោម៖

១- ពេលព្រឹកពីម៉ោង៧ និង០០នាទី ដល់ ម៉ោង១១ និង៣០នាទី។

២- ពេលរសៀលពីម៉ោង២ និង០០នាទី ដល់ម៉ោង៥ និង៣០នាទី។

៣- ក្នុងករណីចាំបាច់ឬក្នុងពេលបំពេញបេសកកម្ម មន្ត្រីនគរបាលជាតិ ត្រូវបំពេញបេសកកម្មតាមបញ្ជារបស់អង្គភាពឬថ្នាក់ដឹកនាំ ដោយមិនគិតពីពេលវេលាដែលបានកំណត់ខាងលើ។

**ប្រការ២១.–**

ការកំណត់ម៉ោងរដ្ឋបាលដូចមានចែងក្នុងប្រការ២០ នៃប្រកាសនេះ មិនអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលបំពេញមុខងារនិងភារកិច្ចនៅតាមអង្គភាពជំនាញមួយចំនួន ដែលតម្រូវឱ្យបំពេញភារកិច្ច ២៤ម៉ោងលើ២៤ម៉ោង ជារៀងរាល់ថ្ងៃ រួមទាំងថ្ងៃឈប់សម្រាកផង។ មន្ត្រីនគរបាលជាតិនោះត្រូវត្រៀមខ្លួនក្នុងការផ្លាស់ប្តូរវេនបំពេញភារកិច្ច ឬប្រចាំការ ឬតាមមុខងារនិងភារកិច្ចត្រូវអនុវត្ត ឬតាមបញ្ជារបស់ប្រធានអង្គភាព ដែលការកំណត់ម៉ោងរដ្ឋបាលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ២២.–**

មន្ត្រីនគរបាលជាតិកម្ពុជា មានសិទ្ធិសុំច្បាប់សម្រាកពីការងារ ដោយអនុវត្តតាមការកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែកឬតាមគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ២៣.–**

មន្ត្រីនគរបាលជាតិកម្ពុជាគ្រប់លំដាប់ថ្នាក់ ត្រូវថែរក្សាឱ្យបានគង់វង្សរាល់គ្រឿងសព្វាវុធ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងយុទ្ធោបករណ៍ទាំងឡាយដែលបានបំពាក់ឱ្យ។ ការធ្វើឱ្យបាត់បង់ឬខូចខាតគ្រឿងសព្វាវុធ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងយុទ្ធោបករណ៍ ត្រូវទទួលទណ្ឌកម្មខាងវិន័យឬទណ្ឌកម្មតាមច្បាប់កំណត់។

**ប្រការ២៤.–**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមក្បួនខ្នាតនៃការប្រើអាវុធ។

មន្ត្រីនគរបាលជាតិ អាចប្រើអាវុធបានតែក្នុងកាលៈទេសៈណាចាំបាច់បំផុតឬស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចនៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

ការបង្កឱ្យមានគ្រោះថ្នាក់ដោយអាវុធ ទោះបីចេតនាក៏ដោយ ក៏មន្ត្រីនគរបាលជាតិរូបនោះត្រូវទទួលទោសឬទណ្ឌកម្មតាមច្បាប់។

**ប្រការ២៥.-**

ពេលស្លៀកពាក់ឯកសណ្ឋាន មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវដាក់អាវុធខ្លីក្នុងស្រោម ក្រវាត់នៅចង្កេះខាងស្តាំ។ មន្ត្រីនគរបាលជាតិដែលស្លៀកពាក់ស៊ីវិលចុះបំពេញបេសកកម្ម ត្រូវសៀតអាវុធខ្លីខាងក្នុងខោអាវដោយភាពលាក់បាំង។

**ប្រការ២៦.-**

មន្ត្រីនគរបាលជាតិកម្ពុជាគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តនិងគោរពច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ២៧.-**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងអស់ ត្រូវទទួលខុសត្រូវអំពីកំហុសនិងការធ្លាំធ្លងក្នុងវិជ្ជាជីវៈ ព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន។

ក្នុងករណីដែលមានពាក្យបណ្តឹងពីតតិយជន ចំពោះមន្ត្រីនគរបាលជាតិអំពីកំហុសក្នុងការបម្រើសេវាដែលមិនមែនជាកំហុសផ្ទាល់ខ្លួន ក្រសួងមហាផ្ទៃត្រូវការពារមន្ត្រីនគរបាលជាតិរូបនោះ និងធានាចេញសំណងផ្នែករដ្ឋប្បវេណី។

ក្នុងពេលបំពេញភារកិច្ច មន្ត្រីនគរបាលជាតិដែលទទួលការគំរាមកំហែងឬការវាយប្រហារដោយប្រការណាមួយពីសំណាក់ជនណាម្នាក់ដែលមិនមែនជាកំហុសផ្ទាល់ខ្លួន ត្រូវបានក្រសួងមហាផ្ទៃការពារ និងចេញមុខប្តឹងទៅតុលាការ។

## ជំពូកទី ៤
## ការចូលរួមការងារសង្គម

**ប្រការ២៨.-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានលើកទឹកចិត្តឱ្យចូលរួមសកម្មភាពក្នុងសង្គមជាលក្ខណៈឯកជនដែលទាក់ទងទៅនឹងការងារមនុស្សធម៌ សប្បុរសធម៌ សុខភាពសាធារណៈ ការងារសង្គម និងអប់រំដើម្បីជួយប្រជាពលរដ្ឋក្នុងពេលមានគ្រោះមហន្តរាយឬកាលៈទេសៈចាំបាច់ណាមួយ។

## ជំពូកទី ៥
## ការលើកសរសើរនិងជូនរង្វាន់

**ប្រការ២៩.-**

អង្គភាពនគរបាលជាតិឬមន្ត្រីនគរបាលជាតិកម្ពុជាដែលមានស្នាដៃល្អ ត្រូវទទួលបានការលើកទឹកចិត្តការលើកសរសើរឬការជូនរង្វាន់ តាមការកំណត់របស់ក្រសួងមហាផ្ទៃឬរាជរដ្ឋាភិបាល។

ការលើកសរសើរឬការជូនរង្វាន់ ត្រូវបានចែកចេញជាពីរប្រភេទ គឺលក្ខណៈពិសេស និងលក្ខណៈធម្មតា។ ការលើកសរសើរទាំងអស់ត្រូវកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីនគរបាលជាតិកម្ពុជា។

គ្រឿងឥស្សរិយយស ត្រូវបានផ្តល់ដល់មន្ត្រីនគរបាលជាតិ ដោយផ្អែកលើគុណសម្បត្តិ និងស្នាដៃក្នុងការបំពេញភារកិច្ចស្របច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ប័ណ្ណសរសើរ លិខិតសរសើរ ឬរង្វាន់ អាចផ្តល់ជូនមន្ត្រីនគរបាលជាតិ ដែលមានគុណសម្បត្តិ និងសមត្ថភាពក្នុងការបំពេញភារកិច្ច។

ប្រធានអង្គភាពអាចផ្តល់រង្វាន់ ដើម្បីលើកទឹកចិត្តដល់មន្ត្រីនគរបាលជាតិដែលបានចូលរួមក្នុងការងារកីឡា សិល្បៈ ឬការងារសង្គម។

១០/១៤

## ជំពូកទី ៦
## ការដាក់ទណ្ឌកម្ម

**ប្រការ៣០.–**

ការដាក់ទណ្ឌកម្មចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- មន្ត្រីនគរបាលជាតិ ដែលប្រព្រឹត្តល្មើសនឹងបទវិន័យនគរបាលជាតិកម្ពុជា។

២- ការដាក់ទណ្ឌកម្មត្រូវពិចារណាឱ្យបានហ្មត់ចត់ ត្រឹមត្រូវសមស្រប និងមានទំនាក់ទំនងស៊ីសង្វាក់ទៅនឹងទោសកំហុសដែលមន្ត្រីនគរបាលជាតិនោះបានប្រព្រឹត្ត ព្រមទាំងមានភស្តុតាងគ្រប់គ្រាន់។

៣- ប្រធានអង្គភាពគ្រប់គ្រងមន្ត្រីនគរបាលជាតិនោះផ្ទាល់ មានសមត្ថកិច្ចដាក់ទណ្ឌកម្មដោយផ្ទាល់តាមរូបភាពអប់រំ ណែនាំ ព្រមានផ្ទាល់មាត់ ឬការលុបឈ្មោះចេញពីតារាងដំឡើងឋានន្តរស័ក្តិ ឬលើកសំណើដាក់ទណ្ឌកម្មស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន។

៤- ការដាក់ទណ្ឌកម្មតាមរូបភាព ការព្រមានជាលាយលក្ខណ៍អក្សរ ឬការដាក់ឱ្យទំនេរគ្មានប្រាក់បៀវត្សដោយបញ្ញត្តិមិនឱ្យលើសពី១ឆ្នាំ ឬការដកមុខតំណែងឱ្យនៅក្នុងស្ថានភាពអសកម្ម ឬការបន្ថយឋានន្តរស័ក្តិមួយថ្នាក់ឬច្រើនថ្នាក់ ឬការដកហូតមុខតំណែង ឬការផ្លាស់ចេញពីអង្គភាព ឬការដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬការបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ឬការបញ្ជូនសំណុំរឿងនិងវត្ថុតាងទៅតុលាការ ដោយផ្អែកលើសំណើតាមនីតិវិធីនិងឋានានុក្រម ឬសំណើរបស់ក្រុមប្រឹក្សាវិន័យ។

៥- រូបភាពនៃការដាក់ទណ្ឌកម្មខាងវិន័យមាន២កម្រិត គឺ៖

- ទណ្ឌកម្មខាងវិន័យកម្រិតទី១ តាមរូបភាពអប់រំ ស្តីបន្ទោស ធ្វើកិច្ចសន្យា ឬព្រមានជាលាយលក្ខណ៍អក្សរ ឬការលុបឈ្មោះចេញពីតារាងដំឡើងឋានន្តរស័ក្តិ ដោយប្រធានអង្គភាពឬរដ្ឋមន្ត្រី
- ទណ្ឌកម្មខាងវិន័យកម្រិតទី២ តាមរូបភាព ការដាក់ឱ្យទំនេរគ្មានប្រាក់បៀវត្សដោយបញ្ញត្តិមិនឱ្យលើសពី១ឆ្នាំ ឬការដកមុខតំណែងឱ្យនៅក្នុងស្ថានភាពអសកម្ម ឬការបន្ថយឋានន្តរស័ក្តិមួយថ្នាក់ ឬច្រើនថ្នាក់ ឬការដកហូតមុខតំណែង ឬការផ្លាស់ចេញពីអង្គភាព ឬការដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬការបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវមានការប្រជុំសម្រេចពីក្រុមប្រឹក្សាវិន័យ ស្របតាមជំពូកទី៧ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា។

៦- ការបញ្ជូនសំណុំរឿងនិងវត្ថុតាងទៅតុលាការ។

**ប្រការ៣១.–**

បែបបទនៃការដាក់ទណ្ឌកម្មដល់មន្ត្រីនគរបាលជាតិកម្ពុជា មានដូចខាងក្រោម៖

១- ត្រូវឱ្យមន្ត្រីនគរបាលជាតិ ដែលបានប្រព្រឹត្តខុសឆ្គង សរសេរសារណាការពារខ្លួនដោយខ្លួនឯងផ្ទាល់ដើម្បីដោះបន្ទុក។

២- ត្រូវដាក់កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាវិន័យចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់មន្ត្រីនគរបាលជាតិនោះ។

៣- ត្រូវកំណត់ប្រភេទនៃការដាក់ទណ្ឌកម្មខាងវិន័យមន្ត្រីនគរបាលជាតិណាម្នាក់ ដោយសរសេរឱ្យបានច្បាស់លាស់អំពីឋានន្តរស័ក្តិ ឈ្មោះ អត្តលេខ អាយុ ភេទ មុខតំណែង អង្គភាពដែលសាមីខ្លួនកំពុងបម្រើការងារ កំហុស និងរូបភាពនៃទណ្ឌកម្មនោះ។

៤- អង្គភាពគ្រប់គ្រងមន្ត្រីនគរបាលជាតិផ្ទាល់ ត្រូវពិនិត្យពិចារណាលើកំហុសនោះ ក្នុងការដាក់ទណ្ឌកម្មឱ្យបានសមស្របនិងយុត្តិធម៌ ដើម្បីលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យនិងសម្រេច។

**ប្រការ៣២._**

រូបភាពនិងខ្លឹមសារនៃការដាក់ទណ្ឌកម្មខាងវិន័យដល់មន្ត្រីនគរបាលជាតិកម្ពុជា មានដូចខាងក្រោម៖

**ក- ត្រូវដាក់ទណ្ឌកម្មខាងវិន័យកម្រិតទី១ ចំពោះមន្ត្រីនគរបាលជាតិដែល៖**

១- អវត្តមានឥតច្បាប់ជាប់ៗគ្នាពី៣ថ្ងៃ ដល់៧ថ្ងៃនៃថ្ងៃធ្វើការ។

២- មិនគោរពពេលម៉ោងរដ្ឋបាលទៀងទាត់។

៣- មិនគោរពអនុវត្តបញ្ជាឬការណែនាំរបស់ប្រធានអង្គភាព។

៤- បានជួល ឬឱ្យខ្ចី ឬលក់ឯកសណ្ឋាននគរបាលជាតិកម្ពុជាដល់អ្នកដទៃក្រៅក្របខ័ណ្ឌនគរបាលជាតិកម្ពុជា។

៥- យកមធ្យោបាយរបស់រដ្ឋឬអង្គភាពទៅប្រើប្រាស់ ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន។

៦- មិនគោរពបទបញ្ជាផ្ទៃក្នុងអង្គភាព ឬសាលា ឬមជ្ឈមណ្ឌលហ្វឹកហ្វឺន។

៧- មានភាពអសកម្មក្នុងការងារ។

៨- គេចវេសឬមិនចូលរួមពិធីផ្លូវការ ដែលថ្នាក់ដឹកនាំឬអង្គភាពបានចាត់តាំង។

៩- ប្រព្រឹត្តផ្ទុយនឹងចំណុចទី២ ទី៣ ទី៥ ទី៦ ទី៧ ទី៨ ទី៩ ឬទី១២ នៃប្រការ៩ ឬប្រព្រឹត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៨ ប្រការ១៩ ប្រការ២៥ នៃប្រកាសនេះ។

១០- ប្រព្រឹត្តល្មើសនឹងបម្រាមចំណុចទី៤ ទី៩ ទី១៣ ទី១៥ ឬទី១៦ នៃប្រការ១០ នៃប្រកាសនេះ។

**ខ- ត្រូវដាក់ទណ្ឌកម្មខាងវិន័យកម្រិតទី២ ចំពោះមន្ត្រីនគរបាលជាតិ ដែល៖**

១- បានទទួលការព្រមានជាលាយលក្ខណ៍អក្សរចំនួនពីរដងរួចហើយ តែមិនព្រមរាងចាល។

២- អវត្តមានឥតច្បាប់ជាប់ៗគ្នាចាប់ពី៨ថ្ងៃឡើងទៅនៃថ្ងៃធ្វើការ។

៣- ធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិរដ្ឋ ឬអង្គភាព ដោយចេតនា។

៤- បានប្រព្រឹត្តអំពើពុករលួយ។

៥- កិបកេង លក់ទ្រព្យសម្បត្តិរដ្ឋ ឬឯកជន។

៦- ក្លែងបន្លំឯកសារសាធារណៈ ឬឯកជន ឬប្រើប្រាស់ឯកសារក្លែង ឬឱ្យអ្នកដទៃខ្ចីលិខិតរបស់ខ្លួនប្រើប្រាស់។

៧- ចំណាយថវិការដ្ឋមិនត្រឹមត្រូវតាមការកំណត់ ខ្ជះខ្ជាយឬយកថវិការដ្ឋទៅបង្វិល ដើម្បីប្រយោជន៍បុគ្គល។

៨- ធ្វើការផ្សព្វផ្សាយ ឬចែកចាយព័ត៌មានមិនពិត ឬបញ្ចេញមតិក្នុងចេតនាមួលបង្កាច់ ឬវាយប្រហារនាំឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ឬកិត្តិយសបុគ្គល ឬអង្គភាព ស្ថាប័ន។

៩- រក្សាទុកមិនចាត់ការឯកសារឬសំណុំរឿង ដែលស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនដោះស្រាយ ដែលនាំឱ្យយឺតយ៉ាវ បាត់បង់ ឬបង្កការលំបាកដល់អ្នកទទួលសេវា ឬដល់អង្គភាព។

១០- បំផ្លាញ ឬធ្វើឱ្យបាត់បង់ ឬដោះដូរ ឬកាឡៃភាពដើមនៃមធ្យោបាយ សម្ភារៈ ទ្រព្យសម្បត្តិ ឯកសារ ដែលជាវត្ថុតាង ស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនដោះស្រាយ។

១១- ផាកពិន័យមិនត្រឹមត្រូវឬមិនចេញបង្កាន់ដៃ តាមការកំណត់។

១២- ធ្វេសប្រហែស ធ្វើឱ្យជនសង្ស័យឬជនជាប់ចោទរត់គេចខ្លួន។

១២/១៤

១៣- ឃុបឃិតកសាងសំណុំរឿង កាឡៃវត្ថុតាង ដើម្បីសម្រាលឬបន្ថែមស្ថានទម្ងន់ទោសដល់ជនសង្ស័យឬពិរុទ្ធជន។

១៤- សួរចម្លើយដោយធ្វើទារុណកម្មគ្រប់រូបភាព កៀបបង្ខំឬបញ្ចេះចម្លើយ។

១៥- ធ្វេសប្រហែសឬបង្កភាពយឺតយ៉ាវក្នុងការប្រតិបត្តិការអន្តរាគមន៍ បណ្តាលឱ្យអន្តរាយដល់អាយុជីវិតឬទ្រព្យសម្បត្តិបន្ថែមទៀត។

១៦- ធ្វេសប្រហែសក្នុងការការពារអង្គភាព គណៈប្រតិភូជាតិ អន្តរជាតិ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិ បណ្តាលឱ្យខូចខាតឬមានគ្រោះថ្នាក់។

១៧- មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈឬជាមួយមុខងារក្នុងស្ថាប័នផ្សេងទៀត។

១៨- គេចវេសឬបោះបង់វគ្គបណ្តុះបណ្តាល ដែលថ្នាក់ដឹកនាំឬអង្គភាពបានចាត់តាំង។

១៩- ប្រើប្រាស់ឬសេពគ្រឿងញៀនគ្រប់ប្រភេទ។

២០- ប្រព្រឹត្តផ្ទុយនឹងចំណុចទី១ ទី៤ ទី១៣ ទី១៤ ឬទី១៥ នៃប្រការ៩ ឬប្រព្រឹត្តផ្ទុយនឹងប្រការ១១ ប្រការ១២ ប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ២៣ ប្រការ២៤ និងប្រការ២៦ នៃប្រកាសនេះ។

២១- ប្រព្រឹត្តល្មើសនឹងបម្រាមចំណុចទី១ ទី២ ទី៣ ទី៥ ទី៦ ទី៧ ទី៨ ទី១០ ទី១១ ទី១២ ទី១៤ ឬទី១៧ នៃប្រការ១០ នៃប្រកាសនេះ។

**គ- បញ្ជូនសំណុំរឿងនិងវត្ថុតាងទៅតុលាការ ចំពោះមន្ត្រីនគរបាលជាតិ ដែល៖**

១- បានឃុបឃិតឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។

២- ជួញដូរអាវុធ ឬឱ្យអ្នកដទៃខ្ចីអាវុធប្រើប្រាស់ ឬផ្តល់គ្រាប់កាំភ្លើងឱ្យអ្នកដទៃ។

៣- ធ្វើទារុណកម្មឬវាយយកចម្លើយជនសង្ស័យបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ពិការ ឬបាត់បង់ជីវិត។

៤- បញ្ជាដោយបំពានច្បាប់ឬខុសឆ្គងនឹងបញ្ញត្តិច្បាប់ជាធរមាន ដែលបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិ ឬបង្កឱ្យមានរបួសស្នាម ឬដល់អាយុជីវិតប្រជាពលរដ្ឋ។

៥- ឃុបឃិត សមគំនិត ធ្វើឱ្យជនសង្ស័យឬជនជាប់ចោទរត់គេចខ្លួន។

៦- លួចផ្តល់ព័ត៌មានសម្ងាត់ឬសមគំនិតក្នុងបំណងបំផ្លិចបំផ្លាញសន្តិសុខជាតិ។

**ប្រការ៣៣.‒**

ការដាក់ទណ្ឌកម្មខាងវិន័យត្រូវកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីនគរបាលជាតិកម្ពុជា។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**ប្រការ៣៤.‒**

វិន័យលេខ០០៦ ប.ប.ជ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីវិន័យរបស់កងកម្លាំងនគរបាលជាតិរបស់ក្រសួងមហាផ្ទៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ។

១៣/១៤

**ប្រការ៣៥ .–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានជនជានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ សុក្រ ១០រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣៥
- ឯកសារ កាលប្បវត្តិ

១៤/១៤

# ក្រុមការងាររៀបចំតាក់តែងសៀវភៅ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**បណ្ឌិត្យសភានគរបាលកម្ពុជា**

លេខ : ...១០០ ល.ប.ក.

## លិខិតបង្គាប់ការ

**យោង** : តាមការចាំបាច់របស់បណ្ឌិត្យសភានគរបាលកម្ពុជា

ត្រូវបានបង្កើតក្រុមការងាររៀបចំសៀវភៅគោលស្តីពី **អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ** របស់បណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានសមាសភាពនិងភារកិច្ចដូចខាងក្រោម៖

**ក- សមាសភាព**

| | | | |
|---|---|---|---|
| ១- ឯកឧត្តមនាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ | **ឯក មនោសែន** | ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | ប្រធាន |
| ២- ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ | **ប្រាក់ ណារ៉ុង** | ប្រធានក្រុមការងារពិគ្រោះយោបល់ | អនុប្រធាន |
| ៣- ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **នួន វិទ្យាស័ក** | អនុប្រធានក្រុមការងារសៀវភៅគោល | **អនុប្រធានអចិន្ត្រៃយ៍** |
| ៤- ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **ត្រី គីមសេង** | អនុប្រធានក្រុមប្រឹក្សាគ្រូនគរបាលជាតិ | អនុប្រធាន |
| ៥- ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **អួន សុខន** | អនុប្រធានក្រុមប្រឹក្សាគ្រូនគរបាលជាតិ | អនុប្រធាន |
| ៦- ឧត្តមសេនីយ៍ឯក បណ្ឌិត | **ឡាយ សុបញ្ញា** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | អនុប្រធាន |
| ៧- ឧត្តមសេនីយ៍ឯក | **សួន ផល្លា** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | អនុប្រធាន |
| ៨- ឧត្តមសេនីយ៍ឯក | **ពេជ្រ ពិសិដ្ឋ** | នាយកសាលាមធ្យមបច្ចេកទេស | សមាជិក |
| ៩- ឧត្តមសេនីយ៍ទោ បណ្ឌិត | **គ្រៀង សុគី** | ប្រធានក្រុមប្រឹក្សាគ្រូនគរបាលជាតិ | សមាជិក |
| ១០- ឧត្តមសេនីយ៍ទោ សាស្ត្រាចារ្យជំនួយ | **ឡេង បូរាណ** | អនុប្រធានក្រុមប្រឹក្សាគ្រូនគរបាលជាតិ | សមាជិក |
| ១១- ឧត្តមសេនីយ៍ទោ បណ្ឌិត | **ប៊ុន ភក្តី** | ប្រធានមន្ទីរចាត់ការ | សមាជិក |
| ១២- ឧត្តមសេនីយ៍ត្រី បណ្ឌិត | **យ៉េន យ៉ាត** | នាយកវិ.ស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល | សមាជិក |
| ១៣- ឧត្តមសេនីយ៍ត្រី | **ខែម សាវី** | នាយក វិ. បណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល | សមាជិក |
| ១៤- វរសេនីយ៍ឯក បណ្ឌិត | **កែប ប៊ុនលី** | នាយក វិ.ក្រោយបរិញ្ញាបត្រ | សមាជិក |
| ១៥- វរសេនីយ៍ឯក | **វិទ្ធ រ៉ាម៉ូ** | នាយក វិ.ព័ត៌មានវិទ្យានិងភាសាបរទេស | សមាជិក |

**ខ- ភារកិច្ច**

ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវប្រមូលព័ត៌មាន និងវិភាគទិន្នន័យអំពីតម្រូវការទាក់ទងនឹងការរៀបចំសៀវភៅ
- រៀបចំគម្រោងមាតិកាសៀវភៅ គាំទ្រការពង្រឹងគុណភាពក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីនគរបាលជាតិ
- កសាងផែនការកំណត់គោលដៅនិងពេលវេលាច្បាស់លាស់ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព
- បែងចែកប្រគល់ភារកិច្ចទទួលខុសត្រូវក្នុងការសរសេរអត្ថបទតាមផ្នែកនីមួយៗឱ្យមានសង្គតិភាព និងប្រទាក់ក្រឡាគ្នា ៧

-១-

- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា។

ក្រុមការងារអាចប្រើប្រាស់មន្ត្រីនគរបាលជាតិក្រោមឱវាទ ដើម្បីជាជំនួយដល់ភារកិច្ចរបស់ខ្លួនក្នុងកិច្ចដំណើរការនៃការរៀបចំសៀវភៅគោលនេះតាមការចាំបាច់។

សាមីខ្លួនដែលមានឈ្មោះក្នុងលិខិតបង្គាប់ការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារនិងអនុប្រធាននីមួយៗ។

ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងលិខិតបង្គាប់ការនេះ ត្រូវអនុវត្តភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះរហូតដល់ត្រូវបានបញ្ចប់តាមផែនការកំណត់៕ ៧

ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ជីតដូ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២៥

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**

**កន្លែងទទួល:**
- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- អង្គភាពនិងក្រុមការងារចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា
- សាមីខ្លួន
- ឯកសារ កាលប្បវត្តិ

-២-

